

# វេយ្យាករណ៍ខ្មែរ

## វណ្ណយុត្តិ ពាក្យ ថ្នាក់ពាក្យ កន្សោមពាក្យ ល្បះ

សុខ ឈន, ឆាន់ គឹមសឿន, គេន រង្សី

វេយ្យាករណ៍ខ្មែរ
សុខ ឈន, ឆាន់ គឹមសឿន, គេន រង្សី

២៥៦៦ | ២០២២

# វេយ្យាករណ៍ខ្មែរ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
មហាវិទ្យាល័យអប់រំ
កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន

# វេយ្យាករណ៍ខ្មែរ

**រៀបរៀងដោយ**
លោក សុខ ឈន
សាស្ត្រាចារ្យជំនួយ ឆាន់ គឹមសឿន
សាស្ត្រាចារ្យជំនួយ គេន រង្សី

ឯកសារប្រើប្រាស់ផ្ទៃក្នុង
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ព.ស.២៥៦៨ គ.ស.២០២៤

© រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយអ្នករៀបរៀង
គ្មានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានផលិតឡើងវិញដោយគ្មានការអនុញ្ញាត
ជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិឡើយ ទោះតាមរូបភាពឬមធ្យោបាយណាមួយក៏ដោយ។
បោះពុម្ពលើកទី១ ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដោយរោងពុម្ព LN Printing
អាសយដ្ឋាន៖ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ។

# មាតិកា


**អារម្ភកថា** ........ xiv
**សេចក្តីផ្តើម** ........ xv
**ផ្នែកទី១ ទ្រឹស្តី** ........ ១
**មេរៀនទី១ ញាណទូទៅនៃវេយ្យាករណ៍** ........ ២
១. និយមន័យ ........ ២
២. ន័យវេយ្យាករណ៍ ........ ២
២.១. ទម្រង់ រូបរាង ស្តែងឡើងដោយន័យវេយ្យាករណ៍ ........ ៣
៣. ប្រភេទវេយ្យាករណ៍ ........ ៤
៣.១. ប្រភេទវេយ្យាករណ៍ដែលប្រាប់ថ្នាក់ពាក្យ ........ ៥
៣.២. ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ផ្លាស់ប្តូររបស់ពាក្យ ........ ៦
៣.៣. ប្រភេទវេយ្យាករណ៍ដែលប្រាប់ទីកន្លែងរបស់ពាក្យ ........ ៦
៣.៤. ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ល្បះ ........ ៦
**មេរៀនទី២ វណ្ណយុត្តិនិងសញ្ញាល្បះ** ........ ៧
១. វណ្ណយុត្តិ ........ ៧
១.១. សញ្ញាបន្តក់ឬរស្សសញ្ញា ( ់ ) ........ ៧
១.២. សំយោគសញ្ញា (័) ឬសញ្ញាផាត់លើ ........ ៧
១.៣. យុគលពិន្ទុ (ៈ) ឬសញ្ញាចុចពីរ ........ ៨
១.៤. វិសជ្ជនីយ (ះ) ឬសញ្ញារះមុខ ........ ៨
១.៥. និគ្គហិត (ំ) ឬសញ្ញាដំលើ ........ ៨
១.៦. សញ្ញាលេខទោ (ៗ) ........ ៨
១.៧. សញ្ញាលេខប្រាំបី (៉) ឬលេខអស្តា ........ ៩
១.៨. សញ្ញាជើងក្អែក (៊) ឬសញ្ញាកាកបាទ ........ ៩
១.៩. សញ្ញាបដិសេធ (៍) ឬទណ្ឌឃាត ........ ៩
១.១០. សញ្ញារបាទ (៌) ........ ១០
១.១១. សញ្ញាមូលសិកទន្តឬសញ្ញាធ្មេញកណ្តុរ (៉) ........ ១១
១.១២. សញ្ញាត្រីសព្ទឬសញ្ញាសក់ក (៏) ........ ១១

២. សញ្ញាល្បះ ........ ១១
២.១. សញ្ញាប្រយោគបង្កើតដោយបុព្វបុរសខ្មែរ ........ ១១
២.១.១. សញ្ញាខណ្ឌ (។) ........ ១១
២.១.២. សញ្ញាខណ្ឌចប់ (៕) ........ ១២
២.១.៣. សញ្ញាដកឃ្លាឬដំណកឃ្លា ........ ១២
២.១.៤. សញ្ញាបេយ្យាលៈ (។ល។) (ឡ្ងាក់) ........ ១៣
២.១.៥. សញ្ញាចំណុចពីគូសឬដំពីរ (៖) ........ ១៣
២.១.៦. សញ្ញាគោមូត្រ (៚) ........ ១៤
២.១.៧. សញ្ញាកុក្កុដនេត្រឬភ្នែកមាន់ (៙) ........ ១៤
២.២. សញ្ញាប្រយោគខ្ចីពីភាសាបារាំង ........ ១៤
២.២.១. រជ្ជុសញ្ញា (-) (ឬ «ត្រេ») ........ ១៤
២.២.២. សញ្ញាវង់ក្រចក ( ) ........ ១៥
២.២.៣. សញ្ញាចុចមួយ ( . ) ........ ១៥
២.២.៤. សញ្ញាចំណុចរាយឬពងត្រី (...) ........ ១៥
២.២.៥. សញ្ញាវង់ក្រចកចំណុចរាយឬវង់ក្រចកពងត្រី (...) ........ ១៦
២.២.៦. សញ្ញាក្បៀស ( , ) ........ ១៦
២.២.៧. សញ្ញាចុចក្បៀស ( ; ) ........ ១៦
២.២.៨. សញ្ញាសួរ (?) ........ ១៦
២.២.៩. សញ្ញាឧទាន ( ! ) ........ ១៦
២.២.១០. អព្ភន្តរសញ្ញា («  ») ........ ១៦
២.២.១១. សញ្ញាឃ្នាប ( [ ] ) ........ ១៧
២.២.១២. សញ្ញា «និង» ( & ) ........ ១៧
២.២.១៣. សញ្ញាបន្ទាត់ទ្រេត ( / ) ........ ១៧
២.២.១៤. សញ្ញាផ្កាយ ( * ) ........ ១៨
២.២.១៥. សញ្ញារ៉ាត់ ( { ) ឬ ( } ) ........ ១៨
២.២.១៦. សញ្ញារ៉ាត់ឃ្នាប ( { } ) ........ ១៨
២.២.១៧. សញ្ញាស្មើ ( = ) ........ ១៨
២.២.១៨. សញ្ញាទៅជាឬធំជាង ( > ) ........ ២០

២.២.១៩. សញ្ញា«មកពី/តូចជាង» ( < ) ........................................................ ២០
២.២.២០. សញ្ញា «ផ្ទុយពីឬខុសពី» ( # ) ........................................................ ២០
**មេរៀនទី៣ ពាក្យ** ........................................................ ២០
១. ពាក្យជាអ្វី? ........................................................ ២០
២. សំណួររបស់ពាក្យ ........................................................ ២០
២.១. សំណួរព្យាង្គក្នុងពាក្យ ........................................................ ២០
២.២. សំណួរពាក្យតាមការអាន ........................................................ ២១
២.២.១. សូរអានតាមបាលី-សំស្រ្កឹត ........................................................ ២១
២.២.២. សូរអានតាមខ្មែរ ........................................................ ២១
២.២.៣. សូរអានតាមនិយាម ........................................................ ២២
២.៣. សំណួរពាក្យតាមការនិយាយ ........................................................ ២២
២.៣.១. បន្លឺតាមទីសម្ព័ន្ធ ........................................................ ២៣
២.៣.២. បន្លឺតាមទីកន្លែង ........................................................ ២៣
២.៣.៣. បន្លឺតាមទីឋាន ........................................................ ២៣
៣. រូបរាងរបស់ពាក្យ ........................................................ ២៣
៣.១. និយមន័យ ........................................................ ២៣
៣.២. មូលដ្ឋានក្នុងការសម្រេចអក្ខរាវិរុទ្ធខ្មែរ ........................................................ ២៤
៣.២.១. ឫសគល់ពាក្យ ........................................................ ២៤
៣.២.២. បម្រែបម្រួលសូរ ........................................................ ២៤
ក. បម្រែបម្រួលសូរសទ្ទ ........................................................ ២៥
ខ. បម្រែបម្រួលសូរព្យាង្គ ........................................................ ២៥
៣.២.៣. ទំនាញសូរ ........................................................ ២៥
៣.២.៤. សម្ព័ន្ធរូបសព្ទ ........................................................ ២៦
៣.២.៥. សម្ព័ន្ធសញ្ញាព្យាង្គ ........................................................ ២៧
៣.៣. លក្ខណៈសម្គាល់អក្ខរាវិរុទ្ធខ្មែរ ........................................................ ២៧
៣.៣.១. លក្ខណៈសម្គាល់អក្ខរាវិរុទ្ធពាក្យខ្មែរសុទ្ធ ........................................................ ២៧
៣.៣.២. លក្ខណៈសម្គាល់អក្ខរាវិរុទ្ធពាក្យកម្ចីបាលី-សំស្រ្កឹត ........................................................ ២៨
៤. ន័យរបស់ពាក្យ ........................................................ ២៨

៤.១. តើន័យរបស់ពាក្យកើតឡើងយ៉ាងដូចម្ដេច? ........................................ ២៩
៤.១.១. ទម្រង់ខាងក្នុងរបស់ពាក្យ ........................................ ២៩
៤.១.២. ការចូលរួមក្នុងសម្ព័ន្ធ ........................................ ៣០
៤.១.៣. បម្លាស់ប្ដូរន័យ ........................................ ៣០
៤.១.៤. ការយល់ឃើញ ........................................ ៣០
៤.២. ដំណាក់កាលន័យរបស់ពាក្យ ........................................ ៣០
៤.២.១. ន័យដំណាក់ទី១ ........................................ ៣១
៤.២.២. ន័យដំណាក់ទី២ ........................................ ៣១
៤.៣. ប្រភេទន័យរបស់ពាក្យ ........................................ ៣១
៤.៣.១. ន័យចំ ........................................ ៣១
៤.៣.២. ន័យធៀប ........................................ ៣១
៤.៣.៣. ន័យច្រើន ........................................ ៣២
៤.៣.៤. ន័យដូច ........................................ ៣២
៤.៣.៥. ន័យផ្ទុយ ........................................ ៣២
៤.៣.៦. ន័យរូបី ........................................ ៣២
៤.៣.៧. ន័យអរូបី ........................................ ៣៣
៥. ទំនាក់ទំនងពាក្យ ........................................ ៣២
៥.១. ពាក្យសូរដូច ........................................ ៣៣
៥.២. ពាក្យរូបដូច ........................................ ៣៣
៥.៣. ពាក្យន័យដូច ........................................ ៣៣
៥.៤. ពាក្យពហុន័យ ........................................ ៣៤
៥.៥. ពាក្យន័យផ្ទុយ ........................................ ៣៤
៦. សន្តានពាក្យ ........................................ ៣៤
៧. ប្រភេទពាក្យសព្ទ ........................................ ៣៥
៧.១. ពាក្យសព្ទថ្មីនិងពាក្យសព្ទបុរាណ ........................................ ៣៥
៧.២. ពាក្យសព្ទសកម្មនិងពាក្យសព្ទអកម្ម ........................................ ៣៥
៧.៣. ពាក្យសព្ទប្រជាជន ពាក្យសព្ទវប្បធម៌ ពាក្យសព្ទសន្ទនា ........................................ ៣៦
៧.៤. ពាក្យសព្ទកណ្ដាល ពាក្យសព្ទជំនាញ ........................................ ៣៦

៧.៥. ពាក្យន័យដូច ពាក្យន័យផ្ទុយ ពាក្យសូរដូច ........................................ ៣៧
៧.៦. ពាក្យសព្វភាសាចម្បងនិងពាក្យសព្វកម្ម ............................................. ៣៨
៨. ជម្រើសពាក្យ........................................................................................ ៣៩
៩. បម្រើបម្រាស់ពាក្យ................................................................................ ៤០
៩.១. វណ្ណយោបាយ..................................................................................... ៤០
៩.២. ទេសយោបាយ ..................................................................................... ៤០
៩.៣. កាលយោបាយ..................................................................................... ៤១
**មេរៀនទី៤ ការបែងចែកថ្នាក់ពាក្យ** ................................................................ ៤២
១. បច្ចេកសព្ទសម្គាល់ "ថ្នាក់ពាក្យ" .............................................................. ៤២
២. និយមន័យ............................................................................................ ៤២
៣. ប្រវត្តិនិងបំណែងចែកថ្នាក់ពាក្យ............................................................. ៤៣
**មេរៀនទី៥ នាម** ........................................................................................ ៤៥
១. និយមន័យ............................................................................................ ៤៥
២. ប្រភេទរបស់នាម .................................................................................. ៤៥
២.១. នាមសាធារណ៍ឬសាធារណនាម.................................................................. ៤៥
២.២. នាមអសាធារណ៍ឬអសាធារណនាម ............................................................. ៤៥
២.៣. នាមករណ៍ឬករណនាម............................................................................ ៤៦
២.៤. នាមការក៍ឬការកនាម............................................................................. ៤៦
២.៥. នាមរូបី .............................................................................................. ៤៧
២.៦. នាមអរូបី............................................................................................. ៤៧
២.៧. នាមជីវចល ......................................................................................... ៤៨
២.៨. នាមអជីវចល ....................................................................................... ៤៨
៣. មុខងាររបស់នាម.................................................................................... ៤៨
**មេរៀនទី៦ សព្វនាម**.................................................................................. ៥០
១. និយមន័យ............................................................................................ ៥០
២. ប្រភេទរបស់សព្វនាម ............................................................................. ៥០
២.១. សព្វនាមបុរិសៈ ................................................................................... ៥០
២.២. សព្វនាមចង្អុល .................................................................................... ៥០

២.៣. សព្វនាមសំណួរ ............................................................ ៥០
២.៤. សព្វនាមមិនច្បាស់ ............................................................ ៥១
២.៥. សព្វនាមឈ្នាប់ ............................................................ ៥១
៣. មុខងាររបស់សព្វនាម ............................................................ ៥១
**មេរៀនទី៧ គុណនាម** ............................................................ ៥២
១. និយមន័យ ............................................................ ៥២
២. ប្រភេទគុណនាម ............................................................ ៥២
២.១. គុណនាមប្រក្រតី ............................................................ ៥២
២.២. គុណនាមកំណត់ ............................................................ ៥២
២.២.១. គុណនាមចង្អុល ............................................................ ៥៣
២.២.២. គុណនាមចំនួន ............................................................ ៥៣
២.២.៣. គុណនាមកម្មសិទ្ធិ ............................................................ ៥៣
២.២.៤. គុណនាមសំណួរ ............................................................ ៥៣
២.២.៥. គុណនាមមិនច្បាស់ ............................................................ ៥៣
៣. ទម្រង់គុណនាម ............................................................ ៥៤
៣.១. គុណនាមកំណើត ............................................................ ៥៤
៣.២. គុណនាមកម្លាយ ............................................................ ៥៤
៣.៣. គុណនាមផ្សំ ............................................................ ៥៤
៤. កម្រិតគុណនាម ............................................................ ៥៤
៤.១. កម្រិតវិជ្ជមាន ............................................................ ៥៤
៤.២. កម្រិតទាក់ទងឬទំហៀប ............................................................ ៥៥
៤.៣. កម្រិតដាច់ខាតឬគ្មានទំហៀប ............................................................ ៥៥
៥. លំដាប់គុណនាមនៅក្នុងកន្សោមនាម ............................................................ ៥៥
៦. សម្ព័ន្ធគុណនាម ............................................................ ៥៧
៦.១. សម្ព័ន្ធគុណនាមប្រក្រតី ............................................................ ៥៨
៦.២. សម្ព័ន្ធគុណនាមចង្អុល ............................................................ ៥៩
៦.៣. សម្ព័ន្ធគុណនាមចំនួន ............................................................ ៦០
៦.៤. សម្ព័ន្ធគុណនាមកម្មសិទ្ធិ ............................................................ ៦១

៦.៥. សម្ព័ន្ធគុណនាមសំណួរ .................... ៦១
៦.៦. សម្ព័ន្ធគុណនាមមិនច្បាស់ .................... ៦២
**មេរៀនទី៨ កិរិយាសព្ទ** .................... ៦៣
១. និយមន័យ .................... ៦៣
២. ប្រភេទរបស់កិរិយាសព្ទ .................... ៦៣
២.១. កិរិយាសុទ្ធ .................... ៦៣
២.២. កិរិយាហេតុ .................... ៦៣
២.៣. កិរិយាសកម្ម .................... ៦៤
២.៤. កិរិយាអកម្ម .................... ៦៥
២.៥. កិរិយាចំណាង .................... ៦៥
២.៦. កិរិយាជំនួយ .................... ៦៥
២.៦.១. កិរិយាបំពេញ .................... ៦៥
២.៦.២. កិរិយាទិសដៅ .................... ៦៦
២.៦.៣. កិរិយាខាងដើម .................... ៦៦
៣. ការប្រើប្រាស់កិរិយាសព្ទខ្លះក្នុងសម្ព័ន្ធ .................... ៦៧
**មេរៀនទី៩ គុណកិរិយា** .................... ៦៨
១. និយមន័យ .................... ៦៨
២. ប្រភេទគុណកិរិយា .................... ៦៨
២.១. គុណកិរិយាបំណែប .................... ៦៨
២.២. គុណកិរិយាកាល .................... ៦៨
២.៣. គុណកិរិយាកន្លែង .................... ៦៨
២.៤. គុណកិរិយាសំណួរ .................... ៦៩
២.៥. គុណកិរិយាបរិមាណ .................... ៦៩
៣. ទម្រង់គុណកិរិយា .................... ៦៩
៣.១. គុណកិរិយាកំណើត .................... ៦៩
៣.២. គុណកិរិយាកម្លាយ .................... ៦៩
៣.៣. គុណកិរិយាផ្សំ .................... ៦៩
៣.៤. គុណកិរិយាផ្ទួន .................... ៧០

៤. សម្ព័ន្ធគុណកិរិយា ............................................................................................. ៧០
៤.១. សម្ព័ន្ធគុណកិរិយាបំណែប ....................................................................................... ៧០
៤.២. សម្ព័ន្ធគុណកិរិយាកាល ........................................................................................... ៧១
៤.៣. សម្ព័ន្ធគុណកិរិយាកន្លែង ......................................................................................... ៧២
៤.៤. សម្ព័ន្ធគុណកិរិយាសំណួរ......................................................................................... ៧២
៤.៥. សម្ព័ន្ធគុណកិរិយាបរិមាណ ....................................................................................... ៧៣
**មេរៀនទី១០ ធ្នាក់** ..................................................................................................... ៧៤
១. និយមន័យ.................................................................................................................. ៧៤
២. ប្រភេទរបស់ធ្នាក់ ........................................................................................................ ៧៤
**មេរៀនទី១១ ឈ្នាប់** .................................................................................................... ៧៦
១. និយមន័យ.................................................................................................................. ៧៦
២. ប្រភេទឈ្នាប់ ............................................................................................................. ៧៦
២.១. ឈ្នាប់ចង ................................................................................................................ ៧៦
២.២. ឈ្នាប់ឃ្លា ................................................................................................................ ៧៧
៣. បម្រើបម្រាស់ឈ្នាប់ឃ្លា ............................................................................................... ៧៧
**មេរៀនទី១២ ឧទានសព្ទ** ............................................................................................... ៧៩
១. និយមន័យ.................................................................................................................. ៧៩
២. ប្រភពឧទានសព្ទ ......................................................................................................... ៧៩
៣. បម្រើបម្រាស់ឧទានសព្ទ................................................................................................ ៧៩
**មេរៀនទី១៣ កន្សោមពាក្យ**............................................................................................. ៨១
១. បញ្ញត្តិនៃកន្សោមពាក្យ ................................................................................................ ៨១
២. ប្រភេទកន្សោមពាក្យ.................................................................................................... ៨១
២.១. កន្សោមនាម ........................................................................................................... ៨២
២.១.១. និយមន័យ ........................................................................................................... ៨២
២.១.២. ទម្រង់នៃការបង្កើតកន្សោមនាម ............................................................................... ៨៣
ក. ពង្រីករណប ................................................................................................................. ៨៣
ខ. ពង្រីកមិនរណប............................................................................................................. ៨៣
២.១.៣. វិភាគកន្សោមនាម..................................................................................................... ៨៤

២.២. កន្សោមគុណនាម ........................................................................ ៨៧
២.២.១. និយមន័យ ........................................................................ ៨៧
២.២.២. ទម្រង់នៃការបង្កើតកន្សោមគុណនាម ........................................................................ ៨៧
២.២.៣. វិភាគកន្សោមគុណនាម ........................................................................ ៨៨
២.៣. កន្សោមកិរិយា ........................................................................ ៨៩
២.៣.១. និយមន័យ ........................................................................ ៨៩
២.៣.២. ទម្រង់នៃការបង្កើតកន្សោមកិរិយា ........................................................................ ៩០
២.៣.៣. វិភាគកន្សោមកិរិយា ........................................................................ ៩០
២.៤. កន្សោមគុណកិរិយា ........................................................................ ៩១
២.៤.១. និយមន័យ ........................................................................ ៩១
២.៤.២. ទម្រង់នៃការបង្កើតកន្សោមគុណកិរិយា ........................................................................ ៩២
២.៤.៣. វិភាគកន្សោមគុណកិរិយា ........................................................................ ៩២
២.៥. កន្សោមមានធ្នាក់ ........................................................................ ៩៣
២.៥.១. និយមន័យ ........................................................................ ៩៣
២.៥.២. ទម្រង់នៃការបង្កើតកន្សោមមានធ្នាក់ ........................................................................ ៩៥
២.៥.៣. វិភាគកន្សោមមានធ្នាក់ ........................................................................ ៩៥
៣. មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមពាក្យ ........................................................................ ៩៦
៣.១. មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមនាមប្រធាន ........................................................................ ៩៦
៣.១.១. គុណបទ ........................................................................ ៩៦
៣.១.២. កម្មបំពេញបទរបស់នាម/កម្មរបស់នាម ........................................................................ ៩៦
៣.១.៣. ឧបបទ ........................................................................ ៩៦
៣.២. មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមកិរិយាបម្រាប់ប្រធាន ........................................................................ ៩៧
៣.២.១. កម្មបទផ្ទាល់ ........................................................................ ៩៧
៣.២.២. កម្មបទទី២ ........................................................................ ៩៧
៣.២.៣. កម្មបទមិនផ្ទាល់ ........................................................................ ៩៧
៣.២.៤. កម្មភ្នាក់ងារ ........................................................................ ៩៧
៣.២.៥. គុណប្រធាន ........................................................................ ៩៨
៣.២.៦. កម្មទេសកាល ........................................................................ ៩៨

**មេរៀនទី១៤ ល្បះ** ........ ១០០
១. និយមន័យ ........ ១០០
២. ទម្រង់នៃការបង្កើតល្បះ ........ ១០២
២.១. ល្បះបង្កើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា ........ ១០២
២.២. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា
ដែលមានកន្សោមនាមកម្មបទផ្ទាល់ ........ ១០៣
២.៣. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា
ដែលមានកន្សោមនាមកម្មបទមិនផ្ទាល់ ........ ១០៣
២.៤. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា
ដែលមានកន្សោមនាមកម្មបទផ្ទាល់និងកន្សោមនាមកម្មបទមិនផ្ទាល់ ........ ១០៤
២.៥. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា
ដែលមានកន្សោមនាមគុណប្រធាន ........ ១០៤
៣. វិភាគធាតុនៃល្បះ ........ ១០៥
៤. មុខងាររបស់កន្សោមពាក្យក្នុងល្បះ ........ ១០៧
៤.១. កន្សោមនាមប្រធាន ........ ១០៧
៤.១.១. និយមន័យ ........ ១០៧
៤.១.២. ប្រភេទកន្សោមនាមប្រធាន ........ ១០៧
៤.២. កន្សោមកិរិយា (បម្រាប់ប្រធាន) ........ ១០៨
៤.២.១. អំពីកិរិយា ........ ១០៨
៤.២.២. ប្រភេទកិរិយា ........ ១០៨
៥. រចនាសម្ព័ន្ធល្បះ ........ ១០៨
៥.១. ល្បះទោល ........ ១០៨
៥.១.១. និយមន័យ ........ ១០៨
៥.១.២. ទម្រង់នៃការបង្កើតល្បះទោល ........ ១០៩
៥.១.៣. វិភាគល្បះទោល ........ ១០៩
៥.២. ល្បះផ្សំ ........ ១១០
៥.២.១. និយមន័យ ........ ១១០
៥.២.២. ទម្រង់នៃការបង្កើតល្បះផ្សំ ........ ១១១

៥.២.៣. វិភាគល្បះផ្សំ ........................................ ១១១
៥.២.៤. ឃ្លាផ្សេងៗនៃល្បះផ្សំ ........................................ ១១៤
ក. ឃ្លានាម ........................................ ១១៤
ក.១. និយមន័យ ........................................ ១១៤
ក.២. មុខងារនៃឃ្លានាម ........................................ ១១៥
ក.៣. ឃ្លានាមសំណួរមិនផ្ទាល់ ........................................ ១១៦
ក.៤. គំនូសតាងល្បះ ........................................ ១១៧
ខ. ឃ្លាគុណនាម ........................................ ១១៨
ខ.១. និយមន័យ ........................................ ១១៨
ខ.២. ឃ្លាគុណនាមគុណបទ ........................................ ១១៨
ខ.៣. ឃ្លាគុណនាមឧបបទ ........................................ ១១៩
ខ.៤. គំនូសតាងល្បះ ........................................ ១១៩
គ. ឃ្លាទេសកាល ........................................ ១២១
គ.១. និយមន័យ ........................................ ១២១
គ.២. មុខងារនៃឃ្លាទេសកាល ........................................ ១២១
គ.២.១. ឃ្លាទេសកាលប្រាប់កាលឬឃ្លាកាល ........................................ ១២២
គ.២.២. ឃ្លាទេសកាលបំណងឬឃ្លាបំណង ........................................ ១២៣
គ.២.៣. ឃ្លាទេសកាលហេតុឬឃ្លាហេតុ ........................................ ១២៣
គ.២.៤. ឃ្លាទេសកាលទំនាស់ឬឃ្លាទំនាស់ ........................................ ១២៤
គ.២.៥. ឃ្លាទេសកាលបំណែបឬឃ្លាបំណែប ........................................ ១២៥
គ.២.៦. ឃ្លាទេសកាលបន្ថែមឬឃ្លាបន្ថែម ........................................ ១២៥
គ.២.៧. ឃ្លាទេសកាលលើកលែងឬឃ្លាលើកលែង ........................................ ១២៥
គ.២.៨. ឃ្លាទេសកាលវិបាកឬឃ្លាវិបាក ........................................ ១២៥
គ.២.៩. ឃ្លាទេសកាលប្រៀបធៀបឬឃ្លាប្រៀបធៀប ........................................ ១២៦
គ.២.១០. ឃ្លាទេសកាលបំណើឬឃ្លាបំណើ ........................................ ១២៧
៥.៣. ល្បះក្រង ........................................ ១២៨
៥.៣.១. និយមន័យ ........................................ ១២៨
៥.៣.២. ល្បះរងភ្ជាប់គ្នាដោយសារ "ឈ្នាប់ចង" ........................................ ១២៨

៥.៣.៣. ល្បះរងនៅបន្តបន្ទាប់គ្នា ........ ១២៩
៦. បែបឬប្រភេទនិងរូបរាងនៃល្បះ ........ ១២៩
៦.១. បែបឬប្រភេទនៃល្បះ ........ ១២៩
៦.១.១. ល្បះបញ្ជាក់ ........ ១២៩
៦.១.២. ល្បះបញ្ជា ........ ១២៩
៦.១.៣. ល្បះសំណួរ ........ ១៣០
ក. ល្បះសំណួរទាំងមូល ........ ១៣០
ខ. ល្បះសំណួរផ្នែក ........ ១៣០
គ. បែបនៃល្បះសំណួរ ........ ១៣១
គ.១. ល្បះសំណួរបែបបញ្ជាក់ ........ ១៣១
គ.២. ល្បះសំណួរបែប *ឬទេ* ........ ១៣១
គ.៣. ល្បះសំណួរបែបដណ្ដឹង ........ ១៣១
៦.១.៤. ល្បះឧទាន ........ ១៣១
៦.២. រូបរាងនៃល្បះ ........ ១៣២
៦.២.១. ល្បះស្របនិងល្បះមិនស្រប ........ ១៣២
ក. ល្បះបញ្ជាក់ ........ ១៣២
ខ. ល្បះបញ្ជា ........ ១៣៣
គ. ល្បះសំណួរ ........ ១៣៤
ឃ. ល្បះឧទាន ........ ១៣៥
៦.២.២. ល្បះកត៌ុនិងល្បះកម្ម ........ ១៣៥
ក. ល្បះបញ្ជាក់ ........ ១៣៥
ក.១. ល្បះបញ្ជាក់កត៌ុ ........ ១៣៥
ក.២. ល្បះបញ្ជាក់កម្ម ........ ១៣៦
ខ. ល្បះសំណួរ ........ ១៣៦
ខ.១. ល្បះសំណួរកត៌ុ ........ ១៣៦
ខ.២. ល្បះសំណួរកម្ម ........ ១៣៦
គ. ល្បះឧទាន ........ ១៣៦
៦.២.៣. ល្បះធម្មតានិងល្បះសង្កត់ ........ ១៣៦

៦.២.៤. កថាផ្ទាល់និងកថាមិនផ្ទាល់ ........ ១៤០
ក. កថាផ្ទាល់ (រចនាបថផ្ទាល់) ........ ១៤០
ខ. កថាមិនផ្ទាល់ (រចនាបថមិនផ្ទាល់) ........ ១៤០
**ផ្នែកទី២ អនុវត្តន៍** ........ ១៤២
អនុវត្តន៍មេរៀនទី១ សញ្ញាណទូទៅនៃវេយ្យាករណ៍ ........ ១៤៣
អនុវត្តន៍មេរៀនទី២ វណ្ណយុត្តិនិងសញ្ញាល្បះ ........ ១៤៦
អនុវត្តន៍មេរៀនទី៣ ពាក្យ ........ ១៥៤
អនុវត្តន៍មេរៀនទី៤ ការបែងចែកថ្នាក់ពាក្យ ........ ១៦០
អនុវត្តន៍មេរៀនទី៥ នាម ........ ១៦៤
អនុវត្តន៍មេរៀនទី៦ សព្វនាម ........ ១៦៨
អនុវត្តន៍មេរៀនទី៧ គុណនាម ........ ១៧១
អនុវត្តន៍មេរៀនទី៨ កិរិយាសព្ទ ........ ១៧៤
អនុវត្តន៍មេរៀនទី៩ គុណកិរិយា ........ ១៧៨
អនុវត្តន៍មេរៀនទី១០ ធ្នាក់ ........ ១៨២
អនុវត្តន៍មេរៀនទី១១ ឈ្នាប់ ........ ១៨៦
អនុវត្តន៍មេរៀនទី១២ ឧទានសព្ទ ........ ១៩០
អនុវត្តន៍មេរៀនទី១៣ កន្សោមពាក្យ ........ ១៩៥
អនុវត្តន៍មេរៀនទី១៤ ល្បះ ........ ១៩៦
**គន្ថនិទ្ទេស** ........ ១៩៩

# អារម្ភកថា

វេយ្យាករណ៍ខ្មែរមានសារៈសំខាន់ណាស់ចំពោះអ្នកសិក្សាភាសាខ្មែរ ពិសេសប្រជាជនខ្មែរដែលប្រើប្រាស់ភាសាខ្មែរជាភាសាផ្លូវការ។ ហេតុនេះហើយទើបគេបញ្ចូលវេយ្យាករណ៍ខ្មែរជាមុខវិជ្ជាស្នូលមួយទៅក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រឯកទេសអក្សរសាស្ត្រខ្មែរនិងភាសាវិទ្យា។

សៀវភៅមេរៀនវេយ្យាករណ៍ខ្មែរនេះត្រូវបានរៀបរៀងឡើងទុកជាសៀវភៅគោលក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ឯកទេសអក្សរសាស្ត្រខ្មែរ។ ដោយសារវេយ្យាករណ៍មានវិសាលភាពទូលំទូលាយពេក ហើយសម្របទៅតាមកម្រិតនៃការសិក្សារបស់និស្សិតផង ក្នុងសៀវភៅមេរៀននេះ យើងខ្ញុំផ្តោតសំខាន់ទៅលើខ្លឹមសារមួយចំនួនប៉ុណ្ណោះដូចជាវណ្ណយុត្តិ ពាក្យ ថ្នាក់ពាក្យ កន្សោមពាក្យ និងល្បះ។ រាល់ខ្លឹមសារទាំងនេះយើងខ្ញុំបានដកស្រង់ចេញពីសៀវភៅវេយ្យាករណ៍ សារណាបញ្ចប់ការសិក្សា សៀវភៅមេរៀនភាសាខ្មែរ និងស្នាដៃស្រាវជ្រាវមួយចំនួនទៀត។ ដើម្បីពង្រីកការចេះដឹងរបស់ខ្លួននិស្សិតអាចសិក្សាស្វែងយល់បន្ថែមដោយខ្លួនឯងតាមរយៈឯកសារទាំងនេះបាន។

សៀវភៅនេះចែកជាពីរផ្នែកធំៗ គឺផ្នែកទ្រឹស្តីនិងផ្នែកអនុវត្តន៍។ ផ្នែកទ្រឹស្តី គឺជាខ្លឹមសារមេរៀនដែលមានចំនួន១៤មេរៀនតាំងពីសញ្ញាណទូទៅនៃវេយ្យាករណ៍ វណ្ណយុត្តិ ពាក្យ ថ្នាក់ពាក្យ កន្សោមពាក្យ រហូតដល់ល្បះ។ ចំណែកផ្នែកទី២ អនុវត្តន៍ គឺជាសំណួរនិងលំហាត់អនុវត្តន៍សម្រាប់វាស់ស្ទង់សមត្ថភាពយល់ដឹងរបស់និស្សិតក្រោយពីបញ្ចប់មេរៀននីមួយៗ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅមេរៀននេះនឹងក្លាយជាឯកសារជំនួយដ៏សំខាន់ក្នុងការសិក្សាអំពីវេយ្យាករណ៍ខ្មែរបន្ថែមលើឯកសារស្រាវជ្រាវដែលមានស្រាប់ពីមុន។ ជាបទពិសោធ "ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច" ដូច្នេះបើឃើញមានកំហុសឆ្គងណាមួយនៅក្នុងសៀវភៅនេះ យើងខ្ញុំជាអ្នករៀបរៀងនឹងទទួលខុសត្រូវ ហើយទទួលយកមតិកែលម្អប្រកបដោយលក្ខណៈវិទ្យាសាស្ត្រគ្រប់ពេលវេលា។

ថ្ងៃចន្ទ ៩រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤

**អ្នករៀបរៀង**

# សេចក្តីផ្តើម

យោងតាមអត្ថបទសិលាចារឹកអង្គរបុរីដែលចារជាភាសាខ្មែរនាឆ្នាំ៦១១ បានបង្ហាញឱ្យឃើញសំណេរពាក្យនិងល្បះក្នុងភាសាខ្មែរយ៉ាងច្បាស់លាស់។ ដូច្នេះគេអាចសន្និដ្ឋានបានថា នៅពេលនោះវេយ្យាករណ៍ខ្មែរបានលេចធ្លោឡើងយ៉ាងប្រាកដ ប៉ុន្តែពុំមានក្បួនវេយ្យាករណ៍ភាសាខ្មែរបុរាណណាមួយបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះទេ។ មកដល់ឆ្នាំ១៩១៥ ទើបគេឃើញមានសៀវភៅវេយ្យាករណ៍ខ្មែរមួយជាភាសាបារាំងដែលជាស្នាដៃស្រាវជ្រាវរបស់អ្នកប្រាជ្ញបារាំងម្នាក់ឈ្មោះ Georges Maspero។

ចាប់តាំងពីពេលនោះមកមានអ្នកសិក្សាខ្មែរជាច្រើននាក់បានខិតខំស្រាវជ្រាវនិងចងក្រងក្បួនវេយ្យាករណ៍ខ្មែរជាបន្តបន្ទាប់រហូតកើតបានជាសៀវភៅវេយ្យាករណ៍ដ៏ច្រើនសន្ធឹកសន្ធាប់។ ពីដំបូងវេយ្យាករណ៍ខ្មែរទាំងនោះនៅជាប់ឥទ្ធិពលវេយ្យាករណ៍បរទេសនៅឡើយ ប៉ុន្តែបន្តិចម្តងៗវេយ្យាករណ៍ខ្មែរបានងាកមករកលក្ខណៈខេមរភាសាវិញ។

វេយ្យាករណ៍ខ្មែរបានប្រមូលផ្តុំលើផ្នែកសូរវិទ្យា ពាក្យ ថ្នាក់ពាក្យ ល្បះ សញ្ញាពិសេស មុខងារពាក្យ និងន័យជាដើម។ ក្នុងនោះអ្នកនិពន្ធបានបង្ហាញអំពីទំនាក់ទំនងរវាងសូរនិងសញ្ញាអក្ខរក្រមខ្មែរ, ក្បួនបង្កើតពាក្យនិងធាតុបង្កើតពាក្យក្នុងភាសាខ្មែរ, ប្រភេទល្បះនិងបែបល្បះ, តួនាទីវណ្ណយុត្តិនិងសញ្ញាល្បះជាដើម។ សំណុំក្បួនវេយ្យាករណ៍ទាំងនេះត្រូវបានសិក្សាស្រាវជ្រាវនិងចងក្រងឡើងដើម្បីបំពេញមុខងារក្នុងការសិក្សា បម្រើបម្រាស់ អភិរក្ស និងអភិវឌ្ឍន៍ភាសាខ្មែរឱ្យបានរីកចម្រើន។

ជារួមវេយ្យាករណ៍មានលក្ខណៈទូទៅនិងអរូបីខ្ពស់ ពោលគឺមានលក្ខណៈឯកភាពជាប្រព័ន្ធ ហើយស្មុគស្មាញពិបាកយល់ដែលទាមទារឱ្យអ្នកសិក្សាទាំងឡាយសង្វាតរៀនសូត្រនិងអនុវត្តជារឿយៗទើបមានសមត្ថភាពអាចប្រើប្រាស់ភាសាបានត្រឹមត្រូវ ពិសេសលើផ្នែកសំណេរ។

# ផ្នែកទី១
# ទ្រឹស្ដី

# មេរៀនទី១
# សញ្ញាណទូទៅនៃវេយ្យាករណ៍

### ១. និយមន័យ

វេយ្យាករណ៍ជាផ្នែកមួយសំខាន់របស់ភាសាវិទ្យាដែលសិក្សាអំពីប្រព័ន្ធវេយ្យា-ករណ៍របស់ភាសា គឺជាសំណុំក្បួនសកម្មភាពរបស់បណ្ដាឯកតាភាសាដែលស្ថិតនៅក្នុងកម្រិតថ្នាក់ផ្សេងៗគ្នា។ និយាយច្បាស់ជាងនេះទៅទៀត គឺជាសំណុំក្បួនបង្កើតពាក្យសព្ទដំបូងគឺក្បួនបង្កើតពាក្យដោយរូបសព្ទ (morphèm) ក្បួនបង្កើតកន្សោមពាក្យ ល្បះ ហើយនិងបណ្ដាធាតុសមាសបន្សំរបស់វាដែលលេចចេញពីពាក្យសព្ទឬនិយាយដោយសង្ខេបជាងនេះទៅទៀត វេយ្យាករណ៍វិទ្យាសិក្សាបណ្ដាវិធីនិងមធ្យោបាយបង្កើតពាក្យនិងល្បះ។

### ២. ន័យវេយ្យាករណ៍

ន័យវេយ្យាករណ៍មានលក្ខណៈផ្ទុយនឹងន័យវចនៈ។ ន័យវចនៈ គឺជាន័យដោយឡែករបស់ពាក្យ គឺជាន័យពិសេសដោយឡែករបស់ពាក្យនីមួយៗជាប្រាកដដាច់ខាត។ ដូចនេះ ន័យវេយ្យាករណ៍ជាអ្វី?

ន័យវេយ្យាករណ៍ គឺជាន័យរួម ន័យទូទៅ បង្ហាញឱ្យឃើញនូវពាក្យណាមួយនោះអំពីផ្នែកខ្លឹមសារឬរូបរាង។ ន័យវេយ្យាករណ៍មិនមែនត្រឹមតែស្ដែងឡើងក្នុងពាក្យនិងរូបរាងរបស់ពាក្យប៉ុណ្ណោះទេ តែថែមទាំងស្ដែងឡើងក្នុងបន្សំពាក្យនិងក្នុងល្បះនិយាយរួម។

ឧទាហរណ៍ ៖

ក. *ផ្ទះ ទីក្រុង ទន្លេ ផ្សារ មនុស្ស កៅអី នាឡិកា*...ជាពាក្យដូចគ្នាទៅតាមទីសេចក្ដីដែលមានន័យបង្ហាញវត្ថុ។

ខ. *ស្លូត ល្អ រឹង មាំ វែង*... ជាពាក្យមានន័យរួមដែលបង្ហាញគុណភាព និងចរិតលក្ខណៈរបស់វត្ថុ។

គ. *សើច និយាយ ធ្វើការ ប្រយុទ្ធ ផលិត*...ជាពាក្យមានសភាពដូចគ្នាទៅតាមកន្លែងវា សុទ្ធតែមាន ន័យបង្ហាញសកម្មភាព។

ន័យប្រាប់វត្ថុ ន័យប្រាប់គុណភាព និងលក្ខណៈ ន័យប្រាប់សកម្មភាព គឺជាបណ្ដាន័យវេយ្យាករណ៍ របស់នាម គុណនាម កិរិយាសព្ទ។

ក្នុងភាសាទាំងឡាយដែលផ្លាស់ប្ដូររូបរាង គឺរូបរាងពាក្យ និងរូបរាងផ្លាស់ប្ដូររបស់

ពាក្យ ក៏អាចមានន័យវេយ្យាករណ៍ដែរ។ ឧទាហរណ៍ក្នុងភាសាបាលី *កុមារ កុមារា កុមារី* ក្នុងភាសាអង់គ្លេស *man men, woman women* ។

អាស្រ័យដោយលក្ខណៈពិសេសនេះដែលភាសាផ្លាស់ប្តូររូបរាងពាក្យទាំងឡាយ គេនៅតែនិយាយថា ន័យវេយ្យាករណ៍របស់ពាក្យប្រឆាំងបដិបក្ខគ្នានឹងន័យវចនៈ ហើយមានលក្ខណៈជាទម្រង់រូបរាង។ ចំណែកន័យពាក្យសព្ទ គឺមានន័យបង្ហាញវត្ថុមាន លក្ខណៈតថៈ។ ប្រការនោះបានសេចក្តីថា ន័យពាក្យសព្ទ បង្ហាញនូវបាតុភូតនិងវត្ថុតថភាពទាំងឡាយ បង្ហាញនូវពិភពសម្ភារៈ។ ចំណែកន័យវេយ្យាករណ៍ គឺមិនបង្ហាញនូវសញ្ញារួម លក្ខណៈពិសេសរួមរបស់វត្ថុទាំងឡាយនិងបណ្តាបាតុភូតទាំងឡាយដែលបានស្តែងឡើងឬបង្ហាញនៅក្នុងពាក្យនោះទេ ន័យវេយ្យាករណ៍ គឺទូទៅនីយកម្ម អរូបីនីយកម្មនូវបណ្តាពាក្យសព្ទទាំងឡាយ។

ន័យវេយ្យាករណ៍ស្តែងឡើងនិងអភិវឌ្ឍតាមក្បួនច្បាប់ទាំងឡាយរបស់ភាសា ក៏ប៉ុន្តែមិនមែនទៅតាមក្បួនច្បាប់សមហេតុផលដែលមនុស្សធ្លាប់ស្គាល់ក្នុងសកម្មភាពប្រតិបត្តិរាល់ថ្ងៃទេ។ ឧទាហរណ៍បញ្ញត្តិ អំពីលក្ខណៈវត្ថុក្នុងវេយ្យាករណ៍ចង្អុលប្រាប់ជាន់គ្នាលើផ្នែកណាមួយជាមួយបញ្ញត្តិក្នុងជីវភាពរស់នៅធម្មតារាល់ថ្ងៃរបស់នាម *មនុស្ស ផ្ទះ វាលស្រែ...* និងទាំងក្នុងពាក្យ *ការស្មោះត្រង់ គំរូល្អ នយោបាយ សេដ្ឋកិច្ច...*។

### ២.១. ទម្រង់ រូបរាង ស្តែងឡើងដោយន័យវេយ្យាករណ៍

មិនថាឡើយន័យរបស់ពាក្យណាមួយ កន្សោមពាក្យណាមួយ ល្បះណាមួយទេ សុទ្ធតែមានរូបភាព បង្ហាញជាប្រាកដ។ បណ្តាន័យទាំងឡាយរបស់ភាសាសុទ្ធតែមានមធ្យោបាយ វិធី បង្ហាញសម្តែង។

ន័យវេយ្យាករណ៍ក៏ពុំមែនជៀសផុតពីច្បាប់ក្បួនរួមនោះទេ។ ភារកិច្ចសំខាន់មួយរបស់ភាសាវិទ្យា គឺស្រាវជ្រាវអំពីមធ្យោបាយ វិធី បង្ហាញន័យវេយ្យាករណ៍ទាំងឡាយដែលបានប្រើក្នុងភាសាផ្សេងៗគ្នាលើសកលលោក។

ដូចដែលយើងបានដឹងហើយ មធ្យោបាយសំខាន់ៗ ដើម្បីបង្ហាញន័យពាក្យសព្ទរបស់ពាក្យ គឺឫសពាក្យ និងធាតុរូបសព្ទ សម្រាប់បង្កើតពាក្យមូលបទ។

វិធីបង្ហាញន័យវេយ្យាករណ៍ក្នុងភាសាទាំងឡាយដែលផ្លាស់ប្តូររូបរាង ដូចជាភាសាសូវៀត ភាសាបាលី ភាសាអង់គ្លេស ភាសាបារាំងជាដំបូង គឺបណ្តាបទភ្ជាប់។

មធ្យោបាយឬវិធីសំខាន់ទី២ ដែលបង្ហាញនូវន័យវេយ្យាករណ៍ គឺបណ្តាពាក្យគ្មានន័យពាក្យសព្ទ ដូចជាពាក្យនាំមុខនាម ធ្នាក់ ឈ្នាប់។ ធ្នាក់និងឈ្នាប់ដែលប្រើដើម្បី ស

ម្ដែងន័យវេយ្យាករណ៍ក្នុងបណ្ដាភាសាជាច្រើនលើពិភពលោក។ ឧទាហរណ៍ពាក្យ *ព្រោះ* ក្នុងភាសាខ្មែរបង្ហាញនូវន័យវេយ្យាករណ៍ប្រាប់បុព្វហេតុ។ ឧទាហរណ៍ *ខ្ញុំមិនទៅរៀន ព្រោះឈឺ*។

វិធីបង្ហាញន័យវេយ្យាករណ៍ទី៣ គឺលំដាប់ពាក្យក្នុងល្បះនិងលំដាប់ពាក្យនៃសមាសធាតុក្នុងល្បះ។ វិធីនេះបានប្រើប្រាស់ក្នុងភាសាផ្សេងៗគ្នា មិនដូចគ្នាទេ។ ក្នុងភាសាខ្មែរ *បងស្រឡាញ់ប្អូន* បើផ្លាស់លំដាប់ពាក្យក្នុងល្បះ យើងនឹងបាន *ប្អូនស្រឡាញ់បង ស្រឡាញ់បងប្អូន ស្រឡាញ់ប្អូនបង បងប្អូនស្រឡាញ់ ប្អូនបងស្រឡាញ់*។ ដូចនេះ ក្នុងភាសាខ្មែរ បើលំដាប់ពាក្យក្នុងល្បះផ្លាស់ប្ដូរ គឺន័យវេយ្យាករណ៍ រវាងសមាសធាតុរបស់ល្បះក៏ផ្លាស់ប្ដូរដែរឬនិយាយម្យ៉ាងទៀត ទីកន្លែងរបស់ពាក្យក្នុងល្បះ ក៏ជាវិធីសម្ដែងនូវន័យវេយ្យាករណ៍ដែរ។

សម្ដីបង្អូស សញ្ញាកាត់ល្បះ ព្យាង្គសង្កត់ក្នុងពាក្យ គឺជាវិធីទី៤ ដែលសម្ដែងន័យវេយ្យាករណ៍។ ឧទាហរណ៍ក្នុងភាសាខ្មែរ បើលើកសំឡេងនៅចុងល្បះ គឺថាល្បះស្របនឹងផ្លាស់ជាល្បះសំណួរ។ ឧទាហរណ៍ *Vous avez à lécole aujour d'hui?*។ ក្នុងភាសាវៀតណាមមិនប្រើវិធីលើកសំឡេងចុងឃ្លាទេ ប៉ុន្តែប្រើសញ្ញាកាត់ឃ្លាឬដកឃ្លាដើម្បីបង្ហាញន័យវេយ្យាករណ៍។ ក្នុងភាសាខ្មែរ ល្បះ *ខ្ញុំទៅរៀន* មានន័យន័យវេយ្យាករណ៍ខុសគ្នា បើអានសង្កត់ បង្អូស ឬអានធម្មតា។

ក្នុងភាសាមួយចំនួន ពាក្យខ្ទាន់ក៏ជាវិធីបង្ហាញន័យវេយ្យាករណ៍ដែរ។ ឧទាហរណ៍ក្នុងភាសាជប៉ុន ភាសាម៉ាឡាយូ ភាសាវៀតណាម ភាសាខ្មែរ។ *មនុស្សមនុស្ស នរណានរណា ប្រាំប្រាំ ថ្ងៃថ្ងៃ...។* ម្យ៉ាងទៀតការផ្លាស់ប្ដូរស្នៀងក្នុងឫសពាក្យ ក៏បង្ហាញនូវន័យវេយ្យាករណ៍ដែរ។ ឧទាហរណ៍: ភាសាអង់គ្លេស អារ៉ាប់ សូវៀត...។

រួមសេចក្ដីមកវិញ វិធី មធ្យោបាយ បង្ហាញន័យវេយ្យាករណ៍ក្នុងបណ្ដាភាសាលើពិភពលោក គឺអាចជាបទភ្ជាប់បណ្ដាពាក្យគ្មានន័យពាក្យសព្ទ លំដាប់ពាក្យ ពាក្យបង្អូស ព្យាង្គសង្កត់ ពាក្យខ្ទាន់ បម្លាស់ប្ដូរស្នៀង ទំនាក់ទំនងសម្ពន្ធ បន្សំពាក្យ តាមគម្រូ បែបបទពិសេស តាមរូបរាងពិសេស។

### ៣. ប្រភេទវេយ្យាករណ៍

ដូចនិយាយខាងលើពីន័យពាក្យសព្ទក៏ដូចជាន័យវេយ្យាករណ៍សុទ្ធតែមានវិធីសម្ដែងពិសេស។ បើយើងនិយាយអំពីពាក្យជាបឋមយើងត្រូវគិតដល់អង្គធាតុ តថភាពដែលមានន័យពាក្យសព្ទនិងមានវិធីបង្ហាញជាក់ស្ដែងនូវន័យនោះ។ បើនិយាយអំពីន័យ

វេយ្យាករណ៍ ក៏ដូចនោះដែរ គឺបានន័យថាន័យវេយ្យាករណ៍ស្ដែងឡើងក្នុងអង្គធាតុមានសញ្ញារូបរាងជាក់ស្ដែង។ ប្រភេទវេយ្យាករណ៍ គឺជាអង្គធាតុថេរបស់ភាសាដែលមានន័យវេយ្យាករណ៍និងមានសញ្ញាសម្ភារៈជាក់ស្ដែងបង្ហាញនូវន័យនោះ។ ឧទាហរណ៍បើយើងនិយាយប្រភេទវេយ្យាករណ៍ដែលស្ដីអំពីកាលរបស់កិរិយានិងសញ្ញាប្រាប់នូវបណ្ដាអត្ថន័យទាំងនោះ។

ប្រភេទវេយ្យាករណ៍ត្រូវបានរកឃើញក្នុងទម្រង់បដិបក្ខ ពីព្រោះក្នុងភាសាវិទ្យា គេនៅតែឱ្យនិយមន័យប្រភេទវេយ្យាករណ៍ថាជាប្រព័ន្ធនៃបណ្ដាន័យវេយ្យាករណ៍ផ្ទុយគ្នាប្រឆាំងគ្នាដែលស្ដែងឡើងដោយសញ្ញារូបរាងណាមួយនោះ។

មនុស្សដោយការអនុវត្ត បានក្ដាប់ជាប់រឹងមាំនូវភាសាតាំងពីតូចមក ប៉ុន្តែត្រូវឆ្លងកាត់ការរៀនសូត្រ ស្រាវជ្រាវភាសាវិទ្យា ទើបបានយល់ច្បាស់លាស់អំពីប្រភេទវេយ្យា-ករណ៍ជាអ្វី? ហើយវាមានសភាពចលនាបែបណាក្នុងភាសា។

ប្រភេទវេយ្យាករណ៍ក៏ដូចជាន័យវេយ្យាករណ៍ដែរ វាមានចរិតទូទៅនិងមានលក្ខណៈអរូបីខ្ពស់។ ប្រភេទវេយ្យាករណ៍នីមួយៗ គឺជាលក្ខណៈរួមមួយ (ទូទៅ) ដែលចេញពីឯកតាអង្គធាតុ ពាក្យសព្ទជាច្រើនលើបណ្ដាសញ្ញាដូចគ្នាលើផ្នែកន័យនិងរូបរាង។ ប្រភេទវេយ្យាករណ៍អំពីពហុវចនៈនៃនាមសព្ទ ភាសាអង់គ្លេសមានន័យវេយ្យាករណ៍ប្រាប់នូវពហុវចនៈនិងមានរូបភាពស្ដែងឡើងជាពិសេសនៅចុងពាក្យ – (e) s ៖

Book books *សៀវភៅច្រើន*

Friend friends *មិត្តច្រើន*

Table tables *តុច្រើន*

City cities *ទីក្រុងច្រើន*

ប្រភេទវេយ្យាករណ៍ក្នុងភាសានីមួយៗមានរូបរាងផ្សេងៗគ្នាស្រេចតែទៅតាមលក្ខណៈរបស់ន័យវេយ្យាករណ៍ដែលបានបង្ហាញឬស្ដែងឡើងនិងទំនាក់ទំនងរវាងបណ្ដាន័យនោះចំពោះតថភាព។

គេអាចចែកប្រភេទវេយ្យាករណ៍មូលដ្ឋានជាបួនយ៉ាងដូចតទៅនេះ ៖

### ៣.១. ប្រភេទវេយ្យាករណ៍ដែលប្រាប់ថ្នាក់ពាក្យ

ប្រភេទវេយ្យាករណ៍របស់ពាក្យ គឺជាប្រភេទដែលប្រាប់សញ្ញារួមណាមួយនោះរបស់ថ្នាក់ពាក្យណា មួយ... ដូចជានាម កិរិយាសព្ទ គុណនាម ភេទបុរស ភេទស្ត្រី អភេទក្នុងភាសាឥណ្ឌូអឺរ៉ុប...។

### ៣.២. ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ផ្លាស់ប្ដូររបស់ពាក្យ

ប្រភេទវេយ្យាករណ៍ប្រាប់ទម្រង់ផ្លាស់ប្ដូររបស់ពាក្យបង្ហាញឡើងនូវភាពដូចគ្នាតែមួយគត់របស់ថ្នាក់ពាក្យណាមួយនោះទៅតាមសញ្ញាជារូបរាងផ្លាស់ប្ដូររួម។ ឧទាហរណ៍ ប្រភេទវេយ្យាករណ៍ដែលបង្ហាញរូបរាងផ្លាស់ប្ដូរវិភត្តិរបស់នាមសព្ទរបស់កិរិយានិងគុណនាមក្នុងភាសាសូវៀតឬបាលី។ ប្រភេទវេយ្យាករណ៍ឯកវចនៈនិងពហុវចនៈក្នុងភាសាបារាំងនិងភាសាអង់គ្លេស។ ឧ. Table tables *តុ* , Child children *ក្មេង* , Man men *បុរស*។

### ៣.៣. ប្រភេទវេយ្យាករណ៍ដែលប្រាប់ទីកន្លែងរបស់ពាក្យ

ប្រភេទវេយ្យាករណ៍អំពីទីកន្លែងរបស់ពាក្យ គឺជាឯកភាពនៃទំនាក់ទំនង ហើយនិងរូបរាងដែលបង្ហាញឡើងរបស់បណ្ដាពាក្យដែលមានន័យពាក្យសព្ទមានទីតាំងដូចគ្នាក្នុងល្បះ។ ឧទាហរណ៍ប្រភេទបម្រាប់ប្រធាននៅក្នុងល្បះនិងបណ្ដាប្រភេទសមាសធាតុនៃល្បះ។

### ៣.៤. ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ល្បះ

នោះជាប្រភេទវេយ្យាករណ៍អំពីល្បះដែលមានទំនាក់ទំនងច្រើនបំផុត ហើយនិងមានរូបរាងបង្ហាញច្រើនបំផុតពីផ្នែកវេយ្យាករណ៍ដូចជាប្រភេទល្បះទោល ល្បះផ្សំ...។

ក្នុងភាសាវិទ្យាមានផ្នែកមុខវិជ្ជាពីរដែលស្រាវជ្រាវអំពីប្រភេទវេយ្យាករណ៍ទាំងឡាយខាងលើ គឺរូបសព្ទវិទ្យាឬសណ្ឋានវិទ្យានិងសម្ព័ន្ធវិទ្យា។

# មេរៀនទី២
# វណ្ណយុត្តិនិងសញ្ញាល្បះ

ក្នុងភាសាខ្មែរមានសញ្ញាទាំងឡាយសម្រាប់ប្រើបន្ថែមឬប្រើផ្សំជាមួយនឹងអក្សរ ដើម្បីលម្អៀងសព្ទដើមឱ្យប្លែកចាកលំនាំដើមក៏មាន សម្រាប់ប្រើខណ្ឌសេចក្ដីជាសង្កាត់ៗ ឱ្យមានរបៀបជាឃ្លាល្បះឬជាប្រយោគនីមួយៗដើម្បីឱ្យងាយស្ដាប់កុំឱ្យច្រឡំសេចក្ដីក៏មាន។ សញ្ញាទាំងនោះចែកជាពីរផ្នែក គឺវណ្ណយុត្តិនិងសញ្ញាល្បះ។

**១. វណ្ណយុត្តិ**

**វណ្ណយុត្តិ** គឺជាពួកសញ្ញាដែលប្រើលើតួអក្សរឬប្រើផ្សំជាមួយនឹងអក្សរដើម្បីបំប្លែងតួអក្សរឬសព្ទដើមឱ្យមានសំឡេងប្លែកចាកលំនាំដើម។

**១.១. សញ្ញាបន្តក់ឬរស្សសញ្ញា** ( ់ )

វណ្ណយុត្តិមួយបែបនេះមានសណ្ឋានកំបុតខ្លីយ៉ាងនេះ ( ់) សម្រាប់ប្រើបំបែរសំឡេងវែងឱ្យខ្លីកំបុត ធ្ងន់ ប្រើដាក់បានតែពីលើតួអក្សរប្រកបរបស់ខ្មែរដែលជាស្រៈ អ អា ពីរនេះ ហើយតួដែលប្រកបនោះជាអក្សរ **ក ង ច ញ ត ន ប ល ស** ។

| | | |
|---|---|---|
| ឧ. | *កក > កក់* | *ចង្កាក > ចង្កាក់* |
| | *កង > កង់* | *ដាច > ដាច់* |
| | *ចាញ > ចាញ់* | *កត > កត់* |
| | *កាន > កាន់* | *បង្កាន > បង្កាន់* |
| | *ចប > ចប់* | *កប > កប់* |
| | *ដាល > ដាល់* | *ដល > ដល់* |
| | *ទាស > ទាស់* | *ស្គាល > ស្គាល់* ។ |

ពាក្យខ្ចីពីបាលីឬសំស្ក្រឹត ទោះបីពាក្យនោះកើតមកអំពីស្រៈ អ ឬ អា ហើយប្រកបនឹងអក្សរទាំង៩តួខាងលើនេះក្ដី ក៏មិនត្រូវប្រើបន្តក់ដែរ។

**១.២. សំយោគសញ្ញាឬសញ្ញាផាត់លើ** ( ័ )

សំយោគសញ្ញាប្រើសម្រាប់៖

-កត់សូរ «**អា**» ខ្លី។ ឧ. *អាល័យ អាស្រ័យ ចល័ត*...។

-កត់សូរ «**អ័រ**» ដោយមានឬគ្មានព្យញ្ជនៈ រ។ ឧ. *ជ័រ ញ័រ ខ្ញ័រ*...។

**១.៣. យុគលពិន្ទុឬសញ្ញាចុចពីរ** (ៈ)

យុគលពិន្ទុប្រើសម្រាប់កត់សូរ «**អា**» ខ្លី ជាពិសេសជាមួយនឹងពាក្យខ្ចីពីភាសាបាលី-សំស្ក្រឹត ។ ឧ. *ឋានៈ វីរៈ ភារៈ សាធារណៈ គណៈ សច្ចៈ...*។

កាលណាពាក្យដែលមានយុគលពិន្ទុទាំងនេះប្រើផ្សំជាមួយពាក្យដទៃ គឺគេត្រូវលុបយុគលពិន្ទុចេញដើម្បីបង្កើតពាក្យសមាស។ ឧ. *សាធារណរដ្ឋ ភារកិច្ច វីរភាព សច្ចភាព...* លើកលែងតែពាក្យមួយចំនួនដូចជា *គណៈកម្មការ គណៈរដ្ឋមន្ត្រី កាលៈទេសៈ សារៈសំខាន់...* ដែលនៅរក្សាយុគលពិន្ទុដដែល។

**១.៤. វិសជ៌នីយឬសញ្ញារះមុខ** (ះ)

សញ្ញារះមុខប្រើសម្រាប់ជំនួសសូរព្យញ្ជនៈចុងព្យាង្គ *ហ* ដើម្បីរួមបង្កើតសូរព្យាង្គ។ ឧ. *ជិះ ចង្អឹះ ត្រិះរិះ ច្រែះ កែះ...*។

**១.៥. សញ្ញានិគ្គហិតឬសញ្ញាដំណើ** (ំ)

សញ្ញានិគ្គហិតឬដំណើប្រើដើម្បីកត់សូរព្យញ្ជនៈចុងព្យាង្គ «ង» ដើម្បីរួមបង្កើតសូរព្យាង្គក្នុងពាក្យដែលមានប្រភពពីបាលីសំស្ក្រឹត។ ឧ. *សំស្ក្រឹត សំយោគ រូបំ ទុក្ខំ មំសាសត្វ ហឹសា ហានេយ្យំ...*។

**១.៦. សញ្ញាលេខទោ** (ៗ)

លេខទោមានឈ្មោះម្យ៉ាងទៀតថា អាមេណ្ឌិតសញ្ញា។ លេខទោមានន័យថា លេខ២ ប៉ុន្តែបុព្វបុរសខ្មែរមិនធ្វើរូបរបស់វាឱ្យដូចលេខ២ទេ ព្រោះខ្លាចច្រឡំ។ សញ្ញានេះមានក្បាលដូចលេខ២ ហើយមានកន្ទុយទាញចុះក្រោម ដូចដែលយើងធ្លាប់ស្គាល់ស្រាប់។

គេប្រើលេខទោនៅជាប់នឹងពាក្យមួយដើម្បីឱ្យពាក្យនោះត្រូវអានផ្ទួនជាប់គ្នា។ ពាក្យដែលមានសញ្ញាលេខទោជាពាក្យដែលសម្គាល់ន័យច្រើន ច្រើនដងឬដដែលៗ។ ឧ. *ម្ហូបៗ ម្ដើបៗ ផ្សេងៗ ម្ដងៗ យាយៗ ប្អូនៗ មួយៗ យឺតៗ...*។

គេមិនប្រើលេខទោជាមួយពាក្យដែលត្រូវអានផ្ទួន ហើយមានប្រភពពីភាសាបាលីទេ គឺគេត្រូវរក្សារូបដើមរបស់វាវិញ ដោយសរសេរពីរដងជាប់គ្នាឬបន្តគ្នា។ ឧ. *នានា, អាបោ អាបោ, ភិយ្យោភិយ្យោ...*។

ល្បះមួយអាចមានវត្តមានពាក្យឬក្រុមពាក្យដដែលនៅជាប់គ្នា ប៉ុន្តែយើងមិនប្រើលេខទោទេ បើវាជាធាតុរបស់ល្បះផ្សេងគ្នា ពីព្រោះដូចយើងអធិប្បាយរួចមកហើយថា

គេប្រើលេខទោតែជាមួយពាក្យដែលត្រូវអានផ្ទួនជាប់គ្នា។

ដូច្នេះ គេសរសេរ៖ *បើឯងមិនប្រាប់គាត់ គាត់ធ្វើម៉េចនឹងដឹង។*

មិនមែន៖ *បើឯងមិនប្រាប់គាត់ៗធ្វើម៉េចនឹងដឹង។*

**១.៧. សញ្ញាលេខប្រាំបីឬលេខអស្តា** ( ៏ )

អស្តាប្រើដាក់នៅពីលើព្យញ្ជនៈ **ក ដ ន ម ហ** ដើម្បីឱ្យវាក្លាយជាព្យាង្គ *ក៏ ដ៏ ន៏ ម៏ ហ៏* ដែលមានស្រៈកប់តួ «អ» ឬ «អឺ» នៅជាមួយ ហើយគេត្រូវអានព្យាង្គទាំងនេះខ្លី ហើយរហ័ស។ ឧ. *ឆ្កែក៏ដោយ ឆ្មាក៏ដោយ ផ្ទះដ៏ល្អ*...។

**កំណត់សម្គាល់៖**

ពាក្យ *ដរាប* ត្រូវសរសេរបែបនេះជាពាក្យពីរព្យាង្គ មិនត្រូវសរសេរជា *ដ៏រាប* ទេ ពីព្រោះពាក្យ *រាប* ជាគុណនាម ដូច្នេះការសរសេរបែបទីពីរជាកន្សោមគុណនាម (ដូចយើងអធិប្បាយរួចមកហើយថា *ដ៏* ប្រើនៅមុខគុណនាម) ដែលមានន័យថា *ដែលរាប*។

-*ឰដ៏* មានន័យថានៅឯ ឯនាយ ឧ. *ឰដ៏អាកាស* ។

-*ន៏* ប្រើជាមួយពាក្យដែលជាសព្វនាមចង្អុលឱ្យមានដំណើរកាន់តែច្បស់ឬប្រើចេញជាអាការៈស្រដៀងនឹងឧទានសព្ទ។ ឧ. *អុញន៏! នុះន៏! ឯណោះន៏!*...។

-*ម៏* ជាពាក្យនិយាយសាមញ្ញ កាត់ខ្លីមកពីពាក្យ *មក* ប្រើសម្តែងអាការៈប្រញាប់។ ឧ. *ម៏ ទៅផ្ទះ!*

-*ហ៏* ប្រើសម្តែងការប្រញាប់។ ឧ. *ហ៏ យកចុះ!*

**១.៨. សញ្ញាជើងក្អែកឬសញ្ញាភាគបាន** ( ៏ )

សញ្ញាជើងក្អែកប្រើដាក់លើពាក្យដើម្បីសម្គាល់ថាពាក្យនោះត្រូវអានឱ្យខ្លាំងខ្ពស់ឡើងជាងប្រក្រតី។ ពាក្យ *ហ្ន អ្ហយ ចា នុះ ក្ងក នៃ* អាចឱ្យគេបន្ថែមសញ្ញាជើងក្អែកដើម្បីសម្គាល់ថា ត្រូវអានវាឱ្យខ្លាំងខ្ពស់ឡើងជាងមុន *ហ្ន៎ (អ៊ីហ្ន៎) អ្ហយ៎ ចា៎ ក្ងក៎ នៃ៎ (នេះនៃ៎)* ។

**១.៩. សញ្ញាបដិសេធឬទណ្ឌឃាត** ( ៍ )

ទណ្ឌឃាតប្រើសម្រាប់បដិសេធការអានព្យញ្ជនៈប្រកបឬព្យាង្គដែលនៅខាងក្រោមវា។ ឧ. *មក៍ រក៍ យក៍ អនុវត្តន៍ ឧទាហរណ៍*។ ដោយសារភាសាខ្មែរជាភាសាដែលសម្បូរទៅដោយពាក្យឯកព្យាង្គ គេប្រើសញ្ញាបដិសេធដើម្បីកាត់បន្ថយចំនួនព្យាង្គរបស់ពាក្យដែលមានប្រភពពីភាសាបាលី-សំស្ក្រឹត។ ឧ. *ប្រយោជន (ប្រយោ៉ចជាក់ណាក់)* > *ប្រយោជន៍ (ប្រយោ៉ច) , អភិវឌ្ឍន (អាក់ភិវាត់ធាក់ណាក់)* > *អភិវឌ្ឍន៍ (អាក់ភិវាត់) ,ការណ (ការ៉ាក់ណាក់)* >  *ការណ៍* (*កា*) ...និងដោយសារជនជាតិខ្មែរពុំអានព្យញ្ជនៈប្រកបឱ្យ

ចេញជាសូរឃោសៈឬអឃោសៈ ទើបគេរក្សាទុកសញ្ញាតំណាងសូរចុងព្យាង្គរបស់ពាក្យបារាំងដើម្បីឱ្យដឹងថា វាមានប្រភពមកពីអ្វីក្នុងភាសានោះ (ឧ. *ស៊ីម៉ង់ត៍*)។ ដោយសារហេតុនេះហើយ ទើបយើងឃើញថាព្យញ្ជនៈឬព្យាង្គនោះពុំមានប្រយោជន៍ដើម្បីឱ្យគេសរសេរប្រកបជាមួយអក្សរដទៃឡើយ ប៉ុន្តែគេនៅប្រើព្យញ្ជនៈឬព្យាង្គនោះដោយដាក់សញ្ញាបដិសេធពីលើ ដើម្បីសម្គាល់ជាតិសព្ទ (ប្រភពពាក្យ) របស់ពាក្យនោះតែប៉ុណ្ណោះ។

ពាក្យដូចជា *ហេតុ ប្រវត្តិ ជាតិ ភស្តុតាង* ដែលមានប្រភពមកពីពាក្យក្នុងភាសាបាលី-សំស្ក្រឹត ដែលមានស្រៈនៅខាងចុង ហើយដែលខ្មែរពុំអានសូរនោះ គេមិនប្រើសញ្ញាបដិសេធលើព្យាង្គនោះទេ ព្រោះព្យញ្ជនៈដើមព្យាង្គរបស់ព្យាង្គទាំងនេះ ប្រើជាព្យញ្ជនៈប្រកបទៅហើយ បើគេប្រើសញ្ញាបដិសេធពីលើព្យាង្គ នាំឱ្យគេលែងអានព្យញ្ជនៈដើមព្យាង្គរបស់វាជាព្យញ្ជនៈប្រកបទៀតហើយ។ ដូច្នោះ *ហេតុ៍* ត្រូវអានជា *ហេ ប្រវត្តិ៍* ត្រូវអានជា *ប្រវ ភស្តុ៍តាង* ត្រូវអានជា *ភតាង* ។

**១.១០. សញ្ញារបាទ** ( ៌ )

របាទមានន័យថាជើង *រ* (ជើងអក្សរ *រ* )។ ប៉ុន្តែតាមការពិនិត្យ យើងឃើញថាឈ្មោះនេះផ្ទុយពីការប្រើប្រាស់របស់វា ពីព្រោះបើរបាទជាជើង *រ* ដូច «្រ» នោះពាក្យ *និទ៌ុក្ខ* ត្រូវអានថា និ-ទ្រុក មិនមែន និ-រ-ទុក ហើយដែលអាចឱ្យគេសរសេរ និរទេស (ដែលមានសូរ រ មុន) បែបនេះបានទេ។

គេប្រើរបាទដាក់ពីលើព្យញ្ជនៈមួយ (ចំពោះពាក្យដែលខ្ចីមកពីភាសាសំស្ក្រឹត ឬភាសាសំស្ក្រឹតក្លាយ) ដើម្បីឱ្យវាមានសូរញ៉រ «រ» ហើយបើព្យញ្ជនៈនោះមានស្រៈនៅជាមួយ វាក្លាយទៅជាព្យញ្ជនៈដើម្បីព្យាង្គរបស់ព្យាង្គទី២ (ឧ. *ធម៌ ព័ណ៌ ពណ៌នា គ័ភ៌ និទ៌ុក្ខ សួគ៌*)។ ដោយសារលក្ខណៈនេះ យើងឃើញថាព្យញ្ជនៈដែលមានរបាទនៅពីលើប្រើដូចជាព្យញ្ជនៈផ្ញើជើង ពាក្យក្នុងឧទាហរណ៍ខាងលើមានលំនាំជា *ធម្ម ពណ្ណ ពណ្ណនា គព្ភ និរុទ្ទុក្ខ សួគ្គ*។

បើមានស្រៈទើសទាក់ គេមិនប្រើរបាទទេ គេប្រើអក្សរ រ វិញ។ ឧ. *ទុរ្ភិក្ស រាមកេរ្តិ៍ តិរ្ថិយ អន្យតិរ្ថិយ* ជាដើម។ ជួនកាលពុំមានស្រៈទើសទាក់ទេ ប៉ុន្តែគេសរសេរអក្សរ រ ដែរ ដើម្បីកុំឱ្យច្រឡំពិបាកអាន។ ឧ. *កម៌ន* (អាចច្រឡំអានថា កៈ រ មន) *អស្ចាយ៌ អាចាយ៌* (អាចពិបាកអានសូរ រ ខាងក្រោយ) គេសរសេរជា *កម៌្មន អស្ចារ្យ អាចារ្យ* (ប្រើសម្រួលឱ្យងាយមើល ងាយថា)។ បើមានអក្សរ រ ជាតួប្រកបពីខាងចុង និងប្រើជា របាទ (រេផៈ) នេះផងពុំបានឡើយ ដូចជា *ជ័រ ញ៉័រ ទទ័រ* ជាដើម (សរសេរយ៉ាងនេះត្រឹមត្រូវហើយ) កុំ

សរសេរជា *ជ័រ ជារ ទទ័រ* ដូច្នេះឡើយ។

**១.១១. សញ្ញាមូសិកទន្តឬសញ្ញាធ្មេញកណ្ដុរ** ( ៉ )

ជាទូទៅ សញ្ញាមូលសិកទន្តឬសញ្ញាធ្មេញកណ្ដុរ ប្រើដាក់លើព្យញ្ជនៈចុងវគ្គពួកអ៊ «ង ញ ន ម» និងព្យញ្ជនៈសេសវគ្គពួកអ៊ «យ រ ល វ» ឱ្យក្លាយជាព្យញ្ជនៈពួកអ។ ឧ. *ក៉ូន ង៉ែត ឧកញ៉ា ម៉េឌីនា ម៉ៃ យ៉ាង វ៉ែ មល៉ាយូ តវ៉ា...*។

**កំណត់សម្គាល់៖**

-សញ្ញាមូលសិកទន្តឬសញ្ញាធ្មេញកណ្ដុរ ប្រើលើព្យញ្ជនៈ ប ឱ្យក្លាយទៅជា ប៉ ដែលជាព្យញ្ជនៈពួកអ ដូច ប ដែរ។

-សញ្ញាមូលសិកទន្ត កាលណាគេប្រើជាមួយសញ្ញាស្រៈនិស្ស័យដែលនៅខាងលើព្យញ្ជនៈ គេត្រូវជំនួសសញ្ញាមូលសិកទន្តនេះ ដោយសញ្ញាបុកជើងវិញ ឧ. *ញុាំ ញុាំញុើ ង៉ុ ងើ ង៉ិកង៉ក់...*។

**១.១២. សញ្ញាត្រីសព្ទឬសញ្ញាសក់ក** ( ៊ )

សញ្ញាត្រីសព្ទឬសញ្ញាសក់ក ប្រើដាក់លើសញ្ញាព្យញ្ជនៈពួកអ «ប ស ហ អ» ឱ្យក្លាយជាព្យញ្ជនៈពួកអ៊។ ឧ. *ប៊ីចេង ប៊ិក សាប៊ូ តស៊ូ ស៊ី កៅស៊ូ តៅហ៊ូ អ៊ូអរ...*។

**កំណត់សម្គាល់៖**

-សញ្ញាត្រីសព្ទ កាលណាគេប្រើជាមួយសញ្ញាស្រៈនិស្ស័យដែលនៅខាងលើព្យញ្ជនៈ គេត្រូវជំនួសសញ្ញានេះដោយសញ្ញាបុកជើងវិញ លើកលែងតែ ប៊ ដែលត្រូវរក្សាសញ្ញាត្រីសព្ទឱ្យនៅដដែលដើម្បីកុំឱ្យច្រឡំនឹង ប៉។

**២. សញ្ញាល្បះ**

**សញ្ញាល្បះឬសញ្ញាពិសេស** គឺជាសញ្ញាទាក់ទងជាពិសេសនឹងឃ្លាល្បះ។ វាត្រូវបានគេប្រើនៅក្នុងល្បះ។ សញ្ញាល្បះនេះ លោកបណ្ឌិត ច័ន្ទ សំណព្វ បានឱ្យឈ្មោះថា **វណ្ណវាទ** ជាប្រភេទមួយនៃសិប្បសញ្ញាគ្មានតួនាទីប្រកបសូរទេ។ លោកបណ្ឌិត កេង វ៉ាន់សាក់ បានឱ្យឈ្មោះថា **សញ្ញាសម្ព័ន្ធ** ជាសញ្ញាសម្រាប់សម្គាល់ន័យ សេចក្ដីបំណាង ហើយនិងរូបរាងលក្ខណៈរបស់ឃ្លាប្រយោគ។

សព្វថ្ងៃ ខ្មែរយើងប្រើសញ្ញាល្បះមានដូចជា៖

**២.១. សញ្ញាប្រយោគបង្កើតដោយបុព្វបុរសខ្មែរ**

**២.១.១. សញ្ញាខណ្ឌ** ( ។ )

គេប្រើសញ្ញានេះ នៅចុងបញ្ចប់នៃល្បះប្រកាសឬនៅចុងបញ្ចប់នៃវគ្គរបស់កំណាព្យ។

ឧ. *- អូនកុំនិយាយយ៉ាងនេះនាំឱ្យបាបនឹងទេវតា។*

*- នរអ្នកណា នឹងស្វែងប្រាជ្ញា ឱ្យបានខ្លួនថ្លៃ ចូរដឹងខុសគាប់ ដោយអធ្យាស្រ័យ ផ្តាប់ដោយហឫទ័យ អ្នកជាបាធ្យាយ។*

**២.១.២. សញ្ញាខណ្ឌចប់** (៕)

ដូចមានឈ្មោះមកស្រាប់ សញ្ញាខណ្ឌចប់គឺជាសញ្ញាសម្រាប់បញ្ចប់អត្ថបទ។

ឧ. *...រឿងនេះបញ្ចប់តែត្រឹមនេះ៕*

*...ឯរំតែងតាំងតាមវោហារ យើងសន្មតថាទុកជាច្បស់*

*ស្រេចនូវប្រការជាអណ្តាប់ សាស័ព្ទថែងចប់ម៉្លេះឯងហោង៕*

**២.១.៣. សញ្ញាដកឃ្លាឬដំណកឃ្លា**

ដកឃ្លាឬដំណកឃ្លាជាគម្លាតឬចន្លោះរវាងពាក្យពីរម៉ាត់ឬកន្សោមពាក្យពីរកន្សោម។ ដោយខ្មែរយើងសរសេរមិនដកឃ្លាពីពាក្យមួយទៅពាក្យមួយ បុព្វបុរសយើងបាននាំប្រើដំណកឃ្លាក្នុងករណីមួយចំនួន លេចថ្កោលឡើងដើម្បីឱ្យងាយយល់។ ពិតមែនតែនៅមានការស្នាក់ស្ទើរបន្តិចបន្តួច ប៉ុន្តែជាទូទៅ អ្នកអក្សរសាស្ត្រខ្មែរបានប្រើដំណកឃ្លាសមស្របតាមលក្ខណៈសម្ព័ន្ធរបស់ល្បះ គឺដកឃ្លាជាកន្សោមៗ មានៈ កន្សោមនាម កន្សោមកិរិយា កន្សោមមានផ្ទាក់...។ គេដកឃ្លាៈ

-នៅចន្លោះពាក្យ កន្សោមពាក្យ ដែលមានសមភាព ហើយដែលត្រូវបានគេរាយដោយមានឬគ្មានប្រើក្បៀស។

ឧ. *-សត្វពាហនៈមាន គោ ក្របី សេះ ដំរី។ល។*

*-ប៉ុន្តែបើមានស្រៈដែលទើសពិបាកសរសេរនោះ ត្រូវដាក់អក្សរ រ ពេញតួពីលើជើងអក្សរខាងចុងវិញ, ដូចជា ទុរ្ភិក្ស, មូរ្តិ, រាមកេរ្តិ៍, តិរ្ថិយ ជាដើម។*

-នៅខាងឆ្វេងនិងខាងស្តាំបេយ្យាលៈ។

*ឧ. បើត្រូវសរសេររាយតួជា កំរាល, កំរាស់ ។ល។ តាមទម្លាប់នោះសិនទៅក៏បាន (...)។*

-នៅខាងស្តាំសញ្ញាខណ្ឌ។

ឧ. *-កាយវិញ្ញាណ សេចក្តីដឹងច្បាស់នូវអារម្មណ៍តាមទ្វារកាយ គឺកាយធាតុនិងផោដ្ឋព្វធាតុមានការប៉ះទង្គិចគ្នានាំឱ្យកើតសេចក្តីដឹងឡើង។ កាយវិវេក សេចក្តីស្ងប់ស្ងាត់នៃកាយ (ម.ព វិវេក)។*

-នៅចន្លោះនាមត្រកូលនិងនាមខ្លួននៃឈ្មោះមនុស្ស ព្រមទាំងនៅខាងឆ្វេងនិង

ខាងស្ដាំនៃឈ្មោះទាំងមូល។ ឧ. *លោក តន់ ព្រឿង, លោក ស៊ុន ម៉េងស្រ៊ុន អធិការនគរបាលជាតិ, លោក កិម ធុក និង លោក ភួង ភិន នាយត្រួតនគរបាលជាតិ បានជួយឧបត្ថម្ភដោយពុំញញើត* (...)។

-នៅខាងឆ្វេងនិងខាងស្ដាំលេខ ឧ. *វចនានុក្រមខ្មែរនេះ បានចាប់កំណើតឡើងដោយមានព្រះរាជប្រកាសលេខ ៦៧ ចុះថ្ងៃទី ៤ ខែធ្នូ គ.ស. ១៩១៥*។

-ក្នុងល្បះ គេដកឃ្លាធ្វើឱ្យមានគម្លាតរវាងកន្សោមពាក្យដែលមានមុខងារផ្សេងគ្នា។

ឧ. *មុននឹងផ្ដើមការរៀបរៀង គណៈកម្មការបានប្រឹក្សាយ៉ាងយូរ (...)*។

**២.១.៤. សញ្ញាបេយ្យាលៈ (ឡាក់) (។ល។)**

គេប្រើសញ្ញានេះសម្រាប់ប្រាប់ថា ពាក្យ សេចក្ដី ដែលគេបានរៀបរាប់នោះ មិនទាន់ចប់ទេ នៅមានតទៅទៀត។

ឧ. *សត្វពាហនៈមានគោ ក្របី សេះ។ល។*

**២.១.៥. ចំណុចពីរគូសបន្ទុះដំពីរ (៖)**

បុព្វបុរសខ្មែរបានបង្កើតសញ្ញាចំណុចពីរគូស ដើម្បីប្រើដូចសញ្ញាចុចពីរ ( : ) របស់ភាសាអឺរ៉ុបមានបារាំង អង់គ្លេសជាដើម។

-ដើម្បីស្រង់យកសម្ដីផ្ទាល់របស់នរណាម្នាក់មកបង្ហាញ។

ឧ. *អ្នកស្រី អ៊ឹង ម៉ាល័យ បានសរសេរថា ៖ «អាយតនិបាតមិនមែនជាបញ្ហាថ្មីស្រឡាងទេ យើងឃើញថា មានការសិក្សាជាច្រើនលើប្រភេទពាក្យនេះ ប៉ុន្តែ មិនទាន់មានលក្ខណៈលម្អិតនៅឡើយ»*។

-ដើម្បីបង្ហាញសេចក្ដីដែលនរណាម្នាក់នឹកគិតក្នុងចិត្ត។

ឧ. *គាត់ខំប្រឹងស្មារតីទប់កុំឱ្យភ្លាត់មាត់ថា ៖ «យកចុះ! យកចុះ!»*។

-ដើម្បីរៀបរាប់។

ឧ. *ដើម្បីឱ្យស្នាដៃមានលក្ខណៈអន្តរជាតិទៅបាន វាជាបញ្ហាមួយលំបាកបំផុត ទាមទារឱ្យអក្សរសិល្ប៍មានលក្ខណៈដូចតទៅ៖*

*-មានតម្លៃគ្រប់សម័យកាលគ្រប់សង្គម*

*-ទេពកោសល្យនៃស្នាដៃវាល្អខ្ពស់ឆ្ងាយពីស្នាដៃមុនៗ*

*-មានតម្លៃសីលធម៌ជឿនលឿន*

*-បង្កប់នូវខ្លឹមសារល្អ ជាគំនិតវិទ្យាសាស្ត្រ ទស្សនវិជ្ជាជឿនលឿន។*

**២.១.៦. គោមូត្រ** ( ៚ )

សញ្ញានេះមានរូបសណ្ឋានស្រដៀងនឹងកង្កាញ់ទឹកនោមគោ។ គេប្រើសម្រាប់សរសេរដាក់ត្រង់កន្លែងបញ្ចប់សេចក្ដី ដែលចប់អស់ហើយ។ រីឯអ្នកលង្កាទ្វីបប្រើដាក់ត្រង់ទីចប់នៃគាថាបាលីមួយៗ (សព្វថ្ងៃនេះ មិនសូវមានឃើញប្រើទេ)។

*៙ ហែមហាជនសប្បុរស ទោះស្រីប្រុស ...ច្បាប់ធម៌ថាសុខស្រេចហោង ៚*

**២.១.៧. សញ្ញាកុក្កុដនេត្រឬភ្នែកមាន់** ( ៙ )

សញ្ញានេះមានសណ្ឋានជាទម្រង់មូលពីរជាន់តូចក្នុង ធំក្រៅ ស្រដៀងនឹងភ្នែកមាន់យ៉ាងនេះ (៙) សម្រាប់ប្រើដាក់លើក្បាលបន្ទាត់ដើមសេចក្ដីធំនីមួយៗ ឬប្រើដាក់នៅខាងដើមបទ ក្នុងពាក្យកាព្យឃ្លោង (សព្វថ្ងៃនេះមិនសូវមានឃើញប្រើទេ)។

ឧ. *៙ ជុលីហត្ថនមស្ការដាក់លើកេស តាងប្រទីបកោសុមបទុមទេស...។*

**២.២. សញ្ញាប្រយោគខ្ចីពីភាសាបារាំង**

**២.២.១. វជ្ជសញ្ញាឬគ្រេ** ( - )

គេប្រើសញ្ញានេះ៖

-សម្រាប់តម្រៀបអ្វីៗដែលគេរាប់ ដើម្បីឱ្យអ្វីៗនោះលេចធ្លោលឡើង (ផ្ទុយពីការរាប់បន្តៗគ្នាតាមបន្ទាត់តែមួយ)។ គេប្រើវជ្ជសញ្ញាបន្ទាប់ពីមានសញ្ញាចុចពីគូស។

ឧ. *ព្រហ្មញ្ញសាសនា គោរពព្រះអាទិទេព ៣ អង្គ៖*

*-ព្រះវិស្ណុ*

*-ព្រះសិវៈ*

*-ព្រះព្រហ្ម។*

-សម្រាប់បង្ហាញការឆ្លើយឆ្លងគ្នា។

ឧ. *- នាងអញ្ជើញនៅពិសាបាយនឹងខ្ញុំនេះហើយ។*

*- ចាសថៃ កុំព្រួយ ខ្ញុំមានការបន្ទាន់បន្តិច។*

-សម្រាប់ផ្ដាច់ព្យាង្គរបស់ពាក្យមួយ ដែលគេសរសេរមកដល់ចុងក្រដាសហើយមិនអស់ តម្រូវឱ្យតមកបន្ទាត់ខាងក្រោមទៀត។

ឧ. *រដ្ឋាភិបាលជប៉ុនតែងតែផ្ដល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ អនុ-បណ្ឌិត និងបណ្ឌិតដល់មន្ត្រីរាជការខ្មែរជារៀងរាល់ឆ្នាំ។*

-សម្គាល់ន័យថា រហូតដល់។

ឧ. *ទស្សនាវដ្ដីឥន្ទ្រទេវី លេខ៣១ ថ្ងៃទី២៥ ខែធ្នូ ១៩៩៩-១០ មករា ២០០០។*

-សម្រាប់ភ្ជាប់ពាក្យពីរដែលជាប់ទាក់ទងគ្នាដោយប្រការណាមួយឬដែលត្រូវផ្ទឹមនឹងគ្នា។

ឧ. *ភាសាសំស្ក្រឹត-បាលី, វចនានុក្រមបារាំង-ខ្មែរនិងខ្មែរ-បារាំង។*

-សម្រាប់ផ្ដាច់ពាក្យមួយព្យាង្គដែលកើតពីព្យញ្ជនៈនិងស្រៈកប់គួ (ពាក្យកំព្រា) ចេញពីពាក្យដទៃទៀតដែលនៅក្បែរវា គឺដើម្បីកុំឱ្យច្រឡំអានវាជាព្យញ្ជនៈប្រកប។

ឧ. *ទូក-ង, កុកស-ក។*

-ក្នុងវចនានុក្រម សម្រាប់ក្នុងការពន្យល់ ផ្ដាច់ព្យាង្គពីគ្នាក្នុងពាក្យណាមួយ។

ឧ. *កក្កដ (ក័ក-ក:-ដ:) , ធម្ម (ធ័ម-ម:) ...។*

-ក្នុងវចនានុក្រមសម្រាប់ជំនួសព្យាង្គដែលមិនពិបាកអាន ដើម្បីប្រាប់របៀបអានតែព្យាង្គណាដែលពិបាកអាន។

ឧ. *កង្កែបអាចម៍គោ (-អាច់-)។*

-ក្នុងវេយ្យាករណ៍ សម្រាប់កត់ត្រាមូលបទ (បុព្វបទ អន្តេបទ បច្ឆិមបទ)។

ឧ. *-បុព្វបទ / ប៉- / (ប៉ឹង < ដឹង)*

*-អន្តេបទ / -ន- / (ឃ្នាប < គាប)*

*-បច្ឆិមបទ / -វិទូ / (ភាសាវិទូ < ភាសា) ...។*

**២.២.២. សញ្ញាវង់ក្រចក** ( )

គេប្រើវង់ក្រចកដើម្បីៈ

-ប្រាប់ព័ត៌មានបញ្ជាក់ បន្ថែម អំពីអ្វីដែលគេទើបនិយាយរួច។

ឧ. *ព្រះបាទភវវរ្ម័នទី១ (គ.ស. ៥៥០ - ៦០០)។*

-ប្រាប់ថា «តាមបាន» គឺគេអាចប្រើឬមិនប្រើ។

ឧ. *វិជ្ជាដែលសិក្សាពីវាក្យស័ព្ទហៅថា «វាក្យ (ស័ព្ទ) វិទ្យា» បានសេចក្ដីថា គេអាចទម្លាក់ពាក្យ «ស័ព្ទ» ចោល (= វាក្យវិទ្យា) ឬ ក៏គេទុក (= វាក្យស័ព្ទវិទ្យា)។*

**២.២.៣. សញ្ញាចុចមួយ** ( . )

គេប្រើសញ្ញានេះជាមួយអក្សរកាត់។

ឧ. *ន. (នាម) , គុ. (គុណនាម)។*

**២.២.៤. សញ្ញាចំណុចរាយឬពងក្រពើ** (...)

គេប្រើសញ្ញានេះដូចបេយ្យាលៈដែរ ដើម្បីបង្ហាញថា សេចក្ដីដែលបានរៀបរាប់ខាងដើមមានច្រើនតទៅទៀត ដោយគេមិនរាយទាំងអស់។

*ឧ. ឫស្សីស្រុក ឫស្សីគ្រាច់ ឫស្សីរលៀក ឫស្សីទ្រនំមាន់...។*

**២.២.៥. សញ្ញាខង់ក្រចកចំណុចរាយឬខង់ក្រចកពងត្រី** (...)

សញ្ញានេះមានន័យថា អ្នកនិពន្ធមិនស្រង់យកសម្ដីរបស់អ្នកដទៃមកបង្ហាញទាំងអស់ទេ ដោយហេតុថា វាវែងពេក ហើយគាត់យកតែសេចក្ដីដែលគាត់ចង់បង្ហាញ ដោយយកសញ្ញានេះមកជំនួសសេចក្ដីដែលគាត់មិនស្រង់យក។

*ឧ. លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះសាសនមុនី កិម-ត្រូវ (ចន្ទមង្គលោ) សមាជិកក្រុមជំនុំព្រះត្រៃបិដក (...) ឱ្យទទួលបំពេញមុខងារនេះ។*

**២.២.៦. សញ្ញាក្បៀស** ( , )

គេប្រើក្បៀស ក្នុងករណីដែលមានដំណាក់ឃ្លាច្រើនកន្លែង ដើម្បីចៀសវាងកុំឱ្យច្រឡំត្រង់កន្លែងណាមួយក្នុងការភ្ជាប់ ពាក្យនិងពាក្យឬកន្សោមនិងកន្សោម។

*ឧ. ពាក្យដែលខ្ចីពីភាសាបាលីទាំងនេះមិនប្រើសញ្ញាលេខទោទេះ នានា, អាបោអាបោ, ភិយ្យោ ភិយ្យោ។*

**២.២.៧. សញ្ញាចុចក្បៀស** ( ; )

ប្រើក្នុងស្ថានភាពដែលល្បះទី២, ទី៣, ...ខ្ចីសេចក្ដីពីល្បះទី១។

*ឧ. គោ គុ.កិ., គុ. ដែលកោងទោរ, កោងប្រដោ, ដែលមានអាការៈឱនៗកោងៗ : វាយគោខ្លួន; ដើរគោៗ; ដំណើរគោៗ។*

**២.២.៨. សញ្ញាសួរ** ( ? )

គេប្រើសញ្ញានេះ នៅចុងបញ្ចប់នៃល្បះសំណួរ។

*ឧ. បង! យីបង មកពីកាលណាហ្នឹង?*

**២.២.៩. សញ្ញាឧទាន** ( ! )

សញ្ញានេះប្រើនៅចុងបញ្ចប់នៃល្បះឧទាន និង ជាមួយនឹងពាក្យឧទាន។

*ឧ. ឈប់ពីរខែ ជយោ! , ឱវាលស្រែនេះ!*

**២.២.១០. អព្ភន្តរសញ្ញា** (« »)

គេប្រើសញ្ញានេះដើម្បីៈ

-ដកស្រង់ឬលើកយកសម្ដីរបស់នរណាម្នាក់។

*ឧ. ថ្ងៃនោះឯង នាងបានហៅសំឡាញ់នាងជាល្បែងថា «បងប៉ូលៗ»។*

-បង្ហាញចំណងជើង ឬឈ្មោះសៀវភៅ ឬក៏សារព័ត៌មាន។

*ឧ. នាងនឹកឃើញកាលដែលប៊ុន ធឿន និទានរឿង «ប៉ូលនិងវៀហ្ស៊ីនី» ប្រាប់នាង។*

-សម្គាល់ក្នុងវេយ្យាករណ៍ថា ពាក្យដែលគេដាក់ក្នុងអព្ភន្តរៈជាពាក្យដែលគេចង់ពន្យល់ ហើយ គេអាចប្រើជាប្រធានឬកម្មរងរបស់កិរិយាស័ព្ទបាន ទោះពាក្យនោះមិនមែនជានាមក៏ដោយ។

ឧ. *«លើ» ឬ «ក្រោម» ជានិបាតស័ព្ទ។*

-សម្គាល់ពាក្យថ្មីដែលតាមរយៈសញ្ញានេះ អ្នកប្រើហាក់បីដូចជាសុំសេចក្ដីអនុគ្រោះ។

ឧ. *ដើម្បីសិក្សាពីភាសាជនជាតិភាគតិច អ្នកស្រាវជ្រាវត្រូវការ «អ្នកបម្រាប់» ពីរនាក់។*

**២.២.១១. សញ្ញាឃ្នាប** ( [ ] )

គេប្រើសញ្ញានេះដើម្បីៈ

-ជំនួសវង់ក្រចក កាលណាបើការប្រើវង់ក្រចកនាំឱ្យច្រឡំឬកាលណាវង់ក្រចកត្រូវប្រើជាន់គ្នាពីរដងភ្លាមៗ។

ឧ. *កិរិយាស័ព្ទ «ខ្លាច» ត្រូវការប្រធានដែលមានសញ្ញាតា «+ជីវិតភាព»និងកម្មរងដែលមានសញ្ញាតា«-ជីវិតភាព» ៖ [ (+ជីវិតភាព) __ (+ជីវិតភាព/-ជីវិតភាព) ] ។*

-កត់ត្រាសូរក្នុងភាសាវិទ្យា។

ឧ. *បាតុភូត [pa:tophu:t] ; [ba:laok] ។*

**២.២.១២. សញ្ញា «និង»** ( & )

គេប្រើសញ្ញានេះ ដើម្បីជំនួសសន្ធានស័ព្ទ «និង» កាលណាគេចង់ឱ្យភាគខាងឆ្វេង និងភាគខាងស្ដាំដែលភ្ជាប់សញ្ញានេះលេចធ្លោឡើង។

ឧ. *សទ្ទតា /p/ កត់ត្រាដោយអក្សរ ប៉ & ព, សទ្ទតាវិទ្យា&សូរវិទ្យា។*

**២.២.១៣. សញ្ញាបន្ទាត់ទ្រេត** ( / )

គេប្រើសញ្ញានេះដើម្បីៈ

-ចុះលេខក្នុងច្បាប់ផ្សេងៗ។

ឧ. *ព្រះរាជក្រមលេខ នស រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ។*

-ជំនួសសន្ធានស័ព្ទ «ឬ» ។

ឧ. *លោក/លោកស្រី, លោក/អ្នកគ្រូ។*

**២.២.១៤. សញ្ញាផ្កាយ** ( * )

គេប្រើសញ្ញាផ្កាយដើម្បីបង្ហាញថា ពាក្យ, កន្សោមពាក្យឬឈ្មោះនៅខាងស្តាំសញ្ញាផ្កាយនេះជាពាក្យ, កន្សោមពាក្យឬឈ្មោះមិនត្រឹមត្រូវតាមវេយ្យាករណ៍របស់ភាសាណាមួយ។

ឧ. _យើងអាចនិយាយថា «ឈើចាក់ធ្មេញថ្មី ស្បែកជើងក្រហម...» តែយើងមិនអាចនិយាយថា *ឈើចាក់ថ្មីធ្មេញ *ស្បែកក្រហមជើង បានឡើយ។_

**២.២.១៥. សញ្ញាវ៉ាត់** ( { ) **ឬ** ( } )

គេប្រើសញ្ញានេះដើម្បី៖

-ជៀសមិនសរសេរឡើងវិញចំណែករួមដែលត្រូវភ្ជាប់ទៅចំណែកច្រើនទៀត។

ឧ.

_វិទ្យា ត្រូវអានថា_ { _វិត-ទ្យា_ / _វិត-ត្យា_

-បង្ហាញប្រព័ន្ធសមីការក្នុងគណិតវិទ្យា។

ឧ.

_ប្រព័ន្ធសមីការ_ $\begin{cases} X + Y = 20 \\ 5X + 2Y = 15 \end{cases}$

**២.២.១៦. វ៉ាត់ឃ្នាប** ( { } )

គេប្រើសញ្ញាវ៉ាត់ឃ្នាប ដើម្បីប្រើក្នុងសម្ព័ន្ធវិទ្យា សម្រាប់គាបសញ្ញាណមួយចំនួនដែលគេត្រូវជ្រើសយកសញ្ញាណាមួយ។

ឧ.

_គ្រោង_ { _ប្រកាស_ / _សំណួរ_ / _បញ្ជា_ / _ឧទាន_ } _+ (បដិសេធន៍) + (សំនួន) + (កម្មវាចក:)_

**២.២.១៧. សញ្ញាស្មើ** ( = )

គេប្រើសញ្ញានេះ ដើម្បីសម្គាល់ន័យថា «ស្មើ/មានន័យថា»។

ឧ. _-វប្ប = ការសាបព្រោះ ការបណ្ដុះពូជ ការបង្កបង្កើត_

_-១ + ៦ = ៧ ។_

**២.២.១៨. សញ្ញាទៅជាឬធំជាង** ( > )

គេប្រើសញ្ញានេះដើម្បីៈ

-ក្នុងគណិតវិទ្យាក្នុងន័យថា «ធំជាង» គឺចំនួនឬលទ្ធផលគណនាចំនួននៅខាងឆ្វេង ធំជាងចំនួនឬលទ្ធផលគណនាចំនួនដែលនៅខាងស្តាំសញ្ញានេះ។

ឧ. *៥ + ៦ > ១០។*

-ក្នុងវេយ្យាករណ៍ សម្គាល់ន័យថា ទៅជា គឺក្លាយទៅជាឬប្រែទៅជា។

ឧ. *ដេក + /ប៉-/ > ផ្តេក*

*រុក + /-អ៊ំ/ន-/ > រន្ទុក*

**២.២.១៩. សញ្ញា«មកពីឬតូចជាង»** ( < )

គេប្រើសញ្ញានេះដើម្បីៈ

-ក្នុងគណិតវិទ្យា សម្គាល់ន័យថា ចំនួនឬលទ្ធផលគណនាចំនួននៅខាងឆ្វេង ធំជាងចំនួនឬលទ្ធផលគណនាចំនួន ដែលនៅខាងស្តាំសញ្ញានេះ។

ឧ. *៥ + ៧ < ១៥ ។*

-ក្នុងវេយ្យាករណ៍សម្គាល់ន័យថា «មកពី» គឺពាក្យឬកន្សោមពាក្យឬឃ្លាប្រយោគនៅខាងឆ្វេងសញ្ញានេះបានមកពីពាក្យឬកន្សោមពាក្យឬឃ្លាប្រយោគដែលនៅខាងស្តាំសញ្ញានេះ។

ឧ. *វប្បធម៌ < វប្ប + ធម៌ ។*

**២.២.២០. សញ្ញា «ផ្ទុយពីឬខុសពី»** ( ≠ )

គេប្រើសញ្ញានេះ ដើម្បីសម្គាល់ន័យថា ពាក្យនៅខាងឆ្វេងមានន័យផ្ទុយពីពាក្យនៅខាងស្តាំ។

ឧ. *ទាប ≠ ខ្ពស់, ល្អ ≠ អាក្រក់ ។*

# មេរៀនទី៣
# ពាក្យ

**១. ពាក្យជាអ្វី?**

**ពាក្យ** គឺជាឯកតាតូចបំផុតនៃភាសាដែលប្រកប ដោយសមាសភាពបីសំខាន់ គឺ សំណូរ សំណេរ និងន័យ ហើយមានមុខងារវេយ្យាករណ៍នៅក្នុងសម្ព័ន្ធ (គេន រង្សី, ២០២១)។

**២. សំណូររបស់ពាក្យ**

សំណូរជាសមាសភាពដំបូងនិងដ៏សំខាន់របស់ពាក្យ ធម្មតាជាសំឡេងដែលបន្លឺឡើងដោយមនុស្សតាមរយៈអក្ខរាវិរុទ្ធពាក្យ។ ក្នុងឯកសារវេយ្យាករណ៍ ថ្នាក់ទី៥ បានផ្ដល់ការសិក្សាឱ្យឃើញថា សំណូររបស់ពាក្យផ្ដោតជាសំខាន់ទៅលើសូរសំឡេងអានចេញពីពាក្យ ហើយសូរនេះកើតចេញពីសូរព្យាង្គនៅក្នុងពាក្យ (ក្រសួងអប់រំ, ១៩៨៣)។

តាមឯកសារវេយ្យាករណ៍ខ្មែរសង្ខេប ភាគទី១ សូរសទ្ទខ្មែរ បានឱ្យនិយមន័យថា សូរសព្ទជាសូររបស់ពាក្យដែលបន្លឺឬអានតាមបែបបទផ្សេងៗ មានបីបែបដែលសំខាន់ គឺ សូរព្យាង្គ សូរបន្លឺ សូរអាន។

តទៅនេះ យើងនឹងសិក្សាអំពី **សំណូរព្យាង្គក្នុងពាក្យ សំណូរពាក្យតាមការអាន** និង **សំណូរពាក្យតាមការនិយាយ**។

**២.១. សំណូរព្យាង្គក្នុងពាក្យ**

**សំណូរព្យាង្គក្នុងពាក្យ** គឺជាសូរបន្លឺឡើងរបស់ព្យាង្គកើតឡើងនៅក្នុងពាក្យ។ សំណូរនេះគេអាចអនុវត្តបានទៅលើពាក្យដែលមានចំនួនព្យាង្គចាប់ពីពីរឡើងទៅ។ សំណូរព្យាង្គក្នុងពាក្យចែកជាព្យាង្គបន្ធើរ ព្យាង្គសង្កត់ ព្យាង្គបើក ព្យាង្គបិទ ព្យាង្គអ ព្យាង្គអ៊ (ក្រសួងអប់រំ, ១៩៨៣:៥៩-៦០)។

-**ព្យាង្គបន្ធើរ** ជាព្យាង្គដែលឮតិច មិនពេញលេញ។

-**ព្យាង្គសង្កត់** ជាព្យាង្គដែលឮខ្លាំង ពេញលេញ។

-**ព្យាង្គបើក** ជាព្យាង្គដែលមានសូរស្រៈនៅខាងចុង។

-**ព្យាង្គបិទ** ជាព្យាង្គដែលមានសូរព្យញ្ជនៈនៅខាងចុង។

-**ព្យាង្គ អ** ជាព្យាង្គដែលមានព្យញ្ជនៈពួក អ នៅខាងដើមព្យាង្គ។

-**ព្យាង្គ អ៊** ជាព្យាង្គដែលមានព្យញ្ជនៈពួក អ៊ នៅខាងដើមព្យាង្គ។

### ២.២. សំណួរពាក្យតាមការអាន

**សូរអាន** ជាសូរសព្ទរបស់ពាក្យដែលអានឡើងដោយចេតនាដឹងខ្លួន តាមការចេះដឹងល្អាក់ល្អមឬមែនទែនអំពីភាសា។ សូរអានបែងចែកជាបីប្រភេទ គឺ **សូរអានតាមបាលី-សំស្ក្រឹត សូរអានតាមខ្មែរ សូរអានតាមនិយាម** (កេង វ៉ាន់សាក់, ១៩៦៦)។

### ២.២.១. សូរអានតាមបាលី-សំស្ក្រឹត

**សូរអានតាមបាលី-សំស្ក្រឹត** ជាសំឡេងពាក្យអានតាមសូរសទ្ទបាលី-សំស្ក្រឹត ហើយមានចំពោះពាក្យថ្មីទើបនឹងកើតឡើងឬចំពោះពាក្យក្លាយខ្មែរ ពោលគឺពាក្យដើមបាលី-សំស្ក្រឹត ដែលបានប្រែក្លាយមានរូបរាងន័យសេចក្ដីតាមបែបខ្មែរវិញ។ ការខំអានពាក្យទាំងនេះតាមបែបបាលី-សំស្ក្រឹត បានបង្កើតសូរអានបែបបាលី-សំស្ក្រឹតក្នុងសូរសព្ទខ្មែរសព្វថ្ងៃ។ ឧទាហរណ៍ដូចជាសូរអានដែលខំបន្លឺស្រៈខ្លី *អៈ ឥ ឧ* ឱ្យឮឡើងវិញនៅក្នុងព្យាង្គក្រោយរបស់ពាក្យទោលឬក្នុងព្យាង្គតកណ្ដាលរបស់ពាក្យផ្សំ។ ពាក្យទោល *អនាគត* អានឱ្យឮ *អនាគៈតៈ* ដោយបន្លឺស្រៈ *អៈ* ឱ្យរស់ឡើងវិញ។ ពាក្យផ្សំ *មូលឋាន* អានឱ្យឮ *មូលាត់ឋាន* ដូចនេះត្រូវសរសេរតាមបែបបាលី *មូលដ្ឋាន* យ៉ាងណាមិញ ដរាបណាស្រៈ *អៈ* ក្នុង *ល* រស់វិញហើយ ដរាបនោះត្រូវតព្យាង្គតាមសន្ធិបែបបាលីដោយចុះ តួ *ដ* ១ទៀតធ្វើជាខ្យល់ប្រកបនឹង *លៈ* ហើយសរសេរតំរួតលើ *ឋ* ដែលប្រែទៅជាជើង ្ឋ ដើម្បីឱ្យបានត្រឹមត្រូវទៅតាមក្បួនវិធីបាលីនោះឯង។ សូរអានតាមបាលី-សំស្ក្រឹតជាសូរសព្ទផ្ទុយទៅនឹងលក្ខណៈជាតិខ្មែរ។

### ២.២.២. សូរអានតាមខ្មែរ

**សូរអានតាមខ្មែរ** ជាសូរសព្ទដែលបន្លឺសំឡេងពាក្យឱ្យឮសូរបែបខ្មែរតាមការនិយាយខ្មែរធម្មតា។ សូរអានតាមខ្មែរមានចោទបញ្ហាចំពោះសូរសព្ទរបស់ពាក្យថ្មីឬចំពោះពាក្យក្លាយខ្មែរមកអំពីបាលី-សំស្ក្រឹត។ ចំពោះពាក្យទាំងនេះសូរអានតាមខ្មែរមានក្បួនវិធីផ្ទុយគ្នាទៅនឹងសូរអានតាមបាលី-សំស្ក្រឹត គឺជាក្បួនវិធីនៃសូរសព្ទខ្មែរនេះឯង។ មានច្រើនណាស់ យើងគ្រាន់តែលើកឧទាហរណ៍ខ្លះមកបញ្ជាក់សេចក្ដីៈ

សូរអានតាមខ្មែរមានក្បួនវិធីទូទៅមួយដែលទម្លាក់ចោលឬកែប្រែព្យាង្គបើកខ្លីបាលី-សំស្ក្រឹត។ ព្យាង្គបើកខ្លីជាព្យាង្គមានស្រៈខ្លី *អៈ ឥ ឧ* ជាខ្យល់ចុងក្រោយបង្អស់ ឧ. *អនាគៈតៈ មុនិ គរុ*។ ព្យាង្គបើកផ្ទុយទៅនឹងព្យាង្គបិទ ពីព្រោះព្យាង្គបិទមានតួព្យញ្ជនៈជាខ្យល់ប្រកបនៅបិទពីក្រោយ ឧ. *គត់ គំនិត រុករាន*។ សូរអានតាមខ្មែរតែងតែកែប្រែព្យាង្គ

បើកខ្លីបាលី-សំស្ក្រឹតឱ្យប្រែក្លាយជាសូរសព្ទបែបខ្មែរវិញ ពីព្រោះសូរសទ្ទខ្មែរពុំមានព្យាង្គបើកខ្លីនេះទេ។

**-ទម្លាក់ព្យាង្គបើកខ្លីចោលតែម្តង៖** *kamma កម្ម, Siddhi សិទ្ធិ, Vastu វត្ថុ...*។

**-កែព្យាង្គបើកខ្លីឱ្យបើកវែង៖** *sāsna សាសនា, Vicārana ពិចារណា, Muni មុនី, Kavi កវី, Garu គ្រូ, Paramānu បរមាណូ...*។

**-កែព្យាង្គបើកខ្លីឱ្យទៅជាបិទ៖** *kala កល, Anāgata អនាគត, Bhūmi ភូមិ...*។

## ២.២.៣. សូរអានតាមនិយាម

**សូរអានតាមនិយាម** គឺជាសូរសព្ទបន្លឺពាក្យឱ្យមានសំឡេងតាមនិយាមដែលជាក្បួនច្បាប់តម្រូវឱ្យធ្វើតាមដោយទទួលថាជាច្បាប់ត្រឹមត្រូវ ហើយចម្រើនលឿនលឿន។ វេយ្យាករណ៍និយាមបានបង្កើតក្បួនវិធីសម្រាប់តម្រូវឱ្យមានពាក្យតាមរបៀបបែបបទណាមួយ ជាហេតុបង្កើតនូវសូរអានបែបទី៣ នេះ គឺសូរអានតាមនិយាម ដែលជាសូរសព្ទមួយដ៏ចាំបាច់។ យ៉ាងណាមិញ សូរបន្លឺផ្លាស់ប្តូរសូរសព្ទទៅតាមទីកន្លែងនិងទីឋាន។ សូរអានផ្លាស់ប្តូរសូរសព្ទទៅតាមបាលី-សំស្ក្រឹតឬទៅតាមខ្មែរ។

ដូចនេះសូរអានតាមនិយាមជាការចាំបាច់ដែលអាចធ្វើឱ្យសូរសព្ទមានឯកភាពរបៀបរៀបរយនិងសមហេតុផល។ ជាការចាំបាច់ម្យ៉ាងទៀត ពីព្រោះសូរអានតាមនិយាមមានមុខងារសម្រាប់សម្គាល់ន័យសេចក្តីឱ្យបានច្រើនសម្បូរថែមទៀត ឧទាហរណ៍៖

-*សិល្បៈ* សូរអានតាមបាលី-សំស្ក្រឹត

-*សិល្ប៍* សូរអានតាមខ្មែរ

-*សិល្បៈ* Art សិល្ប៍ Esthétique សូរអានតាមនិយាម និយាមប្រាប់ថាអាន *សិល្បៈ* ក៏បាន *សិល្ប៍* ក៏បាន ពីព្រោះជាពាក្យពីរមានន័យផ្សេងពីគ្នា។

-ដូចគ្នាដែរចំពោះពាក្យ *ទស្សនៈ ទស្សន៍, សាសនៈ សាសន៍...*។

## ២.៣. សំណូរពាក្យតាមការនិយាយ

**សូរបន្លឺ** (សំណូរពាក្យតាមការនិយាយ) ជាសំឡេងសព្ទបន្លឺក្នុងទម្រង់ឃ្លាប្រយោគតាមបែបបទផ្សេងៗរបស់អ្នកនិយាយភាសា។ សូរបន្លឺគឺជាសំឡេងរបស់សព្ទទាំងមូលដែលជាលទ្ធផលរួមនៃព្យាង្គ ហើយដែលផ្លាស់ប្តូរស្នូរទៅតាមចំណងភ្ជាប់នឹងសព្ទឯទៀតក្នុងឃ្លាប្រយោគ។ មិនតែប៉ុណ្ណោះសោត សូរបន្លឺអាស្រ័យទៅលើទម្លាប់និយាយរបស់អ្នកប្រើភាសាថែមទៀត។ សូរបន្លឺអាចមានបែបបទជា **សូរតាមទីសម្ព័ន្ធ បន្លឺតាមទីកន្លែង បន្លឺតាមទីឋាន**។

### ២.៣.១. បន្លឺតាមទីសម្ព័ន្ធ

**បន្លឺតាមទីសម្ព័ន្ធ** ជាចំណងសព្ទទាក់ទងគ្នាក្នុងឃ្លាប្រយោគ។ សម្ព័ន្ធជាទីមួយដែលនាំឱ្យសព្ទនីមួយៗមានសំឡេងទាក់ទងទៅនឹងសព្ទឯទៀត។ ពាក្យមួយៗដាច់ពីគ្នាមានសំឡេងពិសេសរបស់ខ្លួន។ ប៉ុន្តែដរាបណាចងក្រង ហើយបិតជាប់ជាមួយនឹងគេឯទៀត ដរាបនោះអាចប្តូរសំឡេងប្រែទៅជាបន្លឺឱ្យមានសូរសព្ទ១បែបទៀតជាហេតុនាំឱ្យមានសូរបន្លឺសព្ទក្នុងសម្ព័ន្ធ។ ឧ. *ទឹកលិច ទិសខាងលិច, វែកនំ ដងវែក*...។

### ២.៣.២. បន្លឺតាមទីកន្លែង

**បន្លឺតាមទីកន្លែង** ជាសូរបន្លឺតាមស្រុក ភូមិ ក្រុង ធានី។ កន្លែង ស្រុក ភូមិ ស្រែចម្ការ ទីក្រុង រាជធានី ជាទី១ទៀតដែលនាំឱ្យសព្ទមានសំឡេងផ្លាស់ប្តូរប្លែកគ្នាទៅតាមទម្លាប់និយាយរៀងៗខ្លួន។ អ្នកស្រុកបាត់ដំបង សៀមរាប តាកែវ កំពត -ល- និងអ្នកធានីភ្នំពេញនិយាយបន្លឺពុំដូចគ្នាទេ ប៉ុន្តែសុទ្ធតែមានសូរបន្លឺពិសេសរបស់ខ្លួន គេថាសូរបន្លឺអ្នកលើច្រើនរដឺន សូរបន្លឺអ្នកភ្នំពេញច្រើនទំយើ សូរសម្តីអ្នកសៀមរាបច្រើនទន់រមើយ។ ក្រៅពីលក្ខណៈទូទៅបែបនេះ សូរបន្លឺនាំឱ្យមានដំណើរពិសេសចំពោះស្រៈ ព្យញ្ជនៈ ព្យាង្គពាក្យ និងប្រយោគតាមបែបបទនិងទម្លាប់អ្នកស្រុកថែមទៀត។ ឧទាហរណ៍អ្នកស្រុកកំពតខ្លះថា *ស្រ* ពុំកើតទេ ប៉ុន្តែថា *ច្រ* ទៅវិញ *ស្រូវ ច្រូវ ស្រែ ច្រៃ ដើមស្រល់ ដើមច្រល់*។

### ២.៣.៣. បន្លឺតាមទីឋាន

**បន្លឺតាមទីឋាន** ជាសូរបន្លឺតាមឋានៈវណ្ណៈមជ្ឈដ្ឋាន។ ឋានៈ មជ្ឈដ្ឋាន មនុស្សអ្នកចេះ ឬល្ងង់ អ្នកមានឬក្រ អ្នកធំឬតូច អ្នកមុខរបរ កម្មករ កម្មករលីសែង កម្មកររោងចក្រថឹថុង លោកអ្នកផ្សារផ្សោរ ខ្មែរសុទ្ធឬកូនកាត់ ចៅចិន -ល- ទាំងនេះជាទីសំខាន់១ទៀតដែលនាំឱ្យសូរសព្ទខ្មែរបែកខ្ញែកប្លែកគ្នាច្រើនបែបច្រើនយ៉ាងណាស់។

សូរបន្លឺតាមទីទាំងបី គឺទីសម្ព័ន្ធ ទីកន្លែង និងទីឋានៈ ជាសូរសព្ទសំខាន់របស់ពាក្យដែលចងក្រងគ្នាជាឃ្លាប្រយោគក្នុងភាសានិយាយមែនទែនរបស់អ្នកស្រុកទូទៅ។ ប៉ុន្តែចំពោះអ្នកចេះដឹង ចេះអាន ចេះសរសេរនេះទៀត សូរសព្ទអាចបែកប្លែកគ្នាដូចនេះដែរ (កេង វ៉ាន់សាក់, ១៩៦៦:១២-១៣)។

## ៣. រូបរាងរបស់ពាក្យ

### ៣.១. និយមន័យ

បច្ចេកសព្ទដែលអ្នកស្រាវជ្រាវធ្លាប់បានប្រើដើម្បីសម្គាល់រូបរាងរបស់ពាក្យមាន **រូបពាក្យ អក្សរាវិរុទ្ធ អក្ខរាវិរុទ្ធ** និង **សំណេរ**។ ក្នុងចំណោមនេះបច្ចេកសព្ទ **សំណេរ** និង **អក្ខរាវិរុទ្ធ** បាននិងកំពុងប្រើប្រាស់រហូតដល់សព្វថ្ងៃ។

**សំណេរ** គឺជារូបពាក្យដែលកើតឡើងពីលទ្ធភាពសរសេរពាក្យ រួមមានសំណេរតាមបែបរាយព្យាង្គ តំរួតព្យាង្គ ឫសគល់ពាក្យ បម្រែបម្រួលសូរ ទំនាញសូរ...។ មានន័យថាពាក្យមួយ (សំណួរ) អាចសរសេរបានច្រើនយ៉ាង ដូចជា *បម្រើ បំរើ, ចម្លើយ ចំលើយ ចំឡើយ, ចន្ទ ច័ន្ទ, ហ្វឡង់ ហ្វឡង់ដ៍*...។

**អក្ខរាវិរុទ្ធ** គឺជាកន្សោមអក្ខរក្រមដែលកើតឡើងតាមស្តង់ដារនីយកម្មដោយអនុលោមទៅតាមប្រភេទអក្ខរក្រមនិងក្បួនដើម្បីបង្ហាញពីទំនាក់ទំនងរវាងសំណួរនិងរូបរាងនៃពាក្យ បង្កើតបានជាប្រព័ន្ធសំណេរមួយច្បាស់លាស់នៅក្នុងភាសា។ ឧ. រវាង *ឱ្យ អោយ ឱយ ឲ្យ* គឺ *ឱ្យ* ជាអក្ខរាវិរុទ្ធ។

### ៣.២. មូលដ្ឋានក្នុងការសម្រេចអក្ខរាវិរុទ្ធខ្មែរ

បើផ្អែកលើការសិក្សាកន្លងមកដែលប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ មូលដ្ឋានក្នុងការសម្រេចអក្ខរាវិរុទ្ធខ្មែរមានដូចជា **ឫសគល់ពាក្យ បម្រែបម្រួលសូរ ទំនាញសូរ សម្ព័ន្ធរូបសព្ទ** និង **សម្ព័ន្ធសញ្ញាព្យាង្គ**។

#### ៣.២.១. ឫសគល់ពាក្យ

**ឫសគល់ពាក្យ** គឺជាប្រភពដំបូងរបស់ពាក្យដែលកើតចេញពីភាសាណាមួយ។ ឫសគល់ពាក្យបានក្លាយជាមូលដ្ឋានមួយក្នុងការសម្រេចអក្ខរាវិរុទ្ធខ្មែរ។ មូលដ្ឋានមួយនេះបានធ្វើឱ្យអក្ខរាវិរុទ្ធខ្មែរមានវត្តមាន **អក្សរស្ងាត់ បែបរាយព្យាង្គ បែបតំរួតព្យាង្គ ស្រៈពេញតួ វណ្ណយុត្តិ** (៉ ៊ ់ ៈ ៌) **ព្យញ្ជនៈប្រកបបាលី-សំស្ក្រឹត** (ព្យញ្ជនៈប្រកបចុងព្យាង្គនៃពាក្យកម្ចីបាលី-សំស្ក្រឹត) និង **អវត្តមានសញ្ញាបន្តក់**។

-វត្តមានអក្សរស្ងាត់៖ *ប្រវត្តិសាស្ត្រ, ភស្តុតាង, ហេតុ* ...។

-បែបរាយព្យាង្គ៖ *ដំណើរ, កំណើត, ជំនួន*...។

-បែបតំរួតព្យាង្គ៖ *ចម្លើយ, បម្រើ, បម្រាប់, សម្រេច*...។

-ស្រៈពេញតួ៖ *ឯកជន, ឧបបទ, ឫទ្ធី, ឱកាស*...។

-វណ្ណយុត្តិ៖ *និវន្តរ៍, ជាតក៍, គភ៌, ភ័យ*...។

-ព្យញ្ជនៈប្រកបបាលី-សំស្ក្រឹត៖ *សុខ, សមាជ, មេឃ, គ្រុឌ*...។

-អវត្តមានសញ្ញាបន្តក់៖ *ជន, ជល, កល, ធន*...។

#### ៣.២.២. បម្រែបម្រួលសូរ

តាមទិដ្ឋភាពភាសាវិទ្យាប្រតិកាល គ្រប់ផ្នែកនៃភាសាត្រូវបានទុកជាកម្មវត្ថុប្រែប្រួល។ ក្នុងនោះសូរជាកម្មវត្ថុចម្បងនៃភាសាវិទ្យាប្រតិកាល (Fredinan de Saussure,

1959)។ បម្រែបម្រួលសូរឆ្លងសម័យកាល ក៏ជាកត្តាមួយនៃការកំណត់អក្ខរាវិរុទ្ធពាក្យផង ដែរ។ ផ្ទុយទៅវិញបើគេយកចិត្តទុកដាក់ទៅលើភាសាសរសេរជាងភាសានិយាយ ប្រហែលជាគេពិបាកនឹងរកមើលការប្រែប្រួលនោះណាស់ ព្រោះភាសាសរសេរគេអភិរក្ស ទុកដើម្បីរក្សាអត្តសញ្ញាណរបស់ខ្លួន។ យ៉ាងណាក៏ដោយក៏លេចឡើងនូវអក្ខរាវិរុទ្ធដែលកើត ពីបម្រែបម្រួលសូរនៃភាសាធម្មជាតិ។

កត្តាបម្រែបម្រួលសូរបានក្លាយទៅជាមូលដ្ឋានមួយក្នុងការសម្រេចអក្ខរា-វិរុទ្ធខ្មែរ ទាំងពាក្យខ្មែរសុទ្ធទាំងពាក្យកម្ចី។ បម្រែបម្រួលសូរមានពីរបែប គឺ **បម្រែបម្រួលសូរសទ្ទ** និង **បម្រែបម្រួលសូរព្យាង្គ** ដែលកើតឡើងស្របតាមទិដ្ឋភាពបី គឺកាលយោបាយ ទេសយោបាយ និងវណ្ណយោបាយ។

**ក. បម្រែបម្រួលសូរសទ្ទ**

**បម្រែបម្រួលសូរសទ្ទ** គឺជាការវិវត្តសូរស្រៈឬព្យញ្ជនៈដោយឆ្លងកាត់ពេលវេលា។ ការវិវត្តនេះបានធ្វើឱ្យអក្ខរាវិរុទ្ធកើតមាន **បម្រែបម្រួលសញ្ញាស្រៈ** ឬ **បម្រែបម្រួលសញ្ញាព្យញ្ជនៈ** នៅក្នុងពាក្យ។

ឧ. *មួយ > ម៉ា, កីឡដ្ឋាន > កីឡាដ្ឋាន, បុរាណ > បូរាណ, កុលាប > កូលាប, សកល > សាកល, សុរិយា > សូរិយា*...។

**ខ. បម្រែបម្រួលសូរព្យាង្គ**

**បម្រែបម្រួលសូរព្យាង្គ** គឺជាការវិវត្តសូរបន្លឺមួយបន្សាយសំឡេងនៅក្នុងពាក្យដែលមានចំនួនព្យាង្គចាប់ពីពីរឡើងទៅ។ ការវិវត្តសូរនេះកើតមានឡើងទាំងក្នុងពាក្យខ្មែរទាំងក្នុងពាក្យកម្ចី ដែលអាចធ្វើឱ្យអក្ខរាវិរុទ្ធកើតមាន **បម្រែបម្រួលសញ្ញាព្យញ្ជនៈ បម្រែបម្រួលសញ្ញាស្រៈ** និង **បម្រែបម្រួលសញ្ញាព្យាង្គ**។

ឧ. *កលិង្គ > ក្លិង្គ, រពៅ > ល្ពៅ, ជាតក > ជាតក៍, យុថិកា > យុថ្កា* ...។

**៣.២.៣. ទំនាញសូរ**

**ទំនាញសូរ** គឺជាឥទ្ធិពលនៃព្យញ្ជនៈឬព្យាង្គទី១ ពួក *អ* ឬ *អ៊* ទៅលើព្យញ្ជនៈឬព្យាង្គទី២ ពួក *អ៊* ឬ *អ* ដើម្បីបានពួក *អ* ឬ *អ៊* ដូចគ្នា (ក្រសួងអប់រំ, ១៩៨៦:៦៦)។ ច្បាប់ទំនាញសូរអាចអនុវត្តបានទៅលើពាក្យមួយដែលមានពីរឬច្រើនព្យាង្គ ហើយវាពុំអាចប្រើបានទៅលើពាក្យផ្សេងគ្នានោះឡើយ (ច័ន្ទ សំណព្វ, ២០១២:៧១)។ ទំនាញសូរមានពីរយ៉ាង គឺ **ទំនាញសូរក្នុងពាក្យមួយព្យាង្គ** និង **ទំនាញសូរក្នុងពាក្យពីរព្យាង្គឬច្រើនព្យាង្គ** (ក្រសួងអប់រំ, ១៩៨៦:៦៦)។

នៅទីនេះ សូមលើកយកតែករណីទំនាញសូរក្នុងពាក្យពីរព្យាង្គឬច្រើនព្យាង្គមកបង្ហាញជូនតែប៉ុណ្ណោះ ព្រោះទំនាញសូរក្នុងករណីនេះនាំឱ្យមានកំហុសអក្ខរាវិរុទ្ធក្នុងភាសាខ្មែរ។

ក្នុងពាក្យពីរព្យាង្គ ទំនាញសូរឋិតនៅលើទំនាញរវាងសូរនៃសញ្ញាព្យាង្គទី១ និងទី២ ក្នុងពាក្យ (១៩៦៦:៧២)។ ទំនាញសូរក្នុងពាក្យពីរព្យាង្គប្រព្រឹត្តទៅតាមក្បួន៤យ៉ាងដូចខាងក្រោម៖

-ក្បួនទី១៖ កាលណាព្យាង្គ *អ* ខាងដើមកើតមកអំពីតួព្យញ្ជនៈ ខ្យល់ស្ទះពួក *អ* ព្យាង្គ *អ៊* ខាងចុងដែលកើតមកអំពីតួព្យញ្ជនៈខ្យល់បង្ហូរពួក *អ៊* ត្រូវដូរជាព្យាង្គ *អ* វិញ។

ឧ. *កង្វល់ កន្លង់ កម្រង ក្រយៅ ចង្រៃ ចង្វាក់ តាវៅ បន្លា*...។

-ក្បួនទី២៖ កាលណាព្យាង្គ *អ* ខាងដើមកើតមកអំពីតួព្យញ្ជនៈខ្យល់ស្ទះពួក *អ* ព្យាង្គ *អ៊* ខាងចុងដែលកើតមកអំពីតួព្យញ្ជនៈខ្យល់ច្រមុះពួក *អ៊* ត្រូវដូរជាព្យាង្គ *អ* វិញ។

ឧ. *កំញើញ ក្រមម ច្រងាង ច្រមុះ ត្រងិល ត្រមែង*...។

-ក្បួនទី៣៖ កាលណាព្យាង្គ *អ* ខាងដើមកើតមកអំពីតួព្យញ្ជនៈខ្យល់បង្ហូរត្រដុស *ស* ព្យាង្គ *អ៊* ខាងចុងដែលកើតមកពីតួព្យញ្ជនៈខ្យល់បង្ហូរ *អ៊* ឬច្រមុះពួក *អ៊* ត្រូវដូរជាព្យាង្គ *អ* វិញ។

ឧ. *សំងាត់ សំញេញ សំនាក់ ស្រមោល ស្រយុត សំរេច ស្រវា*...។

-ក្បួនទី៤៖ កាលណាព្យាង្គ *អ៊* ខាងដើមកើតមកអំពីតួព្យញ្ជនៈខ្យល់ស្ទះពួក *អ៊* ព្យាង្គ *អ* ខាងចុងដែលកើតមកអំពីតួព្យញ្ជនៈខ្យល់បង្ហូរ *ហ* ត្រូវដូរជាព្យាង្គ *អ៊* វិញ។

ឧ. *គំហាក គ្រហឹម ជំហរ ជំហាន ទំហឹង ទ្រហោ ព្រហាម ព្រហើន*...។

**កំណត់សម្គាល់៖** ទំនាញសូរពុំមានក្នុងពាក្យពីរព្យាង្គជា៖

-នាមសាធារណ៍៖ *សារ៉ូ ប៉ៃលិន ប៊ុលការី អាមេរិច សារ៉ា*...។

-ពាក្យកម្ចីក្រៅពីបាលី-សំស្ក្រឹត៖ *ការី មេកានិច*...។

ដូចនេះ មូលដ្ឋានទំនាញសូរបានធ្វើឱ្យអក្ខរាវិរុទ្ធខ្មែរអវត្តមាន **សញ្ញាធ្មេញកណ្ដុរ** (៊) និង **សញ្ញាត្រីសព្ទ** (៊) ទោះបីមានការផ្លាស់ប្ដូរសូរព្យាង្គពីព្យាង្គ *អ* ទៅព្យាង្គ *អ៊* ឬពីព្យាង្គ *អ៊* ទៅព្យាង្គ *អ* ក៏ដោយ។

### ៣.២.៤. សម្ព័ន្ធរូបសព្ទ

**សម្ព័ន្ធរូបសព្ទ** គឺជាចំណងភ្ជាប់រវាងរូបសព្ទនិងរូបសព្ទស្របទៅតាមក្បួនមួយដើម្បីបង្កើតបានជាពាក្យថ្មី។ សម្ព័ន្ធរូបសព្ទបានធ្វើឱ្យអក្ខរាវិរុទ្ធខ្មែរមានលក្ខណៈតំរូតព្យាង្គ

និងរាយព្យាង្គដោយមានតំណព្យាង្គជាស្រៈឬព្យញ្ជនៈ។

-អក្ខរាវិរុទ្ធបែបតំរួតព្យាង្គ៖ ឧ. *ដើម + បី > ដើម្បី, គាប់ + បី > គប្បី, ប៉ុន + នោះ > ប៉ុណ្ណោះ, ប៉ុន + មាន > ប៉ុន្មាន, ប៉ុន + តែ > ប៉ុន្តែ, សង + ខាង > សង្ខាង, ជូន + [ជញ់-] > ជញ្ជូន, ស្រស់ + [-អម់-] > សម្រស់*...។

-អក្ខរាវិរុទ្ធបែបរាយព្យាង្គ៖ ឧ. *រូប + អារម្មណ៍ > រូបារម្មណ៍, ប្រធាន + អធិបតី > ប្រធានាធិបតី, សេនា + អធិការ > សេនាធិការ, សុខ + ឧទ័យ > សុខោទ័យ, ឧទ្យាន + អនុរក្ស > ឧទ្យានុរក្ស, មនោ + អារម្មណ៍ > មនោរម្មណ៍, ពេញ + [បម់-] > បំពេញ, សឹក + [-អម់/ណា-] > សំណឹក* ...។

### ៣.២.៥. សម្ព័ន្ធសញ្ញាព្យាង្គ

ដើម្បីកុំឱ្យច្រឡំនឹងចំណុចសម្ព័ន្ធរូបសព្ទខាងលើ នៅត្រង់ចំណុចនេះ **សម្ព័ន្ធ-សញ្ញាព្យាង្គ** ដែលជាតំណព្យាង្គក្នុងពាក្យពហុព្យាង្គ ពិសេសពាក្យពីរព្យាង្គ អនុវត្តតែទៅលើពាក្យពហុព្យាង្គដែលព្យាង្គនីមួយៗពុំមែនជារូបសព្ទតែប៉ុណ្ណោះ។ តំណព្យាង្គនៅក្នុងពាក្យពហុព្យាង្គ ពិសេសពាក្យពីរព្យាង្គ បានធ្វើឱ្យអក្ខរាវិរុទ្ធត្រូវបានសម្រេចជាពីរបែប គឺ **បែបរាយព្យាង្គ** និង **បែបតំរួតព្យាង្គ**។

ឧ. ពាក្យ *កំបោរ សំខាន់ ចំបើង សៀវភៅ កំសៀវ*... ត្រូវបានសម្រេចអក្ខរាវិរុទ្ធបែបរាយព្យាង្គ។ ចំណែកពាក្យ *ចង្កៀង សង្គ្រាម ដណ្ដើម សន្ដាន បង្អួច បញ្ជា*... ត្រូវបានសម្រេចអក្ខរាវិរុទ្ធបែបតំរួតព្យាង្គ។

## ៣.៣. លក្ខណៈសម្គាល់អក្ខរាវិរុទ្ធខ្មែរ

អក្ខរាវិរុទ្ធពាក្យខ្មែរសុទ្ធនិងអក្ខរាវិរុទ្ធពាក្យកម្ចីមានលក្ខណៈខុសគ្នាមួយចំនួនគួរឱ្យកត់សម្គាល់។

### ៣.៣.១. លក្ខណៈសម្គាល់អក្ខរាវិរុទ្ធពាក្យខ្មែរសុទ្ធ

ថ្វីបើមិនអាចសម្គាល់បានគ្រប់ជ្រុងជ្រោយ  ក៏យើងអាចដឹងបានថាអក្ខរាវិរុទ្ធពាក្យខ្មែរសុទ្ធប្រកបដោយលក្ខណៈដូចខាងក្រោម៖

-ព្យញ្ជនៈប្រកបខ្មែរ (ព្យញ្ជនៈប្រកបចុងព្យាង្គនៃពាក្យខ្មែរសុទ្ធ) មានដូចជា *ក ង ច ញ ត ន ប ម យ រ ល ស ះ ដេក លេង សើច ទាញ កើត*...។

-ពុំមានវណ្ណយុត្តិ ៊ ៉ ៈ៖ *កកាយ ញ័រ លាក់* ...។

-មានសញ្ញាបន្តក់ (់) ៖ *ដាក់ រាក់ សាច់ កត់*...។

-មានវត្តមានអក្សរស្ងាត់ *រ* ៖ *ដើរ ហើរ ចរចា ទារ*...។

-តំរួតព្យាង្គក្នុងករណីព្យាង្គទី១ បញ្ចប់ដោយព្យញ្ជនៈច្រមុះ *ម ង ន ណ ញ*៖ *សម្រាប់ បង្អើប បន្ត ដណ្ដើម ជញ្ជូន*...។

-មានសញ្ញាព្យញ្ជនៈឬសញ្ញាស្រៈដូចគ្នា ក្នុងករណីពាក្យមានពីរព្យាង្គឬបួនព្យាង្គ៖ *ដេញដោល កែប្រែ ប្រដំប្រសង ប្រកាច់ប្រកិន ប្រហាក់ប្រហែល ត្រឈឹងត្រឈៃ ព្រលឹងព្រលះ*...។

## ៣.៣.២. លក្ខណៈសម្គាល់អក្ខរាវិរុទ្ធពាក្យកម្ចីបាលី-សំស្ក្រឹត

ពាក្យកម្ចីបាលី-សំស្ក្រឹត គឺជាពាក្យដែលមានប្រភពចេញពីភាសាបាលី-សំស្ក្រឹត ហើយដែលខ្មែរបានទទួលយកមកប្រើដើម្បីបំពេញបន្ថែមនៅក្នុងភាសារបស់ខ្លួន។ ឆ្លងកាត់ការប្រើប្រាស់រយៈពេលច្រើនរយឆ្នាំ ពាក្យកម្ចីទាំងនោះទទួលរងនូវខ្មែរនីយកម្មលើផ្នែកសំណូរ សំណេរ និងន័យ។ ពេលខ្លះ យើងពិបាកសម្គាល់ពាក្យកម្ចីទាំងនោះផង ដូចលោក ឃិន សុខ (២០០៧) បានលើកឡើងថា "កាលណាគេវែកញែកប្រាប់អំពីប្រភពពាក្យទាំងអស់នោះ ប្រជាជនខ្មែរហាក់ដូចជាស្ទាក់ស្ទើរមិនចង់ជឿថា ជាពាក្យខ្ចីមកពីបាលីឬសំស្ក្រឹត ដូចជា*ប្រុស ស្រី គោ ពេល ទ្វារ ស្គរ*..." (ទំ.១២៧)។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែអាចធ្វើការកត់សម្គាល់នូវអក្ខរា-វិរុទ្ធពាក្យកម្ចីបាលី-សំស្ក្រឹតបានមួយចំនួនធំដែរ ដោយសារកត្តានិរុត្តិសាស្ត្រ។ លក្ខណៈសម្គាល់ទាំងនោះមានដូចជា៖

-ព្យញ្ជនៈប្រកបជាព្យញ្ជនៈប្រកបបាលី-សំស្ក្រឹត (ព្យញ្ជនៈប្រកបចុងព្យាង្គនៃពាក្យកម្ចីបាលី-សំស្ក្រឹត) មានដូចជាសញ្ញាទោល *ខ គ឴ ឃ ជ ឌ ថ ទ ធ ដ ព ភ ណ* និងសញ្ញាផ្សំ *ក្ក ក្ខ ក្យ ក្រ ង្ឃ ញ្ញ ត្ត ទ្ធ ដ្ឋ ច្ច ជ្រ ត៌ ដិ តុ មិ* ជាដើម៖ *មុខ មិគសិរ មេឃ សមាជ គ្រុឌ ចក្កយក្ខ ចក្រ សង្ឃ អារញ្ញ ខេត្ត*...។

-ផ្ដើមដោយស្រៈពេញតួ *ឧ ឱ អ អា ឫ ឥ ឮ*...៖ *ឱកាស អាណានិគម ឫទ្ធី*...។

-មានវណ្ណយុត្តិ ៑ ៍ ៈ ័៖ *ទុគ៌ត ន័យ និវន្ត៍ ទេសចរណ៍ កាលៈទេសៈ*...។

-មិនប្រើសញ្ញាបន្តក់ដើម្បីកត់ត្រាសូរខ្លី៖ *ជន ផល កុសល កុហក កល*...។

-មិនប្រើលេខទោ (ៗ) ដើម្បីកត់ត្រាសូរផ្ទួន៖ *នានា អាបោអាបោ*។

## ៤. ន័យរបស់ពាក្យ

**ន័យរបស់ពាក្យ** គឺជាបុគ្គលិកលក្ខណៈកណ្ដាលនៃពាក្យ។ ន័យរបស់ពាក្យទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងមុខងារសំខាន់នៃភាសា (ទំនាក់ទំនង បញ្ជាក់ មនោ-សញ្ចេតនា) (Gayane Girunyan, ២០០៩)។

ទាក់ទិននឹងន័យរបស់ពាក្យ តាមរយៈឯកសារ Semantics បានពន្យល់ថាចំណុចសំខាន់មួយដែលត្រូវបានបង្កើតឡើងដោយភាសាវិទូ Ferdinand de Saussure (1974) ដែលគំនិតរបស់គាត់មានឥទ្ធិពលខ្លាំងណាស់ទៅលើការអភិវឌ្ឍភាសាវិទ្យាទំនើប គឺថាន័យនៃសំនួនភាសាទាញចេញពីប្រភពពីរ វាជាផ្នែកនៃភាសា ហើយវាពណ៌នាអំពីពិភពលោក។ ពាក្យឈរក្នុងទំនាក់ទំនងជាមួយពិភពលោកឬចំណាត់ថ្នាក់គំនិតរបស់យើងចំពោះពិភពលោក។ ពួកវាអនុញ្ញាតឱ្យយើងបញ្ជាក់អត្តសញ្ញាណនៃពិភពលោក ហើយបង្កើតឈ្មោះអំពីវា។ យ៉ាងណាក៏ដោយ ពាក្យត្រូវបានទាញចេញពីតម្លៃនៃទីតាំងរបស់វានៅក្នុងប្រព័ន្ធភាសា។ ទំនាក់ទំនងតាមរយៈភាសាពាក់ព័ន្ធនឹងពិភពលោក ជាធម្មតាគេហៅថាយោង។ តំណភ្ជាប់ន័យរវាងធាតុផ្សេងៗជាមួយនឹងប្រព័ន្ធវាក្យសព្ទ គឺជាទិដ្ឋភាពនៃគំនិតរបស់ពួកគេឬជាន័យ (John I. Saeed, 2004)។

តាមឯកសារវចនវិទ្យានិងវេយ្យាករណ៍វិទ្យា **ន័យរបស់ពាក្យ** គឺប្រាកដជាទំនាក់ទំនងសូរនិងវត្ថុមួយដាច់ខាត គឺទំនាក់ទំនងរវាងពាក្យនិងវត្ថុ។ ភាសាវិទូមួយចំនួនទៀតនៅឱ្យនិយមន័យថា ន័យរបស់ពាក្យ គឺជាចំណាំងវត្ថុដែលស្ថិតក្នុងពាក្យ (អុក ចូន, ១៩៨៧)។

### ៤.១. តើន័យរបស់ពាក្យកើតឡើងយ៉ាងដូចម្តេច?

ន័យអាចត្រូវបានសិក្សាដោយផ្សារភ្ជាប់នឹងទិដ្ឋភាពដូចជាទស្សនវិជ្ជា ចិត្តវិទ្យា គតិវិទ្យា និមិត្តរូបនិយម ភាសាវិទ្យា (Alan Cruse, ២០០០)។

នៅក្នុងទិដ្ឋភាពភាសាវិទ្យា ន័យរបស់ពាក្យអាចកើតឡើងបានតាមរយៈ៖

-ទម្រង់ខាងក្នុងរបស់ពាក្យ (Gayane Girunyan, ២០០៩)

-ការចូលរួមក្នុងសម្ព័ន្ធ (Alan Cruse, ២០០០)

-កើតចេញពីពាក្យចាស់ (Alan Cruse, ២០០០) ឬបម្លាស់ប្តូរន័យ (ក្រសួងអប់រំ, ១៩៨៣)

-ការយល់ឃើញ (David Crystal, ២០០៨)។

#### ៤.១.១. ទម្រង់ខាងក្នុងរបស់ពាក្យ

ទម្រង់ខាងក្នុងរបស់ពាក្យសំដៅទៅលើរូបសព្ទ សូរ និងន័យ (Gayane Girunyan, ២០០៩)។

-**រូបសព្ទ**៖ សម្ព័ន្ធរវាងផ្នត់និងពាក្យឫស អក្ខរាសបទនិងពាក្យឫស...។

-**សូរ**៖ សូរឧទាន សូរសំឡេង សូរសទ្ទ...។

-**ន័យ៖** ន័យចាស់ឬន័យដំណាក់ទី១ បម្រៀបន័យ...។

### ៤.១.២. ការចូលរួមក្នុងសម្ព័ន្ធ

ន័យរបស់ពាក្យកើតឡើងផ្សេងពីគ្នាអាស្រ័យលើសហបទដែលវាចូលរួម (Alan Cruse, ២០០០)។ សហបទដែលបានចូលរួមស្ថាបនាន័យនោះអាចស្ថិតក្នុងកម្រិតកន្សោមពាក្យ ឃ្លា ឬល្បះ។

-**កន្សោមពាក្យ៖** ពាក្យបន្សំ សំនួនពាក្យ បម្រៀបន័យ សុភាសិត...។

-**ល្បះ៖** ល្បះទោល ល្បះផ្សំ ល្បះក្រង...។

### ៤.១.៣. បម្លាស់ប្តូរន័យ

ន័យពាក្យថ្មីតែងតែកើតឡើងដោយរបៀបផ្លាស់ប្តូរពាក្យមួយដែលមានស្រាប់ (កើតឯង) បង្ហាញនូវវត្ថុមួយឬបាតុភាព សភាពថ្មីមួយ។ ន័យថ្មីរបស់ពាក្យកើតឡើងដោយវិធីបម្លាស់ប្តូរន័យពាក្យចាស់ហៅថាន័យផ្លាស់ប្តូរ (ន័យបម្លាស់) គឺបម្លាស់ប្តូរន័យរបស់ពាក្យសម្អាងលើភាពដូចគ្នានៃវត្ថុឬផ្អែកលើទំនាក់ទំនងទៅវិញទៅមករវាងពាក្យនិងពាក្យ។ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រតែងលើកឡើងនូវវិធីបម្លាស់ប្តូរន័យរបស់ពាក្យពីរយ៉ាងគឺ **បម្រៀបន័យ** និង **បន្ទេរន័យ** (អុក ចូន, ១៩៨៧)។

-**វិធីបម្រៀបន័យ៖** រូបរាងខាងក្រៅ មុខងារ សូរសំឡេង ការនឹកភ្នក។

-**វិធីបន្ទេរន័យ៖** ខាងក្រៅនិងខ្លឹមសារ ទាំងមូលនិងផ្នែក វត្ថុធាតុដើមនិងផលិតផល អ្នកនិពន្ធនិងស្នាដៃ។

### ៤.១.៤. ការយល់ឃើញ

តាមរយៈការយល់ឃើញ ន័យរបស់ពាក្យត្រូវបានបញ្ជាក់ដោយបញ្ញត្តិនីយកម្មរចនសម្ព័ន្ធនិងដំណើរប្រព្រឹត្តទៅដែលជាផ្នែកមួយនៃបទពិសោធគំនិត (David Crystal, ២០០៨)។ ទ្រឹស្តីខាងនេះបានបញ្ជាក់ពីដំណើរប្រព្រឹត្តទៅមួយចំនួននៃបម្រៀបន័យនិងនិមិត្តរូប។

ឧ. *ភ្នំទុក្ខ ផ្លែបម្រើ មាន់ថ្មី ព្រាបស ជញ្ជីង ស្លាបប៉ាកា*...។

## ៤.២. ដំណាក់កាលន័យរបស់ពាក្យ

រចនាសម្ព័ន្ធន័យរបស់ពាក្យជាសំណុំនៃអន្តរទំនាក់ទំនងរវាងវចនៈនិងន័យផ្សេងៗពីគ្នាដែលចងជារចនាសម្ព័ន្ធមួយ។ រចនាសម្ព័ន្ធន័យរបស់ពាក្យជាការចងសម្ព័ន្ធនៃន័យផ្សេងៗពីគ្នា។ រចនាសម្ព័ន្ធន័យរបស់ពាក្យអាចកើតឡើងពីរដំណាក់ ដែលគេអាចហៅថា **ន័យដំណាក់ទី១** និង **ន័យដំណាក់ទី២**។

#### ៤.២.១. ន័យដំណាក់ទី១

**ន័យដំណាក់ទី១** របស់ពាក្យ គឺជាន័យឬការប្រើប្រាស់ដែលលេចឡើងដំបូងនៅក្នុងភាសា។ តាមអ័ក្សសមកាល (synchronically) ន័យដំណាក់ទី១នេះអាចក្លាយជាន័យបន្ទាប់បន្សំមួយក្នុងចំណោមន័យបន្ទាប់បន្សំ (marginal meaning) របស់ពាក្យ។

សូមពិនិត្យមើលល្បះខាងក្រោម៖

*(ក) ទឹកឃ្មុំមានអត្ថប្រយោជន៍យ៉ាងច្រើនចំពោះសុខភាព។*

ពាក្យ *ទឹកឃ្មុំ* មានន័យថាទឹកផ្អែមដែលបានមកពីឃ្មុំក្រេបយកលម្អងផ្កា។ ន័យនេះជាន័យដំណាក់កាលទី១ របស់ *ទឹកឃ្មុំ*។

#### ៤.២.២. ន័យដំណាក់ទី២

**ន័យដំណាក់ទី២** របស់ពាក្យ គឺជាន័យទាំងឡាយក្រៅពីន័យដំណាក់ទី១។ ពួកវាត្រូវបានគេនិយាយមិននៅចំកណ្ដាលនោះទេ គឺនៅខាងក្រៅ។ លើសពីនេះន័យដំណាក់ទី២ របស់ពាក្យត្រូវបានចូលរួមដោយសហបទដែលមិនមែនជាសហបទរបស់ន័យដំណាក់ទី១។ វាលេចឡើងបន្ទាប់ពីន័យដំណាក់ទី១ កំពុងមានវត្តមាន ហើយយោងលើន័យដំណាក់ទី១។ តាមអ័ក្សប្រតិកាល (diachronically) ន័យដំណាក់ទី២នេះអាចក្លាយទៅជាន័យកណ្ដាលរបស់ពាក្យ (central meaning)។ ន័យដំណាក់ទី២ ត្រូវបានវិវត្តចេញពីបរិបទដែលបង្ហាញដោយការសម្ដែងរបស់កិរិយាសព្ទ។

សូមពិនិត្យឧទាហរណ៍ខាងក្រោម៖

*(ខ) រាត្រីទឹកឃ្មុំដំបូង គឺពិតជាមានន័យណាស់សម្រាប់មនុស្សគ្រប់រូប។*

*ទឹកឃ្មុំ* នៅក្នុងល្បះនេះមានន័យថា ភាពផ្អែមល្ហែមអំឡុងពេលផ្សំដំណេករបស់គូស្វាមីភរិយាថ្មីទើបរៀបការរួច។ ន័យនេះជាន័យដំណាក់កាលទី២ របស់ *ទឹកឃ្មុំ*។

### ៤.៣. ប្រភេទន័យរបស់ពាក្យ

ន័យរបស់ពាក្យត្រូវបានបែងចែកជាប្រភេទដូចជាន័យចំ ន័យធៀប ន័យច្រើន ន័យដូច ន័យផ្ទុយ (ក្រសួងអប់រំ, ១៩៨៣)។

#### ៤.៣.១. ន័យចំ

**ន័យចំ** (literal meaning) គឺជាន័យគ្រឹះ តាមធម្មជាតិ តាមកំណើត (ក្រសួងអប់រំ, ១៩៨៣)។

ឧ. *សៀវភៅ ដប កុំព្យូទ័រ ប៊ិក...*។

#### ៤.៣.២. ន័យធៀប

**ន័យធៀប** (non-literal meaning) គឺជាន័យប្រដូច ប្រៀបផ្ទឹម ពុំចំតាមន័យកំណើត

(ក្រសួងអប់រំ, ១៩៨៣)។

ឧ. *ក្ដៅចិត្ត ត្រចៀកស្រាល បាតដៃទីបី ...*។

**៤.៣.៣. ន័យច្រើន**

**ន័យច្រើន** (polysemy) គឺជាន័យរបស់ពាក្យតែមួយ មានច្រើនបែបយ៉ាង (ក្រសួងអប់រំ, ១៩៨៣)។

ឧ. *បើកឡាន បើកសៀវភៅ..., បុកគ្រឿង គ្រឿងម៉ាស៊ីន ទូរសព្ទ១គ្រឿង...*។

**៤.៣.៤. ន័យដូច**

**ន័យដូច** (synonym) គឺជាន័យប្រហែលគ្នា។ ន័យដូចរបស់ពាក្យណាមួយមានន័យប្រហែលគ្នា តែសំណេរនិងសំណូរពុំដូចគ្នាទេ (ក្រសួងអប់រំ, ១៩៨៣)។

ឧ. *ផ្ទះ គេហដ្ឋាន ភូមិគ្រឹះ, ម្ដាយ ម៉ែ មាតា ម៉ាក់...*។

**៤.៣.៥. ន័យផ្ទុយ**

**ន័យផ្ទុយ** (antonym) គឺជាន័យទំនាស់នឹងគ្នា (ក្រសួងអប់រំ, ១៩៨៣)។

ឧ. *ស ខ្មៅ, លក់ ទិញ, ម៉ែ ឪ, ស្រី ប្រុស...*។

**៤.៣.៦. ន័យរូបី**

**ន័យរូបី** គឺជាន័យរបស់ពាក្យផ្សារភ្ជាប់នឹងវត្ថុពិសេសណាមួយនោះឬជាន័យផ្សារភ្ជាប់នឹងសញ្ញារូបភាព ឆ្លុះបញ្ចាំងវត្ថុក្នុងអារម្មណ៍ (អុក ចូន, ១៩៨៧)។

ឧ. *ផ្លូវ ម៉ូតូ ឡាន បាង...*។

**៤.៣.៧. ន័យអរូបី**

**ន័យអរូបី** គឺជាន័យរបស់ពាក្យមិនផ្សារភ្ជាប់នឹងវត្ថុពិសេសណាមួយទេឬជាន័យមិនផ្សារភ្ជាប់ជាមួយសញ្ញារូបភាពជាក់ស្ដែង (អុក ចូន, ១៩៨៧)។

ឧ. *នឹករឭក អប់រំ ផែនការ គោលការណ៍...*។

**៥. ទំនាក់ទំនងពាក្យ**

ទំនាក់ទំនងពាក្យកើតឡើងតាមរយៈសំណូរ សំណេរ និងន័យ។ តាមរយៈទំនាក់ទំនងនេះ កន្លងមកអ្នកសិក្សាចែកពាក្យសព្ទជាពាក្យសូរដូច ពាក្យរូបដូច ពាក្យន័យដូច ពាក្យពហុន័យ ពាក្យផ្ទុយ វេវចនសព្ទ សទិសសព្ទ (សទិសលេខ សទិសសូរ)។ ក្នុងចំណោមបច្ចេកសព្ទទាំងអស់នេះ សូមជ្រើសរើសបច្ចេកសព្ទមួយចំនួនមកប្រើតែប៉ុណ្ណោះ ចៀសវាងការប្រើប្រាស់បច្ចេកសព្ទច្រើននាំឱ្យមានការភ័ន្តច្រឡំ។ បច្ចេកសព្ទទាំងនេះមានដូចជា **ពាក្យសូរដូច ពាក្យន័យដូច ពាក្យរូបដូច ពាក្យន័យផ្ទុយ** និង **ពាក្យន័យច្រើន**។

ឯកសារស្រាវជ្រាវនានាបានផ្ដល់និយមន័យដល់បច្ចេកសព្ទទាំងនេះដូចតទៅ៖

### ៥.១. ពាក្យសូរដូច

ក្នុងឯកសារនានា អ្នកសិក្សាបានប្រើបច្ចេកសព្ទពីរ គឺ **ពាក្យសូរដូច** និង **សទិសសូរ** ដើម្បីសម្គាល់ទៅលើក្រុមពាក្យតែមួយ។ ក្នុងចំណោមបច្ចេកសព្ទទាំងពីរនេះ សូមប្រើប្រាស់បច្ចេកសព្ទ **ពាក្យសូរដូច**។

**ពាក្យសូរដូច** គឺជា៖

-បណ្ដាពាក្យដែលអានដូចគ្នា ប៉ុន្តែមានអត្ថន័យនិងក្បួនបម្រើបម្រាស់ខុសគ្នា។ ពាក្យសូរដូចអាចមានអក្ខរាវិរុទ្ធប្លែកគ្នា ដែលធ្វើមិនឱ្យច្រឡំក្នុងសំណេរ (ក្រសួងអប់រំ, ១៩៨៦)។

-ពាក្យដែលមានសូរដូចគ្នា (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៣)។

-សព្ទដែលមានសូរដូចគ្នាឬស្រដៀងគ្នា តែមានអត្ថន័យខុសគ្នាឬផ្សេងគ្នា។ ឧ. *គូ គូរ* (សួន ឱសថ, ២០១៣)។

### ៥.២. ពាក្យរូបដូច

ពីមុនមក ឃើញមានគេប្រើបច្ចេកសព្ទពីរ គឺ **ពាក្យរូបដូច** និង **សទិសលេខ** ដើម្បីសម្គាល់ទៅលើក្រុមពាក្យតែមួយ។ នៅទីនេះ សូមប្រើប្រាស់បច្ចេកសព្ទ **ពាក្យរូបដូច**។

**ពាក្យរូបដូច** គឺជា៖

-បណ្ដាពាក្យដែលសរសេរដូចគ្នា។ គេពុំអាចញែកវាចេញពីគ្នាដោយអក្ខរាវិរុទ្ធបានទេ។ ពាក្យរូបដូចខ្លះមានសូរដូចគ្នាទៀត (ក្រសួងអប់រំ, ១៩៨៦)។

-ពាក្យដែលមានសំណេរដូចគ្នា (*គុន គុន លិច លិច*)។

### ៥.៣. ពាក្យន័យដូច

កន្លងមកអ្នកសិក្សាបានប្រើបច្ចេកសព្ទ **ពាក្យន័យដូច សទិសន័យ** និង **វេវចនសព្ទ** ដែលមានន័យសំដៅយកក្រុមពាក្យប្រហាក់ប្រហែលគ្នា។ ដូច្នេះដើម្បីកុំឱ្យមានការភាន់ច្រឡំនិងប្រើប្រាស់ឱ្យឯកភាពគ្នាផង សូមជ្រើសរើសយកបច្ចេកសព្ទតែមួយយកមកប្រើ គឺ **ពាក្យន័យដូច**។

**ពាក្យន័យដូច** គឺជា៖

-ពាក្យឬកញ្ចុំពាក្យពីរជាកម្មសិទ្ធិរបស់ថ្នាក់វេយ្យាករណ៍តែមួយ ហើយអាចផ្លាស់ប្តូរគ្នាបានដោយគ្មានធ្វើឱ្យផ្លាស់ប្តូរន័យទូទៅនៃឃ្លា (ក្រសួងអប់រំ, ១៩៨៦)។

-ពាក្យពីរម៉ាត់ឬវាចាវិលាសពីរម៉ាត់ឬក៏ច្រើនម៉ាត់ជាវេវចនសព្ទនឹងគ្នាកាលណាពាក្យឬវាចាវិលាសនោះមានប្រភេទដូចគ្នានិងអាចជំនួសគ្នាបានក្នុងឃ្លាដោយឥត

បណ្ដាលឱ្យល្បះមានន័យផ្សេង (*លាចាកលោក ទទួលមរណភាព ប្ដី ស្វាមី*) (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៣)។

-សព្ទដែលមានសូរខុសគ្នាឬផ្សេងគ្នា តែមានអត្ថន័យដូចគ្នាឬស្រដៀងគ្នា។ ឧ. *មិត្រ សម្លាញ់ គូកន ពួកម៉ាក គឿន* (សួន ឱសថ, ២០១៣)។

### ៥.៤. ពាក្យពហុន័យ

**ពាក្យពហុន័យ** គឺជា៖

-ពាក្យដែលមានសំណូរនិងសំណេរដូចគ្នាសម្គាល់ន័យច្រើនយ៉ាងទាក់ទងគ្នា។ រូបរាងនេះជារបស់ពាក្យតែមួយដែលមានន័យច្រើន (ក្រសួងអប់រំ, ១៩៨៦)។

### ៥.៥. ពាក្យន័យផ្ទុយ

ពីមុនអ្នកសិក្សាប្រើបច្ចេកសព្ទ **ពាក្យផ្ទុយ** និង **បដិសព្ទ** ដើម្បីសម្គាល់ទៅលើក្រុមពាក្យតែមួយឬប្រហាក់ប្រហែលគ្នា។ ដើម្បីងាយស្រួលសិក្សា សូមប្រើបច្ចេកសព្ទ **ពាក្យន័យផ្ទុយ**។

**ពាក្យន័យផ្ទុយ** គឺជា៖

-ពាក្យដែលប្រឈមគ្នា តែលក្ខណ៍ន័យមួយកំណត់ជាន័យវិជ្ជមាននៅពាក្យមួយ ហើយជាអវិជ្ជមាននៅពាក្យមួយទៀត។ ពាក្យផ្ទុយចែកជាពាក្យបង្គ្រប់ បដិស័ព្ទ ពាក្យច្រាល។ ពាក្យបង្គ្រប់ គឺជាពាក្យផ្ទុយគ្នាពីរម៉ាត់ដែលមិនចុះសំរុងគ្នាទៅវិញទៅមក (*ប្រុស ស្រី*)។

-ពាក្យមួយគូផ្ទុយគ្នាដែលភាពមិនស្របនៃពាក្យមួយនាំឱ្យមានភាពស្របនៃពាក្យមួយទៀតទេ (*ក្ដៅ ត្រជាក់*)។

-ពាក្យដែលកំណត់ទិដ្ឋភាពពីរនៃប្រព្រឹត្តិតែមួយ ហើយអាចដាក់បញ្ច្រាសគ្នាកន្សោមនាមពីរ គឺកន្សោមនាមប្រធាននិងកន្សោមនាមកម្មបទ (*ទិញ លក់*) (ក្រសួងអប់រំ, ១៩៨៦)។

-ពាក្យទាំងឡាយដែលមានន័យផ្ទុយគ្នា (*ញី ឈ្មោល ទិញ លក់*)។ បដិសព្ទមានព្រំដែនមានជាក់លាក់ ព្រោះវាអាចជាបដិសព្ទសម្គាល់ភាពប្រៀបធៀប (*តូច ធំ*) បដិសព្ទសម្គាល់ប្រតិភាពឬទៅវិញទៅមក (*ទិញ លក់ ប្រពន្ធ ប្ដី*) បដិសព្ទសម្គាល់ភាពដៃគូនឹងគ្នា (*រស់ ស្លាប់*) (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៣)។

## ៦. សន្ដានពាក្យ

**សន្ដានពាក្យ** គឺជាពាក្យទាំងឡាយដែលត្រូវបានបង្កើតឡើងចេញពីធាតុឫសតែ

មួយ ហើយមានន័យទាក់ទងគ្នា។

ឧ. *បណ្ដើរ ថ្មើរ ការដើរ ដំណើរ ដណ្ដើរ, ទស្សនា ទស្សនីយភាព ទស្សនិកជន...* ជាសន្តានពាក្យ។

**៧. ប្រភេទពាក្យសព្ទ**

ពាក្យសព្ទត្រូវបានបែងចែកជាប្រភេទអាស្រ័យលើមូលដ្ឋានផ្សេងពីគ្នា។ ប្រភេទពាក្យសព្ទទាំងនោះមានដូចជាពាក្យថ្មីនិងពាក្យចាស់ (ការផ្លាស់ប្ដូរនិងការវិវត្ត) ពាក្យសកម្មនិងពាក្យអកម្ម (តម្លៃនៃការប្រើប្រាស់) ពាក្យសព្ទប្រជាជន ពាក្យសព្ទវប្បធម៌ ពាក្យសព្ទសន្ទនាឆ្លងឆ្លើយ ពាក្យសព្ទតំបន់ (អត្ថិភាពនិងវិវត្តរបរាងខាងក្រៅភាសា) ពាក្យសព្ទកណ្ដាល ពាក្យសព្ទមុខជំនាញ ពាក្យសព្ទលិខិតផ្លូវការ ពាក្យសព្ទក្នុងកំណាព្យ-ចម្រៀង (រចនាបថភាសា) ពាក្យសទិសន័យ ពាក្យបដិន័យ ពាក្យសទិសសូរ (ទំនាក់ទំនងន័យនិងពាក្យ) ពាក្យសព្ទភាសាចម្បងនិងពាក្យសព្ទកម្ចី (ប្រភពឬកំណើតរបស់ពាក្យ)។

**៧.១. ពាក្យសព្ទថ្មីនិងពាក្យសព្ទបុរាណ**

**ពាក្យសព្ទថ្មី** គឺជាពាក្យមានលក្ខណៈទំនើបទើបតែកើតឡើង បង្ហាញប្រាប់វត្ថុបាតុភូតថ្មីឬដើម្បីផ្លាស់ប្ដូរពាក្យចាស់។ ពាក្យថ្មីឆ្លើយតបសំណូមពររីកចម្រើនផ្នែកនយោបាយ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ... (អុក ចូន, ១៩៨៧)។

ឧ. *អ៊ីនធើណែត ហ្វេសប៊ុក ពិពិធកម្ម សមាហរណកម្ម...*។

**ពាក្យសព្ទបុរាណ** គឺជាពាក្យកើតមុននេះដែលសព្វថ្ងៃគេមិនប្រើទៀតទេ។ វាចូលទៅក្នុងទុនពាក្យអកម្ម។ ពាក្យបុរាណពីមុននេះបង្ហាញវត្ថុនិងបាតុភូត ប៉ុន្តែសព្វថ្ងៃវត្ថុនិងបាតុភូតទាំងនោះគ្មានអត្ថិភាពទៀតទេ ដែលគេអាចហៅពាក្យទាំងនេះថាពាក្យសព្ទប្រវត្តិ (អុក ចូន, ១៩៨៧)។

ឧ. *មេស្រុក កម្រតាង គម្លែង...*។

**៧.២. ពាក្យសព្ទសកម្មនិងពាក្យសព្ទអកម្ម**

**ពាក្យសព្ទសកម្ម** គឺជាពាក្យដែលត្រូវប្រើរាល់ថ្ងៃ គឺបណ្ដាពាក្យដែលត្រូវប្រើប្រាស់ញឹកញាប់បំផុត (អុក ចូន, ១៩៨៧)។

ឧ. *ស៊ី ដេក ដើរ ផ្សារ សាលា ទូរសព្ទ ...*។

**ពាក្យសព្ទអកម្ម** គឺជាពាក្យដែលមិនសូវប្រើប្រាស់ឬមិនប្រើប្រាស់ញឹកញាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ (អុក ចូន, ១៩៨៧)។

ឧ. *មាសមេ ប្រកាស ពិសោធ...*។

## ៧.៣. ពាក្យសព្ទប្រជាជន ពាក្យសព្ទវប្បធម៌ ពាក្យសព្ទសន្ទនាឆ្លងឆ្លើយ ពាក្យសព្ទតំបន់

**ពាក្យសព្ទប្រជាជន** ឬគេអាចហៅថា **ពាក្យសព្ទភាសារួម** គឺជាបណ្ដាពាក្យប្រើប្រាស់រួមទាំងក្នុងភាសាសន្ទនាទាំងភាសាសរសេរ (អុក ចួន, ១៩៨៧)។

ឧ. *លេង ទៅ ចេញ ម៉ូតូ ផ្លូវ ...*។

**ពាក្យសព្ទវប្បធម៌** គឺជាពាក្យសព្ទផ្លូវការរួមសម្រាប់ប្រជាជននិងមានក្បួនប្រើប្រាស់ច្បាស់លាស់ទាំងផ្នែកន័យទាំងផ្នែកវេយ្យាករណ៍។ ពាក្យសព្ទវប្បធម៌ក្នុងសំណេរផ្ទុយពីពាក្យសព្ទសន្ទនា។ ពាក្យសព្ទវប្បធម៌ត្រូវបានប្រើក្នុងអក្សរសិល្ប៍ ឯកសារប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ ក្រសួងមន្ទីរ ឬសាលារៀន។

ឧ. *ព្រឹត្តិការណ៍ ចលនា ពាណិជ្ជកម្ម នាយករដ្ឋមន្ត្រី ...*។

**ពាក្យសព្ទសន្ទនាឆ្លើយឆ្លង** គឺជាបណ្ដាពាក្យដែលត្រូវបានប្រើដើម្បីពិគ្រោះ ឆ្លើយឆ្លងតាមមាត់ មិនស្ថិតក្នុងតំបន់ដែលមនុស្សរស់នៅទេ ប៉ុន្តែត្រូវបានប្រជាជនក្នុងប្រទេសមួយប្រើប្រាស់។ ពាក្យសព្ទសន្ទនាឆ្លើយឆ្លងត្រូវបានប្រើប្រាស់ទូលំទូលាយក្នុងសកម្មភាពប្រចាំថ្ងៃរបស់មនុស្ស (អុក ចួន, ១៩៨៧)។

ឧ. *អ៊ីចឹង ទៅ អ្នកណា មិនដឹង ...*។

**ពាក្យសព្ទតំបន់** គឺជាបណ្ដាពាក្យដែលត្រូវបានប្រើក្នុងវិស័យផ្សេងៗក្នុងតំបន់មួយ ទីក្រុងមួយ ខេត្តមួយ ឬភូមិភាគមួយ។ ពាក្យសព្ទតំបន់បង្កើតឧបសគ្គដល់ភាសាសម្រាប់ទំនាក់ទំនងរួមរបស់ប្រជាជន ប៉ុន្តែពាក្យសព្ទតំបន់ក៏ជាប្រភពពាក្យសព្ទបំពេញបន្ថែមឱ្យពាក្យសព្ទសន្ទនារួមដែរ (អុក ចួន, ១៩៨៧)។

ឧ. *ម៉ូតូអូម សោ មិត ពឹត ចេវ ...*។

## ៧.៤. ពាក្យសព្ទកណ្ដាល ពាក្យសព្ទជំនាញ ពាក្យសព្ទក្នុងលិខិតផ្លូវការ ពាក្យសព្ទក្នុងកំណាព្យ-ចម្រៀង

**ពាក្យសព្ទកណ្ដាល** គឺជាបណ្ដាពាក្យដែលអាចប្រើក្នុងប្រភេទរចនាបថភាសាទាំងអស់។ វាមិននាំមកនូវរចនាបថណាផ្ទាល់ដោយឡែកទាំងអស់។ ពាក្យសព្ទនេះស្ថិតនៅឋានៈកណ្ដាលច្រើន ហើយវាផ្សារភ្ជាប់ជាមួយរចនាបថភាសានិងឯកភាពជាមួយវប្បធម៌ភាសា (អុក ចួន, ១៩៨៧)។

ឧ. *ខំប្រឹង ម៉ូឌុប ចេកទំ ...*។

**ពាក្យសព្ទមុខជំនាញ** គឺជាបណ្ដាពាក្យដែលផ្សារភ្ជាប់ជាមួយរចនាបថភាសាវិទ្យា-

សាស្ត្រនិងធម្មតាក៏មានពាក្យសព្ទមុខជំនាញក្នុងបណ្ដាវិស័យសកម្មភាពសង្គមផ្សេងៗ ដូចជាបច្ចេកសព្ទមុខរបរ។ លក្ខណៈពិសេសរួមរបស់ពាក្យសព្ទមុខជំនាញ គឺវាមានលក្ខណៈឡូស៊ិក (អុក ចួន, ១៩៨៧)។

ឧ. *គីមី អាស៊ីត ជនជាប់ចោទ តុលាការ អតិផរណា* ...។

**ពាក្យសព្ទក្នុងលិខិតផ្លូវការ** គឺជាបណ្ដាពាក្យដែលប្រើក្នុងលិខិតផ្លូវការ លិខិតរដ្ឋបាល និងក្នុងឯកសារប្រវត្តិរដ្ឋបាល។

ឧ. *យល់ព្រម សម្រេច ឯកភាព តាមរយៈ កម្មវត្ថុ* ...។

**ពាក្យសព្ទក្នុងកំណាព្យ-ចម្រៀង** គឺជាបណ្ដាពាក្យដែលតំណាងភាសាសិល្បៈ វាមានលក្ខណៈសម្ដែងមនោសញ្ចេតនា លក្ខណៈរូបភាព និងលក្ខណៈសិល្បៈ។ ពាក្យសព្ទកំណាព្យ-ចម្រៀងស្ថិតនៅក្នុងរចនាបថភាសាវប្បធម៌សិល្បៈ ហើយតែងតែត្រូវបានប្រើនៅក្នុងស្នាដៃអក្សរសិល្ប៍ (អុក ចួន, ១៩៨៧)។

ឧ. *មាសមេ ស្នេហ៍ស្និទ្ធ ប្រតិព័ទ្ធ អស្ដង្គត* ...។

### ៧.៥. ពាក្យន័យដូច ពាក្យន័យផ្ទុយ ពាក្យសូរដូច

**ពាក្យន័យដូច** គឺជាបណ្ដាពាក្យដែលមានសូរខាងក្រៅខុសគ្នា ប៉ុន្តែមានន័យដូចគ្នា ឬប្រហាក់ប្រហែលគ្នា (អុក ចួន, ១៩៨៧)។

ឧ. *ស៊ី ហូប ពិសា ឆាន់ សោយ* ...។

ពាក្យន័យដូចមានតួនាទីធំធេងក្នុងការពង្រីកវប្បធម៌របស់មនុស្ស។ មនុស្សកាន់តែក្លាប់បានរឹងមាំនិងមានទុនពាក្យន័យដូចសំបូរបែប គឺកាន់តែសម្ដែងចេញឱ្យឃើញច្បាស់លាស់ប្រាកដនិងងាយស្រួលដល់មនោរម្មណ៍ជាមួយលក្ខណៈមធ្យ័តល្អិតល្អន់គ្រប់បែបយ៉ាង។ បើចំណេះដឹងពីពាក្យន័យដូចខ្សត់ខ្សោយ គឺពាក្យសម្ដីរបស់មនុស្សក៏នៅខ្សត់ខ្សោយមិនសំបូរ ហើយការប្រើប្រាស់ពាក្យក៏ជួបការលំបាកច្រើន (អុក ចួន, ១៩៨៧)។

**ពាក្យន័យផ្ទុយ** គឺជាបណ្ដាពាក្យដែលមានន័យផ្ទុយគ្នា។ ពាក្យបដិន័យស្ដែងឡើងក្នុងញាណមនុស្សនូវបាតុភូតផ្ទុយគ្នាក្នុងតថភាពជាក់ស្ដែងឬឆ្លុះបញ្ចាំងនូវភាពប្រឆាំងគ្នាទៅវិញទៅមករបស់បញ្ញត្តិ (អុក ចួន, ១៩៨៧)។

ឧ. *សកម្ម អសកម្ម ឆ្ងាយ ជិត ខ្ពស់ ទាប រីករាយ ព្រួយ* ...។

មានពាក្យន័យផ្ទុយខ្លះបង្ហាញន័យចំផ្ទុយគ្នា ប៉ុន្តែមិនសូវផ្ទុយគ្នាណាស់ណាទេឬមិនមានភាពផ្ទុយគ្នាក្នុងន័យធៀបទេ។

ឧ. *កម្លាំងមាំ កម្លាំងខ្សោយ ស៊ីខ្លាំង ស៊ីខ្សោយ* ...។

**ពាក្យសូរដូច** គឺជាបណ្ដាពាក្យដែលមានន័យផ្សេងគ្នា តែមានសូរខាងក្រៅដូចគ្នា។ ពាក្យនេះកើតឡើងអាស្រ័យលើការបែងចែកន័យច្រើនយ៉ាងរបស់ពាក្យ បានន័យថាពាក្យពហុន័យមួយបែងចែកជាពាក្យសទិសសូរច្រើនដែលមានន័យខុសៗគ្នា (អុក ចូន , ១៩៨៧)។

ឧ. *កា ការ កាណ៌ ការណ៍, បិទ បិត, សរ ស* ...។

មានអ្នកខ្លះនិយាយថាពាក្យសូរដូច គឺជាបាតុភូតមួយគ្មានប្រយោជន៍ក្នុងភាសា ពីព្រោះវានាំមកនូវការយល់ឡូកឡំគ្នាជាមួយវត្ថុនិងបញ្ញត្តិ។ យោបល់នោះមិនត្រឹមត្រូវទេ ព្រោះពាក្យសូរដូចជាបាតុភូតមិនអាចចៀសផុតក្នុងដំណាក់កាលរីកចម្រើននៃភាសា ក៏ដូចជាបាតុភូតពហុន័យដែរ។ ពាក្យសូរដូចមិនសូវបង្កើតឧបសគ្គក្នុងបណ្ដូរទំនាក់ទំនងដូចជាពាក្យពហុន័យទេ។ ពាក្យសូរដូចក៏ដូចជាពាក្យន័យដូច មានឥទ្ធិពលប្រាកដច្បាស់លាស់ជាងបញ្ញត្តិរបស់យើងអំពីវត្ថុនិងទំនាក់ទំនងរបស់វា។ ពាក្យសទិសសូរមានផលឬឥទ្ធិពលច្រើនក្នុងការសន្សំសំចៃលើផ្នែកប្រើសូរសំឡេងដែលជាសូរសំឡេងខាងក្រៅតែមួយគត់ ប៉ុន្តែវាសម្ដែងនូវខ្លឹមសារឬអត្ថន័យច្រើន (អុក ចូន, ១៩៨៧) ។

### ៧.៦. ពាក្យសព្ទភាសាចម្បងនិងពាក្យសព្ទកម្ចី

**ពាក្យសព្ទភាសាចម្បង** គឺជាបណ្ដាពាក្យដែលមានស្រាប់របស់ភាសាដែលត្រូវបានបង្កើតឡើងតាមក្បួនបង្កើតពាក្យរបស់ភាសានោះ (អុក ចូន, ១៩៨៧)។

ឧ. *ដំណើរ រីករាយ អ្នកស្រែ* ...។

**ពាក្យសព្ទកម្ចី** គឺជាបណ្ដាពាក្យដែលខ្ចីពីបរទេស។ កម្ចីនេះអាចជាកម្ចីពាក្យទាំងមូលឬអាចខ្ចីតែរូបសព្ទដើម្បីបង្កើតពាក្យ។ ពាក្យកម្ចីពីភាសាបរទេសក៏ត្រូវបានផ្លាស់ប្ដូរឱ្យស្របនឹងក្រឹត្យក្រមបញ្ចេញសំឡេងនៃភាសាជាតិ (អុក ចូន, ១៩៨៧)។

ឧ. *ដុល្លារ កុំព្យូទ័រ អ៊ីនធើណែត អាជាតមិន* ...។

កម្ចីពាក្យបរទេស គឺជាបាតុភូតមួយដែលពុំអាចចៀសផុតក្នុងដំណាក់កាលបណ្ដូរទំនាក់ទំនងសេដ្ឋកិច្ច វប្បធម៌រវាងបណ្ដាជនជាតិក្នុងដំណើរការផ្លាស់ប្ដូរបទពិសោធរៀនសូត្រទៅវិញទៅមកលើផ្នែកវិទ្យាសាស្ត្រ បច្ចេកទេសរវាងបណ្ដាប្រទេសនិងជនជាតិ ប៉ុន្តែគប្បីខ្ចីពាក្យបរទេសក្នុងករណីណាដែលចាំបាច់។ បើមានក្នុងភាសារបស់ខ្លួនហើយ គប្បីបង្កើតឱ្យមានបានដែរដើម្បីងាយស្រួលដល់សិស្សនិស្សិតរបស់យើងក្នុងការសិក្សាជាភាសាជាតិ។ សព្វថ្ងៃក្នុងវិស័យវិទ្យាសាស្ត្របច្ចេកទេស យើងមានទំនោរប្រើបច្ចេកសព្ទដែលមានលក្ខណៈអន្តរជាតិដែរដើម្បីងាយដល់ការផ្លាស់ប្ដូរវិទ្យាសាស្ត្រលើសកលលោក

(អុក ចូន, ១៩៨៧)។

## ៨. ជម្រើសពាក្យ

ក្រោយពេលភាសាខ្មែរទទួលយកពាក្យកម្ចីបាលី-សំស្ក្រឹត ពេលនោះពាក្យក្នុងភាសាខ្មែរចាប់ផ្ដើមសម្បូរបែប។ ទោះបីជាពាក្យកម្ចីបាលី-សំស្ក្រឹតមានវត្តមានប្រជំប្រសងគ្នានឹងពាក្យខ្មែរយ៉ាងណាក្ដី ក៏បម្រើបម្រាស់ឥតមានប្រឆាំងគ្នាឡើយ ព្រោះត្រូវបានប្រើប្រាស់ក្នុងបរិបទផ្សេងពីគ្នា។

រហូតមកដល់ពាក់កណ្ដាលទី២ នៃសតវត្សទី១៩ ខ្មែរស្ថិតនៅក្រោមអាណាព្យាបាលបារាំង នាំឱ្យខ្មែរទទួលយកពាក្យបារាំងមកប្រើប្រាស់បន្ថែមទៀតនៅក្នុងកិច្ចការរដ្ឋបាលឬបច្ចេកទេសផ្សេងៗ។

ក្រោយឆ្នាំ១៩៩៣ ឥទ្ធិពលភាសាបារាំងបានថយចុះ ពាក្យកម្ចីបារាំងនៅទ្រឹងហើយត្រូវបានបោះបង់ចោលមួយចំនួន ដោយជំនួសមកវិញនូវពាក្យកម្ចីអង់គ្លេស។ អស់រយៈពេលជាង២៥ឆ្នាំមកហើយ ឥទ្ធិពលភាសាអង់គ្លេសនៅតែខ្លាំងក្លានៅឡើយ បានធ្វើឱ្យពាក្យកម្ចីអង់គ្លេសមានចំនួនកាន់តែច្រើនឡើងៗ។

ដោយសារមូលហេតុខាងលើនេះហើយ បានធ្វើឱ្យបម្រើបម្រាស់ពាក្យក្នុងភាសាខ្មែរមានជម្រើសរវាង៖

**-ពាក្យខ្មែរនិងពាក្យខ្មែរ៖** *ញ៉ាំ ស៊ី ហូប ឆី, ចាស់ កញ្ចាស់, ស្បោង ថង់...។*

**-ពាក្យខ្មែរនិងពាក្យកម្ចីបាលី-សំស្ក្រឹត៖** *ចំណេះ វិជ្ជា, ភ្លើង អគ្គិសនី, ឡាន រថយន្ត, ក្មេង កុមារ ...។*

**-ពាក្យខ្មែរនិងពាក្យបារាំង៖** *ក្ដារខៀន តាប្លូ, ថតចម្លង កូពី, បនល្បែង កាស៊ីណូ, អំណោយ កាដូ, ស្លាក ផ្លាក...។*

**-ពាក្យខ្មែរនិងពាក្យអង់គ្លេស៖** *គ្រូ ឈ័រ, ផ្អែមល្ហែម ស្វីត, ផ្សាយផ្ទាល់ ឡាយ, ហៅខល, ទីផ្សារ ម៉ាឃីតធីង, គម្រោង ប្រូជិក...។*

**-ពាក្យបាលី-សំស្ក្រឹតនិងពាក្យបាលី-សំស្ក្រឹត៖** *សាកលលោក ពិភពលោក, ភរិយា ប្រពន្ធ, ស្វាមី ប្ដី, បក្ខ បក្ស, សាក្សី សក្ខី ...។*

**-ពាក្យកម្ចីបាលី-សំស្ក្រឹតនិងពាក្យកម្ចីបារាំង៖** *វេជ្ជបណ្ឌិត ដុកទ័រ, គណៈកម្មការកណ្ដាល សង់ត្រាល, សាស្ត្រាចារ្យ ប្រូហ្វេស័រ, មធ្យមសិក្សាទុតិយភូមិ បាក់ឌុប, អត្តសញ្ញាណបណ្ណ កាត ...។*

**-ពាក្យកម្ចីបាលី-សំស្ក្រឹតនិងពាក្យកម្ចីអង់គ្លេស៖** *កម្មវិធី ប្រូក្រាម, អង្គុលីទស្សន៍*

*កុំព្យូទ័រ, អាជីវកម្ម ប៊ីសនីស, វិកយបត្រ វីសិប ...*។

**-ពាក្យកម្ចីបាលី-សំស្រ្កឹត ពាក្យកម្ចីបារាំង និងពាក្យកម្ចីអង់គ្លេស៖** *ទូរសព្ទ តេខល, តំរួត ប៉ូលីស នគរបាល ...*។

## ៩. បម្រើបម្រាស់ពាក្យ

តាមរយៈគ្រឹះរបស់លោក ហ្សង់ ហ្គាញើប៉ាំង និងលោក ជោន រ៉ុស បានបង្ហាញថា ភាសាបានវិវត្តជាប្រព័ន្ធដែលមានពទិស គឺ រយៈកាល រយៈតំបន់ និងរយៈក្រុម។ តាមរយៈកាល ភាសាវិវត្តជាសម្តីសំដៅប្លែកៗតាមដំណាក់កាលឬជាកាលយោបាយ (យោបាយមុនអង្គរ យោបាយក្រោយអង្គរ យោបាយបច្ចុប្បន្ន)។តាមរយៈតំបន់ ភាសាជាសម្តីសំដៅតាមតំបន់ឬវិវត្តជាទេសយោបាយ (យោបាយអ្នកក្រុង យោបាយអ្នកជនបទ យោបាយខ្មែរកម្ពុជាក្រោម យោបាយខ្មែរសុរិន្ទ្រ)។ តាមរយៈក្រុម ភាសាវិវត្តជាសម្តីសំដៅតាមក្រុមឬវិវត្តជាវណ្ណយោបាយ (យោបាយស្តេច យោបាយមន្ត្រី យោបាយកម្មករ) (ព្រំ ម៉ល់, ២០១៣)។

ដូចគ្នានេះ បម្រើបម្រាស់ពាក្យក៏ស្របទៅតាមរយៈកាលទាំងបីខាងលើដែរ គឺ៖

### ៩.១. វណ្ណយោបាយ

បម្រើបម្រាស់ពាក្យទៅតាមវណ្ណយោបាយ គឺផ្អែកទៅលើកម្រិតជីវភាព កម្រិតចំណេះដឹង កម្រិតអាយុ កម្រិតឋានៈ និងកម្រិតក្រុម។ ជម្រើសពាក្យដែលគេយកមកប្រើមានលក្ខណៈពាក្យសាមញ្ញ ពាក្យវប្បធម៌ ពាក្យពីរោះពិសា ពាក្យអសុរោះ ពាក្យទំយើ ពាក្យធម្មតា ពាក្យខ្ពង់ខ្ពស់ ពាក្យសង្ឃ ពាក្យរាស្ត្រ និងពាក្យស្តេចជាដើម។

ឧ. -បម្រើបម្រាស់តាមជម្រើសរវាង *ពិសា ហូប ញ៉ាំ ស៊ី*

*-លោកតាពិសាបាយ។*

*-ម៉ែហូបបាយ។*

*-ក្មេងញ៉ាំបាយ។*

-បម្រើបម្រាស់តាមជម្រើសរវាង *អញ ខ្ញុំ អាត្មា*

*-ឯងទៅបាន តែអញទៅមិនបានទេ។*

*-ខ្ញុំសុំឱ្យលោកជួយខ្ញុំបន្តិចបានទេ?*

*-អាត្មាទៅបិណ្ឌបាត្រនៅម៉ោង៩ព្រឹក។*

### ៩.២. ទេសយោបាយ

បម្រើបម្រាស់ពាក្យទៅតាមទេសយោបាយ គឺផ្អែកទៅលើកម្រិតតំបន់អាចជា

រាជធានី ជនបទ ភូមិភាគធំៗជាដើម។ តំបន់រាជធានីប្រើពាក្យសព្ទកណ្ដាល តំបន់ជនបទមានប្រើពាក្យសព្ទតំបន់ ហើយភូមិភាគធំៗមួយចំនួនដូចជានៅកម្ពុជាក្រោម កម្ពុជាកណ្ដាល និងកម្ពុជាលើក៏មានប្រើពាក្យផ្សេងៗពីគ្នាដែរ។

ឧ. *-អ្នកភ្នំពេញ៖ ស្រី* *អ្នកតាកែវ៖ ច្រី*

*-អ្នកភ្នំពេញ៖ ផឹក* *អ្នកព្រៃវែង៖ ផក់*

*-អ្នកភ្នំពេញ៖ អស់កម្លាំង* *អ្នកសៀមរាប៖ សោ*

*-អ្នកភ្នំពេញ៖ ស្លា* *អ្នកកំពង់ចាម៖ ឡា...*។

**៩.៣. កាលយោបាយ**

បម្រើបម្រាស់ពាក្យទៅតាមកាលយោបាយ គឺផ្អែកទៅលើបរិបទសម័យកាលនៅក្នុងប្រវត្តិសាស្ត្រ។ ការប្រើប្រាស់ពាក្យពេចន៍ប្រែប្រួលទៅតាមសង្គមបរិយាកាស។

ឧ. -សម័យបារាំងគេប្រើពាក្យ *វាយខ្សែលួស*

-សម័យបច្ចុប្បន្នគេប្រើពាក្យ *ទូរសព្ទ...*។

# មេរៀនទី៤
# ការបែងចែកថ្នាក់ពាក្យ

## ១. បច្ចេកសព្ទសម្គាល់ "ថ្នាក់ពាក្យ"

ថ្នាក់ពាក្យជាបញ្ហាសំខាន់សម្រាប់ការវិភាគវេយ្យាករណ៍នៃភាសាតាំងពីបុរាណមក។ ហេតុនេះសូម្បីតែនៅក្នុងភាសាមួយ ក៏យើងសង្កេតឃើញមានប្រើពាក្យប្លែកៗគ្នាដែរ។

នៅក្នុងភាសាបារាំង ក្រៅពីពាក្យ parties du discours យើងឃើញគេប្រើពាក្យជាច្រើនទៀតដូចជា classes de mots, classes distributionnelles, catégories de mots, catégories syntaxiques, និង catégories grammaticales ជាដើម។

ចំណែកនៅក្នុងភាសាអង់គ្លេសវិញ យើងឃើញក៏គេប្រើបច្ចេកសព្ទស្រដៀងគ្នាច្រើនដែរ ដូចជា part of speech, word classes, lexical classes, lexical categories, syntactic categories និង grammatical categories ជាដើម។

ឯនៅក្នុងភាសាខ្មែរវិញ យើងក៏ឃើញមានប្រើបច្ចេកសព្ទសម្គាល់ថ្នាក់ពាក្យប្លែកៗគ្នាច្រើនដែរដូចជាពាក្យ "ជំនុំពាក្យ" (ពូវ អ៊ុម, ១៩៥៥) , "សង្កាត់សុន្ទរកថា" (រ៉ាយ ប៊ុក, ១៩៥៥) , "សព្ទប្រភេទ" (កេង វ៉ាន់សាក់, ១៩៦៤) , "លក្ខណៈនៃពាក្យ" (ខៀវ ជុំ, ១៩៦៦) , "ថ្នាក់ពាក្យ" និង "ប្រភេទពាក្យ" (ក្រសួងអប់រំ, ១៩៨២)។

## ២. និយមន័យ

**ថ្នាក់ពាក្យ** ត្រូវបានអ្នកសិក្សាផ្ដល់និយមន័យទៅតាមការស្រាវជ្រាវដូចតទៅ៖

-**ថ្នាក់ពាក្យ** គឺជាប្រភេទពាក្យទាំង ឡាយដែលកំណត់បានដោយទីតាំងក្នុងឃ្លាដូចគ្នា។ ឧ. គេចាត់ថាពាក្យណាមួយជា «កំណត់» ដោយសារវាស្ថិតនៅក្បែរនាមដែលវាបញ្ជាក់លក្ខណៈ ដូចជា «សៀវភៅមួយ» *មួយ* ជាពាក្យនៅក្នុងថ្នាក់*កំណត់*" (ហ៊ាន សុខុម, ១៩៩៨)។

-**ថ្នាក់ពាក្យ** ជាសញ្ញាណវេយ្យាករមួយដែលគេបានកំណត់ឡើង ដើម្បីបែងចែកពាក្យក្នុងភាសាជាថ្នាក់ កិរិយាសព្ទ នាមសព្ទ គុណនាម គុណកិរិយា ឈ្នាប់ សព្វនាម ភាគសព្ទ (នៃវាទកម្ម)។ល។ វាជាបញ្ញត្តិទូទៅដែលមានលក្ខណៈជាវេយ្យាករ ហើយអាចឱ្យបែងចែកពាក្យជាប្រភេទខុសៗគ្នា។ ថ្នាក់ពាក្យមិនជាប់ទៅនឹងពាក្យណាមួយនោះទេ

តែជាសំណុំនៃលក្ខណៈវិនិច្ឆ័យដែលគ្របដណ្តប់លើពាក្យជាច្រើន ហើយមានដែនប្រទាក់គ្នាពីមួយទៅមួយ។ វាត្រូវបានបញ្ញត្តិឡើងដោយក្រុមមនុស្សដែលមិនត្រឹមតែបានយកពាក្យមកប្រើប្រាស់នោះទេ ថែមទាំងបានសិក្សាទៅលើលក្ខណៈរបស់ពាក្យទាំងនោះទៀតផង" (ច័ន្ទ សំណព្វ, ២០១០)។

-វចនានុក្រមភាសាវិទ្យារបស់សាកលវិទ្យាល័យអុកស្វ៊ត (The Concise Oxford Dictionary of Linguistics) បានពន្យល់ថា "**ថ្នាក់ពាក្យ** ជាទូទៅគឺជាថ្នាក់នៃពាក្យណាមួយដែលគេបែងចែកទៅតាម លក្ខណៈដូចគ្នាក្នុងផ្នែកសម្ព័ន្ធឬវេយ្យាករណ៍ (Mattews, P.H., ១៩៩៧)។

-វចនានុក្រមភាសាវិទ្យានិងសូរវិទ្យា (A Dictionary of Linguistics and Phonetics) បានពន្យល់ថា "ពាក្យ «**ថ្នាក់**» ដែលប្រើក្នុងភាសាវិទ្យាច្រើនសំដៅលើក្រុមនៃឯកតាភាសាដែលមានទម្រង់ឬលក្ខណៈន័យជាក់លាក់រួមគ្នា។ ពាក្យនេះត្រូវគេប្រើច្រើនក្នុងចំណែកថ្នាក់នៃរូបតានិងពាក្យ (Crystal D., 2008)។

**ថ្នាក់ពាក្យ** ឬ **ប្រភេទពាក្យ** គឺជាការបែងចែកពាក្យនៅក្នុងភាសាណាមួយជាក្រុមផ្សេងៗពីគ្នាដោយពឹងផ្អែកជាពិសេស លើមុខងាររបស់ពាក្យនៅក្នុងប្រយោគ ព្រមទាំងអាចពឹងផ្អែកលើរូបសាស្ត្ររបស់ពាក្យនោះ។

តាមនិយមន័យខាងលើ យើងឃើញថា មានសេចក្តីពន្យល់ប្លែកៗគ្នាអំពីថ្នាក់ពាក្យ។ ប៉ុន្តែ និយមន័យទាំងនេះ មានលក្ខណៈរួមមួយ គឺនិយាយអំពីលក្ខណៈវិនិច្ឆ័យខ្លះដែលនាំឱ្យគេបែងចែកពាក្យនៅក្នុងភាសានានាជាក្រុមផ្សេងៗគ្នា។ លក្ខណៈវិនិច្ឆ័យទាំងនោះ មានលក្ខណៈន័យ ទម្រង់ និងសម្ព័ន្ធ។

## ៣. ប្រវត្តិនិងចំណែកចែកថ្នាក់ពាក្យ

ចាប់តាំងពីសម័យដែលមានការសិក្សាអំពីវេយ្យាករណ៍មក ពាក្យត្រូវគេចែកទៅតាមក្រុមផ្សេងៗគ្នាដែលគេច្រើនហៅថា "ថ្នាក់ពាក្យ"។ ការសិក្សាអំពីថ្នាក់ពាក្យកើតមានតាំងពីមុនគ្រិស្តសករាជមកម្ល៉េះ។

នៅប្រទេសឥណ្ឌាបុរាណ អ្នកវេយ្យាករណ៍សំស្រ្កឹតឈ្មោះ យាស្កៈ (Yāska) បានចែកថ្នាក់ពាក្យជា៤ប្រភេទនៅក្នុងគម្ពីរនិរុត្ត (Nirukta) តាំងពីសតវត្សទី៥ឬទី៦មុនគ.ស. ម្ល៉េះ។ ប្រភេទពាក្យទាំង៤នោះមាន នាម អាខ្យាត ឧបសគ្គ (សំ. ឧបសគ៌) និងនិបាត។

ចំណែកនៅក្រិកបុរាណវិញ មានក្រុមអ្នកវេយ្យាករណ៍ជាច្រើនបានគិតពីបញ្ហានេះដែរ។ នៅក្នុងស្នាដៃដែលមានចំណងជើងថា "Cratyle" ទស្សនវិទូប្លាតុង (៤២៨-៣៤៨មុន

គ.ស.) បានបែងចែកថ្នាក់ពាក្យជា២ប្រភេទ គឺនាម (rhēma) និងកិរិយាសព្ទ (ónoma) (ប៊ី សុខគង់, ២០០២)។ ប្លាតុងបានសរសេរក្នុងស្នាដៃនោះថា "...ខ្ញុំយល់ថា ល្បះគឺជាបន្សំនៃកិរិយាសព្ទនិងនាម (...sentences are, I conceive, a combination of verbs [rhēma] and nouns [ónoma])"។ លុះក្រោយមកសាវ័ករបស់គាត់ គឺអារីស្តូត (៣៨៤-៣២២មុនគ.ស.) បានចែកថ្នាក់ពាក្យជា៣ គឺនាម (rhēma) កិរិយាសព្ទ (ónoma) និងសន្ធាន (sýndesmos)។ លុះដល់ចុងសតវត្សទី២ នៃគ.ស. ទើបក្រុមអ្នកវេយ្យាករណ៍មួយក្រុមទៀតពង្រីកបំណែងចែកថ្នាក់ពាក្យរហូតដល់ទៅ៨ប្រភេទនៅក្នុងស្នាដៃមួយឈ្មោះថា"សិល្បៈនៃវេយ្យាករណ៍ (Tékhnē grammatiké) "។ ថ្នាក់ពាក្យទាំង៨យ៉ាងនោះរួមមាន នាម (rhēma) កិរិយាសព្ទ (ónoma) Participle (metokhḗ) Article (árthron) សព្វនាម (antōnymía) អាយតនិបាត (próthesis) កិរិយាវិសេសន៍ (epírrhēma) សន្ធាន (sýndesmos)។ នៅរវាងឆ្នាំ៥០០ នៃគ.ស. អ្នកវេយ្យាករណ៍ឡាតាំងម្នាក់ឈ្មោះ Priscian បានកែប្រែបំណែងចែកទាំង៨នេះ។ ដោយសារភាសាឡាតាំងគ្មាន Article ទើបគាត់គាត់ដកវាចេញ ហើយជំនួសទៅវិញដោយឧទានសព្ទ។

បំណែងចែកថ្នាក់ពាក្យនេះបានជះឥទ្ធិពលលើពិភពលោក ជាពិសេសលើភាសានានានៅតំបន់អឺរ៉ុប។ ជាតួយ៉ាង វេយ្យាករណ៍ទូទៅ "Port-Royale" ដែលក្រុមអ្នកនិពន្ធបារាំងបាននិពន្ធឡើងនៅក្នុងឆ្នាំ១៦៦០ ក៏បានទទួលឥទ្ធិពលពីវេយ្យាករណ៍ក្រិកនិងឡាតាំងដែរ។

ចំណែកនៅក្នុងភាសាខ្មែរសព្វថ្ងៃ យើងឃើញគេច្រើនបែងចែកថ្នាក់ពាក្យជា៨ប្រភេទ។ ថ្នាក់ពាក្យទាំងនោះមាន៖

-នាម (ន.)

-គុណនាម (គុ.)

-សព្វនាម (សព្វ.)

-កិរិយាសព្ទ (កិ.)

-គុណកិរិយា (គុ.កិ.) ឬកិរិយាវិសេសន៍ (កិ.វិ.)

-ធ្នាក់ (ធ.)

-ឈ្នាប់ (ឈ.)

-ឧទានសព្ទ (ឧ.)។

# មេរៀនទី៥
## នាម

### ១. និយមន័យ

ដោយផ្អែកលើគោលការណ៍រូប-សម្ពន្ធ័ យើងអាចផ្ដល់និយមន័យថា នាមជាពាក្យដែលក្នុងករណីខ្លះ មានរូបសាស្ត្រប្លែកពីរូបសាស្ត្រនៃពាក្យដទៃទៀត និងជាពាក្យដែលអាចបំពេញមុខងារជាប្រធានឬកម្មរងនៅក្នុងល្បះ។ នាមសព្ទជាធាតុចាំបាច់នៃកន្សោមនាម។

### ២. ប្រភេទរបស់នាម

យើងបានដឹងរួចមកហើយថា នាមត្រូវបានគេបែងចែកជាច្រើនប្រភេទខុសៗគ្នា។ មតិមួយចំនួនបានបែងចែកជា៨ប្រភេទ ខ្លះទៀតមាន៤ប្រភេទ ឯខ្លះទៀតមាន៥ប្រភេទ ប៉ុន្តែយើងអាចទាញយកលក្ខណៈសមស្របអាចទទួលព្រមនោះ គឺមាន៨ប្រភេទ៖

#### ២.១. នាមសាធារណ៍ឬសាធារណនាម

**នាមសាធារណ៍** គឺជានាមសំដែងឈ្មោះទូទៅមិនចំពោះ។

ឧ. *ពូខ្ញុំដឹកគោទៅឱ្យស៊ីស្មៅតាមភ្លឺស្រែ។*

ពាក្យ *ពូ គោ ស្មៅ ភ្លឺស្រែ* ជានាមសាធារណ៍។

នាមសាធារណ៍មាន៖

- នាមសាធារណ៍សម្គាល់មនុស្ស៖ *កសិករ កម្មករ ពលករ មា មីង បង ប្អូន*...។
- នាមសាធារណ៍សម្គាល់សត្វ៖ *គោ ក្របី ចាប*...។
- នាមសាធារណ៍សម្គាល់រុក្ខជាតិ៖ *ស្វាយ ល្ហុង ចេក*...។
- នាមសាធារណ៍សម្គាល់ទីកន្លែង៖ *សាលា ជនបទ សួន*...។
- នាមសាធារណ៍សម្គាល់វត្ថុ៖ *សៀវភៅ បន្ទាត់ ចប*...។

#### ២.២. នាមអសាធារណ៍ឬអសាធារណនាម

**នាមអសាធារណ៍** គឺជានាមសំដែងឈ្មោះប្រាកដ ចំពោះ មិនទូទៅ។

ឧ. *តាសុកនាំអាពាលទៅរកសត្វព្រៃភ្នំខ្សាច់ស។*

ពាក្យ *សុក ពាល ខ្សាច់ស* ជានាមអសាធារណ៍។

នាមអសាធារណ៍ក្នុងភាសាបរទេសដូចជាបារាំង អង់គ្លេសជាដើម អាចសម្គាល់

បានដោយសារពាក្យនោះផ្ដើមដោយអក្សរធំ។

-នាមអសាធារណ៍សម្គាល់សមនុស្ស៖ *សុក សំ ធីតា កញ្ញា...* ។

-នាមអសាធារណ៍សម្គាល់សត្វ៖ *អាញូង អាពាល អាចម្ប៉ា អាខ្មៅ...* ។

-នាមអសាធារណ៍សម្គាល់ទីកន្លែង៖ *កម្ពុជា ភ្នំពេញ វៀតណាម សូវៀត...*។

## ២.៣. នាមករណ៍ឬករណនាម

**នាមករណ៍** គឺជានាមសំដែងសភាពឬសកម្មភាព។ ករណនាមអាចចេញមកអំពីកិរិយាសព្ទនិងគុណនាម។ យើងអាចសម្គាល់បានដោយសារនាមករណ៍ទាំងនោះមានបន្ថែមពាក្យ *ការ សេចក្ដី* ឬ *វិធី*។

**នាមករណ៍កើតចេញពីកិរិយាសព្ទ៖**

| កិរិយាសព្ទ | នាមករណ៍ | កិរិយាសព្ទ | នាមករណ៍ |
|---|---|---|---|
| *សង្កេត* | *ការសង្កេត* | *អនុវត្ត* | *ការអនុវត្ត* |
| *អធិប្បាយ* | *ការអធិប្បាយ* | *អនុញ្ញាតិ* | *ការអនុញ្ញាត* |
| *ជោរ* | *ជំនោរ* | *ដើរ* | *ដំណើរ* |

**នាមករណ៍កើតចេញពីគុណនាម៖**

| គុណនាម | នាមករណ៍ | គុណនាម | នាមករណ៍ |
|---|---|---|---|
| *ឈ្លាសវៃ* | *ភាពឈ្លាសវៃ* | *ក្រាស់* | *កម្រាស់* |
| *ក្លាហាន* | *សេចក្ដីក្លាហាន* | *ខ្ពស់* | *កម្ពស់* |
| *ថ្លៃថ្នូរ* | *សេចក្ដីថ្លៃថ្នូរ* | *ទាប* | *ទំនាប* |
| *លំបាក* | *សេចក្ដីលំបាក* | *វែង* | *ប្រវែង* |

## ២.៤. នាមការក៍ឬការកនាម

**នាមការក៍** គឺជានាមសំដែងអ្នកធ្វើអំពើឬអ្នកមានសភាពលក្ខណៈបែបណាមួយ។ ការកនាមចេញពី៖

**នាមការក៍កើតចេញពីកិរិយាសព្ទ៖**

| កិរិយាសព្ទ | នាមការក៍ | កិរិយាសព្ទ | នាមការក៍ |
|---|---|---|---|
| *យាម* | *អ្នកយាម* | *ចាំ* | *ឆ្មាំ* |
| *ពោល* | *អ្នកពោល* | *ជួញ* | *ឈ្មួញ* |

| | | | |
|---|---|---|---|
| *ទិតៀន*<br>*សម្លាប់* | *អ្នកទិតៀន*<br>*អ្នកសម្លាប់* | *លួន*<br>*ដើរ* | *លួន*<br>*ថ្មើរ* |

**នាមការក៏កើតចេញពីគុណនាមៈ**

| គុណនាម | នាមការក៍ | គុណនាម | នាមការក៍ |
|---|---|---|---|
| *ធំ*<br>*មាន*<br>*តូច*<br>*ក្រ* | *អ្នកធំ*<br>*អ្នកមាន*<br>*អ្នកតូច*<br>*អ្នកក្រ* | *ពូកែ*<br>*ឧស្សាហ៍*<br>*ខ្លាំង*<br>*ខ្សត់* | *អ្នកពូកែ*<br>*អ្នកឧស្សាហ៍*<br>*អ្នកខ្លាំង*<br>*អ្នកខ្សត់* |

**នាមការក៍កើតចេញពីនាមៈ**

| នាម | នាមការក៍ | នាម | នាមការក៍ |
|---|---|---|---|
| *ក្រុង*<br>*ភូមិ*<br>*ស្រែ*<br>*ចម្ការ* | *អ្នកក្រុង*<br>*អ្នកភូមិ*<br>*អ្នកស្រែ*<br>*អ្នកចម្ការ* | *ជំងឺ*<br>*ចម្រៀង*<br>*ស្រុក*<br>*ទន្លេ* | *អ្នកជំងឺ*<br>*អ្នកចម្រៀង*<br>*អ្នកស្រុក*<br>*អ្នកទន្លេ* |

កំណត់សម្គាល់នាមការក៍បែបបាលី-សំស្រ្កឹតមានៈ

-*ករ* នៅខាងចុងៈ *ឧស្សាហាករ កីឡាករ ពាណិជ្ជករ កសិករ ពលករ*...។

-*ក* ឬ *ក៍* នៅខាងចុងៈ *ទាយក ជនក មគ្គុទេសក៍*...។

-*ឥក* នៅខាងចុងៈ *សមាជិក ទូរទស្សនិក ពុទ្ធសាសនិក*...។

-*ជន* នៅខាងចុងៈ *វរជន យុវជន សប្បុរសជន*...។

## ២.៥. នាមរូបី

**នាមរូបី** គឺជានាមសម្គាល់ឈ្មោះ មនុស្ស សត្វ វត្ថុ ឬទីកន្លែង ដែលមានរូបអាចមើលឃើញឬអាចស្គាល់ អាចដឹងដោយវិញ្ញាណទាំងប្រាំ។

ឧ. *មនុស្ស សៀវភៅ តុ ទូ ទន្លេ ផ្កែ*...។

## ២.៦. នាមអរូបី

**នាមអរូបី** គឺជានាមសម្គាល់អ្វីៗដែលគ្មានរូបរាងពិតប្រាកដ មើលមិនឃើញ ឬមិនអាចដឹងមិនអាចស្គាល់ដោយវិញ្ញាណទាំងប្រាំ។

ឧ. *ការរីកចម្រើន ចំណេះដឹង សេចក្តីស្រឡាញ់ ស្នេហា...។*

**២.៧. នាមជីវចល**

**នាមជីវចល** គឺជានាមសម្គាល់អ្វីៗដែលមានជីវិត អាចធ្វើចលនាដោយខ្លួនឯងតាមលក្ខណៈធម្មជាតិ។

ឧ. *កុមារ ម្តាយ ឪពុក ចង្រិត ទាហាន...។*

**២.៨. នាមអជីវចល**

**នាមអជីវចល** គឺជានាមសម្គាល់អ្វីៗដែលគ្មានជីវិត គ្មានវិញ្ញាណ មិនអាចធ្វើចលនាដោយខ្លួនឯងតាមលក្ខណៈធម្មជាតិ។

ឧ. *សាលា កៅអី កុំព្យូទ័រ តុ...។*

**៣. មុខងាររបស់នាម**

ពាក្យនៅក្នុងភាសាខ្មែរយើងពុំមានលក្ខណៈរូបរាងសម្រាប់សម្គាល់ថ្នាក់របស់វាឡើយ។ យើងអាចដឹងពាក្យមួយជានាម គុណនាម កិរិយាសព្ទ កិរិយាវិសេសន៍ ឬចំណងថ្នាក់បាន ទាល់តែយើងពិនិត្យមើលមុខងាររបស់ពាក្យនោះដែលគេយកទៅប្រើប្រាស់ជាមួយពាក្យដទៃនៅក្នុងឃ្លាឬនៅក្នុងល្បះផ្ទាល់តែម្តង។ នាមអាចមានមុខងារជា៖

**-ប្រធាននៃល្បះ៖** ឧ. ***សិស្ស*** *សរសេរមេរៀន។*

**-កម្មបទរបស់កិរិយាសព្ទ៖** ឧ. *កងវិស្វកម្មស្ថាបនា**ស្ពាន**។*

**-ឧបបទ៖** ឧបបទ គឺជានាមឬកន្សោមនាមដែលប្រើនៅខាងស្តាំនាមបង្គោល ហើយវាបង្ហាញពីឯកលក្ខណភាពរបស់នាមបង្គោលនោះ។ ឧ. *សៀមរាប **រាជធានីបុរាណរបស់ខ្មែរ** ជារមណីយដ្ឋានប្រវត្តិសាស្ត្រដ៏ល្បីល្បាញ។*

**-គុណប្រធាន៖** គុណប្រធាន គឺជានាមឬកន្សោមនាមដែលប្រើនៅខាងក្រោយកិរិយាសព្ទចំណង ហើយវាសំដែងពីគុណលក្ខណៈរបស់ប្រធាន។ ឧ. *សម្តេចសង្ឃជួនណាត ជា**បិតាអក្សរសាស្ត្រជាតិ**។*

**-គុណកម្មបទ៖** គុណកម្មបទ គឺជានាមឬកន្សោមនាមដែលប្រើនៅខាងក្រោយកម្មបទសម្រាប់ជួយបំពេញន័យបន្ថែមឱ្យកម្មបទ។ ឧ. *គេប្រសិទ្ធនាមសម្តេច នរោត្តមសីហនុ **ព្រះមហាវីរក្សត្រនិងវរបិតាជាតិខ្មែរ**។*

**-គុណនាម៖** ក្នុងភាសាខ្មែរ នាមពីរនៅជាប់គ្នា នាមទីមួយជានាមបង្គោល ហើយនាមទីពីរជាគុណនាម។ ឧ. *និស្សិត**សាកលវិទ្យាល័យឯកទេសនៃកម្ពុជា** ភាគច្រើនជាគ្រូបង្រៀន។*

**ចំណាំ:** សូមកុំភាន់ច្រឡំរវាងនាមដើរតួជាគុណនាមនិងនាមដើរតួជាឧបបទ។ នាមជាឧបបទ គឺជានាមដែលប្រើដើម្បីសំដែងឯកលក្ខណភាពរបស់នាមបង្គោល ផ្ទុយទៅវិញ ហើយគេអាចប្តូរទីតាំងនាមជាឧបបទនិងនាមបង្គោលបាន។

**-កម្មបទរបស់ធ្នាក់៖** នាមដែលប្រើនៅខាងក្រោយធ្នាក់ដើម្បីបង្កើតជាកន្សោមមានធ្នាក់ ជាកម្មបទរបស់ធ្នាក់នោះ។ ឧ. *សំនិយាយភាសាអង់គ្លេសជាមួយ**ជនជាតិអាមេរិក**។*

# មេរៀនទី៦
## សព្វនាម

**១. និយមន័យ**

សព្វនាម ជាពាក្យប្រើសម្រាប់ជំនួសនាមឬកន្សោមនាមដើម្បីជៀសវាងការប្រើពាក្យច្រំដែល។ នៅក្នុងល្បះ សព្វនាមបំពេញមុខងារដូចនាមឬកន្សោមនាមដែរ គឺវាអាចជាប្រធានឬកម្មបទរបស់កិរិយាសព្ទ។

**២. ប្រភេទរបស់សព្វនាម**

ក្នុងភាសាខ្មែរ សព្វនាមមាន៥ប្រភេទ គឺសព្វនាមបុរិស: សព្វនាមចង្អុល សព្វនាមសំណួរ សព្វនាមមិនច្បាស់ និងសព្វនាមឈ្នាប់។

**២.១. សព្វនាមបុរិស:**

បង្ហាញវត្ថុ ភាវរស់ដោយមានការសម្គាល់ពីបុរសផ្នែកវេយ្យាករណ៍ ដើម្បីប្រាប់ឱ្យដឹងអំពីអ្នកនិយាយ (ម្ចាស់សម្ដី) អ្នកដែលគេនិយាយទៅរកនិងអ្នកដែលគេលើកយកមកនិយាយ។

សព្វនាមបុរិស:មានបីបុរសះ

**-បុរសទី១ មាន** *ខ្ញុំ អញ អាត្មា គ្នា ...*។

**-បុរសទី២ មាន** *អ្នក លោក ឯង...*។

**-បុរសទី៣ មាន** *គេ វា គាត់ នាង...*។

ឧ. ***គាត់****ចូលចិត្តអានប្រលោមលោក។*

**២.២. សព្វនាមចង្អុល**

ប្រើសម្រាប់សម្គាល់វត្ថុ ភាវៈរស់ដែលគេចង្អុលបង្ហាញ និងប្រើសម្រាប់ជំនួសនាមសព្ទឬកន្សោមនាមដែលគេទើបនឹងបាននិយាយរួចមកហើយ ដោយមានបង្កប់នូវគំនិតចង្អុលទីតាំងជិតឬឆ្ងាយ។ សព្វនាមចង្អុលមានពីរគឺសម្រាប់ទីជិតមាន *នេះ អានេះ ទាំងនេះ ទាំងអស់នេះ...*។ សម្រាប់ទីឆ្ងាយមាននោះ *អានោះ ទាំងនោះ ទាំងអស់នោះ...*។

ឧ. ***នេះ****ជាវចនានុក្រមអង់គ្លេស។*

**២.៣. សព្វនាមសំណួរ**

ប្រើសម្រាប់សួរអំពីមនុស្ស សត្វ វត្ថុ ទីកន្លែង ឬពេលវេលា។ សព្វនាមសំណួរ

មាន *អ្វី ស្អី អី នរណាខ្លះ អ្វីខ្លះ...។*

*ឧ. **នរណាខ្លះ**និយាយជាមួយគាត់?*

**២.៤. សព្វនាមមិនច្បាស់**

ប្រើសម្រាប់បង្ហាញពីការលាក់ទុកព័ត៌មានមួយផ្នែកដែលគេពុំចង់ឬពុំអាចប្រាប់បាន។ សព្វនាមមិនច្បាស់មាន *ម្នាក់ៗ ច្រើនគ្នា ទាំងអស់ ខ្លះ...។*

*ឧ. **ម្នាក់ៗ**សុទ្ធតែចង់ឈ្នះចង់ចាញ់។*

**២.៥. សព្វនាមឈ្នាប់**

នៅក្នុងភាសាខ្មែរ យើងឃើញមានពាក្យតែមួយគត់ដែលចាត់ទុកថាជាសព្វនាមឈ្នាប់នោះ គឺពាក្យ **ដែល**។ សព្វនាមឈ្នាប់ «**ដែល**» ជំនួសនាមឬកន្សោមនាមដែលនៅខាងមុខជាប់វា ហើយបង្កើតឃ្លារណបដោយមានមុខងារផ្សេងៗនៅក្នុងល្បះ។

*ឧ. វត្ថុតាង**ដែល**ប៉ូលិសដកហូតបានមានកាំភ្លើងខ្លីអាកា៥៤។*

**៣. មុខងាររបស់សព្វនាម**

តាមការប្រើប្រាស់ សព្វនាម គឺជាពាក្យដែលប្រើសម្រាប់ជំនួសនាម ឬកន្សោមនាម ហើយវាមានមុខងារផ្សេងៗ នៅក្នុងល្បះ។ សព្វនាមអាចប្រើជា៖

-**ប្រធាននៃល្បះ៖** សព្វនាមដែលជាប្រធាននៃល្បះ ត្រូវស្ថិតនៅខាងឆ្វេង (ខាងដើម) ល្បះ។ ប្រធាននៃល្បះ គឺជាអ្នកធ្វើអំពើ។

*ឧ. សំមានបងប្អូនប្រាំនាក់។ **ពួកគេ**សុទ្ធតែនៅរៀនទាំងអស់។*

-**កម្មបទផ្ទាល់៖** កម្មបទ គឺពាក្យឬក្រុមពាក្យដែលគេដាក់បន្ថែមទៅលើកិរិយាសព្ទដើម្បីឱ្យឃ្លាឬល្បះ មានន័យគ្រប់គ្រាន់។ កម្មបទផ្ទាល់ គឺកម្មបទដែលស្ថិតនៅជាប់នឹងកិរិយាសព្ទដោយផ្ទាល់ មិនចាំបាច់មានឈ្នាប់ឬធ្នាក់ឡើយ ហើយឆ្លើយនឹងសំណួរ អ្វី អ្នកណា (ហ៊ាន សុខុម, ១៩៩៨)។

*ឧ. ពស់ខ្សែគោលូនចូលផ្ទះសុខា។ ឆ្កែសុខាខាំ**វា**ងាប់នៅក្រោមគ្រែ។*

-**កម្មបទមិនផ្ទាល់**៖ កម្មបទមិនផ្ទាល់ គឺជាកម្មបទដែលស្ថិតនៅជាប់ខាងស្តាំធ្នាក់ មិនរងអំពើផ្ទាល់ពីប្រធានទេ។

*ឧ. នីតាបានជួបគ្រូរបស់នាងដោយចៃដន្យ។ នាងបានញ៉ាំបាយជាមួយ**គាត់**។*

-**សព្វនាមឈ្នាប់ប្រើដើម្បីបង្កើតឃ្លារណប៖** សព្វនាមឈ្នាប់ជាពាក្យដែលប្រើសម្រាប់ជំនួសនាមឬកន្សោមនាម ហើយវាមានមុខងារបង្កើតជាឃ្លារណប។

*ឧ. គាត់ចូលចិត្តស្បែកជើងកីឡា**ដែល**ជាផលិតផលក្រុមហ៊ុន Asics។*

# មេរៀនទី៧
## គុណនាម

### ១. និយមន័យ

**គុណនាម** គឺជាថ្នាក់ពាក្យមួយប្រភេទដែលអាស្រ័យនឹងនាម ជាធាតុរណបរបស់នាម មានតួនាទីពណ៌នា បញ្ជាក់លក្ខណៈ និងកំណត់នាម ធ្វើឱ្យនាមនោះប្រាកដច្បាស់ឡើង (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ២. ប្រភេទគុណនាម

គុណនាមមានពីរប្រភេទធំៗ គឺ **គុណនាមប្រក្រតី** និង **គុណនាមកំណត់**។ ក្នុងនោះគុណនាមកំណត់ចែកជា៥ទៀត គឺ **គុណនាមចង្អុល គុណនាមកម្មសិទ្ធិ គុណនាមមិនច្បាស់ គុណនាមសំណួរ** និង **គុណនាមចំនួន**។

គុណនាមប្រក្រតីសម្រាប់បំពេញន័យរបស់នាម ឯគុណនាមកំណត់សម្រាប់កំណត់ន័យរបស់នាម (ក្រសួងអប់រំ, ១៩៨៣: ទំ.៨៥)។ នៅក្នុងភាសាអង់គ្លេសគេហៅថា Determiner ត្រូវនឹងបច្ចេកសព្ទក្នុងភាសាខ្មែរថាកំណត់។ កំណត់ក្នុងភាសាអង់គ្លេសមានមុខងារដូចជាគុណនាមប្រាប់យើងថាមួយណា? ប៉ុន្មាន? របស់នរណា? (Dayne Sherman, Jayetta Slawson, Natasha Whitton, and Jeff Wiemelt, 2010:315-326)។

### ២.១. គុណនាមប្រក្រតី

**គុណនាមប្រក្រតី** គឺជាគុណនាមមួយប្រភេទដែលមានទីតាំងនៅជាប់ខាងស្ដាំនាមឬខាងស្ដាំពាក្យ "ដ៏"។ វាមានតួនាទីបញ្ជាក់ឬពណ៌នាសភាពលក្ខណៈរបស់នាម (គុណភាព ទំហំ សភាព...)។ គុណនាមប្រក្រតីជាធាតុរណបឱ្យនាម។ វាមិនអាចឈរតែឯងបាននៅក្នុងល្បះ។ គុណនាមប្រក្រតីត្រូវបានប្រើដើម្បីឆ្លើយតបទៅនឹងសំណួរថា តើអ្វីមួយមានលក្ខណៈយ៉ាងដូចម្ដេច (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ២.២. គុណនាមកំណត់

គុណនាមកំណត់ចែកជា៥ គឺ **គុណនាមចង្អុល គុណនាមចំនួន គុណនាមកម្មសិទ្ធិ គុណនាមសំណួរ** និង **គុណនាមមិនច្បាស់**។

**២.២.១. គុណនាមចង្អុល**

**គុណនាមចង្អុល** គឺជាគុណនាមមួយប្រភេទដែលមានតួនាទីចង្អុលបង្ហាញឬកំណត់នាមណាមួយកាន់តែជាក់លាក់ឡើង។ គុណនាមចង្អុលមានដូចជា *នេះ នោះ ហ្នឹង ហ្នុង ប៉ុណ្ណេះ ប៉ុណ្ណោះ ប៉ុណ្ណឹង ទាំងនេះ ទាំងនោះ*។ *នេះ ប៉ុណ្ណេះ ប៉ុណ្ណឹង ទាំងនេះ* ប្រើសម្រាប់ចង្អុលទីជិត រីឯ *នោះ ប៉ុណ្ណោះ ទាំងនោះ* ប្រើសម្រាប់ចង្អុលទីឆ្ងាយ (រ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

**២.២.២. គុណនាមចំនួន**

**គុណនាមចំនួន** គឺជាគុណនាមមួយប្រភេទដែលមានតួនាទីកំណត់ចំនួនឬបរិមាណនាមនិងកំណត់លំដាប់នាម។ គុណនាមចំនួនមានដូចជា *មួយ ពីរ បី បួន ទីមួយ ទីពីរ ទីបី ទីបួន*...។

គេអាចចែកគុណនាមចំនួនជាពីរ គឺចំនួនរាប់និងចំនួនរៀប។

**-ចំនួនរាប់៖** ប្រើសម្រាប់បញ្ជាក់ចំនួនឯកតាឬបរិមាណរបស់មនុស្ស សត្វ ឬវត្ថុ។ ឧ. *សៀវភៅបីក្បាល ផ្ទះពីរខ្នង ដូងបួនដើម... បី ពីរ បួន* ជាចំនួនរាប់។

**-ចំនួនរៀប៖** ប្រើសម្រាប់រាប់ឱ្យដឹងពីជាន់ ថ្នាក់ ប៉ុណ្ណេះប៉ុណ្ណោះ។ ឧ. *ថ្នាក់ទី១ ទំព័រទី៥ ភាគទី៨ សិស្សលេខ២ ខែទី១០... ទី១ ទី៥ ទី៨ លេខ២ ទី១០* ជាចំនួនរៀប (រ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

**២.២.៣. គុណនាមកម្មសិទ្ធិ**

**គុណនាមកម្មសិទ្ធិ** គឺជាគុណនាមមួយប្រភេទដែលត្រូវបានប្រើសម្រាប់កំណត់ម្ចាស់កម្មសិទ្ធិរបស់មនុស្ស សត្វ វត្ថុ រុក្ខជាតិ។ គុណនាមកម្មសិទ្ធិសម្រាប់ឆ្លើយតបនឹងសំណួរថា តើមនុស្ស សត្វ វត្ថុ រុក្ខជាតិនោះជារបស់នរណា។ គុណនាមកម្មសិទ្ធិមានដូចជា *ខ្ញុំ វា គាត់ គេ អញ នាង យើង ឯងទាំងអស់គ្នា គេទាំងអស់គ្នា*... (រ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

**២.២.៤. គុណនាមសំណួរ**

**គុណនាមសំណួរ** គឺជាគុណនាមមួយប្រភេទសម្រាប់កំណត់សួរឱ្យនាមនៅក្នុងល្បះសំណួរ។ គុណនាមសំណួរមានដូចជា *ប៉ុន្មាន អ្វី ណាមួយ អ្វីខ្លះ ណា*... (រ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

**២.២.៥. គុណនាមមិនច្បាស់**

**គុណនាមមិនច្បាស់** គឺជាគុណនាមមួយប្រភេទដែលមានតួនាទីកំណត់ឱ្យនាមមនុស្ស សត្វ វត្ថុ រុក្ខជាតិ... តែពុំមានលក្ខណៈច្បាស់លាស់ឡើយ។ គុណនាមមិនច្បាស់

មានដូចជា *ទាំងអស់ ផ្សេងៗ ខ្លះ*... (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ៣. ទម្រង់គុណនាម

**ទម្រង់គុណនាមឬរូបរាងគុណនាម** សំដៅទៅលើលក្ខណៈរូបសាស្ត្រនៃគុណនាម។ គេចែកគុណនាមជាច្រើនថ្នាក់តាមរូបរាងរបស់វា ដូចជាគុណនាមកំណើត គុណនាមក្លាយ គុណនាមផ្សំ (ក្រសួងអប់រំ, ១៩៨៣)។

#### ៣.១. គុណនាមកំណើត

**គុណនាមកំណើត** គឺជាគុណនាមដែលគេមិនទាន់យកទៅកម្លាយដោយផ្នត់ឬផ្សំជាមួយធាតុដទៃទៀត។ គុណនាមកំណើតមានដូចជា *លឿង បៃតង ខៀវ ជូរ*...។

#### ៣.២. គុណនាមកម្លាយ

**គុណនាមកម្លាយ** គឺជាគុណនាមដែលកើតឡើងតាមវិធីកម្លាយដោយផ្នត់ដើមឬផ្នត់ដែក។ គុណនាមក្លាយមានដូចជា *កំពៀច កញ្ចាស់ កម្ទិល កំភូត*...។

#### ៣.៣. គុណនាមផ្សំ

**គុណនាមផ្សំ** គឺជាគុណនាមដែលកើតឡើងតាមវិធីបន្សំ។ គុណនាមផ្សំមានដូចជា *តូចតាច បន្តិចបន្តួច កម្សត់កម្រ*... (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ៤. កម្រិតគុណនាម

កម្រិតគុណនាមមានបីយ៉ាង គឺ **កម្រិតវិជ្ជមាន កម្រិតទាក់ទង** និង **កម្រិតដាច់ខាត** (ក្រសួងអប់រំ, ១៩៨៣)។ ទោះបីគុណនាមនៅក្នុងភាសាខ្មែរពុំមានផ្លាស់ប្តូររូបរាងទៅតាមកម្រិត (*តូច តូចជាង តូចបំផុត តូចណាស់*) ដូចគុណនាមក្នុងភាសាអង់គ្លេសក៏ដោយ (big bigger biggest) ក៏គេអាចកំណត់កម្រិតបានដោយប្រើគុណកិរិយាកម្រិត (*ជាង បំផុត ណាស់*...) ដើម្បីបញ្ជាក់បាន។

#### ៤.១. កម្រិតវិជ្ជមាន

ការសម្តែងគុណភាពមនុស្ស សត្វ ឬវត្ថុ ដែលកើតឡើងដោយសារតែការប្រើគុណនាមប្រក្រតីតែឯងប៉ុណ្ណោះ គឺជាកម្រិតវិជ្ជមាន (នៃការសម្តែងគុណភាព)។ **កម្រិតវិជ្ជមាន** នៅទីនេះសំដៅទៅលើកម្រិតធម្មតាដែលពុំមានការប្រៀបធៀប ពុំមែនសំដៅលើកម្រិតល្អឡើយ។ វាខុសពីបច្ចេកសព្ទ **ន័យវិជ្ជមាន** ដែលសំដៅលើន័យដែលល្អ។

ឧ. *សុកជាសិស្សសុភាពរាបសារ។*
*សៅជាកសិករស្លូតត្រង់។*

*សានជាកម្មករជំនាញ។*

*សុភាពរាបសារ ស្លូតត្រង់ ជំនាញ* ជាគុណនាមកម្រិតវិជ្ជមាន។

### ៤.២. កម្រិតទាក់ទងឬទំហៀប

ការសម្ដែងគុណភាពអាចកើតឡើងដោយការដាក់ឱ្យទាក់ទងគ្នារវាងមនុស្សម្នាក់ (សត្វឬវត្ថុមួយ) និងម្នាក់ទៀត (មួយទៀត) លើកម្រិតប្រពលភាពនៃគុណភាព គឺជាកម្រិតទាក់ទង (នៃការសម្ដែងគុណភាព) ឬទំហៀប។

ឧ. *សុកជាសិស្សសុភាពជាងសំ។*

*ម៉ុកជាកសិករស្លូតត្រង់ដូចម៉ី។*

*មៀនជាកម្មករជំនាញជាងគេ។*

*សុភាពជាង ស្លូតត្រង់ដូច* និង *ជំនាញជាងគេ* ជាគុណនាមកម្រិតទាក់ទងឬគុណ-នាមទំហៀប។ គុណនាមទំហៀបមានពីរយ៉ាង គឺទំហៀបផ្ទឹមនិងទំហៀបផ្ដាច់។

### ៤.៣. កម្រិតដាច់ខាតឬគ្មានទំហៀប

គេប្រើគុណកិរិយា *ណាស់* សម្រាប់សម្ដែងកម្រិតខ្ពស់ណាស់នៃគុណភាព។ កម្រិតបែបនេះហៅថាកម្រិតបណ្ដាច់ឬបណ្ដាច់។

ឧ. *សុកជាសិស្សពូកែណាស់។*

*សៅជាកីឡាករស្ទិតស្ទាញណាស់។*

*ពូកែណាស់ ស្ទិតស្ទាញណាស់* ជាគុណនាមកម្រិតដាច់ខាត។

## ៥. លំដាប់គុណនាមនៅក្នុងកន្សោមនាម

នាមមួយអាចមានគុណនាមច្រើនសម្រាប់បញ្ជាក់។ តាមពិតទៅគ្មានការកំណត់ចំនួនគុណនាមដែលអាចបញ្ជាក់ឱ្យនាមមួយឡើយ (Evelyn P.Altenberg & Robert M.Vago, 2010:58)។ នៅពេលមានគុណនាមពីរឬច្រើននៅបន្ទាប់ពីនាម គុណនាមទាំងនោះត្រូវស្ថិតនៅទីតាំងទៅតាមលំដាប់លំដោយយ៉ាងល្អ ដែលលំដាប់នេះអាស្រ័យលើន័យជាសំខាន់ (John Eastwood, 2002:257)។ នៅក្នុងភាសាអង់គ្លេសគុណនាមមានន័យសម្គាល់ការយល់ឃើញ ទំហំ គុណភាព អាយុ រូបរាង ពណ៌ ប្រភព ប្រភេទវត្ថុធាតុដើម និងគោលបំណងជាដើម (John Eastwood, 2002:256)។ ចំណែកនៅក្នុងភាសាខ្មែរគុណនាមមានន័យសម្គាល់គុណភាព ពណ៌ ទំហំ អាយុ ទ្រង់ទ្រាយ... (អ៊ុក វិបុល, ២០០១: ទំ.១៧)។

សូមពិនិត្យមើលឧទាហរណ៍ខាងក្រោមៈ

*ឧ. ភ្នំខ្ពស់នេះឈ្មោះភ្នំបូកគោ។*

នៅក្នុងកន្សោមនាម *ភ្នំខ្ពស់នេះ* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមប្រក្រតី + គុណនាមចង្អុល**

*ឧ. ប៊ិកខ្ញុំមួយដើមនេះទិញនៅបណ្ណាគារអន្តរជាតិ។*

នៅក្នុងកន្សោមនាម *ប៊ិកខ្ញុំមួយដើមនេះ* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមកម្មសិទ្ធិ + គុណនាមចំនួន + វនាប់ + គុណនាមចង្អុល**

*ឧ. ផ្ទះធំគាត់មួយខ្នងនេះសង់អស់លុយច្រើនណាស់។*

នៅក្នុងកន្សោមនាម *ផ្ទះធំគាត់មួយខ្នងនេះ* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមប្រក្រតី + គុណនាមកម្មសិទ្ធិ + គុណនាមចំនួន + វនាប់ + គុណនាមចង្អុល**

*ឧ. ផ្លូវដ៏វែងមួយខ្សែនេះមានប្រវែង៥០០គីឡូម៉ែត្រ។*

នៅក្នុងកន្សោមនាម *ផ្លូវដ៏វែងមួយខ្សែនេះ* លំដាប់គុណនាម គឺៈ

**-នាម + កន្សោមគុណនាម + គុណនាមចំនួន + វនាប់ + គុណនាមចង្អុល**

*ឧ. ចេកទុំល្អណាស់មួយស្និតនេះទុកធ្វើបង្អែម។*

នៅក្នុងកន្សោមនាម *ចេកទុំល្អណាស់មួយស្និតនេះ* លំដាប់គុណនាម គឺៈ

**-នាម + កន្សោមគុណនាម + គុណនាមចំនួន + វនាប់ + គុណនាមចង្អុល**

*ឧ. សិស្សខ្ញុំទាំងអស់នេះសុទ្ធតែមកពីខេត្តកណ្ដាល។*

នៅក្នុងកន្សោមនាម *សិស្សខ្ញុំទាំងអស់នេះ* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមកម្មសិទ្ធិ + គុណនាមមិនច្បាស់ + គុណនាមចង្អុល**

*ឧ. តើសៀវភៅណាខ្លះបោះពុម្ពនៅរោងពុម្ពពន្លឺខ្មែរ?*

នៅក្នុងកន្សោមនាម *សៀវភៅណាខ្លះ* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមសំណួរ**

*ឧ. តើប្អូនចង់បានអាវក្រហមមួយណា?*

នៅក្នុងកន្សោមនាម *អាវក្រហមមួយណា* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមប្រក្រតី + គុណនាមសំណួរ**

*ឧ. តើអគារខ្ពស់ប៉ុន្មានដែលសាងសង់ដោយក្រុមហ៊ុនចិន?*

នៅក្នុងកន្សោមនាម *អគារខ្ពស់ប៉ុន្មាន* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមប្រក្រតី + គុណនាមសំណួរ**

*ឧ. តើសម្ដីបងចង់សំដៅដល់មនុស្សទាំងឡាយណា?*

នៅក្នុងកន្សោមនាម *មនុស្សទាំងឡាយណា* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមមិនច្បាស់ + គុណនាមសំណួរ**

*ឧ. តើផ្ទះខ្ញុំមួយណាដែលប្អូនកំពុងនិយាយ?*

នៅក្នុងកន្សោមនាម *ផ្ទះខ្ញុំមួយណា* លំដាប់គុណនាម គឺៈ

**-នាម + គុណនាមកម្មសិទ្ធិ + គុណនាមសំណួរ**

ផ្អែកលើបណ្ដាឧទាហរណ៍ខាងលើ យើងអាចកំណត់លំដាប់គុណនាមនៅក្នុងកន្សោមនាមបានដូចខាងក្រោមៈ

| លំដាប់ទី១ | លំដាប់ទី២ | លំដាប់ទី៣ | លំដាប់ទី៤ | លំដាប់ទី៥ |
|---|---|---|---|---|
| **គុ.ប្រក្រតី** | **គុ.កម្មសិទ្ធិ** | **គុ.មិនច្បាស់** | **គុ.ចំនួន** | **គុ.ចង្អុល/គុ.សំណួរ** |

លំដាប់គុណនាមនេះ ខ្លះគេអាចផ្លាស់ប្ដូរបានអាស្រ័យលើន័យផ្ដោតក្នុងល្បះ ឯខ្លះទៀតមិនអាចផ្លាសប្ដូរបានទេ។ បើមិនដូច្នោះទេ នឹងធ្វើឱ្យគុណនាមផ្លាស់ប្ដូរមុខងារនៅក្នុងកន្សោមពាក្យ។

## ៦. សម្ព័ន្ធគុណនាម

សម្ព័ន្ធគុណនាមត្រូវបានសិក្សាដោយផ្ដោតទៅលើទីតាំង តួនាទី និងមុខងាររបស់គុណនាមតាមរយៈល្បះ។

### ទីតាំងគុណនាម

នៅក្នុងល្បះខ្មែរ គុណនាមអាចមានទីតាំងដូចខាងក្រោម (ក្រសួងអប់រំ, ១៩៨៣: ៨៨)ៈ

-នៅខាងស្ដាំជាប់នឹងនាមៈ *មនុស្សបដិវត្តមិនងាយរកបានទេ។*

-គុណនាមអាចនៅដាច់ពីនាមបន្តិចៈ *វាលស្រែប្រែជាខៀវស្រងាត់។*

### តួនាទីគុណនាម

គុណនាមប្រក្រតីជាធាតុសំណង់មិនចាំបាច់នៃកន្សោមនាមឬជាធាតុសំណង់នៃកន្សោមកិរិយាដែលក្នុងនោះមានជំនួយ (កិរិយា) *ហាក់ដូចជា ប្រែជា ក្លាយជា ឡើងជា ទៅជា* -ល- និងគុណនាម (ក្រសួងអប់រំ, ១៩៨៣:៨៨)។ គុណនាមប្រក្រតីបំពេញន័យរបស់នាម។ ឯគុណនាមកំណត់សម្រាប់កំណត់ន័យរបស់នាម។

### មុខងារគុណនាម

អាស្រ័យលើទីតាំងនៅក្នុងល្បះ គុណនាមអាចមានមុខងារដូចខាងក្រោម (ក្រសួងអប់រំ, ១៩៨៣:៨៥) ៖

-កាលណាគុណនាមប្រក្រតីជាធាតុសំណង់មួយនៃកន្សោមនាម វាមានមុខងារជាគុណបទ៖

ឧ. *កណ្តុរតូចៗក៏ដូចកណ្តុរធំៗដែរ សុទ្ធតែជាសត្វចង្រៃចំពោះយើង។*

-កាលណាគុណនាមប្រក្រតីនៅក្នុងកន្សោមកិរិយាដែលមានកិរិយា *ហាក់ដូចជា ក្លាយជា...* វាជាធាតុសំខាន់នៃកន្សោមកិរិយា៖

ឧ. *វាលស្រែប្រែក្លាយជាខៀវស្រងាត់។*

-គុណនាមខ្លះអាចប្រើជាគុណកិរិយា៖

ឧ. *យុវនារីនេះមានរាងខ្ពស់ស្រឡះ។*

-ខ្លះអាចប្រើជាកិរិយាសព្ទបង្គោលនៃល្បះ។ គុណនាមបែបនេះឈ្មោះថាគុណ-នាមកិរិយា៖

ឧ. *តុនេះស្អាតណាស់។*

យោងលើបណ្តាឧទាហរណ៍ខាងលើ ដោយផ្អែកលើទីតាំងនិងតួនាទីនៅក្នុងល្បះ គុណនាមអាចមានមុខងារជាគុណបទ គុណកិរិយា និងកិរិយា។

សូមពិនិត្យមើលការសិក្សាវិភាគលម្អិតទៅលើសម្ព័ន្ធគុណនាមទៅតាមប្រភេទនីមួយៗដូចខាងក្រោម៖

### ៦.១. សម្ព័ន្ធគុណនាមប្រក្រតី

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ.*កម្ពុជាបានប្រកាសពីការរកមិនឃើញនូវករណីថ្មីនៃការឆ្លងវីរុសកូវីដណាឡើយ។*

*ថ្មី* មានទីតាំងនៅជាប់ខាងស្តាំនាម *ករណី* វាមានតួនាទីបញ្ជាក់ន័យឱ្យនាម *ករណី* កាន់តែច្បាស់លាស់ឡើង។ គុណនាមប្រក្រតី *ថ្មី* មានមុខងារជា **គុណបទ**។

ឧ. *ក្នុងនាមជាមេដឹកនាំដ៏ល្អ ត្រូវយល់ច្បាស់ពីបញ្ហាត្រូវប្រឈម។*

*ល្អ* មានទីតាំងនៅជាប់ខាងស្តាំពាក្យ *ដ៏* វាមានតួនាទីបញ្ជាក់ន័យឱ្យនាម *មេដឹកនាំ* កាន់តែច្បាស់លាស់ឡើង។ ការបន្ថែម *ដ៏* ទៅលើគុណនាមប្រក្រតី *ល្អ* បានជា *ដ៏ល្អ* ដើម្បីបញ្ជាក់ឱ្យឃើញលក្ខណៈវិសេសឡើងប្លែកឡើងជាងធម្មតាប៉ុណ្ណោះ។ គុណនាមប្រក្រតី *ល្អ* មានមុខងារជា **គុណបទ**។

ឧ. *អគារខ្ពស់ នេះជាសណ្ឋាគារ។*

*ខ្ពស់* មានទីតាំងនៅចន្លោះនាម *អគារ* និងគុណនាមចង្អុល *នេះ*។ វាមានតួនាទីបញ្ជាក់ន័យឱ្យនាម *អគារ* កាន់តែច្បាស់លាស់ឡើង។ គុណនាមប្រក្រតីមានមុខងារជា **គុណបទ** (Attributive adjective)។

ឧ. *មេឃប្រែជាងងឹត ។*

*ងងឹត* មានទីតាំងនៅជាប់ខាងស្តាំកិរិយាចំណង *ប្រែជា*។ វាមានតួនាទីបញ្ជាក់លក្ខណៈឱ្យនាមប្រធាន *មេឃ*។ គុណនាមប្រក្រតី *ងងឹត* មានមុខងារជា **គុណប្រធាន** (Predicative adjective)។

-គុណនាមប្រក្រតីមានមុខងារជាគុណប្រធាន កាលណាវាមានទីតាំងនៅជាប់ខាងស្តាំក្រុមកិរិយាសព្ទចំណង *ដូចជា ហាក់ដូចជា ប្រែជា ឡើងជា ទៅជា ក្លាយជា* ...។

-គុណនាមមួយចំនួនអាចប្រើជាស្នូលនៃល្បះ។ គុណនាមបែបនេះហៅថាគុណ-នាមកិរិយា។

ឧ. *កុមារីនេះល្អ។ ផ្ទះនេះធំ។ កម្ពុជាតូចហើយក្រីក្រ ប៉ុន្តែចិត្តមិនក្រទេ។ ល្អ ធំ តូច ក្រីក្រ ក្រ* ជាគុណនាមកិរិយា។

យោងតាមការវិភាគបណ្តាឧទាហរណ៍ខាងលើ យើងដឹងថា៖

-គុណនាមប្រក្រតីមានទីតាំងនៅខាងស្តាំជាប់នាម ខាងស្តាំជាប់ពាក្យ *ដ៏* នៅចន្លោះនាមនិងកំណត់ និងនៅខាងស្តាំជាប់ក្រុមកិរិយាសព្ទចំណង។

-គុណនាមប្រក្រតីមានតួនាទីបញ្ជាក់ន័យឬពណ៌នាសភាពលក្ខណៈរបស់នាម។

-គុណនាមប្រក្រតីមានមុខងារជាគុណបទ គុណប្រធាន និងកិរិយាបង្គោល។

### ៦.២. សម្ព័ន្ធគុណនាមចង្អុល

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *យើងការពារទិន្នន័យនេះ។*

- *នេះ* មានទីតាំងនៅជាប់ខាងស្តាំនាម *ទិន្នន័យ*។ វាមានតួនាទីកំណត់នាម *ទិន្នន័យ* ឱ្យកាន់តែច្បាស់លាស់ឡើង។ *នេះ* នៅក្នុងល្បះនេះមានមុខងារជាកំណត់។

ឧ. *ខ្ញុំត្រូវការកុំព្យូទ័រមួយនោះ។*

- *នោះ* មានទីតាំងនៅជាប់ខាងស្តាំគុណនាមចំនួន *មួយ*។ វាមានតួនាទីកំណត់នាម *កំព្យូទ័រមួយ* ឱ្យកាន់តែច្បាស់លាស់ឡើង។ *នោះ* នៅក្នុងល្បះនេះមានមុខងារជាកំណត់។

ឧ. *ក្មេងហ្នឹងឧស្សាហ៍ណាស់។*

-*ហ្នឹង* មានទីតាំងនៅចន្លោះនាម *ក្មេង* និងគុណនាមប្រក្រតី *ឧស្សាហ៍*។ វាមានតួនាទីកំណត់នាម *ក្មេង* ឱ្យកាន់តែច្បាស់លាស់ឡើង។ *ហ្នឹង* នៅក្នុងល្បះនេះមានមុខងារជាកំណត់។

ឧ. *តុធំនេះធ្វើពីឈើបេង។*

- *នេះ* មានទីតាំងនៅជាប់ខាងស្តាំគុណនាមប្រក្រតី *ធំ*។ វាមានតួនាទីកំណត់នាម *តុធំ* ឱ្យកាន់តែច្បាស់លាស់ឡើង។ *នេះ* នៅក្នុងល្បះនេះមានមុខងារជាកំណត់។

ឧ. *រឿងរ៉ាវទាំងឡាយនេះបង្កឡើងដោយក្រុមគាត់។*

- *នេះ* មានទីតាំងនៅជាប់ខាងស្តាំគុណនាមមិនច្បាស់ *ទាំងឡាយ*។ វាមានតួនាទីកំណត់នាម *រឿងរ៉ាវទាំងឡាយ* ឱ្យកាន់តែជាក់លាក់។ *នេះ* នៅក្នុងល្បះនេះមានមុខងារជាកំណត់។

ឧ. *ផ្កាមួយបាច់នេះ ខ្ញុំទិញជូននាង។*

- *នេះ* មានទីតាំងនៅជាប់ខាងស្តាំនាមរនាប់ *បាច់*។ វាមានតួនាទីកំណត់នាម *ផ្កាមួយបាច់* ឱ្យកាន់តែច្បាស់លាស់ឡើង។ វាមានមុខងារជាកំណត់។

ដូចនេះ គុណនាមចង្អុលមានទីតាំងស្ថិតនៅខាងស្តាំជាប់នាម ខាងស្តាំជាប់គុណនាមចំនួន ខាងស្តាំជាប់គុណនាមប្រក្រតី ខាងស្តាំជាប់គុណនាមមិនច្បាស់ និងខាងស្តាំជាប់នាមរនាប់។ វាមានតួនាទីតែមួយគត់ គឺកំណត់ចង្អុលនាមឱ្យជាក់លាក់។ វាមានមុខងារជាកំណត់នៅក្នុងកន្សោមនាមនៃល្បះ។ គុណនាមចង្អុលឬកំណត់ចង្អុលនៅខាងចុងបំផុតនៃកន្សោមនាម។

### ៦.៣. សម្ព័ន្ធគុណនាមចំនួន

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោមៈ

ឧ. *ផ្លូវមួយខ្សែនេះកសាងដោយក្រុមហ៊ុនចិន។*

- *មួយ* មានទីតាំងនៅខាងស្តាំជាប់នាម *ផ្លូវ*។ វាមានតួនាទីកំណត់នាម *ផ្លូវ* ឱ្យដឹងពីចំនួន។ វាមានមុខងារជាកំណត់នៅក្នុងកន្សោមនាម។

ឧ. *ខ្ញុំអង្គុយក្រោមដើមឈើធំមួយនេះ។*

- *មួយ* មានទីតាំងនៅខាងស្តាំជាប់គុណនាមប្រក្រតី *ធំ*។ វាមានតួនាទីកំណត់នាម *ដើមឈើធំ* ឱ្យដឹងពីចំនួន។ វាមានមុខងារជាកំណត់នៅក្នុងកន្សោមនាម។

ឧ. *កុំព្យូទ័រខ្ញុំមួយគ្រឿងនេះទើបទិញពីខែមុន។*

- *មួយ* មានទីតាំងនៅខាងស្តាំជាប់គុណនាមកម្មសិទ្ធិ *ខ្ញុំ*។ វាមានតួនាទីកំណត់

នាម *កុំព្យូទ័រខ្ញុំ* ឱ្យដឹងពីចំនួន។ វាមានមុខងារជាកំណត់នៅក្នុងកន្សោមនាម។

ដូចនេះ គុណនាមចំនួនមានទីតាំងនៅជាប់ខាងស្ដាំនាម ជាប់ខាងស្ដាំគុណនាមប្រក្រតី និងជាប់ខាងស្ដាំគុណនាមកម្មសិទ្ធិ។ វាមានតួនាទីកំណត់បរិមាណឬលំដាប់នាម។ គុណនាមចំនួនមានមុខងារជាកំណត់នៅក្នុងកន្សោមនាមនៃល្បះ។

**៦.៤. សម្ព័ន្ធគុណនាមកម្មសិទ្ធិ**

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *គោវាបាត់ពីម្សិលមិញ។*

- *វា* មានទីតាំងនៅជាប់ខាងស្ដាំនាម *គោ*។ វាមានតួនាទីកំណត់កម្មសិទ្ធិនាម *គោ*។ គុណនាមកម្មសិទ្ធិ *វា* មានមុខងារជាកំណត់នៅក្នុងកន្សោមនាម *គោវា*។

ឧ. *ឡានថ្មីខ្ញុំទុកនៅផ្ទះ។*

- *ខ្ញុំ* មានទីតាំងនៅជាប់ខាងស្ដាំគុណនាមប្រក្រតី *ថ្មី*។ វាមានតួនាទីកំណត់កម្មសិទ្ធិនាម *ឡានថ្មី*។ គុណនាមកម្មសិទ្ធិ *ខ្ញុំ* មានមុខងារជាកំណត់នៅក្នុងកន្សោមនាម *ឡានថ្មីខ្ញុំ*។

ដូចនេះ គុណនាមកម្មសិទ្ធិមានទីតាំងនៅជាប់ខាងស្ដាំនាមនិងជាប់ខាងស្ដាំគុណនាមប្រក្រតី។ គុណនាមកម្មសិទ្ធិមានតួនាទីកំណត់កម្មសិទ្ធិជាក់លាក់ឱ្យនាម។ វាមានមុខងារជាកំណត់នៅក្នុងកន្សោមនាមនៃល្បះ។

**៦.៥. សម្ព័ន្ធគុណនាមសំណួរ**

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *តើអ្នកចង់ញ៉ាំម្ហូបអ្វីខ្លះ?*

-*អ្វីខ្លះ* មានទីតាំងនៅខាងចុងល្បះសំណួរនិងនៅជាប់ខាងស្ដាំនាម *ម្ហូប*។ វាមានតួនាទីកំណត់សួរទៅលើនាម *ម្ហូប*។ គុណនាមសំណួរ *អ្វីខ្លះ* មានមុខងារជាកំណត់នៅក្នុងកន្សោមនាម។

ឧ. *តើលោកស្នាក់នៅអគារខ្ពស់ណាមួយ?*

-*ណាមួយ* មានទីតាំងនៅខាងចុងល្បះសំណួរនិងនៅជាប់ខាងស្ដាំគុណនាមប្រក្រតី *ខ្ពស់*។ វាមានតួនាទីកំណត់សួរទៅលើនាម *អគារខ្ពស់*។ គុណនាមសំណួរ *ណាមួយ* មានមុខងារជាកំណត់នៅក្នុងកន្សោមនាម។

ឧ. *តើស្រីស្អាតម្នាក់ណាដែលតែងឋិតក្នុងដួងចិត្តអ្នក?*

-*ណា* មានទីតាំងនៅជាប់ខាងស្ដាំគុណនាមមិនច្បាស់ *ម្នាក់*។ វាមានតួនាទីកំណត់

សួរទៅលើនាម *ស្រីស្អាតម្នាក់*។ គុណនាមសំណួរ *ណា* មានមុខងារជាកំណត់នៅក្នុងកន្សោមនាម។

ឧ. *តើតារាចម្រៀងមួយរូបណាដែលប្រិយមិត្តថាស្អាតជាងគេ?*

-*ណា* មានទីតាំងនៅជាប់ខាងស្តាំរនាប់ *រូប*។ វាមានតួនាទីកំណត់សួរទៅលើនាម *តារាចម្រៀងមួយរូប*។ គុណនាមសំណួរ *ណា* មានមុខងារជាកំណត់នៅក្នុងកន្សោមនាម។ ដូចនេះ គុណនាមសំណួរមានទីតាំងនៅជាប់ខាងស្តាំនាម គុណនាមប្រក្រតី គុណនាមមិនច្បាស់ និងរនាប់។ វាមានតួនាទីកំណត់សួរទៅលើនាមនិងមុខងារជាកំណត់នៅក្នុងកន្សោមនាមនៃល្បះ។

**៦.៦. សម្ព័ន្ធគុណនាមមិនច្បាស់**

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *សូមអានសេចក្តីប្រកាសព័ត៌មានផ្សេងៗ ។*

-*ផ្សេងៗ* មានទីតាំងនៅជាប់ខាងស្តាំនាម *សេចក្តីប្រកាសព័ត៌មាន*។ វាមានតួនាទីកំណត់នាម សេចក្តីប្រកាសព័ត៌មាន មិនច្បាស់លាស់។ *ផ្សេងៗ* មានមុខងារជាកំណត់មិនច្បាស់នៅក្នុងកន្សោមនាមនៃល្បះ។

ឧ. *គាត់ទាស់គ្នាជាមួយប្រពន្ធរាល់ថ្ងៃ។*

-*រាល់* មានទីតាំងនៅជាប់ខាងឆ្វេងនាម *ថ្ងៃ*។ វាមានតួនាទីកំណត់នាម *ថ្ងៃ* មិនច្បាស់លាស់។ *រាល់* មានមុខងារជាកំណត់មិនច្បាស់នៅក្នុងកន្សោមកិរិយានៃល្បះ។

ឧ. *គ្រប់ខេត្តក្រុងទាំងអស់នៃប្រទេសវៀតណាមស្ថិតក្នុងគ្រោះថ្នាក់ Covid-19។*

-*គ្រប់...ទាំងអស់* មានទីតាំងស្ថិតនៅជាប់សងខាងនាម *ខេត្តក្រុង*។ វាមានតួនាទីកំណត់នាម ខេត្តក្រុង មិនច្បាស់លាស់។ *គ្រប់...ទាំងអស់* មានមុខងារជាកំណត់មិនច្បាស់នៅក្នុងកន្សោមនាមនៃល្បះ។

ដូចនេះ គុណនាមមិនច្បាស់មានទីតាំងនៅជាប់ខាងស្តាំ ជាប់ខាងឆ្វេង និងជាប់សងខាងនាម។ វាមានតួនាទីកំណត់នាមមិនច្បាស់លាស់ ហើយមានមុខងារជាកំណត់មិនច្បាស់នៅក្នុងកន្សោមពាក្យនៃល្បះ។

ជារួមគុណនាមចង្អុល គុណនាមសំណួរ គុណនាមកម្មសិទ្ធិ គុណនាមចំនួន និងគុណនាមមិនច្បាស់ មានមុខងារជាកំណត់នៃនាម។ វាមិនពណ៌នាលក្ខណៈឱ្យនាមដូចគុណនាមប្រក្រតីទេ វាគ្រាន់តែកំណត់នាមឱ្យជាក់លាក់ឬមិនជាក់លាក់តែប៉ុណ្ណោះ។

# មេរៀនទី៨
# កិរិយាសព្ទ

## ១. និយមន័យ

**កិរិយាសព្ទ** ជាពាក្យដែលបង្ហាញអំពីសកម្មភាព ព្រឹត្តិការណ៍ ឬស្ថានភាពបែបណាមួយ។ កិរិយាសព្ទជាស្នូលនៃល្បះ។ ជាធម្មតាកិរិយាសព្ទតែងទាមទារនូវប្រធាន ហើយពេលខ្លះទៀតវាទាមទារកម្មបទដែរ។

## ២. ប្រភេទរបស់កិរិយាសព្ទ

នៅក្នុងភាសាខ្មែរ យើងពុំអាចស្គាល់ថាពាក្យមួយជាកិរិយាសព្ទបានតាមរយៈទម្រង់ពាក្យ (រូបរាងពាក្យ) បានឡើយ។ ដើម្បីងាយស្រួលយល់ន័យរបស់កិរិយាសព្ទឱ្យបានច្បាស់លាស់ គេចែកកិរិយាសព្ទជា៖

### ២.១. កិរិយាសុទ្ធ

កិរិយាប្រើសម្រាប់ប្រាប់អំពើបានមកចំពោះខ្លួនបុគ្គលអ្នកធ្វើវិញ។ កិរិយាទាំងនោះមាន*ស៊ី ផឹក សូត្រ ទន្ទេញ មើល ចេញ ចូល ចេះ*...។

ឧ. *គោ**ស៊ី**ស្មៅ។*

*កូនសិស្សទាំងឡាយ**ទន្ទេញ**ពង្សាវតារខ្មែរ។*

### ២.២. កិរិយាហេតុ

កិរិយាប្រើសម្រាប់ប្រាប់ពីហេតុដែលជាដើមចមនៃអំពើ ពោលគឺកិរិយាសព្ទដែលធ្វើអំពើណាមួយទៅឱ្យបុគ្គលដទៃ។ កិរិយាទាំងនោះមាន *បង្រៀន ពន្យល់ បង្ហាត់ បង្ហូរ បង្រួម*...។

ឧ. *ភិក្ខុ**ពន្យល់**ធម៌ដល់ពុទ្ធបរិស័ទទាំងឡាយ។*

កិរិយាហេតុជាកិរិយាដែលមានបង្កប់ន័យថាធ្វើឱ្យ។ *ពន្យល់* ក្នុងឧទាហរណ៍ខាងលើមានន័យថាធ្វើឱ្យយល់។ កិរិយាហេតុកើតពីកិរិយា គុណនាម ឬនាម ដោយផ្នត់ដើម និងផ្នត់ដែកមួយចំនួន។

ឧ. ទី១៖

| កិរិយាឫស | កិរិយាហេតុ | កិរិយាឫស | កិរិយាហេតុ |
|---|---|---|---|
| *[ប់ង-] + កក់* | *បង្កក់* | *[ប់ន-] + ដុះ* | *បណ្ដុះ* |

| | | | |
|---|---|---|---|
| *[ប់ង-] + កាត់* | *បង្កាត់* | *[ប់ណ-] + ដោះ* | *បណ្ដោះ* |
| *[ប់ង-] + ខិត* | *បង្ខិត* | *[ប់ន-] + ថយ* | *បន្ថយ* |
| *[ប់ង-] + ហាត់* | *បង្ហាត់* | *[ប់ន-] + ថែម* | *បន្ថែម* |
| *[ប់ញ-] + ចប់* | *បញ្ចប់* | *[ព់ង-] + វត់* | *ពង្រាត់* |
| *[ប់ញ-] + ចូល* | *បញ្ចូល* | *[ព់ង-] + រីក* | *ពង្រីក* |
| *[ប់ញ-] + ជូន* | *បញ្ជូន* | *[ព់ន-] + យល់* | *ពន្យល់* |
| *[ប៉-] + ដើយ* | *ភ្ញើយ* | *[ប់ម-] + ភ្លឺ* | *បំភ្លឺ* |
| *[ប៉-] + ទឹម* | *ផ្ទឹម* | *[ប់ម-] + បែក* | *បំបែក* |
| *[-អ់ម-] + ស្លាប់* | *សម្លាប់* | *[រ់ម-] + លេច* | *រំលេច* |

ឧ. ទី២៖

| គុណនាម | កិរិយាហេតុ | គុណនាម | កិរិយាហេតុ |
|---|---|---|---|
| *[ប់ង-] + ខូច* | *បង្ខូច* | *[-អ់ម-] + ស្រួច* | *សម្រួច* |
| *[ប់ញ-] + ឆោត* | *បញ្ឆោត* | *[ព់ង-] + រាប* | *ពង្រាប* |
| *[ប់ញ-] + ជោរ* | *បញ្ជោរ* | *[ព់ង-] + រឹង* | *ពង្រឹង* |
| *[ប់ន-] + ទាប* | *បន្ទាប* | *[ព់ន-] + យឺត* | *ពន្យឺត* |
| *[ប់ន-] + ទុំ* | *បន្ទុំ* | *[ព់ន-] + យារ* | *ពន្យារ* |
| *[-អ់ម-] + ក្ដៅ* | *កម្ដៅ* | *[-អ៊ំម-] + ល្អ* | *លម្អ* |

ឧ. ទី៣៖

*គូ* (នាម) ទៅជា *ផ្គូ* (កិរិយាហេតុ)។

### ២.៣. កិរិយាសកម្ម

**កិរិយាសកម្ម** គឺជាកិរិយាដែលត្រូវការកម្មបទផ្ទាល់និងរងអំពើពីប្រធានផ្ទាល់តែម្ដង។ កិរិយាសកម្ម អាចជាកិរិយាសកម្មត្រូវការកម្មបទមួយ (Monotrasitive Verb) និងកិរិយាសកម្មត្រូវការកម្មបទពីរ (Di-transitive Verb)។

ឧ. *ពួកគេ**រៀន**ប្រវត្តិសាស្ត្រខ្មែរ។ រៀន* ជាកិរិយាសកម្មត្រូវការកម្មបទតែមួយ។

*ម្ដាយ**ឱ្យ**លុយកូន។ ឱ្យ* ជាកិរិយាសកម្មត្រូវការកម្មបទពីរ។

កិរិយាសកម្មមានច្រើនដូចជា *សិក្សា រៀន ពន្យល់ ឱ្យ ផ្ដល់ ជូន ប្រគល់ អាន គូរ សរសេរ ដាំ បណ្ដើរ ស្រលាញ់ ជួសជុល បន្ថែម តុបតែង...*។

### ២.៤. កិរិយាអកម្ម

កិរិយាអកម្ម គឺជាកិរិយាមិនត្រូវការកម្មបទ។ គេអាចប្រើគុណកិរិយាឬកន្សោមមានធ្នាក់ជាពង្រីករបស់កិរិយាសព្ទនេះ។

ឧ. *ខ្ញុំ**កើត**ក្នុងឆ្នាំ១៩៦៨។*

*យើង**រស់នៅ**ជាមួយគ្នាយ៉ាងសុខដុមរម្យនា។*

កិរិយាអកម្មមានដូចជា *ទៅ មក រស់នៅ ច្រៀង សើច យំ ដើរ ស្លាប់ រត់ បោល រាំ ឈរ របេះ ផ្កា មុជទឹក ធ្វើការ ដុះ...។*

<u>**ចំណាំ៖**</u> កិរិយាសព្ទខ្លះ អាចប្រើជាកិរិយាសកម្មផង កិរិយាអកម្មផង។

ឧ. *ឈើនេះ**លាស់**ស្លឹកល្អណាស់។* (សកម្មកិរិយា)

*ខែនេះ ស្លឹកឈើ**លាស់**ល្អណាស់។* (អកម្មកិរិយា)

### ២.៥. កិរិយាចំណង

កិរិយាប្រើសម្រាប់ចងប្រធាននិងគុណប្រធាន។ វាមានទំនាក់ទំនងរវាងប្រធាន និងពាក្យនៅក្នុងបម្រាប់ប្រធាន។

*ឧ. វា**ឡើងជា**ប្រធាន។*

*គាត់**ក្លាយជា**កីឡាករជើងឯក។*

កិរិយាចំណងមាន *ជា គឺជា ប្រែក្លាយជា រលាយជា ធ្វើជា ដើរតួជា...។*

### ២.៦. កិរិយាជំនួយ

**កិរិយាជំនួយ** ជាពាក្យវេយ្យាករណ៍ដែលប្រើសម្រាប់បង្ហាញអំពីទិដ្ឋភាព កាតព្វកិច្ច និងលទ្ធភាព។ កិរិយាជំនួយប្រើសម្រាប់ជួយបំពេញន័យបន្ថែមឱ្យកិរិយាបង្គោលក្នុងល្បះ។ កិរិយាជំនួយមាន *ចេះ កើត អាច នឹង បាន កំពុង...។*

*ឧ. គេ**កំពុង**រៀនភាសាខ្មែរ។*

#### ២.៦.១. កិរិយាបំពេញ

កិរិយាបំពេញសម្រាប់បង្គ្រប់ន័យសេចក្តីរបស់កិរិយាសព្ទបង្គោលលើចំណុចពីរយ៉ាង គឺ **លទ្ធផលនៃអំពើ** និង **លទ្ធភាពសម្រេចអំពើ**។ កិរិយាបំពេញមាន *ឃើញ ទាន់ លក់ លឺ ធំ ផុត មុត ចេះ បាន កើត...។*

| **កិរិយាបំពេញ** | **កិរិយាបង្គោល** | **ឧទាហរណ៍** |
|---|---|---|
| *ឃើញ* | *គិត*<br>*មើល* | *វា គិត**ឃើញ**ត្រូវ។*<br>*គាត់ មើល**ឃើញ**យើង។* |

| | | |
|---|---|---|
| | *រក*<br>*នឹក* | *វា រកស្រែ**ឃើញ**។*<br>*គាត់ នឹក**ឃើញ**។* |
| *ទាន់* | *ទៅ*<br>*ធ្វើ* | *គាត់ ទៅ**ទាន់**ពេល។*<br>*ខ្ញុំ ធ្វើ**ទាន់**ផែនការ។* |
| *លក់* | *ដេក* | *សុក ដេក**លក់**។* |
| *ឮ* | *ស្ដាប់* | *សេក ស្ដាប់**ឮ**។* |
| *មុត* | *កាប់* | *ចបនេះ កាប់**មុត**ល្អណាស់។* |
| *ចេះ* | *រៀន* | *វា រៀន**ចេះ**។* |
| *បាន* | *ទៅ* | *ខ្ញុំ ទៅ**បាន**។* |

### ២.៦.២. កិរិយាទិសដៅ

**កិរិយាទិសដៅ** សម្រាប់ប្រើជាមួយកិរិយាសព្ទបង្គោលសម្រាប់ប្រាប់ទិសឬទិសដៅនៃអំពើរបស់កិរិយាបង្គោលនោះ។ កិរិយាទិសដៅមានដូចជា *មក ទៅ ជូន ឱ្យ ចុះ ឡើង ចូល ចេញ កាត់ ...*។

| កិរិយាបង្គោល | កិរិយាទិសដៅ | ឧទាហរណ៍ |
|---|---|---|
| *សុំ* | *មក* | *ខ្ញុំសុំបារីមួយ**មក**។* |
| *យក* | *ទៅ* | *យកប្រដាប់ប្រដានេសាទទៅផង។* |
| *បើកទ្វារ* | *ជូន* | *បើកទ្វារ**ជូន**លោកតា។* |
| *ប្រមូល*<br>*លើកដៃ* | *ឡើង* | *ប្រមូលអីវ៉ាន់**ឡើង**រថយន្ត។*<br>*លើកដៃ**ឡើង**។* |
| *ដើរ* | *ចូល* | *យើងដើរ**ចូល**ក្នុងថ្នាក់។* |

### ២.៦.៣. កិរិយាខាងដើម

**កិរិយាខាងដើម** ជាកិរិយាជំនួយដែលនៅខាងឆ្វេងកិរិយាបង្គោល សម្រាប់តម្លៃអាការភាព ឬតម្លៃទិដ្ឋភាព ឬក៏តម្លៃកាលនៃអំពើ។ កិរិយាខាងដើមមាន *ចង់ ចូលចិត្ត ប៉ង អាច មាន បាន ត្រូវ ហ៊ាន...*។

| កិរិយាខាងដើម | កិរិយាបង្គោល | ឧទាហរណ៍ |
|---|---|---|
| *ចង់* | *ធ្វើ* | *គាត់ ចង់**ធ្វើ**កសិកម្ម។* |

| | | |
|---|---|---|
| *ចូលចិត្ត* | *ដើរលេង* | *តាសំ **ចូលចិត្ត**ដើរលេងតាមមាត់ទន្លេ។* |
| *ប៉ង* | *មើល* | *ខ្ញុំ ប៉ងមើលសិល្បៈប្រពៃណី។* |
| *មាន* | *ឃើញ* | *ឯង **មាន**ឃើញចម្ការល្ពៅទេ?* |
| *បាន* | *ទៅ* | *វា **បាន**ទៅអង្គរកាលពីអាទិត្យមុន។* |
| *ត្រូវ* | *នៅ* | *កូន **ត្រូវ**នៅផ្ទះ។* |
| *ហ៊ាន* | *ជិះ* | *ខ្ញុំ មិន**ហ៊ាន**ជិះយន្តហោះទេ។* |

### ៣. ការប្រើប្រាស់កិរិយាសព្ទខ្លះក្នុងសម្ព័ន្ធ

កិរិយាជាច្រើនក្នុងភាសាខ្មែរ អាចប្រើជាគុណកិរិយាសម្រាប់បញ្ជាក់លក្ខណៈឱ្យអំពើរបស់កិរិយាសព្ទនៅក្នុងល្បះ។

ឧ. *ខ្ញុំអាចរៀនភាសាអង់គ្លេសចេះ លុះត្រាតែលោកគ្រូមានបទពិសោធខ្ពស់ផ្នែកភាសាអង់គ្លេស។*

ពាក្យ ***ចេះ*** ជាកិរិយាសព្ទ មានមុខងារជាគុណកិរិយាសម្រាប់បញ្ជាក់លក្ខណៈឱ្យអំពើ ***រៀន*** នៅក្នុងល្បះខាងលើ។

**សម្គាល់៖** គុណនាមនៃភាសាខ្មែរភាគច្រើន អាចប្រើជាស្នូលនៃល្បះ។ នៅពេលវាដើរតួជាស្នូលនៃល្បះ វាក្លាយទៅជាកិរិយាសព្ទ។ កិរិយាប្រភេទនេះហៅថាគុណនាមកិរិយា។

ឧ. *សាលានេះ**ល្អ**ណាស់។*

*ធនធានគាត់**ក្រ** តែគំនិតគាត់ពុំ**ក្រ**ទេ។*

នាមមួយចំនួន ក៏អាចប្រើជាកិរិយាបានដែរ។ កិរិយាដែលមានរូបរាងដូចនាម ហើយប្រើជាកិរិយាបង្គោលនៅក្នុងល្បះ ហៅថានាមកិរិយា។

ឧ. *ដើមរាំងខ្ញុំ**ផ្កា**ហើយ។*

*មេឃ**ភ្លៀង**ខ្លាំងណាស់យប់មិញ។*

# មេរៀនទី៩
# គុណកិរិយា

### ១. និយមន័យ

**គុណកិរិយា** គឺជាថ្នាក់ពាក្យមួយប្រភេទដែលមានតួនាទីបញ្ជាក់លក្ខណៈឱ្យកិរិយាសព្ទ គុណនាម និងគុណកិរិយាឱ្យមានសភាពប្លែកពីធម្មតា (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ២. ប្រភេទគុណកិរិយា

យោងលើបំណែងចែកប្រភេទគុណកិរិយារបស់បណ្ដាអ្នកស្រាវជ្រាវកន្លងមក យើងអាចចែកគុណកិរិយាជា៥ប្រភេទ គឺ **គុណកិរិយាបំណែប គុណកិរិយាកាល គុណកិរិយាទីកន្លែង គុណកិរិយាសំណួរ** និង **គុណកិរិយាបរិមាណ**។

### ២.១. គុណកិរិយាបំណែប

**គុណកិរិយាបំណែប** គឺជាគុណកិរិយាមួយប្រភេទដែលមានតួនាទីបញ្ជាក់បែបបទឱ្យកិរិយាសព្ទនិងគុណនាម។ វាឆ្លើយតបទៅនឹងសំណួរ *យ៉ាងម៉េច ដូចម្ដេច*។ វាមានមុខងារជាកម្មទេសកាលប្រាប់បំណែបរបស់កិរិយាសព្ទ (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ២.២. គុណកិរិយាកាល

**គុណកិរិយាកាល** គឺជាគុណកិរិយាមួយប្រភេទដែលមានតួនាទីបញ្ជាក់អំពីពេលវេលានៃសកម្មភាពកើតឡើងរបស់កិរិយាសព្ទ។ វាឆ្លើយតបនឹងសំណួរ *ពេលណា?*។ វាមានមុខងារជាកម្មទេសកាលកាលនៅក្នុងល្បះ (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

### ២.៣. គុណកិរិយាកន្លែង

**គុណកិរិយាកន្លែង** គឺជាគុណកិរិយាមួយប្រភេទដែលមានតួនាទីបញ្ជាក់អំពីទីកន្លែងឬទិសដៅនៃសកម្មភាពអ្វីមួយ។ វាឆ្លើយតបទៅនឹងសំណួរថា *នៅឯណា? ទៅណា? មកពីណា?*។ គុណកិរិយាកន្លែងមានមុខងារជាកម្មទេសកាលកន្លែងនៅក្នុងល្បះ (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

## ២.៤. គុណកិរិយាសំណួរ

**គុណកិរិយាសំណួរ** គឺជាគុណកិរិយាមួយប្រភេទដែលមានតួនាទីចោទសួររកអំពីហេតុ (មូលហេតុអ្វី?) កាល (ពេលណា?) បំណែប (ដូចម្ដេច?) ទីកន្លែង (ឯណា?) ចំនួន (មានប៉ុន្មាន?) តម្លៃ (តម្លៃប៉ុន្មាន?) និងកម្រិត (ល្អយ៉ាងម៉េច?) (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

## ២.៥. គុណកិរិយាបរិមាណ

**គុណកិរិយាបរិមាណ** គឺជាគុណកិរិយាមួយប្រភេទដែលមានតួនាទីបញ្ជាក់កម្រិតបែបបទនិង កម្រិតចំនួននៃគុណកិរិយានិងគុណនាម និងកម្រិតសកម្មភាពនៃកិរិយាសព្ទឱ្យវិសេសឡើង។ គុណកិរិយាបរិមាណមានដូចជា *ច្រើន តិច ពេក ណាស់ ល្មម គ្រប់គ្រាន់ ជាង ដូច...* (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

## ៣. ទម្រង់គុណកិរិយា

ទម្រង់គុណកិរិយាសំដៅទៅលើលក្ខណៈរូបសាស្ត្រនៃគុណកិរិយា។ ដោយឈរលើមូលដ្ឋានឫសគល់និងកំណើតនៃគុណកិរិយា យើងអាចបែងចែកទម្រង់គុណកិរិយាជា **ទម្រង់កំណើត ទម្រង់កម្លាយ ទម្រង់បន្សំ** និង **ទម្រង់ផ្ទួន** ឬអាចហៅថា **គុណកិរិយាកំណើត គុណកិរិយាកម្លាយ គុណកិរិយាផ្សំ** និង **គុណកិរិយាផ្ទួន** (វ៉ា សោភា-ចាន់ វឌ្ឍនា-ឆាន់ គឹមសឿន-គេន រង្សី, ២០២១)។

## ៣.១. គុណកិរិយាកំណើត

**គុណកិរិយាកំណើត** គឺជាទម្រង់ដើមរបស់គុណកិរិយាដែលគេមិនទាន់យកទៅកម្លាយដោយផ្នត់ ផ្សំជាមួយធាតុដទៃទៀត ឬផ្ទួនពាក្យ។

ឧ. *លឿន យឺត រហ័ស ស្អែក ព្រឹក ល្ងាច មុន ក្រោយ ច្រើន តិច ពេក លើ ក្រោម មុខ ក្រោយ ឆ្វេង ស្ដាំ អី ម៉េច អង្កាល់ ហើយ ពិសេស តែ...*។

## ៣.២. គុណកិរិយាកម្លាយ

**គុណកិរិយាកម្លាយ** គឺជាទម្រង់គុណកិរិយាដែលកើតឡើងតាមវិធីកម្លាយដោយផ្នត់ដើមឬផ្នត់ដែក។

ឧ. *សន្សឹម កក្លាកកក្លាយ ប្រុយ ប៉ប៉ាច់ប៉ប៉ោច អន្ទ្រើត បន្ទាប់ បន្ត ...*។

## ៣.៣. គុណកិរិយាផ្សំ

**គុណកិរិយាផ្សំ** គឺជាទម្រង់គុណកិរិយាដែលកើតឡើងតាមវិធីបន្សំ។

ឧ. *ខ្លាំងក្លា ខ្ជាប់ខ្ជួន ម៉ត់ចត់ ម្សិលមិញ ស្អែកមួយ ឆ្នាំក្រោយ សព្វថ្ងៃ ខានស្អែកមួយ ម្ដងម្កាល ដូចម្ដេច យ៉ាងម៉េច ពេលណា ឯណា ប៉ុន្មាន ហេតុអ្វី ជាពិសេស ជាទូទៅ ជារួម សរុបមក ប៉ុន្តែ សរុបសេចក្ដីមក...*។

**៣.៤. គុណកិរិយាផ្ទួន**

**គុណកិរិយាផ្ទួន** គឺជាទម្រង់គុណកិរិយាដែលកើតឡើងតាមវិធីផ្ទួនពាក្យដដែលពីរដង។

ឧ. *ក្តែងៗ ទ្រើតៗ លឿនៗ ឆាប់ៗ មួយៗ សន្សឹមៗ ម៉្ងៃៗ ម្ដងៗ ......*។

**៤. សម្ព័ន្ធគុណកិរិយា**

ចំពោះសម្ព័ន្ធគុណកិរិយា យើងសិក្សាទៅលើទីតាំង តួនាទី និងមុខងាររបស់គុណកិរិយានៅក្នុងល្បះ។

**ទីតាំងគុណកិរិយា**

គុណកិរិយាអាចនៅដើម ក្នុង និងចុងល្បះដូចជា (ក្រសួងអប់រំ, ១៩៨២: ទំ.៤០) ៖

ឧ. *ស្អែកគាត់ចេញដំណើរទៅស្រែហើយ។*

*បងខ្ញុំ កាលពីមុន ធ្វើជាងកំបោរ។*

*វាចេញទៅអំបាញ់មិញ។*

**តួនាទីគុណកិរិយា**

អាស្រ័យលើទីតាំងនៅក្នុងល្បះ គុណកិរិយាអាចមានតួនាទីបញ្ជាក់ពីទីកន្លែង កាល គោលបំណង បែបបទ ហេតុជាដើម។ តួនាទីមួយទៀត គឺគុណកិរិយាអាចមានតួនាទីបញ្ជាក់លក្ខណៈបែបបទនៃនាមសព្ទ។

**មុខងារគុណកិរិយា**

កម្មទេសកាលអាចជាគុណកិរិយា (ក្រសួងអប់រំ, ១៩៨២:១២០)។ កម្មទេស-កាលសម្រាប់ចង្អុលបង្ហាញទីកន្លែង កាល គោលបំណង បែបបទ ហេតុជាដើមរបស់អំពើឬសភាពដែលសម្ដែងឡើងដោយកិរិយាសព្ទ (ក្រសួងអប់រំ, ១៩៨២:៨៨)។

នៅក្នុងនាមផ្សំបែបខ្មែរ ក៏មានធាតុផ្សំមួយមានថ្នាក់ពាក្យគុណកិរិយាដែរ (*ល្បឿនលឿន កាយវិការហ័សរហួន...*)។ ដូច្នេះគុណកិរិយានៅពេលនេះ ក៏មានមុខងារដូចជាគុណនាមផងដែរ។

**៤.១. សម្ព័ន្ធគុណកិរិយាបំណែប**

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *ឡានដឹកខ្សាច់នៅតែបើកបរលឿន ទោះបីធ្លាក់ភ្លៀង។*

- *លឿន* មានទីតាំងនៅជាប់ខាងស្តាំកិរិយាសព្ទ *បើកបរ* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *បើកបរ* កាន់តែច្បាស់លាស់ឡើង។ គុណកិរិយាបំណែប *លឿន* មានមុខងារជាកម្មទេសកាល។

ឧ. *អ្នកគ្រូសរសេរអក្សរស្អាត។*

-*ស្អាត* មានទីតាំងនៅជាប់ខាងស្តាំកម្មបទ *អក្សរ* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *សរសេរ* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណកិរិយាបំណែប *ស្អាត* មានមុខងារជាកម្មទេសកាល។

ឧ. *ក្មេងនេះពូកែញ៉ាំ។*

-*ពូកែ* មានទីតាំងនៅជាប់ខាងឆ្វេងកិរិយាបង្គោល *ញ៉ាំ* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *ញ៉ាំ* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណកិរិយាបំណែប *ពូកែ* មានមុខងារជាកម្មទេសកាល។

សរុបមក គុណកិរិយាបំណែបមានទីតាំងស្ថិតនៅជាប់ខាងស្តាំកិរិយាបង្គោល ជាប់ខាងឆ្វេងកិរិយាបង្គោល និងជាប់ខាងស្តាំកម្មបទនៅក្នុងល្បះ។ វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាបង្គោល។ គុណកិរិយាបំណែបមានមុខងារជាកម្មទេសកាលនៅក្នុងល្បះ។

### ៤.២. សម្ព័ន្ធគុណកិរិយាកាល

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *ស្អែក ខ្ញុំការប្រពន្ធ។*

- *ស្អែក* មានទីតាំងនៅខាងដើមល្បះ *ស្អែកខ្ញុំការប្រពន្ធ* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *ការ* កាន់តែច្បាស់លាស់ឡើង។ គុណកិរិយាកាល *ស្អែក* មានមុខងារជាកម្មទេសកាល។

ឧ. *យើងសម្អាតសួនច្បារឥឡូវ ។*

-*ឥឡូវ* មានទីតាំងនៅចុងល្បះ *យើងសម្អាតសួនច្បារឥឡូវ* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *សម្អាត* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណកិរិយាកាល *ឥឡូវ* មានមុខងារជាកម្មទេសកាល។

ឧ. *គាត់កាលពីមុន ជាជាងកំបោរ។*

- *កាលពីមុន* មានទីតាំងនៅកណ្តាលល្បះ គឺជាប់ខាងឆ្វេងកិរិយាសព្ទបង្គោល *ជា*។ វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាបង្គោល *ជា* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណ-

កិរិយាកាល *កាលពីមុន* មានមុខងារជាកម្មទេសកាល។

សរុបមក គុណកិរិយាកាលមានទីតាំងស្ថិតនៅខាងដើម កណ្ដាល ឬខាងចុងល្បះ។ វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាបង្គោល។ គុណកិរិយាកាលមានមុខងារជាកម្មទេសកាលនៅក្នុងល្បះ។

**៤.៣. សម្ព័ន្ធគុណកិរិយាកន្លែង**

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *ខ្ញុំដេកខាងឆ្វេង ឯងដេកខាងស្ដាំ។*

- *ខាងឆ្វេង ខាងស្ដាំ* មានទីតាំងនៅជាប់ខាងស្ដាំកិរិយាសព្ទ *ដេក* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *ដេក* កាន់តែច្បាស់លាស់ឡើង។ គុណកិរិយាកន្លែង *ខាងឆ្វេង ខាងស្ដាំ* មានមុខងារជាកម្មទេសកាល។

ឧ. *ឯងមកនេះ។*

-*នេះ* មានទីតាំងនៅជាប់ខាងឆ្វេងកិរិយាសព្ទ *មក* វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាសព្ទ *មក* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណកិរិយាកន្លែង *នេះ* មានមុខងារជាកម្មទេសកាល។

សរុបមក គុណកិរិយាកន្លែងមានទីតាំងស្ថិតនៅជាប់ខាងស្ដាំកិរិយាបង្គោលនៅក្នុងល្បះ។ វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយាបង្គោល។ គុណកិរិយាកន្លែងមានមុខងារជាកម្មទេសកាលនៅក្នុងល្បះ។

**៤.៤. សម្ព័ន្ធគុណកិរិយាសំណួរ**

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *ឯងទៅវិញអង្កាល់?*

- *អង្កាល់* មានទីតាំងនៅខាងចុងល្បះ *ឯងទៅវិញអង្កាល់?* វាមានតួនាទីចោទសួររកកាលអំពីកិរិយាសព្ទ *ទៅ*។ គុណកិរិយាសំណួរ *អង្កាល់* មានមុខងារជាកម្មកាល។

ឧ. *ហេតុអ្វី ឯងមិនទៅធ្វើការ?*

-*ហេតុអ្វី* មានទីតាំងនៅខាងដើមល្បះ *ហេតុអ្វីឯងមិនទៅធ្វើការ?* វាមានតួនាទីចោទសួររកមូលហេតុនៃកិរិយាសព្ទ *មិនទៅធ្វើការ* ។ គុណកិរិយាសំណួរ *ហេតុអ្វី* មានមុខងារជាកម្មហេតុ។

ឧ. *តើឯងគិតធ្វើដូចម្ដេច?*

-*តើ...ដូចម្តេច* មានទីតាំងនៅខាងដើមនិងខាងចុងល្បះ *តើឯងគិតធ្វើដូចម្តេច?* វាមានតួនាទីចោទសួររកបែបបទនៃកិរិយាសព្ទ *ធ្វើ*។ គុណកិរិយាសំណួរ *តើ...ដូចម្តេច* មានមុខងារជាកម្មបំណែប។

សរុបមក គុណកិរិយាសំណួរមានទីតាំងនៅខាងដើមល្បះ ខាងចុងល្បះ ព្រមទាំងខាងដើមនិងខាងចុងល្បះ។ វាមានតួនាទីចោទសួររកកាល បែបបទ មូលហេតុ...នៃកិរិយាបង្គោលក្នុងល្បះ។ គុណកិរិយាសំណួរមានមុខងារជាកម្មហេតុ កម្មបំណែប កម្មបំណាង។

### ៤.៥. សម្ព័ន្ធគុណកិរិយាបរិមាណ

សូមពិនិត្យមើលឧទាហរណ៍និងការវិភាគដូចខាងក្រោម៖

ឧ. *គាត់មកដល់យឺតពេក។*

- *ពេក* មានទីតាំងនៅជាប់ខាងស្តាំគុណកិរិយា *យឺត* វាមានតួនាទីបញ្ជាក់កម្រិតឱ្យគុណកិរិយា *យឺត* កាន់តែច្បាស់លាស់ឡើង។ គុណកិរិយាបរិមាណ *ពេក* មានមុខងារជាកម្មទេសកាល។

ឧ. *គាត់និយាយច្រើន។*

-*ច្រើន* មានទីតាំងនៅជាប់ខាងស្តាំកិរិយាបង្គោល *និយាយ* វាមានតួនាទីបញ្ជាក់កម្រិតឱ្យកិរិយាបង្គោល *និយាយ* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណកិរិយាបរិមាណ *ច្រើន* មានមុខងារជាកម្មទេសកាល។

ឧ. *ខ្ញុំចង់បានតុតូចល្មម។*

-*ល្មម* មានទីតាំងនៅជាប់ខាងស្តាំគុណនាម *តូច* វាមានតួនាទីបញ្ជាក់ន័យឱ្យគុណនាម *តូច* ឱ្យកាន់តែច្បាស់លាស់ឡើង។ គុណកិរិយាបរិមាណ *ល្មម* មានមុខងារជាគុណវិសេសន៍ (គុណវិសេសន៍ < គុណវិសេសនៈ) របស់គុណនាម *តូច*។

ឧ. *គាត់រត់យ៉ាងលឿន។*

-*យ៉ាង* មានទីតាំងនៅជាប់ខាងឆ្វេងគុណកិរិយា *លឿន* វាមានតួនាទីបញ្ជាក់ន័យឱ្យគុណកិរិយា *លឿន* ឱ្យប្លែកឡើង។ គុណកិរិយាបរិមាណ *យ៉ាង* មានមុខងារជាកម្មទេសកាល។

សរុបមក គុណកិរិយាបរិមាណមានទីតាំងស្ថិតនៅជាប់ខាងស្តាំកិរិយា ខាងស្តាំគុណកិរិយា ខាងស្តាំគុណនាម និងខាងឆ្វេងគុណកិរិយា។ វាមានតួនាទីបញ្ជាក់ន័យឱ្យកិរិយា គុណនាម និងគុណកិរិយាឱ្យមានន័យប្លែកឡើង។ គុណកិរិយាបរិមាណមានមុខងារជាកម្មទេសកាលនិងគុណវិសេសន៍។

# មេរៀនទី១០
## ធ្នាក់

**១. និយមន័យ**

**ធ្នាក់** ជាពាក្យដែលគេប្រើប្រាស់បង្កើតកន្សោមមានធ្នាក់។ ធ្នាក់ច្រើនមានទីតាំងនៅខាងដើមកន្សោមមានធ្នាក់។ កន្សោមមានធ្នាក់អាចមានមុខងារជាកម្មរងរបស់កិរិយា កម្មរងរបស់នាម និងជាកម្មទេសកាលរបស់ល្បះទាំងមូល។ គេមិនអាចប្រើកន្សោមមានធ្នាក់ជាប្រធាននៃកិរិយាសព្ទបានឡើយ។

ឧ. *គាត់មក**ពី**ប្រទេសអាមេរិក។*

*ខ្ញុំឱ្យសៀវភៅរៀនអាន**ទៅ**ប្អូនរបស់ខ្ញុំ។*

*សំនិយាយភាសាអង់គ្លេស**ជាមួយ**ជនជាតិអាមេរិក។*

*កូនខ្ញុំទៅរៀន**នៅ**ម៉ោង៧ព្រឹក។*

ធ្នាក់ក្នុងភាសាខ្មែរមាន៖ *នឹង នៃ ខាង ក្នុង តាម លើ នូវ ពី អំពី ដើម្បី របស់ ជាមួយ ដោយ ចំពោះ ជិត ក្បែរ ក្រោម កណ្តាល ប្រហែល លើកលែង ពីក្រោយ ពីមុខ ក្រៅ ដោយសារ រហូតដល់ ចាប់តាំងពី ចន្លោះ នៅ នា ឯ ជូន ឱ្យ ដាក់ ព្រោះ។*

**២. ប្រភេទរបស់ធ្នាក់**

តាមការប្រើប្រាស់ ធ្នាក់ក្នុងភាសាខ្មែរ អាចប្រើសម្រាប់បង្ហាញពី៖

-**ទីកន្លែង**៖ *លើ ក្រោម ក្បែរ ជិត ជុំវិញ ចន្លោះ នៅក្នុង...។*

ឧ. *ផ្ទះខ្ញុំស្ថិតនៅ**ក្បែរ**ផ្សារថ្មី។*

-**ពេលវេលា**៖ *នៅ នា ប្រហែល តាំងពី ដល់ មុន រហូតដល់ បន្ទាប់ពី..។.*

ឧ. *សំទៅរៀន**នៅ**ម៉ោង៧ព្រឹក។*

-**បែបបទរបស់កិរិយា**៖ *ដោយ ដោយសារ ...។*

ឧ. *ក្មេងៗទៅសាលា**ដោយសារ**ឡានក្រុង។*

-**កម្មសិទ្ធិ**៖ *របស់ នៃ។*

ឧ. *ភ្នំពេញ គឺជារាជធានី**នៃ**ប្រទេសកម្ពុជា។*

-**មធ្យោបាយ**៖ *ជាមួយ នឹង តាម ដោយសារ។*

ឧ. *ធ្វើស្រែ**នឹង**ទឹក ធ្វើសឹក**នឹង**បាយ។*

**-ការឃ្លាតចេញពី៖** *ពី ។*

ឧ. *យើងទើបទទួលបានសៀវភៅ**ពី**លោកនាយក។*

**-មូលហេតុ៖** *ដោយសារ ព្រោះតែ ។*

ឧ. *មិត្តខ្ញុំស្លាប់**ដោយសារ**គ្រោះថ្នាក់ចរាចរណ៍។*

**-ការប្រគល់៖** *ដល់ ទៅ ចំពោះ។*

ឧ. *គាត់ប្រគល់រង្វាន់**ដល់**ម្ចាស់ជ័យលាភី។*

**-គោលបំណង៖** *សម្រាប់ ដើម្បី ដើម្បីនឹង ។*

ឧ. *អ្នកត្រូវតែប្រឹងប្រែង**សម្រាប់**អនាគតរបស់អ្នក។*

**-ការសម្រេចតាម៖** *យោងតាម តាម យោលទៅតាម។*

ឧ. ***យោលតាម**សេចក្ដីប្រកាសរបស់ក្រសួងអប់រំ បុគ្គលិកសិក្សាដែលមានសញ្ញាបត្របរិញ្ញា អាចប្រឡងផ្ទេរក្របខណ្ឌ។*

**សម្គាល់៖**

ដោយសារធ្នាក់មួយចំនួន ដូចគ្នាទៅនឹងឈ្នាប់ឃ្លា ម្ល៉ោះហើយធ្វើឱ្យអ្នកសិក្សាមានការលំបាក ក្នុងការកត់សម្គាល់ថា ពេលណាវាជាធ្នាក់ ហើយពេលណាវាជាឈ្នាប់ឃ្លា។ ដូច្នេះយើងត្រូវចងចាំថា ពាក្យមួយជាធ្នាក់កាលណាវាមាននាម សព្វនាម ឬកន្សោមនាមណាមួយនៅខាងក្រោយដើម្បីបង្កើតកន្សោមនាមមានធ្នាក់។ ផ្ទុយទៅវិញពាក្យនោះ អាចជាឈ្នាប់ឃ្លាក្នុងករណីដែលវាមានឃ្លានៅខាងក្រោយ។ ឃ្លាដែលផ្ដើមដោយឈ្នាប់ឃ្លា បង្កើតបានជាឃ្លារណប។

ឧ. *យើងខំរៀន**ដើម្បី**ប្រទេសជាតិយើង។* (*ដើម្បី* ជាធ្នាក់)

*យើងខំរៀន**ដើម្បី**ប្រទេសជាតិយើងមានការអភិវឌ្ឍ។* (*ដើម្បី* ជាឈ្នាប់ឃ្លាកម្មទេសកាលដែលវានៅពីមុខឃ្លារណប «*ប្រទេសជាតិយើងមានការអភិវឌ្ឍ*»។

# មេរៀនទី១១
# ឈ្នាប់

**១. និយមន័យ**

**ឈ្នាប់** គឺជាពាក្យសម្រាប់ភ្ជាប់ពាក្យ កន្សោមពាក្យ ឃ្លារណាប ឬល្បះទោលមួយទៅនឹងពាក្យ កន្សោមពាក្យ ឃ្លា ឬល្បះទោលមួយដទៃទៀត។

**-នាម + ឈ្នាប់ + នាម**

ឧ. *ខ្ញុំទើបទិញសៀវភៅ**និង** ខ្មៅដៃមួយចំនួនពីបណ្ណាគារ។*

**-កិរិយា + ឈ្នាប់ + កិរិយា**

ឧ. *គាត់ខ្វាក់**ហើយ** ថ្លង់ទៀត។*

**-គុណនាម + ឈ្នាប់ + គុណនាម**

ឧ. *ខ្ញុំត្រូវការអាវក្រហម**ឬ**ខៀវ។*

**-សព្វនាម + ឈ្នាប់ + សព្វនាម**

ឧ. *ខ្ញុំចូលចិត្តឯង**ជាង**គាត់។*

**-កិរិយាវិសេសន៍ + ឈ្នាប់ + កិរិយាវិសេសន៍**

ឧ. *គាត់សរសេរយឺត **ប៉ុន្តែ**ស្អាត។*

**-ល្បះទោល + ឈ្នាប់ + ល្បះទោល > ល្បះក្រង**

ឧ. *ថ្ងៃនេះ ខ្ញុំបានជួប**ហើយ** បាននិយាយជាមួយក្មួយស្រីរបស់ខ្ញុំ។*

**-ឃ្លាច្បង + ឈ្នាប់ឃ្លា + ឃ្លារណាប > ល្បះផ្សំ**

ឧ. *ខ្ញុំខិតខំរៀនសូត្រ **ព្រោះ** ខ្ញុំចង់បានចំណេះដឹងដ៏ប្រសើរមួយ។*

*គាត់ចង់ទៅរៀន **ប៉ុន្តែ**គាត់គ្មានលុយទិញសៀវភៅ។*

**២. ប្រភេទឈ្នាប់**

ឈ្នាប់ក្នុងភាសាខ្មែរមានពីរ គឺ **ឈ្នាប់ចង** និង **ឈ្នាប់ឃ្លា**។

**២.១. ឈ្នាប់ចង**

**ឈ្នាប់ចង** គឺជាឈ្នាប់សម្រាប់ចងពាក្យ កន្សោមពាក្យ ឬល្បះទោលពីរដែលមានលំនឹងស្មើគ្នា គ្មានមួយណារណាបមួយណាឡើយ ខុសពីឈ្នាប់ឃ្លាដែលភ្ជាប់ឃ្លារណាបទៅនឹងឃ្លាច្បង។ ឈ្នាប់ចងក្នុងភាសាខ្មែរយើងមាន *និង ឬ ប៉ុន្តែ ហើយ ទាំង... ទាំង... មិន*

*ត្រឹមតែ...ថែមទាំង...ទៀតផង* ។ល។

ឧ. *នាង**មិនត្រឹមតែ**ស្អាតទេ **ថែមទាំង**សុភាពរាក់ទាក់ទៀតផង។*

***ទាំង**គេ**ទាំង**ខ្ញុំនរណាមិនចង់ល្អ។*

**២.២. ឈ្នាប់ឃ្លា**

**ឈ្នាប់ឃ្លា** គឺជាពាក្យឬកន្សោមពាក្យដែលបង្កើតឃ្លានាម ឃ្លាគុណនាម ឃ្លាទេសកាល។ ឈ្នាប់ឃ្លាក្នុងភាសាខ្មែរយើង ភាគច្រើនកើតឡើងពីពាក្យដទៃទៀតចូលផ្សំជាមួយគ្នាបង្កើតបានជាឈ្នាប់ឃ្លាមួយទៀត ហៅថាឈ្នាប់ឃ្លាផ្សំ។

ឧ. ***ប្រសិនបើ** អ្នកចង់បញ្ចុះទម្ងន់ អ្នកត្រូវបន្ថយការបរិភោគអាហារ។*

***ទោះបី** មានភ្លៀងធ្លាក់ខ្លាំង**យ៉ាងណាក៏ដោយ** **ក៏**ខ្ញុំទៅចូលរួមក្នុងកម្មវិធីជប់លៀងរបស់មិត្តភក្តិខ្ញុំ**ដែរ**។*

***ដរាបណា** វាមិននិយាយ **ដរាបនោះ** វានៅក្នុងគុកតទៅទៀត។*

ពាក្យនិងសម្ព័ន្ធពាក្យ *ប្រសិនបើ ទោះ...យ៉ាងណាក៏ដោយ ក៏ ដរាបណា...ដរាបនោះ* ជាឈ្នាប់ឃ្លាសម្រាប់ភ្ជាប់ឃ្លាច្បងទៅនឹងឃ្លារណបនៅក្នុងល្បះផ្សំខាងលើ។ ល្បះដែលនៅពីខាងស្តាំឈ្នាប់ឃ្លាហៅថា ឃ្លារណប។ ឈ្នាប់ឃ្លាមាន៖

**-ឈ្នាប់ឃ្លាទោល៖** *ពេល កាល បើ ទំរាំ ព្រោះ ក្រែង ដើម្បី ក្រោយ ទោះ ដូច្នេះ អ៊ីចឹង*។ល។

**-ឈ្នាប់ឃ្លាផ្សំ៖** *ក្រោយពី បន្ទាប់ពី នៅពេល រហូតដល់ ប្រសិនបើ ទាល់តែ ចាប់តាំងពី ហាក់បីដូច ពីព្រោះ មុននឹង ទោះបីជា ថ្វីត្បិតតែ ដូច្នេះហើយ ដោយសារ ព្រោះតែ ដោយហេតុតែ ក្នុងពេលដែល ក្នុងខណៈដែល ក្រែងលោ*។ល។

**៣. បម្រើបម្រាស់ឈ្នាប់ឃ្លា**

តាមការប្រើប្រាស់ឈ្នាប់ឃ្លាអាចប្រើជា៖

**-សម្រាប់បង្ហាញពេលវេលាឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឈ្នាប់ឃ្លាទាំងនេះមាន៖ *ពេល កាល នៅពេល បន្ទាប់ពី ក្រោយពី រហូតដល់ ក្នុងពេលដែល ទំរាំ ទាល់តែ* ។ល។

ឧ. *គាត់មើលសៀវភៅ**ទំរាំ**តែម្តាយគាត់មកដល់។*

*គាត់បានមកដល់ផ្ទះ **បន្ទាប់ពី**អ្នកត្រលប់ទៅផ្ទះវិញ។*

**-សម្រាប់បង្ហាញទីកន្លែងឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឈ្នាប់ទាំងនេះមាន៖ *កន្លែងណា នៅទីកន្លែងណាមួយ ទីណាមួយ ទីណា*។ល។

ឧ.　*ខ្ញុំនឹងទៅរកគាត់នៅ**កន្លែងណាមួយ**ដែលគាត់ធ្លាប់ទៅ។*

*សូមដាក់សៀវភៅនៅ**កន្លែងណា**ដែលស្រួលរក។*

**-សម្រាប់បង្ហាញបែបបទឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឃ្នាប់ឃ្លានេះមាន៖ *ដូចជា ហាក់បីដូចជា*។ល។

ឧ.　*គាត់និយាយ**ដូចជា**គាត់ដឹងអ្វីៗទាំងអស់។*

*នាងសួរខ្ញុំ**ដូចជា** នាងមិនយល់អ្វីទាំងអស់។*

**-សម្រាប់បង្ហាញមូលហេតុឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឃ្នាប់ឃ្លានេះមាន៖ *ព្រោះ ពីព្រោះ ដោយសារ ដោយមូលហេតុ...*។

ឧ.　*ឯងត្រូវតែរុំខ្លួនឱ្យជិត **ព្រោះ**មេឃត្រជាក់ខ្លាំង។*

*សត្វទាំងអស់នេះ រស់រានមានជីវិតបាន **ដោយសារ**គេចិញ្ចឹមវា។*

**-សម្រាប់បង្ហាញលទ្ធផលឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឃ្នាប់ឃ្លានេះមាន៖ *ដូច្នេះ ដូចនេះហើយ*។ល។

ឧ.　*ហាងបិទទាំងអស់ **ដូច្នេះហើយ**យើងមិនអាចទិញអ្វីបានឡើយ។*

**-សម្រាប់ប្រៀបធៀបអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឃ្នាប់ឃ្លានេះមាន៖ *ដូច ដូចជា ប៉ុនគ្នានឹង ស្មើគ្នានឹង ជាង*។ល។

ឧ.　*ចូរអ្នកធ្វើ **ដូច**គាត់និយាយប្រាប់។*

*វាសរសេរពូកែ **ជាង**វានិយាយ។*

**-សម្រាប់បង្ហាញបំណងឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឃ្នាប់ឃ្លានេះមាន៖ *ដើម្បី ដើម្បីនឹង ដើម្បីកុំឱ្យ ខ្លាច មិនឱ្យ កុំឱ្យ*។ល។

ឧ.　*គាត់ក្លែងខ្លួន**ដើម្បី**មិនឱ្យគេស្គាល់គាត់។*

*យើងប្រយុទ្ធគ្មានខ្លាចស្លាប់**ដើម្បី**ប្រទេសយើងបានឯករាជ្យ។*

**-សម្រាប់បង្ហាញទំនាស់ឱ្យអំពើរបស់កិរិយានៅក្នុងល្បះផ្សំ**

ឃ្នាប់ឃ្លានេះមាន៖ ទោះ ទោះបី ទោះជា ទោះបីជា ប៉ុន្តែ តែ។ល។

ឧ.　*ខ្ញុំចេញទៅដើរលេង **ទោះបី**ភ្លៀងក៏ដោយ។*

***ទោះបីជា**ខ្ញុំអង្វរគាត់យ៉ាងណាក៏ដោយ ក៏គាត់នៅតែបដិសេធ។*

# មេរៀនទី១២
# ឧទានសព្ទ

**១. និយមន័យ**

**ឧទានសព្ទ** គឺជាពាក្យមួយម៉ាត់ឬជាកន្សោមពាក្យដែលនៅខាងដើមល្បះសម្រាប់ប្រាប់ប្រតិកម្មទាក់ទងនឹងការជាប់ចិត្តយ៉ាងខ្លាំងក្លា ការព្រមាន ការភ្ញាក់ផ្អើល ការងឿងឆ្ងល់ ការខ្លាច សេចក្ដីលំបាកចិត្តខ្លាំង ការមិនយល់ស្រប (ឃិន សុខ, ២០០៧)។

**ឧទានសព្ទ** គឺជាពាក្យគ្រាប់សូរធម្មជាតិឬជាពាក្យសម្រាប់សម្ដែងចំណាប់អារម្មណ៍ភ្លាមៗ (ក្រសួងអប់រំ, ១៩៨២)។

**២. ប្រភពឧទានសព្ទ**

បើមើលតាមរូបសាស្ត្រ ឧទានសព្ទកើតមកពីប្រភពដូចខាងក្រោម៖

-ឧទានសព្ទអាចជាសម្រែកឬសំឡេងគ្រាប់តាម៖ ស្នៀងនិងកម្ពស់សំឡេងរេទៅតាមអ្នកនិយាយ។

ឧ. *អេ ហ្អេ ហ៊ែ្អ យី យឺះ អ៊ី អ៊ីះ អៃយ៉ូយ អូយយ៉ូយ...*។

-ឧទានសព្ទអាចជាសាធារណនាមឬអសាធារណនាមប្រើតែឯងឬប្រើជាមួយពាក្យកំណត់ន័យ។

ឧ. *ពុទ្ធោ ពុទ្ធោអើយ ព្រះអើយ ព្រះអង្គអើយ ម៉ែអើយ ម៉ែកូនអើយ...*។

-ឧទានសព្ទអាចជាកិរិយាសព្ទដែលប្រើតែឯងឬជាមួយកម្មបទឬជាមួយកិរិយាវិសេសន៍។

ឧ. *ចុយ ចុយយក្ស ងាប ងាប់ហើយ ងាប់តែម្ដង...*។

**៣. បម្រើបម្រាស់ឧទានសព្ទ**

ឧទានសព្ទត្រូវបានគេយកទៅប្រើប្រាស់ក្នុងសម្ដីដើម្បីបង្ហាញពីគោលបំណងផ្សេងៗពីគ្នា។ គោលបំណងទាំងនោះមានដូចជា៖

-សម្រាប់ឧទ្ទិសដល់ព្រះពុទ្ធ

ឧ. ***ពុទ្ធោអើយ!*** *ធ្វើម្ដេចបានលុយខ្ញុំ។*

***ព្រះអើយ!*** *ខ្ញុំមិនដឹងគិតយ៉ាងណាទេ។*

-សម្រាប់បង្ហាញពីអារម្មណ៍ឈឺចាប់ ការឆ្ងល់ ការភ័យខ្លាច ការស្ដាយ ការក្ដៅក្រហាយ ការព្រួយបារម្ភ ការមិនយល់ព្រម ការសើចសរសើរ ការសប្បាយ ការភ្ញាក់ផ្អើល...។

ឧ. ***ងាប់ហើយ!*** *យ៉ាងម៉េចទៀត ទាំងអស់គ្នាជួយស្ដាប់។*

***ងាប់តែម្ដង!*** *វាហ៊ានជេរលោកគ្រូ។*

***ចុយយក្ស!*** *ខ្លោចអស់។*

***ចុមកណ្ដុំឆែប!*** *ខ្មៅចអស់។*

***ហ្អាក!*** *ម៉េចក៏ធ្វើអ៊ីចឹង។*

# មេរៀនទី១៣
# កន្សោមពាក្យ

## ១. បញ្ញត្តិនៃកន្សោមពាក្យ

ក្នុងភាសាខ្មែរ គេនិយមប្រើពាក្យ "កន្សោមពាក្យ" ដែលត្រូវនឹងពាក្យក្នុងភាសាអង់គ្លេសថា "Phrase"។ ខាងក្រោមនេះជាអំណោយន័យខ្លះៗអំពីកន្សោមពាក្យ៖

ឯកតាសម្ព័ន្ធដែលកើតពីក្រុមពាក្យពីរឬច្រើន គឺជាកន្សោមពាក្យ" (Robert Freidin, 2012)។

វចនានុក្រមភាសាវិទ្យារបស់សាកលវិទ្យាល័យអុកស្វឺត បានពន្យល់ថា "កន្សោមពាក្យ គឺ (១) ជាឯកតាសម្ព័ន្ធដែលពុំមែនជាឃ្លានោះទេ។ បើនិយាយឱ្យជាក់លាក់បន្តិចទៅ កន្សោមពាក្យជាឯកតាធំបំផុតដែលមានពាក្យខ្លះស្ថិតក្នុងប្រភេទជាក់លាក់ណាមួយ ជាធាតុបង្គោល ជាតួយ៉ាង the government in Moscow ជាកន្សោមពាក្យមួយដែលមានធាតុបង្គោលគឺ government ដែលនៅនាំមុខកន្សោមពាក្យ in Moscow។ (២) ជាឯកតាសម្ព័ន្ធណាមួយដែលមានលើសពីមួយពាក្យ តែពុំមែនជាល្បះទាំងមូលនោះទេ" (Mattews PH.,1997)។

ចំណែកវចនានុក្រមភាសាវិទ្យានិងសូរវិទ្យា "កន្សោមពាក្យ គឺជាបច្ចេកសព្ទដែលមានប្រើនៅក្នុងការវិភាគវេយ្យាករណ៍ ដោយសំដៅទៅលើធាតុនៃរចនាសម្ព័ន្ធមួយដែលជាទូទៅមានពាក្យលើសពីមួយ តែមិនមែនជាឃ្លាទេ" (Crystal D., 2008)។

អំណោយន័យខាងលើ មានលក្ខណៈរួមគ្នាច្រើន។ ជារួមមក **កន្សោមពាក្យ** គឺជាក្រុមពាក្យដែលមានតួនាទីផ្នែកសម្ព័ន្ធច្បាស់លាស់នៅក្នុងល្បះ។ កន្សោមពាក្យស្ថិតនៅចន្លោះពាក្យនិងឃ្លា។

## ២. ប្រភេទកន្សោមពាក្យ

កន្សោមពាក្យមាន៥ប្រភេទ គឺកន្សោមនាម កន្សោមកិរិយា កន្សោមគុណនាម កន្សោមគុណកិរិយា និងកន្សោមមានធ្នាក់។

**-កន្សោមនាម៖** ធាតុបង្គោលគឺនាមដែលជាធាតុទីមួយ។ ឯធាតុទីពីរឬធាតុបន្តគឺធាតុរណបដែលស្ថិតនៅខាងស្តាំ។

ឧ. *តុល្អ* *តុ* ជាធាតុបង្គោល ឯ *ល្អ* ជាធាតុរណប

*តុល្អនេះ* *តុ* ជាធាតុបង្គោល ឯ *ល្អ* និង *នេះ* ជាធាតុរណប

-**កន្សោមកិរិយា**៖ កិរិយាជាធាតុបង្គោល។ ឯធាតុរណប គឺធាតុទីពីរ (គុណកិរិយា, កម្មបទ) ៖

ឧ. *សំដើរលឿន។*

*សុកដើរយឺត។*

*វានិយាយច្រើន។*

*កសិករធ្វើស្រែចម្ការ។*

*គាត់រៀបចំនង្គ័លរនោស់។*

-**កន្សោមគុណនាម**៖ គុណនាមជាធាតុបង្គោល។ ចំណែកឯគុណកិរិយាជាធាតុរណប។

ឧ. *គាត់មានចម្លាក់ល្អៗណាស់។*

*គាត់មានចំណេះជំនាញណាស់។*

-**កន្សោមគុណកិរិយា**៖ គុណកិរិយាទីមួយជាធាតុបង្គោល។ ឯគុណកិរិយាទីពីរជាធាតុរណប។

ឧ. *ពូសំធ្វើការលឿនណាស់។*

*វាសរសេរយឺតពេក។*

*គាត់ឆ្លើយរហ័សណាស់។*

*សុកភ្ជួរស្រែត្រង់ភ្លឹង។*

-**កន្សោមមានធ្នាក់**៖ ធ្នាក់ជាធាតុបង្គោល។ ឯធាតុរណប គឺជាធាតុទីពីរ (នាម កន្សោមនាម...)។

ឧ. *ចាបយំលើមែកឈើ។*

*សុខនិយាយជាមួយសៅ។*

**២.១. កន្សោមនាម**

**២.១.១. និយមន័យ**

**កន្សោមនាម** ជាកន្សោមពាក្យមួយដែលផ្សំគ្នាចាប់ពីពីរពាក្យឡើងទៅ អាចមានរូបរាងធំជាងនាម ពីព្រោះនាមគ្រាន់តែជាចំណាត់ថ្នាក់របស់ល្បះប៉ុណ្ណោះ។ ចំណែកកន្សោមនាមវិញ គឺផ្អែកទៅលើតួនាទីនិងមុខងាររបស់វានៅក្នុងឃ្លា ហើយវា មានតួនាទីជាប្រធាន ឬកម្មបទរបស់កិរិយាសព្ទនៅក្នុងឃ្លា។ កន្សោមនាមអាចមានមុខងារជាឧបបទ

គុណវិសេសន៍ ពង្រីក កម្មបំពេញបទ គុណប្រធាន ជាដើម (ចាន់ វឌ្ឍនា, ២០១៥)។

កន្សោមនាម គឺជាសមាសធាតុផ្សំនៃកន្សោមពាក្យដែលមាននាមជាធាតុបង្គោល។ កន្សោមនាមអាចមានមុខងារជា ប្រធាន កម្មបទ (ទីមួយឬទី២) និងកម្មបំពេញបទរបស់ធ្នាក់ (Paul R. Kroeger,, 2005)។

### ២.១.២. ទម្រង់នៃការបង្កើតកន្សោមនាម

ទម្រង់នៃការបង្កើតកន្សោមនាមមានពីរ គឺពង្រីករណបនិងពង្រីកមិនរណប។

**ក. ពង្រីករណប**

ពង្រីករណបគឺជាពាក្យឬកន្សោមពាក្យសម្រាប់ធ្វើនាមឱ្យរីក ហើយវាចំណុះឱ្យនាមបង្គោលនៅខាងឆ្វេង។

- **កន** → **ន** + **កគុ** (គុណនាមប្រក្រតីឬកន្សោមគុណនាម)

ឧ. ***សៀវភៅថ្មី*** *នៅលើតុ។*

- **កន** → **ន** + **កមធ** (កន្សោមមានធ្នាក់)

ឧ. ***និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ*** *មានវិន័យល្អ។*

- **កន** → **ន** + **កន** (កន្សោមនាម)

ឧ. ***សុខា មិត្តខ្ញុំ*** *រៀនពូកែណាស់។*

- **កន** → **ន** + **ឃ្លារណប**

ឧ. ***ទំនិញដែលខូចគុណភាព*** *ធ្វើឱ្យប៉ះពាល់ដល់សុខភាព។*

**ខ. ពង្រីកមិនរណប**

ពង្រីកមិនរណប គឺជាពាក្យឬកន្សោមពាក្យសម្រាប់ធ្វើនាមឱ្យរីក ដោយមុខងារធាតុបន្ថែមដូចគ្នាមុខងារធាតុចាស់។ បើគេលុបធាតុបន្ថែមនិងឈ្នាប់ចោល គេនឹងឃើញទម្រង់ដំបូងត្រលប់មកវិញ។ ជួនកាលពង្រីកមិនរណបភ្ជាប់ទៅនឹងធាតុចាស់ដោយដាក់បន្តផ្ទាល់ពុំមានឈ្នាប់ទេ។

- **កន** → **ន** + **ឈ** + **ន**

ឧ. *គោនិងក្របី ជាសត្វពាហនៈ។*

- **កន** → **កនរីក** + **ឈ** + **កនរីក**

ឧ. *កូនរបស់ពូសុកនិងកូនរបស់ពូសៅ ទៅសាលា។*

- **កន** → **ពង្រីកនៃកន** + **ឈ** + **ពង្រីកនៃកន**

ឧ. *កុមារឧស្សាហ៍និងឈ្លាសវៃនេះ ប្រឡងជាប់លេខមួយ។*

### ២.១.៣. វិភាគកន្សោមនាម

ក្នុងការវិភាគកន្សោមនាម យើងត្រូវវិភាគលើចំណុច៤ធំៗគឺ ប្រភេទពាក្យ ទីតាំងតួនាទី និងមុខងារ។ យើងនឹងលើយកទម្រង់កន្សោមនាមនីមួយៗមកវិភាគទៅលើធាតុសំណង់នីមួយៗដែលចូលរួមបង្កើតកន្សោមនាម។

**ពង្រីករណប**

**កន → ន + កគុ**

គុណនាមឬកន្សោមគុណនាមប្រក្រតីជាពង្រីករបស់កន្សោមនាមនៅក្នុងល្បះ។

(១) *ក្មេងល្អ គោរពឪពុកម្តាយ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *ក្មេងល្អ* ជាកន្សោមនាមដែលមានមុខងារជាប្រធានរបស់កន្សោមកិរិយា *គោរពឪពុកម្តាយ* ។ ក្នុងកន្សោមនាម *ក្មេងល្អ* មានធាតុសំណង់ពីរ គឺ *ក្មេង*ដែលជានាមបង្គោលនៅខាងឆ្វេង និង *ល្អ*ជាគុណនាមប្រក្រតីនិងជាធាតុពង្រីករបស់នាម *ក្មេង*នៅខាងស្តាំ។ ដូចនេះធាតុពង្រីក *ល្អ* មានមុខងារជាគុណបទ ជួយបញ្ជាក់ន័យឱ្យនាមបង្គោល *ក្មេង*។

យើងអាចតាងកន្សោមនាមខាងលើដូចនេះ៖

-ប្រអប់




-មែកធាងឬចង្កោម




**កន → ន + កមធ**

(២) ***និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ** មានវិន័យល្អ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ* ជាកន្សោមនាមដែលមានមុខងារជាប្រធានរបស់កន្សោមកិរិយា *មានវិន័យ*

ល្អ ។ ក្នុងកន្សោមនាម *និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ* មានធាតុសំណង់ពីរ គឺ *និស្សិត*ដែលជានាមបង្គោលនៅខាងឆ្វេង និង *នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ* ជាកន្សោមមានធ្នាក់ និងជាធាតុពង្រីករបស់នាម*និស្សិត*នៅខាងស្តាំ។ ដូចនេះធាតុពង្រីក *នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ* មានមុខងារជាកម្មបំពេញបទ ជួយបញ្ជាក់ន័យឱ្យនាមបង្គោល*និស្សិត*។

យើងអាចតាងកន្សោមនាមខាងលើដូចនេះៈ

**-ប្រអប់**




**-មែងធាងឬចង្កោម**




**ពង្រីកមិនរណប**

**កន → ន + ឈ + ន**

(១) *គោនិងក្របីជាសត្វពាហនៈ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះៈ *គោនិងក្របី* ជាកន្សោមនាមដែលមានមុខងារជាប្រធានរបស់កន្សោមកិរិយា *ជាសត្វពាហនៈ*។ ក្នុងកន្សោមនាម *គោនិងក្របី* មានធាតុសំណង់បី គឺ *គោ ក្របី* ដែលជានាមបង្គោលនៅខាងឆ្វេងនិងខាងស្តាំនៃឈ្នាប់ចង *និង*។ ដូចនេះធាតុពង្រីក *និងក្របី* ជាពង្រីកមិនរណប។

យើងសង្កេតឃើញថា *ក្របី* ក៏ជាប្រធានរបស់ *ជា* ដូច *គោ* ដែរ។ ចំណែកឯ *និង* ជាឈ្នាប់សម្រាប់ចងនាមបង្គោល *គោ* ឱ្យជាប់នឹង *ក្របី*។

ល្បះនេះចេញមកអំពីៈ

*-គោជាសត្វពាហនៈ។*

*-ក្របីជាសត្វពាហនៈ។*

→ *គោនិងក្របីជាសត្វពាហនៈ។*

ក្នុងល្បះនេះ មាន «ពង្រីកមិនរណប» កាលណា «មុខងារធាតុបន្ថែម» ដូចគ្នានឹង «មុខងារធាតុចាស់»។ បើគេលុប «ធាតុចាស់» និងឈ្នាប់ចោលគេនឹងឃើញ «ទម្រង់ដំបូង» ត្រលប់មកវិញ។

យើងអាចតាងកន្សោមនាមខាងលើជាមែកធាងដូចខាងក្រោមៈ




**កន → កនរីក + ឈ + កនរីក**

(២) *កូនរបស់ពូសុកនិងកូនរបស់ពូសៅ ទៅសាលា។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះៈ *កូនរបស់ពូសុខនិងកូនរបស់ពូសៅ* ជាកន្សោមនាមដែលមានមុខងារជាប្រធានរបស់កន្សោមកិរិយា *ទៅសាលា* ។ ក្នុងកន្សោមនាម *កូនរបស់ពូសុខ* ជាកន្សោមនាមរីកធាតុសំណង់ពីរ គឺ *កូន* ដែលជានាមបង្គោលនៅខាងឆ្វេង និង *របស់ពូសុខ* ជាធាតុពង្រីកដែលមានមុខងារជាកម្មបំពេញបទ។ រីឯកន្សោមនាមមួយទៀត គឺ *កូនរបស់ពូសៅ* ដែលជាពង្រីកមិនរណបព្រោះផ្នែកនេះមានឈ្នាប់ចង *និង* ដែលសម្រាប់ចងភ្ជាប់កន្សោមនាម *កូនរបស់ពូសុខ* ទៅនឹង *កូនរបស់ពូសៅ*។ ដូចនេះធាតុពង្រីក *និងកូនរបស់ពូសៅ* ជាពង្រីកមិនរណប។

ល្បះនេះចេញមកអំពីល្បះពីរខាងក្រោមនេះៈ

*- កូនរបស់ពូសុក ទៅសាលា។*

*- កូនរបស់ពូសៅ ទៅសាលា។*

→ *កូនរបស់ពូសុកនិងកូនរបស់ពូសៅទៅសាលា។*

កន្សោមនាមរីក *កូនរបស់ពូសុក* និងកន្សោមនាមរីក *កូនរបស់ពូសៅ* មានមុខងារដូចគ្នា គឺជាប្រធានរបស់កិរិយា *ទៅសាលា*។

យើងអាចតាងកន្សោមនាមខាងលើជាមែកធាងដូចខាងក្រោម៖




### ២.២. កន្សោមគុណនាម

### ២.២.១. និយមន័យ

**កន្សោមគុណនាម** ជាកន្សោមពាក្យដែលមានគុណនាមជាបង្គោល ហើយត្រូវគេប្រើបញ្ជាក់លក្ខណៈឱ្យនាម។ នៅក្នុងល្បះ វាមានមុខងារជាពង្រីករបស់នាម។

### ២.២.២. ទម្រង់នៃការបង្កើតកន្សោមគុណនាម

**កគុ** → **គុ**

ឧ. *ម្ដាយខ្ញុំជាមនុស្សល្អ។*

**កគុ** → **គុ** + **គុណ**

ឧ. *គាត់មានដីស្រែច្រើនណាស់។*

**កគុ** → **គុ** + **គុណ** + **គុណ**

ឧ. *គាត់មានគំនិតល្អខ្លាំងណាស់។*

**កគុ** → **គុ** + **គុណ** + **កន**

ឧ. *សៅជាក្មេងឧស្សាហ៍ជាងសាន។*

**កគុ** → **គុ** + **គុណ** + **កមធ**

ឧ. *នាងមានគំនិតឈ្លាសវៃណាស់ខាងកិច្ចការផ្ទះ។*

**កគុ** → **គុ** + **កមធ** + **គុណ** + **កន**

ឧ. *គាត់មានប្រាជ្ញាឈ្លាសវៃខាងភាសាជាងសាន។*

### ២.២.៣. វិភាគកន្សោមគុណនាម

**កគុ → គុ + គុណ**

(១) *គាត់មានដីស្រែច្រើនណាស់។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *ច្រើនណាស់* ជាកន្សោមគុណនាមដែលមានធាតុ*ច្រើន*ជាគុណនាមប្រក្រតី និងជាធាតុបង្គោល ហើយធាតុ*ណាស់*ជាគុណកិរិយាកម្រិត និងជាធាតុរណប។ កន្សោមគុណនាម *ច្រើនណាស់* មានមុខងារជាគុណបទនិងពង្រីករបស់នាមបង្គោល *ដីស្រែ*។ ក្នុងកន្សោមគុណនាម *ច្រើនណាស់* មានធាតុសំណង់ពីរ គឺ *ច្រើន*ដែលជាគុណនាមបង្គោលនៅខាងឆ្វេង និង *ណាស់* ជាគុណកិរិយាកម្រិតសម្រាប់បញ្ជាក់ន័យឱ្យគុណនាម*ច្រើន* ហើយនៅខាងស្តាំ។ ដូចនេះកន្សោមគុណនាម មានមុខងារជាគុណបទ និងធាតុពង្រីករបស់នាម ហើយប្រើបញ្ជាក់ន័យឱ្យនាមនៅខាងឆ្វេងវា។

យើងអាចតាងកន្សោមគុណនាមខាងលើដូចនេះ៖

**-ប្រអប់**




**-មែកធាងឬចង្កោម**




**កគុ → គុ + គុណ + កន**

(២) *សៅជាក្មេងឧស្សាហ៍ជាងសាន។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *ឧស្សាហ៍ជាងសាន* ជាកន្សោមគុណនាមដែលមានធាតុ*ឧស្សាហ៍* ជាគុណនាមប្រក្រតី និងជាធាតុបង្គោល ហើយធាតុ *ជាងសាន* ជាធាតុរណបដែល*ជាង*ជាគុណកិរិយា និង*សាន* ជានាម។ កន្សោមគុណនាម

*ឧស្សាហ៍ជាងសាន* មានមុខងារជាគុណបទនិងពង្រីករបស់នាមបង្គោល *ក្មេង*។ ក្នុងកន្សោមគុណនាម *ឧស្សាហ៍ជាងសាន* មានធាតុសំណង់បី គឺ *ឧស្សាហ៍* ដែលជាគុណនាមបង្គោលនៅខាងឆ្វេង និង *ជាង*និង *សាន* ជាធាតុបញ្ជាក់ន័យឱ្យគុណនាម *ឧស្សាហ៍* ហើយនៅខាងស្តាំ។

យើងអាចតាងកន្សោមគុណនាមខាងលើជាមែកធាងដូចខាងក្រោម៖




## ២.៣. កន្សោមកិរិយា

### ២.៣.១. និយមន័យ

**កន្សោមកិរិយា** គឺជាផ្នែកមួយនៃល្បះ នៅបន្ទាប់ពីកន្សោមនាមប្រធាន។ វាមានមុខងារជាបម្រាប់ប្រធាន។

ឧ. *សុកដើរ។*

*សំទទួលភ្ញៀវ។*

*សានជាសិស្សឧស្សាហ៍។*

*គាត់ទិញសៀវភៅឱ្យមិត្តគាត់។*

ក្នុងល្បះ កិរិយាសព្ទមានមុខងារសំខាន់ណាស់។ វាជាស្នូលនិងជាបង្គោលរបស់ល្បះ។ កិរិយាតែមួយអាចបង្កើតល្បះមួយបាន។

ឧ. *ទៅ!*

-កិរិយាសុទ្ធសកម្ម៖ ឧ. *សិស្សរៀនចំណោទ។*

-កិរិយាសុទ្ធអកម្ម៖ ឧ. *កូនដើរ។*

-កិរិយាហេតុសកម្ម៖ ឧ. *លោកគ្រូបង្រៀនចំណោទដល់សិស្ស។*

-កិរិយាផ្សំ៖ ឧ. *សុវណ្ណចូលចិត្តបន្លែស្រស់។*

ឧ. *ជំងឺនេះធ្វើឱ្យមិត្តយើងស្លាប់។*

-គុណនាម (ប្រើជាកិរិយា) ៖ ឧ. *យុវនារីនេះស្អាតផងល្អផង។*

### ២.៣.២. ទម្រង់នៃការបង្កើតកន្សោមកិរិយា

**កកិ** → **កិ**

ឧ. *ក្មេងយំ។*

**កកិ** → **កិ** + **កន**

ឧ. *កូនសិស្សស្ដាប់លោកគ្រូ។*

**កកិ** → **កិ** + **កមធ**

ឧ. *អ្នកគ្រូនិយាយជាមួយសំ។*

**កកិ** → **កិចំណង** + **កន**

ឧ. *សំជាសិស្ស។*

**កកិ** → **កិ** + **កន** + **កមធ**

ឧ. *សុកជូនផ្លែឈើដល់ម្ដាយវា។*

### ២.៣.៣. វិភាគកន្សោមកិរិយា

**កកិ** → **កិ** + **កន**

(១) *កូនសិស្សស្ដាប់លោកគ្រូ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖

*ស្ដាប់លោកគ្រូ* ជាកន្សោមកិរិយាដែលមានមុខងារជាបម្រាប់ប្រធានរបស់កន្សោមនាមប្រធាន *កូនសិស្ស*។ ក្នុងកន្សោមកិរិយា *ស្ដាប់លោកគ្រូ* មានធាតុសំណង់ពីរ គឺ *ស្ដាប់* ដែលជាកិរិយាបង្គោលនៅខាងឆ្វេង និង *លោកគ្រូ*ជាកន្សោមនាម និងជាកម្មបទផ្ទាល់របស់កិរិយា *ស្ដាប់*នៅខាងស្ដាំ។

យើងអាចតាងកន្សោមកិរិយាខាងលើដូចនេះ៖

**-ប្រអប់**



-មែកធាងឬចង្កោម




**កកិ → កិ + កមធ**

(២) អ្នកគ្រូ*និយាយជាមួយសំ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *និយាយជាមួយសំ* ជាកន្សោមកិរិយាដែលមានមុខងារជាបម្រាប់ប្រធានរបស់កន្សោមនាមប្រធាន *អ្នកគ្រូ*។ ក្នុងកន្សោមកិរិយា *និយាយជាមួយសំ* មានធាតុសំណង់ពីរ គឺ*និយាយ*ដែលជាកិរិយាបង្គោលនៅខាងឆ្វេង និង*ជាមួយសំ*ជាកន្សោមមានធ្នាក់ និងជាកម្មបទមិនផ្ទាល់របស់កិរិយា*និយាយ*នៅខាងស្ដាំ។

យើងអាចតាងកន្សោមកិរិយាខាងលើជាមែកធាងដូចខាងក្រោម៖




## ២.៤. កន្សោមគុណកិរិយា

### ២.៤.១. និយមន័យ

កន្សោមគុណកិរិយា គឺជាកន្សោមពាក្យដែលមានគុណកិរិយាជាធាតុបង្គោលនិងធាតុផ្សេងៗទៀតហើយវាមានតួនាទីជាកម្មបទរបស់គុណនាម គុណកិរិយា និងកិរិយានៅក្នុងល្បះ។ កន្សោមគុណកិរិយាអាចមានតួនាទីជាកន្សោមកម្មទេសកាលដែលបង្ហាញអំពីពេលវេលានិងទីកន្លែង។

ឧ. *សៅរៀនខ្សោយណាស់។*

*សានរៀនពូកែខាងអក្សរសាស្ត្រខ្មែរ។*

យើងសង្កេតឃើញថា *ខ្សោយណាស់ ពូកែខាងអក្សរសាស្ត្រ* ជាកន្សោមពាក្យ

ដែលស្ថិតក្នុងកន្សោមកិរិយា ហើយបញ្ជាក់ន័យឱ្យកិរិយាសព្ទនៅខាងមុខវា។

**២.៤.២. ទម្រង់នៃការបង្កើតកន្សោមគុណកិរិយា**

កន្សោមគុណកិរិយាមានទម្រង់ដូចខាងក្រោមនេះ៖

**កគុណ → គុណ**

ឧ. *សៅដើរលឿន ។*

*គាត់បើកម៉ូតូក៏បាន បើករថយន្តក៏បាន។*

**កគុណ → គុណ + គុណ**

ឧ. *សៅដើរលឿនណាស់។*

**កគុណ → គុណ + កមធ**

ឧ. *សានរៀនពូកែខាងប្រវត្តិសាស្ត្រ។*

**កគុណ → គុណ + គុណ + កមធ**

ឧ. *គាត់រៀនពូកែណាស់ខាងអក្សរសាស្ត្រ។*

**កគុណ → គុណ + កមធ + គុណ + កន**

ឧ. *គាត់រៀនពូកែខាងគណិតវិទ្យាជាងសំ។*

**២.៤.៣. វិភាគកន្សោមគុណកិរិយា**

**កគុណ → គុណ + គុណ**

(១) *សៅដើរលឿនណាស់ ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *លឿនណាស់* ជាកន្សោមគុណកិរិយាដែលមានមុខងារជាគុណវិសេសន៍សម្រាប់បញ្ជាក់ន័យឱ្យកិរិយា *ដើរ*។ ក្នុងកន្សោមគុណកិរិយា *លឿនណាស់* មានធាតុសំណង់ពីរ គឺ *លឿន*ដែលជាគុណកិរិយាបំណែបនិងជាធាតុបង្គោលនៅខាងឆ្វេង និង *ណាស់*ជាគុណកិរិយាកម្រិតដែលមានមុខងារបញ្ជាក់ន័យឱ្យគុណកិរិយា *លឿន*នៅខាងស្តាំ។

យើងអាចតាងកន្សោមគុណកិរិយាខាងលើដូចនេះ៖

**-ប្រអប់**



-មែកធាងឬចង្កោម




**កគុណ → គុណ + កមធ**

(២) *សានរៀនពូកែខាងប្រវត្តិសាស្ត្រ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះៈ *ពូកែខាងប្រវត្តិសាស្ត្រ* ជាកន្សោមគុណកិរិយាដែលមានមុខងារជាគុណវិសេសន៍សម្រាប់បញ្ជាក់ន័យឱ្យកិរិយា *រៀន*។ ក្នុងកន្សោមគុណកិរិយា *ពូកែខាងប្រវត្តិសាស្ត្រ* ដែលកើតឡើងដោយមានធាតុសំណង់ពីរ គឺ*ពូកែ*ដែលជាគុណកិរិយាបំណែបនិងជាធាតុបង្គោលនៅខាងឆ្វេង និង *ខាងប្រវត្តិសាស្ត្រ*ជាកន្សោមមានធ្នាក់ដែលមានមុខងារបញ្ជាក់ន័យឱ្យគុណកិរិយា *ពូកែ*នៅខាងស្តាំ។

យើងអាចតាងកន្សោមគុណកិរិយាខាងលើជាមែកធាងដូចខាងក្រោមៈ




## ២.៥. កន្សោមមានធ្នាក់

### ២.៥.១. និយមន័យ

**កន្សោមមានធ្នាក់** គឺជាកន្សោមពាក្យដែលមានធ្នាក់ជាធាតុបង្គោល និងកម្មបទរបស់វា។ ជាទូទៅ កន្សោមមានធ្នាក់ប្រើបញ្ជាក់ន័យឱ្យកិរិយាសព្ទ គុណកិរិយា ឬនាម។ កន្សោមមានធ្នាក់មានមុខងារជាពង្រីកឱ្យគុណនាម គុណកិរិយា កិរិយាសព្ទ នាម និងកន្សោមមានធ្នាក់ ហើយក៏ជាកម្មបទមិនផ្ទាល់និងកម្មបទទីពីររបស់កិរិយាសព្ទ។ ម្យ៉ាងទៀតកន្សោមមានធ្នាក់ មានមុខងារជាកន្សោមមានធ្នាក់កម្មទេសកាល និងគុណកិរិយាកម្មទេសកាលរបស់កន្សោមកិរិយា នៅក្នុងល្បះផងដែរ។

ឧ.ទី១ *គាត់ធុញនឹងការងារ។*

*សិស្សម្នាក់និយាយអំពីថ្នាក់រៀន។*

*ភារៈនេះស្រេចលើខ្ញុំ។*

យើងសង្កេតឃើញថា៖

កន្សោមនាម *ការងារ ថ្នាក់រៀន ខ្ញុំ* ភ្ជាប់ទៅនឹងកិរិយាសព្ទដោយសារធ្នាក់ *នឹង អំពី លើ*។

កន្សោមនាម *នឹងការងារ.....លើខ្ញុំ* ជាកន្សោមនាមមានធ្នាក់ (កមធ)។ កន្សោមនាមទាំងនេះសម្រាប់បញ្ចប់ន័យសេចក្ដីរបស់កិរិយាសព្ទដោយបញ្ជាក់ឱ្យបានច្បាស់លាស់។ ដូចនេះ កម្មបទមិនផ្ទាល់គឺជាកន្សោមមានធ្នាក់ដែលជាធាតុកន្សោមកិរិយាសម្រាប់បញ្ចប់សេចក្ដីរបស់កិរិយាសព្ទ។

ឧ.ទី២ *សុកឱ្យសៀវភៅមួយក្បាលដល់សៅ។*

*បងវាផ្ញើសំបុត្រពីរច្បាប់ដល់ខ្ញុំ។*

*សំជូនផ្លែឈើមួយកន្ត្រកចំពោះម្ដាយវា។*

យើងឃើញថា៖

-កន្សោមនាមមានកម្មបទពីរគឺ កន (ក១) ៖ *សៀវភៅមួយក្បាល សំបុត្រពីរច្បាប់ ផ្លែឈើមួយកន្ត្រក*។

-កមធ (ក២) ៖ *ដល់សៅ ដល់ខ្ញុំ ចំពោះម្ដាយវា*។

-ធ្នាក់ដែលនៅជាប់ជាមួយកន្សោមនាមគឺ *ដល់ ចំពោះ*។

ដូចនេះ កម្មបទទី២ (ក២) គឺជាកន្សោមនាមដែលជាធាតុរបស់កន្សោមកិរិយាហើយដែលភ្ជាប់ទៅនឹងកិរិយាសព្ទដោយធ្នាក់។

ឧ.ទី៣ *មាន់ចឹកស្រូវនៅលាន។*

*យើងខំរៀនដើម្បីយល់វិទ្យាសាស្ត្រ។*

*វាប្រឡងធ្លាក់ត្បិតខ្ជិល។*

*សុកធ្វើការដោយយកចិត្តទុកដាក់។*

*សំមិនទៅរៀនព្រោះឈឺ។*

*និស្សិតលេងកីឡាដោយរីករាយ។*

ដូច្នេះ យើងសង្កេតឃើញថាកន្សោមមានធ្នាក់អាចមានទម្រង់ជាទូទៅ ធ្នាក់ផ្សំនឹងធាតុរណប។ ធាតុរណបរបស់ធ្នាក់ស្ទើរតែទាំងអស់ជានាមឬកន្សោមនាម ប៉ុន្តែយើង

សង្កេតឃើញថាធ្នាក់មួយចំនួនក៏អាចទទួលយកធាតុរណបដែលជាកិរិយាសព្ទផងដែរ។

### ២.៥.២. ទម្រង់នៃការបង្កើតកន្សោមមានធ្នាក់

កន្សោមគុណកិរិយាមានទម្រង់ដូចខាងក្រោមនេះ៖

**កមធ** → **ធ** + **កន** (**នាម ឬសព្វនាម**)

ឧ. *កុមារលេងក្នុងទីធ្លា។*

*លោកគ្រូនិយាយជាមួយខ្ញុំ។*

ក្នុងល្បះខ្លះនៅក្រោយធ្នាក់មួយចំនួនជាកន្សោមកិរិយាដែលមានមុខងារដូចជាកន្សោមនាមដែលយើងហៅថាកិរិយានាម។ ធ្នាក់ដែលអាចទទួលយកកិរិយាសព្ទបានមានដូចជា *ដោយ សម្រាប់ ដើម្បី ព្រោះ*។

ឧ. *អ្នកនេសាទទៅទន្លេដើម្បីរកត្រី។*

*គាត់ធ្វើការដោយខិតខំ។*

### ២.៥.៣. វិភាគកន្សោមមានធ្នាក់

**កមធ** → **ធ** + **កន** (**នាមឬសព្វនាម**)

(១) *កុមារលេងក្នុងទីធ្លា។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *ក្នុងទីធ្លា* ជាកន្សោមមានធ្នាក់ដែលមានមុខងារជាកម្មបទមិនផ្ទាល់និងជាកម្មទេសកាលកន្លែងរបស់កិរិយា *លេង*។ ក្នុងកន្សោមមានធ្នាក់ *ក្នុងទីធ្លា* មានធាតុសំណាង់ពីរ គឺ*ក្នុង*ដែលជាធ្នាក់និងជាធាតុបង្គោលនៅខាងឆ្វេង និង *ទីធ្លា*ជាកន្សោមនាមដែលមានមុខងារកម្មបទរបស់ធ្នាក់ *ក្នុង*នៅខាងស្តាំ។

យើងអាចតាងកន្សោមមានធ្នាក់ខាងលើដូចនេះ៖

-ប្រអប់



-មែកធាងឬចង្កោម




## ៣. មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមពាក្យ

### ៣.១. មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមនាមប្រធាន

#### ៣.១.១. គុណបទ

**គុណបទ** គឺជាមុខងារវេយ្យាករណ៍របស់គុណនាមដែលប្រើផ្ទាល់ជាមួយនាម។

ឧ. (១) *ផ្ទះធំនេះសង់ជិតផ្លូវពេក។*

(២) *កុមារនេះជាក្មេងល្អ។*

យើងសង្កេតឃើញថា *ធំ ល្អ* ជាគុណនាមប្រក្រតី ដែលមានមុខងារជាគុណបទ ហើយវាប្រើបញ្ជាក់ន័យឱ្យនាមនៅខាងមុខវា។

#### ៣.១.២. កម្មបំពេញបទរបស់នាម/កម្មរបស់នាម

កម្មបំពេញបទរបស់នាមជាពង្រីក (របស់នាម) ដែលភ្ជាប់ទៅនឹងនាមដោយសារធ្នាក់ (*នៃ របស់*)។ វាបង្ហាញឱ្យជាក់លាក់នូវមនុស្ស សត្វ វត្ថុ ដែលសម្ដែងឡើងដោយនាម។ វាកម្រិតភាពជាក់លាក់របស់នាម ដោយប្រាប់ជាពិសេសនូវម្ចាស់កម្មសិទ្ធិ។

ឧ. (១) *ភ្នំពេញជារាជធានីនៃប្រទេសកម្ពុជា។*

(២) *ផ្ទះរបស់ជីតាខ្ញុំសង់ពីឈើ។*

យើងសង្កេតឃើញថា *នៃប្រទេសកម្ពុជា* ក្នុងល្បះទី១ ជាកម្មបំពេញបទរបស់នាម *រាជធានី* និង *របស់ជីតាខ្ញុំ* ក្នុងល្បះទី២ ជាកម្មបំពេញបទរបស់នាម *ផ្ទះ*។

#### ៣.១.៣. ឧបបទ

នាមឧបបទសម្រាប់បញ្ជាក់ន័យរបស់នាមមួយទៀត ដោយសម្ដែងមនុស្ស សត្វ ឬវត្ថុដូចគ្នា។

ឧ. (១) *សៅ មិត្តខ្ញុំរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។*

(២) *សុភី និស្សិតឆ្នើម ក្លាយជាប្រធានថ្នាក់។*

យើងសង្កេតឃើញថា *មិត្តខ្ញុំ* ក្នុងល្បះទី១ ជាឧបបទរបស់នាម *សៅ* និង *និស្សិតឆ្នើម* ក្នុងល្បះទី២ ជាឧបបទរបស់នាម *សុភី* ដែលមានមុខងារជាឧបបទ។

### ៣.២. មុខងារនៃពាក្យឬកន្សោមពាក្យក្នុងកន្សោមកិរិយាបម្រាប់ប្រធាន

#### ៣.២.១. កម្មបទផ្ទាល់

កម្មបទផ្ទាល់ (កបផ) ឬក១ គឺជាកន្សោមនាមដែលជាធាតុរបស់កន្សោមកិរិយានៅជាប់នឹងកិរិយា សម្រាប់បញ្ជាក់សេចក្ដីរបស់កិរិយា។

ឧ. (១) *ទន្សាយស៊ីចេក។*

(២) *សិស្សានុសិស្សទៅសាលារៀន។*

យើងសង្កេតឃើញថា *ចេក* ជាកម្មបទផ្ទាល់របស់កិរិយាសកម្ម *ស៊ី* ក្នុងល្បះទី១ និង *សាលារៀន* ជាកម្មបទផ្ទាល់របស់កិរិយាសកម្ម *ទៅ* ក្នុងល្បះទី២។

#### ៣.២.២. កម្មបទទី២

កម្មបទទី២ (ក២) គឺជាកន្សោមនាម ដែលជាធាតុរបស់កន្សោមកិរិយា ហើយដែលភ្ជាប់ទៅនឹងកិរិយាដោយសារធ្នាក់ (ក២ ប្រាប់ទីដៅនៃអំពើ)។

ឧ. (១) *សានឱ្យសៀវភៅមួយក្បាលដល់សុក។*

(២) *សុភាពជូនផ្លែចេកមួយស្និតចំពោះម្ដាយនាង។*

យើងសង្កេតឃើញថា *ដល់សុក* ជាកម្មបទទី២ (ក២) របស់កិរិយាសព្ទ *ឱ្យ* ក្នុងល្បះទី១ និង *ចំពោះម្ដាយនាង* ជាកម្មបទទី២ (ក២) របស់កិរិយាសព្ទ *ជូន* ក្នុងល្បះទី២។ ក្នុងកម្មបទទី២ (ក២) គឺមានធ្នាក់ដែលនៅជាប់ជាមួយកន្សោមនាមដូចជា *ដល់ ចំពោះ*។

#### ៣.២.៣. កម្មបទមិនផ្ទាល់

កម្មបទមិនផ្ទាល់ (កបម) គឺជាកន្សោមនាមមានធ្នាក់ ដែលជាធាតុរបស់កន្សោមកិរិយា សម្រាប់បញ្ចប់សេចក្ដីរបស់កិរិយាសព្ទ។ ដូចនេះកម្មបទមិនផ្ទាល់ជាកន្សោមមានធ្នាក់ (កមធ)។

ឧ. (១) *សិស្សម្នាក់ៗនិយាយអំពីថ្នាក់រៀន។*

(២) *ខ្ញុំនឹកដល់ស្រុកកំណើតខ្ញុំ។*

យើងសង្កេតឃើញថា *អំពីថ្នាក់រៀន* ជាកម្មបទមិនផ្ទាល់របស់កិរិយាសព្ទ *និយាយ* ក្នុងល្បះទី១ និង *ដល់ស្រុកកំណើតខ្ញុំ* ជាកម្មបទមិនផ្ទាល់របស់កិរិយាសព្ទ *នឹក* ក្នុងល្បះទី២។

#### ៣.២.៤. កម្មភ្នាក់ងារ

**កម្មភ្នាក់ងារ** គឺជាកម្មដែលប្រើសម្រាប់សម្គាល់អ្នកធ្វើអំពើនៅក្នុងល្បះកម្ម។

ឧ. (១) *ប្រាសាទអង្គរវត្តត្រូវបានកសាងឡើងដោយព្រះបាទសូរ្យវរ្ម័នទី២។*

(២) *រឿងកុលាបប៉ៃលិនត្រូវបាននិពន្ធដោយលោក ញ៉ុក ថែម។*

យើងសង្កេតឃើញថា *ដោយព្រះបាទសូរ្យវរ្ម័នទី២* ជាកម្មភ្នាក់ងារនៃកន្សោមកិរិយា *ត្រូវបានកសាងឡើង* ក្នុងល្បះទី១ និង *ដោយលោក ញ៉ុក ថែម* ជាកម្មភ្នាក់ងារនៃកន្សោមកិរិយា *ត្រូវបាននិពន្ធ* ក្នុងល្បះទី២។

### ៣.២.៥. គុណប្រធាន

គុណប្រធាន គឺជាកន្សោមនាម ដែលជាធាតុរបស់កិរិយាសព្ទនៅជាប់នឹងកិរិយាសម្រាប់បង្ហាញឯកលក្ខណភាពនៃប្រធាន ឬសភាពលក្ខណៈនៃប្រធាន។

ឧ. (១) *ប៊ុនធឿនជានិស្សិត។*

(២) *គាត់ឡើងជាមេឃុំ។*

យើងសង្កេតឃើញថា កន្សោមនាម *និស្សិត មេឃុំ* នៅខាងស្តាំកិរិយាសព្ទ *ជា* ហើយវាជាគុណប្រធានរបស់កន្សោមនាមប្រធាន *ប៊ុនធឿន គាត់*។

**កំណត់សម្គាល់៖**

ក្រៅអំពីគុណរបស់ប្រធាន ឬគុណប្រធាន ដែលសម្តែងបុគ្គល ឬលក្ខណៈទាក់ទងនឹងប្រធាន មានគុណរបស់នាមមួយបែបទៀត ហៅថា គុណរបស់កម្មបទ ឬគុណកម្មបទ ដែលសម្តែងបុគ្គលដូចគ្នានឹងកម្មបទ ដូចជា៖

(១) *គេដាក់ងារសៅថាអាញូង។* (សៅគឺអាញូង)

(២) *គេហៅគាត់ថាលោកតា។* (គាត់គឺលោកតា)

(៣) *គេរើសគាត់ជាប្រធាន។* (គាត់គឺប្រធាន)

### ៣.២.៦. កម្មទេសកាល

កម្មទេសកាល គឺសម្រាប់ចង្អុលបង្ហាញទីកន្លែង កាល បំណង បែបបទ ហេតុជាដើមរបស់អំពើឬសភាពដែលសម្តែងឡើងដោយកិរិយាសព្ទ។

ឧ. (១) *ខ្ញុំដេកលើគ្រែ។*

(២) *យើងរៀនដើម្បីយល់វិទ្យាសាស្ត្រ។*

យើងសង្កេតឃើញថា *លើគ្រែ* ជាកម្មទេសកាលកន្លែង ឬកម្មកន្លែងរបស់ល្បះ *ខ្ញុំដេក* ក្នុងល្បះទី១ និង *ដើម្បីយល់វិទ្យាសាស្ត្រ* ជាកម្មទេសកាលបំណង ឬកម្មបំណងរបស់ល្បះ *យើងរៀន* ក្នុងល្បះទី២។

សំណួរសួររកកម្មទេសកាល៖

**-កម្មទេសកាលកន្លែងឬកម្មកន្លែង**

*-សំទៅចម្ការ។*

*-សំទៅណា ?*

**-កម្មទេសកាលកាលឬកម្មកាល**

*-សំមកដល់ពីម្សិលមិញ ។*

*-សំមកដល់ពីអង្កាល់ ?*

**-កម្មទេសកាលបែបបទឬកម្មបំណែប**

*-សៅដើរដោយសប្បាយ ។*

*-សៅដើរដូចម្តេច ?*

**-កម្មទេសកាលហេតុឬកម្មហេតុ**

*-គាត់ទៅផ្សារព្រោះខ្វះម្ហូប ។*

*-គាត់ទៅផ្សារព្រោះអ្វី ?*

**-កម្មទេសកាលបំណងឬកម្មបំណង**

*-គាត់រៀនដើម្បីចេះដឹង។*

*-គាត់រៀនដើម្បីអ្វី ? ក្នុងគោលបំណងអ្វី ?*



# មេរៀនទី១៤

## ល្បះ

### ១. និយមន័យ

ឧ. *មុនីចូលចិត្តម្ហូបខ្មែរ។*

*បងវាចូលចិត្តម្ហូបខ្មែរ។*

*មាវាចូលចិត្តម្ហូបខ្មែរ។*

*មុនីតែងសៀវភៅនេះ។*

*មុនីមើលក្តារខៀន។*

*មុនីស្តាប់លោកគ្រូ។*

**ពិនិត្យឧទាហរណ៍៖**

ឧទាហរណ៍ខាងលើបង្ហាញឱ្យឃើញថា៖

-ក្រុមពាក្យនីមួយៗបញ្ចប់ដោយសញ្ញា (។)

-ក្នុងក្រុមពាក្យមួយខណ្ឌៗ សង្កាត់ពាក្យពីរកន្លែងអាចផ្លាស់បាននឹងសង្កាត់ពាក្យដទៃទៀត ដែលមានលក្ខណៈសមស្រប ដូចជាសង្កាត់ពាក្យកន្លែងទី១ *"មុនី"* អាចផ្លាស់គ្នានឹង *"បងវា"* ឬ *"មាវា"*។

សង្កាត់ពាក្យកន្លែងទី២ *"ចូលចិត្តម្ហូបខ្មែរ"* អាចផ្លាស់គ្នានឹង *"តែងសៀវភៅនេះ"* ឬ *"មើលក្តារខៀន"*...។

សង្កាត់ពាក្យមួយកន្លែងៗ ដូចនេះហៅថា "កន្សោមពាក្យ"។ ហើយកន្សោមពាក្យនេះចែកជា៖

-កន្សោមនៅខាងឆ្វេងហៅថា កន្សោមនាម

-កន្សោមនៅសល់ហៅថា កន្សោមកិរិយា។

ដូចនេះ ល្បះគឺជាបន្សំរវាងកន្សោមពាក្យនិងកន្សោមពាក្យ។ វាមានន័យគ្រប់គ្រាន់ស្តាប់បាន។ ល្បះនីមួយៗបញ្ចប់ដោយសញ្ញាខណ្ឌ (។) សញ្ញាសួរ (?) ឬសញ្ញាឧទាន (!) ក្នុងការសរសេរ។

ល្បះនីមួយៗកើតឡើងដោយកន្សោមពាក្យពីរផ្នែក ដែលជាធាតុសំណង់របស់ខ្លួន។ ក្នុងកន្សោមពាក្យទី១ ពាក្យសំខាន់ជានាម ឯក្នុងកន្សោមពាក្យទី២ ពាក្យសំខាន់ជា

កិរិយា។ ដូចនេះ កន្សោមពាក្យទី១ ហៅថា «កន្សោមនាម» ឯកន្សោមពាក្យទី២ ហៅថា «កន្សោមកិរិយា»។

សរុបមក យើងអាចនិយាយថា ល្បះនីមួយៗកើតឡើងជាចាំបាច់ដោយសារកន្សោមនាមនិងកន្សោមកិរិយា។

យើងអាចសរសេរដូចនេះ៖

ល → កន + កកិ

↓ ល្បះ ↓ កន្សោមនាម ↓ កន្សោមកិរិយា

កន្សោមកិរិយាកើតឡើងដោយសារកិរិយានិងកន្សោមនាម។ កន្សោមកិរិយាអាចសរសេរដូចនេះ ៖

កកិ → កិ + កន

↓ កន្សោមកិរិយា ↓ កិរិយា ↓ កន្សោមនាម

ឧ. *សុកទិញសៀវភៅមួយក្បាល។*

កកិ → កិ + ចំណង + កន

↓ កន្សោមកិរិយា ↓ កិរិយា ↓ កន្សោមនាម

ឧ. *សំប្រទះនឹងខ្លា។*

*នឹង* ជាពាក្យចំណង។

កកិ → កិជា + កន

↓ កិរិយា "ជា"

ប្រធាននិងបម្រាប់ប្រធាន បង្កើតល្បះដោយរួមគ្នា។ ល្បះអាចតាងដោយវិធីច្រើនយ៉ាង។

-ប្រើប្រអប់







-ប្រើមែកធាងឬចង្កោម




## ២. ទម្រង់នៃការបង្កើតល្បះ

### ២.១. ល្បះបង្កើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា

**ល** → **កនប្រ** + **កកិ**

(**កកិ** → **កិ**)

កន្សោមនាមប្រធាននៅខាងឆ្វេងកិរិយាសព្ទ។ កិរិយាជាកិរិយាអកម្ម។

| ឧទាហរណ៍ | |
|---|---|
| **កន្សោមនាម** | **កន្សោមកិរិយា** |
| ប្រធាន | កិរិយាអកម្ម |
| *ឆ្កែ* | *ព្រុស* |
| *ក្មេង* | *យំ* |
| *សេះ* | *រត់* |

## ២.២. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា ដែលមានកន្សោមនាមកម្មបទផ្ទាល់

**ល** → **កនប្រ** + **កកិ**

(**កកិ** → **កិ** + **កន**)

កន្សោមនាមជាប្រធាននៅខាងឆ្វេងកិរិយា។

កិរិយាជាកិរិយាសកម្ម។

កន្សោមនាមជាកម្មបទផ្ទាល់នៅខាងស្តាំកិរិយា។

<table>
<tr><td colspan="3">ឧទាហរណ៍</td></tr>
<tr><td>កន្សោមនាម</td><td colspan="2">កន្សោមកិរិយា</td></tr>
<tr><td>ប្រធាន</td><td>កិរិយាសកម្ម</td><td>កន្សោមនាម</td></tr>
<tr><td>សិស្ស</td><td>ទៅ</td><td>សាលារៀន</td></tr>
<tr><td>សុភី</td><td>ទិញ</td><td>កង់</td></tr>
<tr><td>កសិករ</td><td>ដាំ</td><td>បន្លែ</td></tr>
</table>

## ២.៣. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា ដែលមានកន្សោមនាមកម្មបទមិនផ្ទាល់

**ល** → **កនប្រ** + **កកិ**

**កកិ** → **កិ** + **កមធ**

**កមធ** → **ធ** + **កន**

កន្សោមនាមប្រធាននៅខាងឆ្វេងកិរិយា។

កិរិយាជាកិរិយាអកម្ម។

កន្សោមនាមមានធ្នាក់ «កមធ» នៅខាងស្តាំកិរិយា។

កន្សោមនាមមានធ្នាក់ជាកម្មបទមិនផ្ទាល់។

<table>
<tr><td colspan="4">ឧទាហរណ៍</td></tr>
<tr><td>កន្សោមនាម</td><td colspan="3">កន្សោមកិរិយា</td></tr>
<tr><td rowspan="2">ប្រធាន</td><td rowspan="2">កិរិយាអកម្ម</td><td colspan="2">កន្សោមមានធ្នាក់</td></tr>
<tr><td>ធ្នាក់</td><td>កន្សោមនាម</td></tr>
<tr><td>លោកគ្រូ</td><td>និយាយ</td><td>ជាមួយ</td><td>សិស្សានុសិស្ស</td></tr>
</table>

| | | | |
|---|---|---|---|
| *កុមារ* | *ដេក* | *ក្នុង* | *អង្រឹង* |
| *ស៊ុក* | *ជួប* | *នឹង* | *បងប្រុសវា* |
| *ក្មេងៗ* | *អង្គុយ* | *លើ* | *កៅអី* |

## ២.៤. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា ដែលមានកន្សោមនាមកម្មបទផ្ទាល់និង កន្សោមនាមកម្មបទមិនផ្ទាល់

**ល → កនប្រ + កកិ**

**កកិ → កិ + កន + កមឆ**

**កមឆ → ឆ្នាក់ + កន**

កន្សោមនាមប្រធាននៅខាងឆ្វេងកិរិយា។

កិរិយាជាកិរិយាសកម្ម។

កន្សោមនាមកម្មបទផ្ទាល់នៅខាងស្តាំជាប់នឹងកិរិយា។

កន្សោមនាមកម្មបទមិនផ្ទាល់នៅខាងស្តាំជាប់នឹងកម្មបទផ្ទាល់។

<table>
<tr><td colspan="5" align="center">ឧទាហរណ៍</td></tr>
<tr><td>កន្សោមនាម</td><td colspan="4">កន្សោមកិរិយា</td></tr>
<tr><td rowspan="2">ប្រធាន</td><td rowspan="2">កិរិយាសកម្ម</td><td rowspan="2">កន្សោមនាម</td><td colspan="2">កន្សោមមានធ្នាក់</td></tr>
<tr><td>ធ្នាក់</td><td>កន្សោមនាម</td></tr>
<tr><td>មេភូមិ</td><td>ប្រាប់</td><td>ដំណឹង</td><td>ដល់</td><td>ប្រជាជន</td></tr>
<tr><td>មីងសន</td><td>ផ្ញើ</td><td>លុយ</td><td>ដល់</td><td>កូនគាត់</td></tr>
<tr><td>លោកគ្រូ</td><td>ឱ្យ</td><td>ដំបូន្មាន</td><td>ដល់</td><td>និស្សិត</td></tr>
<tr><td>ប្រធានក្រុម</td><td>ប្រគល់</td><td>ភារកិច្ច</td><td>ចំពោះ</td><td>កូនក្រុម</td></tr>
</table>

## ២.៥. ល្បះកើតឡើងដោយកន្សោមនាមប្រធាននិងកន្សោមកិរិយា ដែលមានកន្សោមនាមគុណប្រធាន

**ល → កនប្រ + កកិ**

**កកិ → កិជា + កន**

កន្សោមនាមប្រធាននៅខាងឆ្វេងកិរិយា។

កិរិយាក្រុមជាមានដូចជា «ជា គឺជា ក្លាយជា ប្រែជា ឡើងជា ដើរតួជា...»។ កន្សោមនាមគុណប្រធាននៅខាងស្តាំកិរិយា។

| ឧទាហរណ៍ | | |
|---|---|---|
| **កន្សោមនាម** | **កន្សោមកិរិយា** | |
| ប្រធាន | ក្រុមកិរិយា "ជា" | កន្សោមនាម |
| *តារា* | *ជា* | *វិស្វករ* |
| *សុភី* | *ជា* | *ប្អូនស្រីខ្ញុំ* |
| *ពូសុក* | *នឹងក្លាយជា* | *ប្រធានក្រុម* |
| *មីងសយ* | *ឡើងជា* | *មេឃុំ* |
| *កុមារនេះ* | *ដើរតួជា* | *ចៅចិត្រ* |

### ៣. វិភាគធាតុនៃល្បះ

**ល** → **កនប្រ** + **កកិ**

(**កកិ** → **កិ**)

ឧ. (១) *ក្មេងយំ។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *ក្មេង* ជាកន្សោមនាមដែលមានមុខងារជាប្រធានរបស់កិរិយា *យំ*។ *យំ* ជាកន្សោមកិរិយា ដែលមានមុខងារជា បម្រាប់ប្រធាន និងជាកិរិយាស្នូលនៃល្បះ។ ល្បះនេះមានធាតុសំណង់ពីរ គឺ *ក្មេង*ជាកន្សោមនាមប្រធាន នៅខាងឆ្វេងនិង *យំ*ជាកិរិយាអកម្ម នៅខាងស្តាំ។

យើងអាចតាងល្បះខាងលើដូចខាងក្រោម៖

-ប្រអប់



-មែកធាងឬចង្កោម




**ល** → **កនប្រ** + **កកិ**

**កកិ** → **កិ** + **កន** + **កមធ**

**កមធ** → **ធ្លាក់** + **កន**

ឧ. (១) *មីងសនផ្ញើលុយដល់កូនគាត់។*

ក្នុងល្បះខាងលើយើងអាចញែកសម្ព័ន្ធដូចនេះ៖ *មីងសន* ជាកន្សោមនាម ដែលមានមុខងារជាប្រធានរបស់កិរិយា *ផ្ញើ*។ *ផ្ញើលុយដល់កូនគាត់* ជាកន្សោមកិរិយា ដែលមានមុខងារជាបម្រាប់ប្រធាន និង *ផ្ញើ*ជាកិរិយាស្នូលនៃល្បះ។ ល្បះនេះមានធាតុសំណង់បួន គឺ *មីងសន*ជាកន្សោមនាមប្រធាន នៅខាងឆ្វេង *ផ្ញើ* ជាកិរិយាអកម្ម នៅខាងស្តាំ *លុយ*ជាកម្មបទផ្ទាល់ (ក១) របស់កិរិយា *ផ្ញើ* និង *ដល់កូនគាត់*ជាកម្មបទមិនផ្ទាល់ (ក២) ឬកន្សោមមានធ្នាក់។

យើងអាចតាងល្បះខាងលើដូចខាងក្រោម៖

-ប្រអប់



-មែកធាងឬចង្កោម




**៤. មុខងាររបស់កន្សោមពាក្យក្នុងល្បះ**

នៅក្នុងល្បះនីមួយៗ កន្សោមពាក្យនីមួយៗមានមុខងារផ្សេងៗទៅតាមទីកន្លែងរបស់ខ្លួន។

**៤.១. កន្សោមនាមប្រធាន**

**៤.១.១. និយមន័យ**

ឧ. *មិត្តរួមថ្នាក់យើងខំប្រឹងរៀនណាស់។*

*ការសិក្សាក៏ជាកត្តាសំខាន់ដែរ។*

ក្នុងឧទាហរណ៍ខាងលើ យើងឃើញថា៖

- កន្សោមនាម *មិត្តរួមថ្នាក់យើង* ជាប្រធានរបស់កិរិយា *ខំប្រឹងរៀន*។
- កន្សោមនាម *ការសិក្សា* ជាប្រធានរបស់កិរិយាសព្ទ *ក៏ជា*។

ដូចនេះ កន្សោមនាមប្រធាន គឺជាពាក្យឬកន្សោមពាក្យដែលសម្រេចនូវអំពើឬធ្វើអំពើនៅក្នុងល្បះ។ វាស្ថិតនៅខាងមុខកន្សោមកិរិយា។

**៤.១.២. ប្រភេទកន្សោមនាមប្រធាន**

- នាម៖ *គង្ហាលរំពៃមើលហ្វូងគោជានិច្ច។*
- គុណនាម៖ *ក្តៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ។*
- កិរិយា៖ *ដើរសប្បាយជាងជិះ។*
- កន្សោមនាម៖ *ល្អុងខ្ញុំបីផ្លែនេះ ជាបន្លែដ៏ប្រសើរ។*

### ៤.២. កន្សោមកិរិយា (បម្រាប់ប្រធាន)

### ៤.២.១. អំពីកិរិយា

ក្នុងល្បះ កិរិយាមានមុខងារសំខាន់ណាស់។ វាជាស្នូលនិងជាបង្គោលរបស់ល្បះ។ កន្សោមកិរិយាមានមុខងារជាបម្រាប់ប្រធាននៅក្នុងល្បះ។

កិរិយាតែមួយអាចបង្កើតល្បះមួយបាន៖

- *ទៅ!*
- *បាញ់ទៅ!*

### ៤.២.២. ប្រភេទកិរិយា

- កិរិយាសុទ្ធសកម្មះ *កូនសិស្សស្ដាប់លោកគ្រូ។*
- កិរិយាសុទ្ធអកម្មះ *កងទ័ពដើរយ៉ាងប្រុងប្រយ័ត្ន។*
- កិរិយាហេតុសកម្មះ *កសិករបញ្ចូលទឹកក្នុងស្រែ។*
- កិរិយាផ្សំះ *កសិករចូលចិត្តបរិភោគបន្លែស្រស់។*
  *គាត់ដើរចូលទៅ។*
  *ជំងឺនេះធ្វើឱ្យមិត្តយើងស្លាប់។*
- គុណនាមកិរិយាះ *យុវនារីនេះស្អាតផងល្អផង។*
  *គាត់ប្រសើរណាស់។*

### ៥. រចនាសម្ព័ន្ធល្បះ

រចនាសម្ព័ន្ធល្បះមាន៣ប្រភេទ គឺល្បះទោល ល្បះផ្សំ និងល្បះក្រង។

### ៥.១. ល្បះទោល

### ៥.១.១. និយមន័យ

**ល្បះទោល** គឺជាល្បះដែលក្នុងនោះមានកន្សោមកិរិយាប្រណាប់ប្រធាន (បម្រាប់ប្រធាន) តែមួយ (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៨)។

ល្បះទោលជាធម្មតាវាចាំបាច់ត្រូវមានកន្សោមពីរយ៉ាងសំខាន់ គឺកន្សោមប្រធាន និងកន្សោមកិរិយាឬបម្រាប់ប្រធាន។

ឧ. (១) *ទឹកហូរក្រោមស្ពាន។*

(២) *គាត់ទិញតុមួយ។*

(៣) *បងសំ កសិករឆ្នើម ក្លាយជាប្រធានភូមិ។*

(៤) *ប្រាសាទដ៏អស្ចារ្យកសាងដោយបុព្វបុរសខ្មែរ។*

(៥) *ខ្ញុំនិងក្រុមគ្រួសាររបស់ខ្ញុំទៅលេងអង្គរវត្ត។*

(៦) *សុកបានមកឈរក្បែរខ្ញុំ។*

(៧) *សុភីនិងសុធាបានមករៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។*

### ៥.១.២. ទម្រង់នៃការបង្កើតល្បះទោល

ល្បះទោលមានទម្រង់បាត (មូលដ្ឋាន) ៤យ៉ាង៖

- **ល** → **កនប្រ** + **កិ** (**អកម្ម**)

ឧ. *ក្មេងយំ។*

*ធារីរាំ។*

- **ល** → **កនប្រ** + **កិ** (**សកម្ម**) + **កន** (**កបផ**)

ឧ. *សំដឹកគោ។*

*គាត់អានកាសែត។*

**ឬ ល** → **កនប្រ** + **កិចំ** (**ក្រុមជា**) + **កន** (**មុខងារជាគុណប្រធាន**)

ឧ. *សុកជាកសិករ។*

*សៀវភៅនេះជារបស់បងប្រុសខ្ញុំ។*

- **ល** → **កនប្រ** + **កិ** (**សកម្ម**) + **កមធ**

ឧ. *សុកនិយាយជាមួយសំ។*

*ម្ដាយគាត់សម្រាន្តលើគ្រែ។*

- **ល** → **កនប្រ** + **កិ** (**សកម្ម**) + **កន** (**កបផ**) + **កមធ**

ឧ. *បូផាឱ្យសៀវភៅមួយដល់ខ្ញុំ។*

*សុកផ្ញើផ្លែឈើចំពោះម្ដាយវា។*

ទម្រង់ល្បះទាំង៤បែបខាងលើនេះ ជាទម្រង់បាត ហើយអាចមានកន្សោមកម្មទេសកាលបន្ថែមទៀត។

ឧ. *សុភាពតែងតែគោរពឪពុកម្ដាយនាងពេលចេញទៅសាលារៀន។*

កម្មកាល

### ៥.១.៣. វិភាគល្បះទោល

**ល** → **កនប្រ** + **កិចំ** + **កន** (**គុប្រ**)

ឧ. *សុភីឡើងជាប្រធានថ្នាក់។*

នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ កន្សោមពាក្យ«*សុភី*»ជាកន្សោមនាមប្រធាន និងជានាមអសាធារណ៍ នៅខាងឆ្វេងកិរិយា«*ឡើងជា*»។ កន្សោមពាក្យ «*ឡើងជាប្រធានថ្នាក់*» ជាកន្សោមកិរិយាដែលមានកិរិយាចំណង«*ឡើងជា*» និងកន្សោមពាក្យ

«*ប្រធានថ្នាក់*» ជាកន្សោមនាមដែលមានមុខងារជាគុណប្រធានរបស់កន្សោមនាមប្រធាន«*សុភី*»។

យើងអាចតាងល្បះខាងលើដូចខាងក្រោម៖

**-ប្រអប់**




**-មែកធាងឬចង្កោម**




### ៥.២. ល្បះផ្សំ

### ៥.២.១. និយមន័យ

**ល្បះផ្សំ** គឺជាល្បះដែលកើតឡើងដោយបន្សំរវាងឃ្លាច្បង (ឃ្លាគោល/ល្បះគោល) និងឃ្លារណាប (ល្បះរណាប)។ ឃ្លារណាបអាចភ្ជាប់នឹងឃ្លាច្បងដោយឈ្នាប់ឃ្លាឬសព្វនាមឈ្នាប់។ ឃ្លាអាចមានន័យគ្រប់គ្រាន់ឬមិនទាន់គ្រប់គ្រាន់។

ល្បះទោលមាន "កនប្រ កិ កន និង កមច" ជាធាតុសំណង់របស់ល្បះទោល។ ល្បះផ្សំមានទម្រង់ដូចគ្នានេះដែរ ប៉ុន្តែវាមានធាតុសំណង់ណាមួយ (នៃល្បះ) ជាល្បះ ឬក្នុងធាតុសំណង់ណាមួយមានពង្រីកជាល្បះ។

ឃ្លាចម្បងនិងឃ្លារណបសុទ្ធតែមានប្រធាន កិរិយា ឬកម្មបទដូចគ្នា។ ឃ្លារណបអាចនៅបន្ទាប់ពីឃ្លាចម្បងឬនៅខាងដើមឃ្លាក៏បាន។ ឃ្លារណបភ្ជាប់នឹងឃ្លាចម្បងដោយសារឈ្នាប់ឃ្លា *ព្រោះ ដើម្បី ដើម្បីនឹង ថា ទោះបី ប្រសិនបើ រហូតដល់ បន្ទាប់ពី ថ្វីត្បិតតែ ដើម្បីឱ្យ លុះ ដែល កាលណា...*។

ឧ. (១) *យើងនឹងទៅអានសៀវភៅនៅបណ្ណាល័យ ប្រសិនបើមេឃមិនភ្លៀង។*

(២) *យើងខំប្រឹងមើលមេរៀនដើម្បីការប្រឡងរបស់យើងបានជោគជ័យ។*

(៣) *ឪពុកម្ដាយចង់បានកូនដែលស្ដាប់បង្គាប់។*

(៤) *លោកគ្រូទូន្មានថាយើងត្រូវខំរៀនបន្ថែមទៀត។*

(៥) *និស្សិតដែលខំរៀន តែងតែប្រឡងជាប់។*

(៦) *សុភាពនៅចាំម្ដាយនាង រហូតដល់គាត់ត្រលប់មកពីផ្សារវិញ។*

### ៥.២.២. ទម្រង់នៃការបង្កើតល្បះផ្សំ

ទម្រង់សំខាន់ៗនៃល្បះផ្សំមានដូចជា៖

**ល** → **កនប្រ** + **កិ** + **ឃ្លារណប** (**ឈ្នាប់ឃ្លា** «**ថា**» + **ល្បះរណប**)

ឧ. *ពួកគេយល់ថាក្រុមគេនឹងឈ្នះក្នុងការប្រកួតនេះ។*

*បងខ្ញុំដឹងថាសំមិនចូលចិត្តលេងល្បែង។*

**ល** → **កនប្រ** + **កិ** + **កន** + **ព** (**ឃ្លារណប**)

ឧ. *យើងចូលចិត្តកន្លែងដែលមានធម្មជាតិស្រស់បំព្រង។*

*ក្មេងៗចូលចិត្តអានសៀវភៅដែលមានរូបគំនូរ។*

**ល** → **កនប្រ** + **ព** (**ឃ្លារណប**) + **កកិ**

ឧ. *កុមារដែលគោរពឪពុកម្ដាយ ជាក្មេងដ៏ល្អ។*

*មនុស្សដែលខ្ញុំស្រលាញ់ មានគុណធម៌ដ៏ល្អ។*

**ល** → **កនប្រ** + **កិ** + **ឃ្លារណប** (**ឈ្នាប់ឃ្លា** + **ល្បះរណប**)

ឧ. *យើងខិតខំរៀនសូត្រដើម្បីប្រទេសជាតិយើងរីកចម្រើន។*

*ជីតាខ្ញុំពាក់វ៉ែនតាដោយសារភ្នែកគាត់មើលមិនសូវច្បាស់។*

### ៥.២.៣. វិភាគល្បះផ្សំ

**ល** → **កនប្រ** + **កិ** + **ឃ្លារណប** (**ឈ្នាប់ឃ្លា** «**ថា**» + **ល្បះរណប**)

ឧ. *បងខ្ញុំដឹងថាសំមិនចូលចិត្តលេងល្បែង។*

នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ *បងខ្ញុំដឹង* ជាឃ្លាចម្បងដែលកើតឡើងដោយកន្សោមនាម *បងខ្ញុំ* ដែលមានមុខងារជាប្រធានរបស់កិរិយា *ដឹង* និងកន្សោមកិរិយា

*ដឹង* ដែលជាកិរិយាបង្គោល។ *ថាសំមិនចូលចិត្តលេងល្បែង* ជាឃ្លារណាប ឬឃ្លានាម ដែលមានមុខងារជាកន្សោមនាមកម្មបទរបស់កិរិយា *ដឹង* ។ ក្នុងឃ្លារណាបនេះកើតឡើងដោយ *ថា* ជាឈ្នាប់ឃ្លា និង *សំ* ជាកន្សោមនាមប្រធាន រីឯ *មិនចូលចិត្តលេងល្បែង* ជាកន្សោមកិរិយា និង *ល្បែង* ជាកន្សោមនាម ដែលមានមុខងារជាកម្មបទផ្ទាល់របស់កិរិយា *ចូលចិត្តលេង*។ ដូច្នេះឃ្លាទាំងពីរនេះ ចងភ្ជាប់គ្នាដោយសារឈ្នាប់ឃ្លា *ថា* បង្កើតបានជាល្បះផ្សំមួយដែលមានន័យពេញលេញ។

យើងអាចតាងល្បះខាងលើដូចខាងក្រោម៖

**-ប្រអប់**




**-មែកធាងឬចង្កោម**




**ល** → **កនប្រ** + **កិ** + **កន** + **ព** ( **ឃ្លារណាប** )

ខ. *ក្មេងៗចូលចិត្តអានសៀវភៅដែលមានរូបគំនូរ។*

នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ *ក្មេងៗចូលចិត្តអានសៀវភៅ* ជា

ឃ្លាច្បងនៅក្នុងល្បះ ដែលកើតឡើងដោយកន្សោមនាម *ក្មេងៗ* ដែលមានមុខងារជាប្រធានរបស់កិរិយា *ចូលចិត្ត* និង *ចូលចិត្តអាន* ជាកិរិយាបង្គោល និង *សៀវភៅ* ជាកម្មបទផ្ទាល់។ *ដែលមានរូបគំនូរ* ជាឃ្លារណប ឬឃ្លាគុណនាម ដែលមានមុខងារជាពង្រីកឱ្យនាម *សៀវភៅ*។ ធាតុ *ដែល* មានមុខងារជាប្រធានរបស់កិរិយា *មាន* និងជាសព្វនាមឈ្នាប់សម្រាប់ជំនួសឱ្យនាម *សៀវភៅ*។ ក្នុងឃ្លារណបនេះកើតឡើងដោយ *ដែល*ជាឈ្នាប់ឃ្លា និង *មានរូបគំនូរ* ជាកន្សោមកិរិយា។

យើងអាចតាងល្បះខាងលើជាមែងធាងដូចខាងក្រោម៖






**ល → កនប្រ + កិ + ឃ្លារណាប** (**ឈ្នាប់ឃ្លា** + **ឃ្លាឬល្បះរណាប**)

ឧ. *យើងខិតខំរៀនសូត្រ ដើម្បីប្រទេសជាតិយើងរីកចម្រើន។*

នៅក្នុងល្បះខាងលើមានរចនាសម្ព័ន្ធដូចជា៖ *យើងខិតខំរៀនសូត្រ* ជាឃ្លាច្បង ដែលកើតឡើងដោយ *យើង* ជាកន្សោមនាមប្រធាន *ខិតខំរៀនសូត្រ* ជាកន្សោមកិរិយា។ ចំណែកឃ្លា *ដើម្បីប្រទេសជាតិយើងរីកចម្រើន* ជាឃ្លារណាប ឬឃ្លាទេសកាល ដែលមានមុខងារជាកន្សោមមានផ្ទាក់របស់កន្សោមកិរិយា *ខិតខំរៀនសូត្រ* ដែលកើតឡើងដោយ *ដើម្បី* ជាឈ្នាប់ឃ្លាទេសកាល បង្ហាញពីបំណងនិង *ប្រទេសជាតិយើង* ជាកន្សោមនាមប្រធាន ហើយ *រីកចម្រើន* ជាកន្សោមកិរិយា។

យើងអាចតាងល្បះខាងលើជាមែកធាងដូចខាងក្រោម៖




ឧទាហរណ៍ខាងលើបញ្ជាក់ថា ក្នុងល្បះផ្សំមាន៖

-ឃ្លារណាប បែប **កន** (កន្សោមនាម) ឬ **ឃ្លានាម**

-ឃ្លារណាប បែប **កគុ** (កន្សោមគុណនាម) ឬ **ឃ្លាគុណនាម**

-ឃ្លារណាបបែប **កគុណ** (កន្សោមគុណកិរិយា) ឬឃ្លាទេសកាល(ឃ្លាគុណកិរិយា)។

### ៥.២.៤. ឃ្លាផ្សេងៗនៃល្បះផ្សំ

#### ក. ឃ្លានាម

#### ក.១. និយមន័យ

**ឃ្លានាម** គឺជាឃ្លារណាបដែលផ្លាស់កន្សោមនាម។ ឃ្លានាមសមមូលនឹងល្បះ។

-បញ្ជាក់៖

*-ខ្ញុំនិយាយអីចេះ៖ សំនឹងទៅដល់ស្រែស្អែក។*

*-ខ្ញុំនិយាយថា សំនឹងទៅដល់ស្រែស្អែក។*

-សំណួរ៖

*-គាត់សួរឯងអីចឹង៖ ឯងទៅណា?*

*-គាត់សួរឯងថា ឯងទៅណា។*

*-គាត់សួរឯងអីចេះ៖ ឯងទៅអង្កាល់?*

*-គាត់សួរឯងថា អង្កាល់ឯងទៅ (ឬឯងទៅអង្កាល់)។*

*-គាត់សួរឯងអីចេះ៖ តើឯងទៅណា?*

*-គាត់សួរឯងថា តើឯងទៅអង្កាល់។*

-បញ្ជា៖

*-ខ្ញុំប្រាប់អីចេះ៖ ចូរឯងរកចបមួយ។*

*-ខ្ញុំប្រាប់ថា ចូរឯងរកចបមួយ។*

**ក.២. មុខងារនៃឃ្លានាម**

ឃ្លានាមមានមុខងារដូចជាកន្សោមនាមដែរ៖

-ប្រធាន

(១) *មិត្តខ្ញុំត្រូវរបួសយ៉ាងធ្ងន់នាំឱ្យខ្ញុំស្លុតចិត្ត។*

→ *អ្វីមួយនាំឱ្យខ្ញុំស្លុតចិត្ត។*

(២) *លោកគ្រូនិយាយមួយៗនាំឱ្យយើងស្រួលស្តាប់ណាស់។*

→ *អ្វីមួយនាំឱ្យយើងស្រួលស្តាប់ណាស់។*

-គុណប្រធាន

(១) *ការពិតនោះគឺ (ថា) សាមគ្គីជាកត្តាជ័យជំនះ។*

→ *ការពិតនោះ គឺដូចនេះ។*

(២) *យោបល់ខ្ញុំ គឺ (ថា) ស្រែយើងឆ្នាំនេះនឹងបានផលលើសឆ្នាំទៅ។*

→ *យោបល់ខ្ញុំ គឺដូចនេះ។*

-កម្មបទផ្ទាល់

(១) *គេប្រកាសថាទឹកជំនន់ឡើងខ្លាំងណាស់។*

→ *គេប្រកាសអ្វីមួយ។*

**-កម្មបទមិនផ្ទាល់**

(១) *គាត់គិតថាថ្ងៃប្រឡងជិតមកដល់ហើយ។*

→ *គាត់គិតដល់អ្វីមួយ។*

**ឃ្លានាមអាចជាកម្មរបស់នាមឬកម្មរបស់គុណនាមកិរិយាៈ**

**-កម្មរបស់នាម**

*-យោបល់ថាយើងនឹងបានជោគជ័យ នាំឱ្យយើងក្លាហាន។*

*-គំនិតថាខ្លួននឹងប្រឡងជាប់ ធ្វើឱ្យសំសប្បាយចិត្តនឹងការរៀនណាស់។*

**-កម្មរបស់គុណនាមកិរិយា**

*-សំសប្បាយនឹងយើងបានរង្វាន់។*

*-វាព្រួយនឹងឪពុកវាមានជំងឺ។*

**ក.៣. ឃ្លានាមសំណួរមិនផ្ទាល់**

ឃ្លានាមសំណួរមិនផ្ទាល់ជាឃ្លារណបអចល័ត ហើយជាពង្រីករបស់កិរិយាសព្ទនៃល្បះ។ សំណួរមិនផ្ទាល់ ជាឃ្លានាមកើតឡើងដោយមានពាក្យដូចជា *កាលណា ដូចម្ដេច ឯណា អង្កាល់ ហេតុដូចម្ដេច នរណា អ្វី... នៅជាមួយនឹង* និងកិរិយាបែប *ប្រាប់ ដឹង មិនដឹង គិត ឃើញ*...។

សំណួរមិនផ្ទាល់មាន២យ៉ាងគឺៈ

**-សំណួរមិនផ្ទាល់ទាំងមូល**

សំណួរមិនផ្ទាល់ទាំងមូលសួរលើឃ្លាទាំងមូល។

ឧ. *គាត់សួរខ្លួនឯងថាតើគាត់ទៅធ្វើការមែនឬទេ។*

*គាត់សួរថាស្រូវនេះជារបស់គាត់មែនឬទេ។*

**-សំណួរមិនផ្ទាល់ផ្នែក**

សំណួរនេះបិតនៅលើធាតុសំណង់ណាមួយនៃឃ្លារណបៈ

**-លើ កន ប្រធាន**

ឧ. *គាត់ចង់ដឹងថាមិត្តមួយណារកឯង។*

*អ្វីកើតឡើងនៅទីនោះ។*

*នរណាដើរមកនោះ។*

**-លើ កន គុណប្រធាន**

ឧ. *វាពុំដឹងថាសំជា<u>នរណា</u>។*

*សុកជាមនុស្សបែបណា។*

*ប្រធានយើងជាបងមួយណា។*

**-លើ កន កម្មបទផ្ទាល់**

ឧ. *ប្រាប់ខ្ញុំមើលថា ឯងធ្វើកំហុសអ្វីខ្លះ។*

*ឯងធ្វើអ្វី។*

*បងឯងទិញអ្វីខ្លះ។*

**-លើ កន កម្មបទមិនផ្ទាល់**

ឧ. *វាចង់ដឹងថា ឯងនិយាយអំពីអ្វី។*

*វានិយាយនឹងនរណា។*

*គាត់គិតដល់អ្វី។*

*វាទាក់ទងនឹងនរណា។*

**-លើ កន កម្មភ្នាក់ងារ**

ឧ. *ខ្ញុំមិនដឹងថាវាត្រូវនរណាសម្លាប់។*

*វាត្រូវនរណាវាយ។*

**-លើ កន កម្មនៃគុណនាមកិរិយា**

ឧ. *គាត់សួរថាឯងព្រួយនឹងអ្វី។*

*វាសប្បាយនឹងអ្វី។*

**-លើ កន កម្មទេសកាល**

ឧ. *វាចង់ដឹងថាវានៅទីណា។*

*ហេតុអ្វីវាមិនទៅស្រែ។*

*កាលណាវាទៅស្រែ។*

*ចបនេះថ្លៃប៉ុន្មាន។*

**ក.៤. គំនូសតាងល្បះ**

**-គំនូសតាងដោយប្រអប់**



-គំនូសតាងដោយចង្កោម

ល → *គាត់សង្ឃឹមថាយើងនឹងបានសុភមង្គល។*




**ខ. ឃ្លាគុណនាម**

**ខ.១. និយមន័យ**

**ឃ្លាគុណនាម** ជាឃ្លារណបអចល័តភ្ជាប់ទៅនឹងកន្សោមនាមដោយសារសព្វនាមឈ្នាប់។ ឃ្លាគុណនាមសមមូលនឹងកន្សោមគុណនាម។ វាមាននាទីសម្តែងគុណរបស់កន្សោមនាម។ ឃ្លាគុណនាមមាន២យ៉ាងគឺ ឃ្លាគុណនាមគុណបទ និងឃ្លាគុណនាមឧបបទ។

**ខ.២. ឃ្លាគុណនាមគុណបទ**

ឃ្លាគុណនាមគុណបទនៅជាប់នឹងនាមដើម្បីបំពេញសេចក្តីឱ្យនាមនោះ។ គេពុំអាចលុបឃ្លាគុណនាមគុណបទបានទេ។ បើគេលុបឃ្លាគុណនាមគុណបទ គេមុខជាពុំអាចយល់ន័យនៃល្បះនោះឡើយៈ

ឧ. *យុវជន<u>ដែលខ្ញុំជួបអម្បាញ់មិញ</u> ជាមិត្តរួមអារុធរបស់ខ្ញុំ។*

(បើយើងលុបឃ្លាគុណនាម យើងបានឃ្លាស្តាប់ពុំបាន "យុវជនជាមិត្តរួមអារុធ

របស់ខ្ញុំ") គេអាចស្គាល់ឃ្លាគុណនាមគុណបទ ដោយសារគេអាចប្តូរ**នាមយោង** (នាមនៅដើមឃ្លាគុណនាមគុណបទ) នឹងពាក្យ *អ្នក អ្វី*...។

ដូចនេះល្បះផ្សំខាងលើ អាចសរសេរថា "អ្នកដែលខ្ញុំជួបអម្បាញ់មិញ ជាមិត្តរួមអាវុធរបស់ខ្ញុំ"។

**ខ.៣. ឃ្លាគុណនាមឧបបទ**

ឃ្លាគុណនាមឧបបទអាចលុបចោលបានដោយគ្មានធ្វើឱ្យល្បះប្រែប្រួលឡើយ។ វាពុំមានផ្តល់ន័យចាំបាច់ដល់ឃ្លាច្បងឡើយ៖

*-សុភាដែលខ្ញុំស្គាល់យូរហើយ ជាមិត្តដ៏ល្អរបស់ខ្ញុំ។*

ឃ្លាគុណនាមឧបបទអាចផ្លាស់នឹងល្បះដាក់ភ្ជាប់នឹងល្បះទី១៖

→ *សុភាជាមិត្តដ៏ល្អរបស់ខ្ញុំ ហើយខ្ញុំស្គាល់វាយូរហើយ។*

❖ **កំណត់សម្គាល់**

**-ឃ្លាគុណនាមអាចជាពង្រីករបស់កន្សោមនាមប្រធានឬកន្សោមនាមកម្មបទរបស់ល្បះ៖**

*-វារកទិញរទេះដែលត្រូវនឹងគោធំៗរបស់វា។*

*-សំដែលជាមិត្តតែម្នាក់របស់ខ្ញុំ អាចជួយដោះស្រាយបញ្ហាខ្ញុំបាន។*

**-ឃ្លាគុណនាមខ្លះអាចសមមូលនឹងកម្មទេសកាល៖**

- ហេតុ៖ *បងខ្ញុំ **ដែលឈឺ** សម្រាកការងារ (ព្រោះឈឺ)។*
- ទំនាស់៖ *ឪពុកខ្ញុំ **ដែលឈឺ** នៅតែធ្វើការ (ទោះឈឺ)។*
- បំណើះ៖ *មនុស្ស **ដែលធ្វើការនេះបានល្អ** ជាវីរជន (បើគាត់ធ្វើការនេះបានល្អ)។*

**-សព្វនាមឈ្នាប់ "*ដែល*" បិតនៅខាងដើមឃ្លាគុណនាមជានិច្ច។**

**ខ.៤. គំនូសតាងល្បះ**

ល → *ខ្ញុំជួបមិត្តម្នាក់ដែលធ្លាប់រៀនជាមួយខ្ញុំ។*

**-គំនូសតាងដោយប្រអប់**



**-តំនួសតាងដោយមែកធាង**




ល → *សំមើលចបកាប់ដែលឪពុកវាទើបនឹងទិញ។*

**-តំនួសតាងដោយប្រអប់**



-គំនូសតាងដោយចង្កោម




**គ. ឃ្លាទេសកាល**

**គ.១. និយមន័យ**

ឃ្លាទេសកាលសមមូលនឹងកន្សោមនាមមានធ្នាក់កម្មទេសកាល (នៅក្នុងល្បះទោល)។ ឃ្លាទេសកាលជាធាតុនៃកន្សោមកិរិយារបស់ល្បះ។ មុខងារនៃឃ្លាទេសកាលស៊ីគ្នានឹងមុខងារនៃកន្សោមនាមមានធ្នាក់កម្មទេសកាល។ ដូចនេះនៅក្នុងល្បះ៖

*ពូសំទៅចម្ការនៅម៉ោង៦ព្រឹក។*

*កន្សោមមានធ្នាក់កម្មទេសកាល*

បើគេផ្លាស់កន្សោមនាមមានធ្នាក់ *"នៅម៉ោង៦ព្រឹក"* នឹងល្បះ គេបានល្បះផ្សំមាន "ឃ្លាទេសកាល"៖

*ពូសំទៅចម្ការ កាលណាភរិយារបស់គាត់ដណ្តាំបាយរួចហើយ។*

*ឃ្លាទេសកាល*

ឃ្លាទេសកាលជាធាតុនៃល្បះ។

**គ.២. មុខងារនៃឃ្លាទេសកាល**

មុខងារនៃឃ្លាទេសកាលស៊ីគ្នានឹងមុខងារនៃកន្សោមនាមមានធ្នាក់ទេសកាល។

**គ.២.១. ឃ្លាទេសកាលប្រាប់កាលឬឃ្លាកាល**

ឃ្លាកាលស៊ីគ្នានឹងកន្សោមនាមមានធ្នាក់ទេសកាលប្រាប់កាល។ វាផ្ដើមដោយឈ្នាប់ឃ្លា (ឬឈ្នាប់រណប) *កាលណា កាលដែល ដល់ លុះ ដល់កាលណា ដល់ពេលដែល ពេលដែល ពេល កាល គ្រាដែល លុះតែ លុះត្រាតែ ទាល់តែ មុននឹង ទំរាំ ក្រោយ ក្រោយពី តាំងពី*...។

ឃ្លាកាលសម្រាប់ប្រាប់ពេលដែលកើតឡើងមុន ក្រោយ ឬជាមួយគ្នានឹងពេលនៃឃ្លាច្បង៖

**គ.២.១.១. អំពើនៃឃ្លាច្បងកើតមុនអំពើនៃឃ្លារណប**

ទេសកាលបែបនេះផ្ដើមដោយឈ្នាប់ឃ្លា៖ *មុនពេល ទម្រាំ ទម្រាំតែ រហូត រហូតដល់ ទាល់តែ ទាល់តែដល់*.....៖

- *ខ្ញុំគិតហើយគិតទៀត <u>មុនពេលខ្ញុំសម្រេចចិត្ត</u>*។
- *គាត់មើលសៀវភៅ <u>ទម្រាំម្ដាយគាត់មកដល់</u>*។
- *នៅទីនេះ <u>រហូតដល់គាត់ត្រឡប់មកវិញ</u>*។
- *វានៅចាំចម្ការ <u>ទាល់តែដល់សណ្ដោកល្ងាចបេះ</u>*។

**គ.២.១.២. អំពើនៃឃ្លាច្បងកើតក្រោយអំពើនៃឃ្លារណប**

ទេសកាលបែបនេះផ្ដើមដោយឈ្នាប់ឃ្លា៖ *តាំងពី ក្រោយពេលដែល បន្ទាប់អំពីពេល*...។

- *<u>តាំងពីគាត់ឈឺ</u> វាពុំដែលដើរលេងសោះ*។
- *<u>ក្រោយពេលដែលបដិវត្តន៍បានជ័យជំនះ</u> ប្រជាជនបានសេចក្ដីសុខ*។
- *<u>បន្ទាប់អំពីពេលដែលកសិករប្រមូលផលស្រូវរួចហើយ</u> រដ្ឋក៏ចាប់ផ្ដើមទិញស្រូវពីកសិករដោយផ្ទាល់*។
- *<u>ក្រោយពេលខ្ញុំគិតហើយគិតទៀត</u> ខ្ញុំក៏សម្រេចចិត្ត*។

**គ.២.១.៣. អំពើនៃឃ្លាច្បងនិងឃ្លារណបកើតឡើងដំណាលគ្នា**

ទេសកាលបែបនេះផ្ដើមដោយឈ្នាប់ឃ្លា *នៅពេលដែល ដំណាលគ្នានឹងពេល*...។

- *ពូសំលីនង្គ័លទៅស្រែ<u>នៅពេលដែលកូនគាត់បរគោទៅស្រែដែរ</u>*។
- *វាចេញទៅសាលារៀន <u>ដំណាលគ្នានឹងពេលបងវាចេញទៅចម្ការ</u>*។
- *<u>នៅពេលដែលមេទាហើរចុះដី</u> កូនទាក៏រត់ស្រទៅរកមេវា*។

<u>**កំណត់សម្គាល់**</u>៖

១. គេអាចប្រើ "កិរិយានាម" ជំនួសឃ្លាកាល កាលណាប្រធាននៃឃ្លាច្បងនិងប្រធាននៃឃ្លាកាលជាបុគ្គលតែម្នាក់៖

- *គាត់គិត មុនគាត់និយាយ*
- *គាត់គិត មុននិយាយ។* (*និយាយ* ជាកិរិយានាម)

២. គេអាចប្រើ "កិរិយាគុណនាម" ជំនួសឃ្លាកាលក៏មាន៖

- *ក្នុងពេលដែលវាសើចរកមិត្តវា វាក៏ចាប់ដៃមិត្តវាយ៉ាងណែនដែរ។*
- *សើចរកមិត្តវាផង វាចាប់ដៃមិត្តវាយ៉ាងណែនផង។*
- *សើចរកមិត្តវាបណ្ដើរ វាចាប់ដៃមិត្តវាយ៉ាងណែនបណ្ដើរ។*

**គ.២.២. ឃ្លាទេសកាលបំណងឬឃ្លាបំណង**

ឃ្លាបំណងស៊ីគ្នានឹងកន្សោមនាមមានធ្នាក់ប្រាប់បំណង។ វាផ្ដើមដោយឈ្នាប់ឃ្លា៖ *ដើម្បី ឱ្យ ដើម្បីកុំឱ្យ ដើម្បីនឹង ខ្លាច ឱ្យ កុំឱ្យ មិនឱ្យ...។*

- *យើងប្រយុទ្ធគ្មានខ្លាចស្លាប់<u>ដើម្បីប្រទេសជាតិយើងបានឯករាជ្យ</u>។*
- *សុំនិយាយឱ្យខ្លាំងៗ <u>ដើម្បីឱ្យយើងទាំងអស់គ្នាស្ដាប់ឮ</u>។*
- *ដើរប្រយ័ត្នប្រយែង<u>ខ្លាចបន្លាមុតជើង</u>។*
- *និយាយតិចៗ <u>កុំឱ្យគេស្ដាប់ឮ</u>។*
- *និយាយតិចៗ <u>ខ្លាចគេស្ដាប់ឮ</u>។*

**កំណត់សម្គាល់៖**

-គេប្រើ "កិរិយានាម" ជំនួសឃ្លាបំណង កាលណាឃ្លារណបមានប្រធានដូចគ្នានឹងឃ្លាច្បង៖

- *គាត់ធ្វើការ ដើម្បីគាត់ចិញ្ចឹមឪពុកម្ដាយគាត់។*
- *គាត់ធ្វើការ ដើម្បីចិញ្ចឹមឪពុកម្ដាយគាត់។*

-បំណងអាចសម្ដែងឡើងដោយកន្សោមនាម៖

- *ប្រយុទ្ធដើម្បីជាតិ។*
- *កាសែតសម្រាប់កុមារ។*
- *វាធ្វើនេះក្នុងបំណងល្អ។*

**គ.២.៣. ឃ្លាទេសកាលហេតុឬឃ្លាហេតុ**

ឃ្លាហេតុស៊ីគ្នានឹងកន្សោមនាមមានធ្នាក់ប្រាប់ហេតុ។ វាផ្ដើមដោយឈ្នាប់ឃ្លា "*ពីព្រោះ ព្រោះ ដោយហេតុ ដោយហេតុតែ ហេតុតែ ដោយសារ ព្រោះតែ ត្បិត...*"៖

- *ឯងត្រូវតែរុំខ្លួនឱ្យជិត <u>ព្រោះមេឃត្រជាក់ខ្លាំង</u>។*
- *គេត្រូវសម្រួលទម្រង់ការ <u>ដោយសារកិច្ចការនេះត្រូវធ្វើដោយបន្ទាន់</u>។*
- *<u>ដោយលេសថាវាឈឺ</u> ទើបវាពុំធ្វើអ្វីទាំងអស់។*

គេអាចប្រើដូចនេះ៖

- *ព្រោះមេឃត្រជាក់ខ្លាំង ទើបឯងត្រូវរុំខ្លួនឱ្យជិត។*
- *វានៅទីនោះពុំមែនដោយសារទីនោះមានខ្យល់ល្អទេ តែដោយសារទីនេះជាភូមិកំណើតរបស់វា។*

**កំណត់សម្គាល់៖**

-គេប្រើ "កិរិយានាម" ជំនួសឃ្លាហេតុ កាលណាឃ្លារណបនិងឃ្លាច្បងមានប្រធានដូចគ្នា៖

- *វាមិនធ្វើការអ្វីសោះ ព្រោះឈឺ។*
- *គាត់ហេវហត់ខ្លាំង មកអំពីធ្វើការច្រើន។*

-ហេតុអាចសម្តែងឡើងដោយកន្សោមនាម៖

- *វាញ័រដោយរងា។*
- *វាប្រឡងជាប់ ព្រោះសេចក្តីព្យាយាម។*
- *វាប្រឡងធ្លាក់ដោយហេតុសេចក្តីខ្ជិល។*

**គ.២.៤. ឃ្លាទេសកាលទំនាស់ឬឃ្លាទំនាស់**

ឃ្លាទំនាស់សម្រាប់ចង្អុលបង្ហាញអំពើទំនាស់ឬផ្ទុយនឹងអំពើក្នុងឃ្លាច្បង។ វាផ្តើមដោយឈ្នាប់ឃ្លា "ទោះបី ទោះតែ ថ្វីត្បិត សូម្បី"៖

- *<u>ទោះបីវាឈឺក្បាល</u> វានៅតែបន្តការងាររបស់វាតទៅទៀត។*
  *(វាឈឺក្បាល ប៉ុន្តែវានៅតែធ្វើការ)*
- *<u>ទោះបីមេឃភ្លៀងយ៉ាងណាក៏ដោយ</u> កសិករក៏នៅតែដកសំណាបញាប់ដៃដដែល។*
- *<u>ថ្វីត្បិតតែយើងរៀនចេះច្រើន</u> យើងត្រូវតែគោរពប្រជាជន។*
- *អាក្បត់វាសម្លាប់ទាំងអស់ <u>សូម្បីកុមារមិនទាន់ចេះស្ដីក៏ដោយ</u>។*

**កំណត់សម្គាល់៖**

-គេប្រើ "យ៉ាងណាក៏ដោយ... (ក៏) " បន្ថែមលើឈ្នាប់ឃ្លាដើម្បីបញ្ជាក់ឱ្យរឹតតែដឹងច្បាស់៖

- *ទោះឯងប្រើកម្លាំងយ៉ាងណាក៏ដោយ* ឯងពុំអាចសម្រេចបំណងទេ។
- *ទោះគាត់ក្រយ៉ាងណាក៏ដោយ* ស្មារតីតស៊ូរបស់គាត់នៅរឹងប៉ឹងជានិច្ច។
- *ទោះវាស្រែកខ្លាំងយ៉ាងណាក៏ដោយ* វាក៏ពុំអាចធ្វើឱ្យគេខ្លាចវាដែរ។

-គេអាចប្រើ "កិរិយានាម" កាលណាមានប្រធានដូចគ្នា៖

- *ទោះបីក្រ* គាត់តែងរក្សាស្មារតីបដិវត្តបានល្អជានិច្ច។

-កន្សោមនាមអាចសម្តែង"ទំនាស់"

- *ខ្ញុំត្រូវតែទៅ ទោះឧបសគ្គក៏ដោយ*។
- *យើងត្រូវតែប្រយុទ្ធ ទោះចក្រពត្តិក៏ដោយ*។

-ប្រើពាក្យ "...នរណាក៏ដោយ...ក៏..."

- *ទោះគាត់ជានរណាក៏ដោយ ខ្ញុំក៏ពុំខ្លាចគាត់ដែរ*។
- *ទោះនរណាក៏ដោយ (ទោះអ្វីក៏ដោយ) ខ្ញុំក៏ពុំញញើតដែរ*។

-ល្បះទោលក៏អាចបញ្ជាក់ទំនាស់បានដែរ៖

- *គាត់ខឹងច្រើន ប៉ុន្តែ (គាត់) ចិត្តល្អទេ*។
- *វាខំស្រែកយ៉ាងណាក៏ដោយ គ្មាននរណាឮទេ*។

**គ.២.៥. ឃ្លាទេសកាលបំណែបឬឃ្លាបំណែប**

ឧ. *ឯងអាចធ្វើតាមឯងចង់ ឱ្យតែយើងបានល្អ*។

*វាដើរចេញទៅ ដោយគ្មាននរណាចាប់ភ្លឹកឡើយ*។

**គ.២.៦. ឃ្លាទេសកាលបន្ថែមឬឃ្លាបន្ថែម**

ឧ. *ថែមលើវាឧស្សាហ៍ វាមានប្រាជ្ញាទៀត*។

*ជាមួយនឹងវាខ្ជិល វាល្ងង់ថែមទៀត*។

**គ.២.៧. ឃ្លាទេសកាលលើកលែងឬឃ្លាលើកលែង**

ឧ. *វាមានគុណសម្បត្តិសព្វគ្រប់ លើកលែងតែវាខ្ជិលបន្តិច*។

*គាត់ស្គាល់គ្រប់កន្លែង លើកលែងតែកន្លែងណាមានព្រៃភ្នំ*។

**គ.២.៨. ឃ្លាទេសកាលវិបាកឬឃ្លាវិបាក**

ឃ្លាវិបាកសម្រាប់ប្រាប់អំពើដែលជាវិបាកនៃអំពើសម្តែងឡើងក្នុងឃ្លាច្បង។ វាផ្តើមដោយឈ្នាប់ឃ្លា "ទាល់តែ រហូតដល់ ដល់ រហូត..."។

ឧ. *គាត់ខំធ្វើការ រហូតដល់គាត់ខ្យល់ចាប់*។

*វានៅតែក្នុងផ្ទះ រហូតវាឈឺ*។

*វាស្រែកខ្លាំង <u>ទាល់តែវាភ្លាត់សំឡេង</u>។*

*វាយំច្រើន <u>ទាល់តែវាហើមភ្នែក</u>។*

*រឿងនេះអច្ឆរិយៈហួសហេតុ <u>ទាល់តែគេលែងជឿគ្រប់គ្នា</u>។*

*វាសើច <u>ដល់ទឹកភ្នែកហូរ</u>។*

*វាភ័យ <u>រហូតដល់វាញ័រខ្លួនយ៉ាងខ្លាំង</u>។*

**កំណត់សម្គាល់៖**

-"វិបាក" អាចសម្តែងដោយកន្សោម៖

- *គាត់ត្រូវរបួសដល់ស្លាប់។*
- *វាផឹកកាផេទាល់តែឆ្អែត។*
- *វាឃ្លានបានជាយំ។*

-ល្បះដាក់បន្តគ្នា៖

- *វាដើរលឿន ខ្ញុំពុំអាចតាមទាន់ទេ។*
- *វានិយាយតិចពេក គេស្តាប់មិនឮសោះ។*

### គ.២.៩. ឃ្លាទេសកាលប្រៀបធៀបឬឃ្លាប្រៀបធៀប

ឃ្លាប្រៀបធៀបចង្អុលបង្ហាញទំនាក់ទំនង ដូចគ្នា ស្មើគ្នា ផ្សេងគ្នា ឬសមាមាត្រនឹងគ្នារវាងអំពើដែលឃ្លារណាបសម្តែងឡើងនិងអំពើដែលឃ្លាច្បងសម្តែងឡើង។ វាផ្តើមដោយឈ្នាប់ឃ្លា *ដូច ដូចជា ស្មើគ្នានឹង ប៉ុនគ្នានឹង ដូចគ្នានឹង*...៖

- *ខ្ញុំស្រឡាញ់ប្រទេសខ្ញុំ <u>ដូចអ្នកឯងស្រឡាញ់ប្រទេសអ្នកឯងដែរ</u>។*
- *ខ្ញុំចូលចិត្តសៀវភៅ <u>ដូចជាវាចូលចិត្តហូបនំ</u>។*
- *នាងតូចនេះយោលកូនក្រមុំ <u>ដូចជាម្តាយយោលទារក</u>។*
- *រូបរាងគាត់នៅតែដដែល <u>ដូចខ្ញុំឃើញគាត់ពីមុន</u>។*
- *វាគោរពឪពុកម្តាយវា <u>ស្មើគ្នានឹងវាស្រឡាញ់គាត់</u>។*

**កំណត់សម្គាល់៖**

-កន្សោមប្រាប់ "ការប្រៀបធៀប"៖

- *វាមានប្រាជ្ញាដូចបងវា (ដូចបងវាមានប្រាជ្ញា)។*
- *គាត់ស្រឡាញ់នំដូចផ្លែឈើ (ដូចគាត់ស្រឡាញ់ផ្លែឈើ)។*
- *វាពូកែជាងមិត្តវា (ជាងមិត្តវាពូកែ)។*
- *វាពូកែជាងឆ្នាំទៅ (ជាងវាពូកែឆ្នាំទៅ)។*

## គ.២.១០. ឃ្លាទេសកាលបំណើឬឃ្លាបំណើ

ឃ្លាបំណើសម្រាប់បង្ហាញលក្ខខ័ណ្ឌណាដែលអាចនាំឱ្យកើតឡើងនូវអំពើក្នុងល្បះច្បង (ល្បះគោល)។ វាផ្តើមដោយចំណងឃ្លា “បើ បើស្រិន បើស្រិនណា បើស្រិនណាជា ក្នុងលក្ខខណ្ឌដែល...”៖

- *<u>បើមិត្តខ្ញុំមក</u> យើងលេងបាល់។*

(បច្ចុប្បន្នទម្លាប់៖ នៅគ្រប់ពេលដែលមិត្តខ្ញុំមកយើងលេងបាល់ (រាល់ដង) )

- *<u>បើឯងបានប្រឡងជាប់</u> យើងនឹងបានសប្បាយទៅហើយ។*
- *<u>បើវាបានត្រូវឆ្នោត</u> វានឹងបានទិញគោមួយនឹមរួចស្រេច។*

(អតថភាពក្នុងអតីត - បំណើពុំបានសម្រេចទេ)

**កំណត់សម្គាល់៖**

-សង្កេត

| | ឃ្លាបំណើ | : ឃ្លាច្បង |
|---|---|---|
| យថាភាពក្នុងបច្ចុប្បន្ន | បើ + ប្រ + កិ | : ប្រ + កិ |
| អតថភាពក្នុងបច្ចុប្បន្ន | បើ + ប្រ + កិ | : ប្រ + នឹង + កិ |
| អតថភាពក្នុងអតីត | បើ + ប្រ + បាន + កិ | : ប្រ + នឹង + បាន + កិ |

| ក | ខ | គ |
|---|---|---|
| ខ្ញុំនិយាយថា | បើវាមក | យើងនឹងលេងបាល់ |

បើធៀបនឹង «ក» និង «ខ», «គ» សម្តែងអនាគត

-សង្កេត

| ខ | គ | ក |
|---|---|---|
| បើវាបានប្រឡងជាប់ | យើងនឹងបានសប្បាយទៅហើយ | ខ្ញុំនិយាយ |

បើធៀបនឹង “ ខ”, “គ” សម្តែងអនាគត។ តែបើធៀបនឹង “ក” វិញ “ខ” និង “ គ” ជាអតីតរបស់ “ក” ។ អំពើ “ ខ” និង “គ” ពុំបានសម្រេចទេ។

-គេប្រើពាក្យយ៉ាងខ្លីសម្គាល់ឃ្លាបំណើ៖

- *ដើរឱ្យលឿន បើពុំដូចនោះទេឯងនឹងទៅពុំទាន់រថភ្លើងទេ។*

(បើពុំនោះទេ/បើមិនអ៊ីចឹងទេ)

-ឃ្លាបំណើកប់ ៖

- *កុំរកអី ឯងរកពុំឃើញទេ (<u>បើឯងរកវា</u> ឯងរកវាពុំឃើញទេ)។*

-ពាក្យសម្តែង "បំណើ"៖

- *<u>ក្នុងករណីឈឺ</u> ឯងទៅមន្ទីរពេទ្យ។*
- *<u>ក្នុងករណីរវល់</u> ឯងពុំបាច់មកទេ។*
- *<u>ក្នុងលក្ខខណ្ឌផ្សេងពីនេះ</u> ឯងរួចខ្លួន។*

*ក្នុងករណីឈឺ ក្នុងករណីរវល់ ក្នុងលក្ខខណ្ឌផ្សេងពីនេះ* ជាកន្សោមមានផ្ទាក់កម្មទេសកាលប្រាប់បំណើ។ ប៉ុន្តែ *"ក្នុងករណីដែលឯងឈឺ ក្នុងករណីដែលឯងរវល់"*វិញ ជាឃ្លាទេសកាលប្រាប់បំណើ។

**គំនូសតាងល្បះ**




ឈ = ឈ្នាប់ឃ្លា យ = ឃ្លា យទ = ឃ្លាទេសកាល

### ៥.៣. ល្បះក្រង

### ៥.៣.១. និយមន័យ

**ល្បះក្រង** គឺជាល្បះដែលកើតឡើងដោយសារល្បះច្រើនចាប់ពីពីរឡើងទៅនៅបន្តបន្ទាប់គ្នា។ ល្បះនីមួយៗហៅថា "ល្បះរង"។ ល្បះរងជាល្បះទោលឬល្បះផ្សំ។ ល្បះរងអាចនៅបន្តបន្ទាប់គ្នាឬអាចភ្ជាប់គ្នាដោយសារ "ឈ្នាប់ចង" (តែ ប៉ុន្តែ និង ឬ)។

### ៥.៣.២. ល្បះរងភ្ជាប់គ្នាដោយសារ "ឈ្នាប់ចង"

ក្នុងល្បះនេះ

*-ធីតាចង់ទៅលេងខេត្តព្រះសីហនុ ប៉ុន្តែនាងជាប់ប្រឡងឆមាសទី១។*

ល្បះរង ល្បះរង

ល្បះ *"ឪតាចង់ទៅលេងខេត្តព្រះសីហនុ"* ភ្ជាប់ទៅនឹងល្បះ *"នាងជាប់ប្រឡងឆមាសទី១"* ដោយសារឈ្នាប់ចង *"ប៉ុន្តែ"*។

**៥.៣.៣. ល្បះរងនៅបន្តបន្ទាប់គ្នា**

ក្នុងល្បះនេះ

- *ម៉ែដាំបាយ កូនស្រីចិតបន្លែ ឪពុកអានសៀវភៅ។*

ល្បះរង ល្បះរង ល្បះរង

ល្បះនេះពុំមានចំណងទេ។ ល្បះរងដាក់បន្តបន្ទាប់គ្នាពីមួយទៅមួយ។

**៦. បែបនិងរូបរាងនៃល្បះ**

**៦.១. បែបនៃល្បះ**

ល្បះមាន៤បែប គឺល្បះបញ្ជាក់ ល្បះបញ្ជា ល្បះសំណួរ និងល្បះឧទាន។

**៦.១.១. ល្បះបញ្ជាក់**

**ល្បះបញ្ជាក់** ទុកដូចជា "ល្បះបាត" នៃល្បះឯទៀត ព្រោះល្បះដទៃទៀតចេញពីល្បះបញ្ជាក់។ ល្បះបញ្ជាក់ងាយមាន៖

- កន្សោមនាមប្រធានចាំបាច់
- កន្សោមកិរិយាចាំបាច់ដែលមានកិរិយាសព្ទនិងកន្សោមនាមកម្មបទ ឬកិរិយាសព្ទ "ជា" និងគុណប្រធាន។
- កន្សោមមានធ្នាក់ (កម្មទេសកាល) បន្ទាប់បន្សំ។

ក្នុងល្បះបញ្ជាក់ ប្រធាននៅខាងឆ្វេងកិរិយា ឯកម្មបទនៅខាងស្តាំកិរិយា៖

- *សុខសំពះឪពុកម្តាយ។*
- *សំដាំពោត។*
- *គាត់វាយវា។*

**៦.១.២. ល្បះបញ្ជា**

**ល្បះបញ្ជា** សម្រាប់ប្រើដើម្បី៖

- **បង្គាប់៖** *ទៅ! ចូរអ្នកទៅចុះ!*
- **ឱ្យដំបូន្មាន៖** *ចូរអ្នកប្រយ័ត្នគ្រោះថ្នាក់។*
- **ធ្វើសំណូមពរ៖** *សូមឱ្យមិត្តបានសុខ។*
- **អង្វរ៖** *សូមបងអភ័យទោស។*

ក្នុងល្បះបញ្ជាមានប្រើពាក្យ៖

- *ចូរ* នៅដើមល្បះបញ្ជា (អ្នកធំទៅអ្នកតូច)
- *សូម* នៅដើមល្បះបញ្ជា (អ្នកតូចទៅអ្នកធំ)
- *សុំ* នៅដើមល្បះបញ្ជា (អ្នកធំនិយាយទៅកាន់អ្នកតូច)។

### ៦.១.៣. ល្បះសំណួរ

**ល្បះសំណួរ** សម្រាប់សួរទៅអ្នករួមប្រាស្រ័យជាមួយៈ

*-សុកទៅផ្សារឬទេ?*

*-តើឯងនៅធ្វើការនេះឬទេ?*

*-ការងារយើងទទួលបានជោគជ័យនៅថ្ងៃណា?*

ល្បះសំណួរចែកជា ៖

**ក. ល្បះសំណួរទាំងមូល**

ល្បះសំណួរទាំងមូល គឺជាល្បះណាដែលសួរទៅលើល្បះទាំងអស់។ ចម្លើយមានពីរយ៉ាងគឺ "បាទឬទេ"។ ល្បះសំណួរអាចកើតឡើងដោយសារៈ

-ល្បះបញ្ជាក់មានសំនៀងសួរ (?)

*សុកទៅស្រែ?*

*វាដាំកូនដូង?*

-តើ + ល្បះបញ្ជាក់

*តើសុកទៅស្រែ?*

*តើវាដាំកូនដូង?*

-ល្បះបញ្ជាក់ + ឬទេ?

*សុកទៅស្រែឬទេ?*

*វាដាំកូនដូងឬទេ?*

**ខ. ល្បះសំណួរផ្នែក**

ល្បះសំណួរផ្នែក គឺជាល្បះណាដែលសួរទៅលើធាតុណាមួយនៃល្បះ។ ចម្លើយជាកន្សោមនាម។ ល្បះសំណួរផ្នែកកើតឡើងដោយៈ

-ប្រើសព្វនាមសំណួរៈ *វាជានរណា?*

-ប្រើគុណនាមសំណួរៈ *ឯងទៅថ្ងៃណា?*

-ប្រើគុណកិរិយាសំណួរៈ *ហេតុអ្វីបានជាវាទៅស្រែ?*

**គ. បែបនៃល្បះសំណួរ**

ល្បះសំណួរមានប្រើច្រើនយ៉ាងដូចជា៖

-ល្បះសំណួរបែប "បញ្ជាក់"

-ល្បះសំណួរបែប "ឬទេ"

-ល្បះសំណួរបែប "ដណ្ដឹង"

-ល្បះសំណួរពេញនិងល្បះសំណួរមិនពេញ។

ឯចម្លើយវិញក៏មានច្រើនណាស់ដែរដូចជា ៖

-ល្បះចម្លើយស្រប

-ល្បះចម្លើយមិនស្រប

-ល្បះចម្លើយវែង

-ល្បះចម្លើយខ្លី។

**គ.១. ល្បះសំណួរបែបបញ្ជាក់**

ល្បះនេះសម្រាប់សួរបញ្ជាក់សេចក្ដី ព្រោះអ្នកសួរដឹងពុំច្បាស់។

| សំណួរ | ចម្លើយ "បាទ" | ចម្លើយ "ទេ" |
|---|---|---|
| *ពីរកញ្ចប់?* | *បាទ! ពីរកញ្ចប់។* | *ទេ! ១កញ្ចប់។* |
| *វត្ថុហ្នឹង?* | *បាទ! វត្ថុហ្នឹង។* | *ទេ! មិនមែនវត្ថុហ្នឹងទេ។* |

**គ.២. ល្បះសំណួរបែប "ឬទេ"**

| សំណួរ | ចម្លើយស្រប "បាទ" | ចម្លើយមិនស្រប "ទេ" |
|---|---|---|
| *គាត់ស្ដាប់បានឬទេ?* | *បាទ! គាត់ស្ដាប់បាន។* | *ទេ! គាត់ស្ដាប់ពុំបានទេ។* |
| *អ្នកយល់ឬទេ?* | *បាទ! ខ្ញុំយល់ហើយ។* | *ទេ! ខ្ញុំមិនយល់ទេ។* |

**គ.៣. ល្បះសំណួរបែប "ដណ្ដឹង"**

ល្បះសំណួរនេះសម្រាប់ដណ្ដឹងសួរដោយអ្នកសួរពុំដឹងសោះ។

| សំណួរ | ចម្លើយខ្លី | ចម្លើយវែង |
|---|---|---|
| *អ្នកណាធ្វើមុន?* | *ខ្ញុំ។* | *ខ្ញុំធ្វើមុន។* |
| *ឯងហៅអ្នកណា?* | *បងសំ។* | *ខ្ញុំហៅបងសំ។* |

### ៦.១.៤. ល្បះឧទាន

**ល្បះឧទាន** ជាល្បះប្រើសម្រាប់សម្ដែងមនោសញ្ចេតនាឬចំណាប់អារម្មណ៍ភ្លាមៗ។ វាមានសំនៀងពិសេសប្លែកពីល្បះសំណួរ។ ល្បះឧទានបញ្ចប់ដោយសញ្ញា

ឧទាន (!)។

ឧ. *ពូឯងអីក៏ប្រសប់អ្វីម្ល៉េះ!*

*ឱ! នារីនេះណាស់តើ!*

ល្បះឧទានប្រើ *អីក៏......ម្ល៉េះទេ!*

-ប្រើ .................*អ្វីម្ល៉េះទេ!*

ស្រូវឆ្នាំនេះល្អអ្វីម្ល៉េះទេ!

-ប្រើ *ណាស់នំ! ណាស់តើ! អស្ចារ្យណាស់! ពេកកន្លង!*

*រូបចម្លាក់នេះសមពេកណាស់!*

*រូបចម្លាក់នេះសមណាស់នំ!*

*កុមារនេះចេះគួរសមណាស់តើ!*

-ប្រើពាក្យឧទានខាងដើមល្បះ

*ឱ! រូបអើយរូប!*

-ប្រើពាក្យ *អើយ*

*ឱ! រូបខ្ញុំអើយ!*

*អញអើយអញ!*

-ប្រើសញ្ញាឧទាន (!)

*ទ័ពយើងបានជោគជ័យហើយ!*

### ៦.២. រូបរាងនៃល្បះ

ល្បះនីមួយៗមានរូបរាង ៣យ៉ាងគឺ ល្បះស្រេបឬល្បះមិនស្រប ល្បះកត្តុឬល្បះកម្ម ល្បះធម្មតាឬល្បះសង្កត់។

### ៦.២.១. ល្បះស្របនិងល្បះមិនស្រប

ល្បះស្របប្រាប់អំពើអ្វីមួយដែលកើតឡើងពិតៗ។ ល្បះមិនស្របប្រាប់អំពើអ្វីមួយដែលពុំមានកើតឡើងទេ។

**ក. ល្បះបញ្ជាក់**

| ល្បះបញ្ជាក់ស្រប | ល្បះបញ្ជាក់មិនស្រប |
|---|---|
| *ខ្ញុំទៅសាលារៀន។* | *ខ្ញុំមិនទៅសាលារៀនទេ។* |
| *ខ្ញុំចង់ទៅស្រែ។* | *ខ្ញុំមិនចង់ទៅស្រែទេ។* |
| *វានឹងទៅភ្នំពេញ។* | *វានឹងមិនទៅភ្នំពេញទេ។* |

*គាត់នៅមើលឃើញ។* *គាត់នៅមើលមិនទាន់ឃើញ។*
*គាត់នៅមើលឃើញ។* *គាត់លែងមើលឃើញ។*
*វាយកទៅបឹង។* *វាមិនទៅបឹងទេ។*
*នោះគឺវា។* *នោះមិនមែនវាទេ។*
*នោះគឺវា។* *នោះមិនគឺវាទេ។*
*នោះជាកុក។* *នោះមិនមែនជាកុកទេ។*
*មានមនុស្ស។* *គ្មានមនុស្សទេ។*
*គាត់ចូលប្រជុំហើយ។* *គាត់មិនទាន់ចូលប្រជុំ។*
*វារកឃើញហើយ។* *វារកពុំទាន់ឃើញទេ។*

**សង្កេត៖** ដើម្បីបង្កើតល្បះបញ្ជាក់មិនស្រប គេត្រូវថែមល្បះបញ្ជាក់ស្របនូវពាក្យសម្រាប់បង្កើតភាពមិនស្រប ៖

- *មិន............ទេឬ* *ពុំ...............ទេ*
- *មិនមែន........ទេឬ* *ពុំមែន..............ទេ*
- *មិនទាន់.........ទេ* *ពុំទាន់..............ទេ។*

○ តែកិរិយា

- គឺ ប្រើ "មិន គឺ..................ទេ " (ក៏បាន)
- ជា ប្រើ "មិនមែនជា...........ទេ"
- មាន ប្រើ "គ្មាន.....................ទេ"។
- "មិន" ប្រើនៅខាងដើមកន្សោមកិរិយា
  ប្រើនៅចន្លោះ "នឹង" និង កិរិយា
  ប្រើនៅខាងឆ្វេងកិរិយាបំពេញ។
- "ទេ" ប្រើនៅខាងចុះល្បះ។

**ខ. ល្បះបញ្ជា**

**ល្បះបញ្ជាស្រប** **ល្បះបញ្ជាមិនស្រប**

*បាញ់ទៅ។* *កុំបាញ់។*
*ទៅរៀនចុះ។* *កុំទៅរៀនអី។*
*ចូរអ្នកឱ្យវាទៅចុះ។* *ចូរអ្នកកុំឱ្យវាទៅអី។*
*សុំឱ្យវាទៅផង។* *សុំកុំឱ្យវាទៅអី។*

| | |
|---|---|
| *យកវាមកណា។* | *កុំយកវាមកណា។* |
| *យកមកវ៉ី។* | *កុំយកមកវ៉ី។* |
| *ឯងត្រូវទៅ។* | *ឯងមិនត្រូវទៅទេ។* |
| | *ឯងត្រូវកុំទៅអី។* |

**សង្កេត៖** ក្នុងល្បះមិនស្របគេប្រើ៖

"កុំ..........អី"

"មិន.............ទេ"

"កុំ...........វ៉ី"។

- "កុំ"នៅដើមកន្សោមកិរិយា
- "កុំ"នៅខាងស្តាំកិរិយាជំនួយ "សុំ" "ត្រូវ"...។
- "មិន" នៅខាងឆ្វេងកិរិយាជំនួយ "ត្រូវ"...។

○ ក្នុងភាសាខ្មែរ ល្បះបញ្ជាគេអាចប្រើប្រធានក៏បានដែរ ដូចជា ៖

*ឯងមិនត្រូវដើរលែងហួសហោតុពេកទេ។*

*ចូរអ្នកខំប្រឹងបំពេញភារកិច្ចបដិវត្តឱ្យបានល្អ។*

**គ. ល្បះសំណួរ**

| **ល្បះសំណួរស្រប** | **ល្បះសំណួរមិនស្រប** |
|---|---|
| *តើឯងទៅផ្ទះឬទេ?* | *តើឯងមិនទៅផ្ទះទេឬ?* |
| *តើឯងចង់ទៅស្រែឬទេ?* | *តើឯងមិនចង់ទៅស្រែទេឬ?* |
| *តើឯងនឹងចេញទៅស្អែកឬទេ?* | *តើឯងនឹងមិនចេញទៅស្អែកទេឬ?* |
| *តើវាមើលឃើញឬទេ?* | *តើវាមើលមិនឃើញទេឬ?* |
| *នោះគឺសញ្ញាជាតិឬទេ?* | *នោះមិនគឺសញ្ញាជាតិទេឬ?* |
| *មានគ្នាច្រើនឬទេ?* | *គ្មានគ្នាច្រើនទេឬ?* |
| *ឯងបានភ្ជួរហើយឬនៅ?* | *ឯងមិនបានភ្ជួរទេឬ?* |
| *ឯងឱ្យវាទៅដែរឬទេ?* | *វាមិនចាំបាច់ទៅទេឬ?* |

**សង្កេត៖**

- *"ឬទេ"* ប្រើនៅខាងចុងល្បះសំណួរស្រប។

*"ទេឬ"* ប្រើនៅខាងចុងល្បះសំណួរមិនស្រប

- សំណួរភ្ជាប់៖ ក្នុងភាសាខ្មែរយើង គេមានប្រើ

សំណួរភ្ជាប់ក្នុងល្បះសំណួរ ៖

*-មេឃចង់ភ្លៀងអ៊ីចឹងមែនទេ?*

*-មេឃចង់ភ្លៀងមែនទេ?*

*-ស្រូវឆ្នាំនេះល្អណាស់មែនទេ?*

ចំពោះសំណួរភ្ជាប់ *"មែនទេ"* គេអាចឆ្លើយថា *"មែនហើយ"* ក៏បាន *"ពុំមែន"* ក៏បាន។ ប៉ុន្តែអ្នកសួរចង់ឱ្យឆ្លើយថា *"មែន"* ព្រោះគេអាចដឹងច្បាស់រួចទៅហើយ (ថាពិត)។

- សំណួរភ្ជាប់៖ ដទៃទៀត

*-ជួយខ្ញុំផងបានទេ?*

*-កុំឡូឡាពួទេ?*

*-ត្រូវខំរៀនស្តាប់បានទេ?*

សំណួរភ្ជាប់បែបនេះសម្រាប់បញ្ជាក់សេចក្តីខាងដើមនិងបង្ខំអ្នកស្តាប់ឱ្យធ្វើតាម។

-ក្នុងល្បះសំណួរគេអាចប្រើពាក្យ *"តើ"* ក៏បាន មិនប្រើក៏បាន។

**ឃ. ល្បះឧទាន**

**ឃ.១. ល្បះឧទានស្រប**

*-ពួឯងអីក៏ល្ងង់ម្ល៉េះទេ!*

*-យោបល់ឯងល្អណាស់តើ!*

*-យីអើ! ថ្ងៃនេះ គំនិតឯងចម្លែកណាស់ន៎!*

**ឃ.២. ល្បះឧទានមិនស្រប**

*-ពួឯងអីក៏មិនល្ងង់សោះអ៊ីចេះ!*

*-យីអើ! ថ្ងៃនេះ គំនិតឯងក៏មិនចម្លែកសោះអ៊ីចឹង!*

**៦.២.២. ល្បះកត្តុនិងល្បះកម្ម**

**ក. ល្បះបញ្ជាក់**

**ក.១. ល្បះបញ្ជាក់កត្តុ**

*-សំវាយឆ្កែនោះ។*

*-គេភានចម្ការនេះ។*

*-យើងគោរពឪពុកម្តាយយើង។*

ក.២. ល្បះបញ្ជាក់កម្ម

*-ផ្លែនេះត្រូវសំវាយ។*

*-ផ្លែនេះត្រូវវាយដោយសំ។*

*-ផ្លែនេះសំវាយ។*

*-ចម្ការនេះត្រូវគេរាន។*

*-ឪពុកម្តាយយើងត្រូវយើងគោរព។*

**ខ. ល្បះសំណួរ**

ខ.១. ល្បះសំណួរកត្តុ

*-តើសំវាយផ្លែនេះដែរឬទេ?*

*-តើគេរានចម្ការនេះឬទេ?*

ខ.២. ល្បះសំណួរកម្ម

*-តើផ្លែនេះត្រូវសំវាយឬទេ?*

*-តើចម្ការនោះត្រូវគេរានឬទេ?*

**គ. ល្បះឧទាន**

គ.១. ល្បះឧទានកត្តុ

*-ឱ! គេឆ្លាក់រូបនេះល្អអ្វីម្ល៉េះទេ!*

*-ឱ! គេវាយឆ្មាខ្ញុំខ្លាំងម្ល៉េះទេ!*

គ.២. ល្បះឧទានកម្ម

*-ឱ! រូបនេះត្រូវគេឆ្លាក់ល្អអ្វីម្ល៉េះទេ!*

*-ឱ! ឆ្មាខ្ញុំត្រូវគេវាយខ្លាំងម្ល៉េះទេ!*

**៦.២.៣. ល្បះធម្មតានិងល្បះសង្កត់**

**ល្បះធម្មតា** គឺល្បះមិនសង្កត់។ ល្បះសង្កត់គឺល្បះដែលគេនិយាយសង្កត់ទៅលើធាតុណាមួយ ដើម្បីពន្លេចឡើងឱ្យឃើញច្បាស់។ ល្បះសង្កត់កើតឡើងដោយៈ

-ដាក់ពាក្យសំខាន់ដែលគេចង់បញ្ជាក់នៅដើមល្បះ៖

- ល្បះធម្មតា

  *ពីម្សិលមិញ ខ្ញុំប្រាប់សុខឱ្យទៅស្រែ។*

- ល្បះសង្កត់

  *ខ្ញុំ ខ្ញុំប្រាប់សុកឱ្យទៅស្រែ។*

  *សុក ខ្ញុំប្រាប់វាឱ្យទៅស្រែ។*

*ពីម្សិលមិញនេះ ខ្ញុំប្រាប់សុកឱ្យទៅស្រែ។*

**-ថែមពាក្យ** "គឺ...ដែល" ... ឬ

"គឺ...នេះហើយ ដែល..."

ឧ. *គឺខ្ញុំដែលប្រាប់សុកឱ្យទៅស្រែ។*

*គឺសុកនេះហើយដែលខ្ញុំប្រាប់ឱ្យទៅស្រែ។*

*គឺម្សិលមិញនេះហើយដែលខ្ញុំប្រាប់សុកឱ្យទៅស្រែ។*

*គឺស្រែនោះហើយដែលខ្ញុំប្រាប់សុកឱ្យទៅ។*

**-សង្កេតទី១**

ល្បះខ្លះអាចជា ល្បះកត្តុផង មិនស្របផង សង្កត់ផង៖

*គឺសំនេះហើយដែលគេមិនវាយវា។*

ឬល្បះកម្មផង មិនស្របផង សង្កត់ផង ៖

*គឺចោរនេះហើយដែលមិនត្រូវគេវាយស្លាប់ដូចចោរដទៃ។*

**-សង្កេតទី២**

ល្បះទោលនីមួយៗអាចមានកម្មទេសកាលច្រើនដូចជា ៖

- **កម្មកាល**

**ពេល៖**

*ស្អែក វាទៅស្រែ។*

*ខែក្រោយ គាត់នឹងទៅលេងស្រុកកំណើត។*

*ពីឆ្នាំទៅ សំបានរង្វាន់។*

*កាលពីដើមឆ្នាំ វាខំភ្លូររាស់ណាស់។*

**រយៈពេល៖**

*តែក្នុងរយៈកាលដ៏ខ្លី កងទ័ពយើងវាយឈ្នះខ្មាំង។*

- **កម្មកន្លែង**

*គាត់ទៅស្រុកកំណើត។(កន្លែងដែលគេទៅកាន់)*

*គាត់ទៅស្រែក្រោម។*

*សំមកពីស្រែ។(កន្លែងដែលគេចាកចេញ)*

*ឪពុកខ្ញុំមកពីបណ្ណាល័យ។*

*ឆ្មាលោតតាមបង្អួច។(កន្លែងដែលគេឆ្លងកាត់)*

*វាដើរកាត់វាលស្មៅ។*

- **កម្មហេតុ**

*-ស្រូវល្អព្រោះប្រើជី។*

*-វាបានជោគជ័យក្នុងការងារ ព្រោះសេចក្ដីព្យាយាមរបស់វា។*

*-វាស្រក់ទឹកភ្នែកដោយកំហឹង។*

*-ដោយសារតែចរិយាល្អរបស់វា សំទទួលបានសេចក្ដីរាប់អានពីគ្រប់មជ្ឈដ្ឋាន។*

*-វាប្រឡងធ្លាក់ត្បិតខ្ជិល។*

- **កម្មបំណែប**

*-សំធ្វើការដោយយកចិត្តទុកដាក់។*

*-គាត់ភ្ជួរដីអំណត់ក្រៃលែង។*

*-កងទ័ពយើងវាយខ្មាំងដោយខ្លាហាន។*

- **កម្មមធ្យោបាយឬកម្មឧបករណ៍**

*-យើងដោះបាយនឹងវែកត្រលោក។*

*-ខ្មែរយើងបរិភោគបាយដោយសមស្លាបព្រា។*

*-គាត់ឆ្លងកាត់ទន្លេដោយទូក។*

*-គេទៅម៉ូស្គូដោយអាកាសយាន។*

- **កម្មបំណង**

*-យើងសង់សាលាសម្រាប់កូនចៅយើង។*

*-យុវជនយើង ខំប្រឹងរៀនដើម្បីអនាគតរបស់ខ្លួននិងប្រទេសជាតិ។*

- **កម្មប្រៀបធៀប**

*-វាយំដូចក្មេង។*

*-សំធ្វើការដូចមនុស្សចាស់។*

*-កុមារនេះសប្បាយរីករាយដូចខ្ញុំ។*

- **កម្មសហ**

*-គាត់ដើរលេងជាមួយគ្រួសារគាត់។*

*-វាធ្វើការជាមួយមិត្តភក្តិវា។*

*-ខ្ញុំច្រូតស្រូវជាមួយនឹងអ្នកភូមិខ្ញុំ។*

- **កម្មលើកលែង**

*-គេទៅស្រែទាំងអស់គ្នាលើកលែងតែសុខ។*

*-យើងនៅសាលាលើកលែងតែអ្នកឈើ។*

- **កម្មតម្លៃ**

*-សៀវភៅនេះថ្លៃ១០៛។*

*-តុនេះថ្លៃ១០៛។*

- **កម្មប្រភព**

*-វាចេញមកពីគ្រួសារកសិករក្រ។*

*-រូបនេះ ស្រង់ចេញមកពីរូបអង្គរ។*

- **កម្មរង្វាស់**

*-ផ្ទះនោះមានកម្ពស់៥០ម។*

*-រូបនេះ មានប្រវែង៤០ម។*

- **កម្មទម្ងន់**

*-សៀវភៅនោះមានទម្ងន់២០គ.ក.។*

*-ស្រូវនេះមានទម្ងន់៥តោន។*

- **កម្មរង្វាល់**

*-ធុងនេះមានចំណុះ៤០ល។*

*-ដបនេះមានចំណុះ១ល។*

- **កម្មរូបធាតុ**

*-អាគារសិក្សាខ្ញុំសង់អំពីឈើ។*

*-អាគារនោះសង់អំពីថ្ម។*

- **កម្មទំនាស់**

*-សំប្រឹងធ្វើការទោះបីជួបនឹងការលំបាក។*

*-វាបន្តការសិក្សាទោះក្រ។*

- **កម្មបំណើ**

*-គេនឹងបានជោគជ័យបើខំប្រឹង។*

*-ស្រែកហៅខ្ញុំ ក្នុងករណីចាំបាច់។*

### ៦.២.៤. កថាផ្ទាល់និងកថាមិនផ្ទាល់

កាលណាគេនិយាយនឹងនរណាម្នាក់ គេតែងប្រើតំហាសេចក្ដីដែលបញ្ជាក់ពីអ្វីមួយ (ល្បះញ្ញាក់) ឬដែលសម្ដែងមនោសញ្ចេតនាភ្លាមៗ (ល្បះឧទាន) ៖

*-សំមកនេះ។ ឯងស្រឡាញ់គោនេះទេ?*

*-គោនេះស្អាតណាស់។ រូបវាសង្ហាអីម្ល៉េះទេ!*

តំហាសេចក្ដីទាំងនេះ បង្កើតជា "កថា" ហើយ "កថា" នេះកំណត់ដោយចំណុចតម្រុយ៖

-ធៀបនឹងអ្នកនិយាយ (ខ្ញុំ) និងអ្នកនិយាយជាមួយ (ឯង វា)

-ធៀបនឹងកន្លែងដែល "ខ្ញុំ" នៅ (ទីនេះ ទីនោះ)។

-ធៀបនឹងពេលដែល "ខ្ញុំ" និយាយ (ម្សិល ថ្ងៃនេះ ស្អែក)។

កថាមានពីរយ៉ាងសំខាន់គឺ

-កថាផ្ទាល់ (រចនាបថផ្ទាល់)

-កថាមិនផ្ទាល់ (រចនាបថមិនផ្ទាល់)។

**ក. កថាផ្ទាល់ (រចនាបថផ្ទាល់)**

**កថាផ្ទាល់** គឺជាបែបបទម្យ៉ាងនៃការលើកយកសម្ដីអ្នកណាម្នាក់មកនិយាយឡើងវិញ។ កថាផ្ទាល់លើកសម្ដីទាំងស្រុងរបស់អ្នកណាម្នាក់ មកនិយាយឡើងវិញ ឱ្យបានដូចសម្ដីដែលអ្នកនោះបាននិយាយរួចមកហើយ។ គេស្ដាប់ឮយ៉ាងណា គេលើកយកមកនិយាយយ៉ាងនោះ៖ ទាំងពេលវេលា ទាំងបុរសនៃសព្វនាម ទាំងកាយវិការ។ កថាផ្ទាល់បិតនៅក្នុងក្បៀសបើកបិទ ("...") និងនៅខាងស្ដាំដំពីរ (៖) ដូចជា៖

*គាត់បាននិយាយប្រាប់ខ្ញុំ៖ "ខ្ញុំទៅស្រែ។ ស្អែកក៏ខ្ញុំនឹងទៅស្រែដែរ។ ចូរឯងទៅរកខ្ញុំនៅទីនោះ"។*

**ខ. កថាមិនផ្ទាល់ (រចនាបថមិនផ្ទាល់)**

**កថាមិនផ្ទាល់** គឺបែបបទម្យ៉ាងទៀតនៃការលើកយកសម្ដីអ្នកណាម្នាក់មកនិយាយឡើងវិញ។ គេពុំប្រើក្បៀសបើកបិទទេ។ មានការផ្លាស់ប្ដូរបុរស (ទី១ទៅទី៣, បុរសទី២ទៅទី១)។

ឧ. *គាត់បាននិយាយប្រាប់ខ្ញុំថា គាត់បានទៅស្រែ ស្អែកឡើងគាត់ក៏នឹងបានទៅស្រែដែរ ហើយឱ្យខ្ញុំទៅរកគាត់នៅទីនោះ។*

ដើម្បីបំប្លែងកថាផ្ទាល់ទៅកថាមិនផ្ទាល់ យើងត្រូវ ៖

- លុបចោលដំពីរ (៖)
- ប្រើចំណងឃ្លា “ថា”
- ប្តូរ បុរសទី១ → ទី៣ និងទី២ → ទី១ ។

**ពិនិត្យ**

| **កថាផ្ទាល់** | | **កថាមិនផ្ទាល់** |
|---|---|---|
| *គាត់បាននិយាយប្រាប់ខ្ញុំ៖ “ខ្ញុំទៅស្រែ។ ស្អែក ខ្ញុំក៏នឹងទៅស្រែដែរ។ ចូរឯងទៅរកខ្ញុំនៅទីនោះ”។* | → | *គាត់បាននិយាយប្រាប់ខ្ញុំថា គាត់បានទៅស្រែ ស្អែកឡើងគាត់ក៏នឹងបានទៅស្រែដែរ ឱ្យខ្ញុំទៅរកគាត់នៅទីនោះ។* |
| **បង្ហាញ** | | |
| សម្តីនាំមកជាល្បះទោល | | សម្តីនាំមកជាឃ្លារណប ផ្តើមដោយ “ថា” |
| **បុរស** | | |
| ខ្ញុំ | → | គាត់ |
| ឯង | → | ខ្ញុំ |
| **ពេលវេលា** | | |
| បច្ចុប្បន្ន | → | អតីត |
| អនាគត | → | អនាគតក្នុងអតីត |

# ផ្នែកទី២
# អនុវត្តន៍

# អនុវត្តន៍
## មេរៀនទី១ សញ្ញាណទូទៅនៃវេយ្យាករណ៍

I. **សំណួរ**

១. ដូចម្ដេចហៅថាវេយ្យាករណ៍?

២. អ្វីជាន័យវេយ្យាករណ៍? ចូរឱ្យឧទាហរណ៍បញ្ជាក់។

៣. តើន័យវេយ្យាករណ៍ត្រូវបានបង្ហាញតាមវិធីប៉ុន្មានយ៉ាង? អ្វីខ្លះ?

៤. តើគេអាចចែកប្រភេទវេយ្យាករណ៍មូលដ្ឋានជាប៉ុន្មានយ៉ាង? អ្វីខ្លះ?

II. **លំហាត់អនុវត្តន៍**

**១. តើពាក្យខាងក្រោមមានន័យវេយ្យាករណ៍បង្ហាញពីអ្វី?**

ក. ទូរទស្សន៍ សៀវភៅ តុ កៅអី ម៉ូតូ

ខ. ស ទាប ក្រាស់ ធំ ល្អ

គ. ដើរ មើល រៀន អង្គុយ ទិញ

ឃ. លឿន ឆាប់ យឺត ពូកែ ខ្ជួលខ្ជាញ់

ង. គេ វា គាត់ នាង អ្នក

**២. តើពាក្យខាងក្រោមផ្លាស់ប្ដូររូបរាងដោយសារអ្វី?**

ក. កុមារា កុមារី កីឡាករ កីឡាការិនី ឧបាសក ឧបាសិកា

ខ. Book books man men woman women

គ. Write wrote writen go went gone watch watched watched

**៣. តើពាក្យខាងក្រោមបង្ហាញន័យវេយ្យាករណ៍អ្វី?**

ក. ព្រោះ ដោយសារ មកពី ពីព្រោះ

ខ. ដើម្បី សម្រាប់ ក្នុងបំណង

គ. លុះត្រាតែ លុះត្រាតែ កាលណា

**៤. តើពាក្យខាងក្រោមមានន័យដូចគ្នាដែរឬទេ? ចូរពន្យល់។**

ក. ស៊ីរើស រើសស៊ី

ខ. ក្មេងស្រី ស្រីក្មេង

គ. ទឹកលុយ លុយទឹក

**៥. ចូរអ្នកសាកល្បងអានល្បះខាងក្រោមដោយលើកដាក់សំឡេងដើម្បីឱ្យល្បះទាំងនេះមានន័យប្លែកពីគ្នា៖**

ក. ទៅ!

ខ. កុំនិយាយ!

គ. ខ្ញុំទទួលខុសត្រូវ!

**៦. តើពាក្យផ្ទួនខាងក្រោមបង្ហាញន័យវេយ្យាករណ៍អ្វី?**

ក. រឿងដដែលៗ បញ្ហាឯទៀតៗ

ខ. ក្មេងៗសម័យហ្វេសប៊ុក ចាស់ៗសម័យបុរាណ

គ. ដើរលេងៗ ឃើញស្លុងៗ

ឃ. ម៉ាកល្បីៗ ដើមឈើខ្ពស់ៗ

**៧. ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវ៖**

ក. *ពពក រាំ ជ្រៅ ស្រស់* ជា៖

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ថ្នាក់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ផ្លាស់ប្តូររបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទីកន្លែងរបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ល្បះ

ខ. *ទាត់បាល់ បាល់ទាត់* ជា៖

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ថ្នាក់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ផ្លាស់ប្តូររបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទីកន្លែងរបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ល្បះ

គ. *នាយក នាយិកា* ជា៖

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ថ្នាក់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ផ្លាស់ប្តូររបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទីកន្លែងរបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ល្បះ

ឃ. *ទឹកហូរ, ទឹកហូរខ្លាំង ព្រោះមានភ្លៀងធ្លាក់ច្រើន* ជា៖

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ថ្នាក់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ផ្លាស់ប្ដូររបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទីកន្លែងរបស់ពាក្យ

□ ប្រភេទវេយ្យាករណ៍ដែលប្រាប់ទម្រង់ល្បះ

# អនុវត្តន៍
# មេរៀនទី២ វណ្ណយុត្តិនិងសញ្ញាល្បះ

## I. សំណួរ

១. ដូចម្ដេចដែលហៅថាវណ្ណយុត្តិ?

២. ចូរអ្នករៀបរាប់វណ្ណយុត្តិនៅក្នុងភាសាខ្មែរ។

៣. ចូរអ្នកពន្យល់ពីបម្រើបម្រាស់វណ្ណយុត្តិណាមួយនៅក្នុងភាសាខ្មែរ។

៤. ដូចម្ដេចដែលហៅថាសញ្ញាល្បះ?

៥. ចូរអ្នករៀបរាប់សញ្ញាល្បះនៅក្នុងភាសាខ្មែរ។

៦. ចូរអ្នកពន្យល់ពីបម្រើបម្រាស់សញ្ញាល្បះណាមួយនៅក្នុងភាសាខ្មែរ។

## II. លំហាត់អនុវត្តន៍

**១. ចូរអ្នកហាត់អានពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. សក់ ចង់ ដប់ កាច់ ចាប់...

ខ. អភិវឌ្ឍន៍ និរន្តរ៍ រតន៍ សាធារណ៍...

គ. ភ័យ សម័យ ជ័យ ន័យ និស្ស័យ ខ្វ័រ ជ័រ ប៉ាស្ត័រ គូល័រ ញ៉័រ...

ឃ. តាៗ ក្មេងៗ ថ្មីៗ ខ្ពស់ៗ ញឹមៗ មួយៗ យឺតៗ...

ង. ក៏ ដ៏ ម៏ ន៏...

ច. មតិក មកិត ពណ៌នា ធម៌ សួគ៌ ពណ៌...

ឆ. សះ ជះ ខះ នេះ ចេះ សេះ ជិះ ប៊ិះ ចុះ ដុះ កោះ តោះ នោះ ចង្កឹះ...

ជ. រយៈ សច្ចៈ កាលៈទេសៈ សុខៈ លោភៈ...

ឈ. ម៉ោង យ៉ាង រ៉ុង ង៉ោង ញ៉ក វ៉ា ប៉ែក ប៉ា...

ញ. ស៊ិក ហ៊ាន អ៊ុត អ៊ូច សាប៊ូ...

ដ. ដំ ខំ នំ ចាំ នាំ កុំ សុំ ទុំ ជុំ បាំង ទាំង សាំង...

ឋ. អួយ៎ នុ៎ះ កូក៎ ន៎...

**២. តើសញ្ញាវណ្ណយុត្តិខាងក្រោមប្រើសម្រាប់ធ្វើអ្វី? ចូរអ្នកជ្រើសរើសចម្លើយត្រឹមត្រូវ៖**

ក. សញ្ញាវណ្ណយុត្តិៈ     បន្តក់

☐ បំបែរសំឡេងវែងឱ្យខ្លីកំបុត

☐ កត់សូរ អា់ និងសូរ អ៊ា់ ដោយមានឬគ្មានព្យញ្ជនៈ រ

☐ បំបាត់សូរព្យញ្ជនៈប្រកបឬព្យាង្គដែលនៅខាងក្រោម

ខ. សញ្ញាវណ្ណយុត្តិៈ     ទណ្ឌឃាត

☐ បំបែរសូរព្យញ្ជនៈពួក អ៊ ទៅព្យញ្ជនៈពួក អ

☐ បំបាត់សូរព្យញ្ជនៈប្រកបឬព្យាង្គដែលនៅខាងក្រោម

☐ បំបែរសូរព្យញ្ជនៈពួក អ ទៅព្យញ្ជនៈពួក អ៊

គ. សញ្ញាវណ្ណយុត្តិៈ     ដំលើ

☐ កត់សូរ អំ អ៊ំ អាំ ប្រកបនឹង ម ឬ កត់សូរ អ័រ ប្រកបនឹងព្យញ្ជនៈ ម

☐ ដាក់ពីលើព្យញ្ជនៈមួយដើម្បីឱ្យមានសូរញ៉រ រ

☐ កត់សូរ អា់ និងសូរ អ៊ា់ ដោយមានឬគ្មានព្យញ្ជនៈ រ

ឃ. សញ្ញាវណ្ណយុត្តិៈ     លេខទោ

☐ បង្កើតព្យាង្គដែលមានសូរខ្លី ហើយរហ័ស

☐ ដាក់ជាប់នឹងពាក្យមួយដើម្បីឱ្យពាក្យនោះអានផ្ទួនជាប់គ្នា

☐ កត់សូរ អា់ និងសូរ អ៊ា់ ដោយមានឬគ្មានព្យញ្ជនៈ រ

ង. សញ្ញាវណ្ណយុត្តិៈ     របាទ

☐ បំបាត់សូរព្យញ្ជនៈប្រកបឬព្យាង្គដែលនៅខាងក្រោម

☐ ដាក់ពីលើព្យញ្ជនៈមួយដើម្បីឱ្យមានសូរញ៉រ រ

☐ បង្កើតព្យាង្គដែលមានសូរខ្លី ហើយរហ័ស

ច. សញ្ញាវណ្ណយុត្តិៈ     លេខទោ

☐ ដាក់ពីលើព្យញ្ជនៈមួយដើម្បីឱ្យមានសូរញ៉រ រ

☐ បំបែរសំឡេងវែងឱ្យខ្លីកំបុត

☐ ដាក់ជាប់នឹងពាក្យមួយដើម្បីឱ្យពាក្យនោះអានផ្ទួនជាប់គ្នា

ឆ. សញ្ញាវណ្ណយុត្តិៈ     រះមុខ

☐ ដាក់ពីលើព្យញ្ជនៈមួយដើម្បីឱ្យមានសូរញ៉រ រ

☐ កត់សូរ អា់ ឬ អ៊ា ប្រកបនឹងព្យញ្ជនៈ ស

☐ បំបែរសូរព្យញ្ជនៈពួក អ៊ ទៅព្យញ្ជនៈពួក អ

ជ. សញ្ញាវណ្ណយុត្តិ៖ យុគលពិន្ទុ

□ កត់សូរខ្លាំង ខ្ពស់ឡើងជាងប្រក្រតី

□ កត់សូរស្រៈ អា ឬ អ៊ា

□ បំបែរសំឡេងវែងឱ្យខ្លីកំបុត

ឈ. សញ្ញាវណ្ណយុត្តិ៖ ធ្មេញកណ្ដុរ

□ បំបាត់សូរព្យញ្ជនៈប្រកបឬព្យាង្គដែលនៅខាងក្រោម

□ ដាក់ជាប់នឹងពាក្យមួយដើម្បីឱ្យពាក្យនោះអានផ្ទួនជាប់គ្នា

□ បំបែរសូរព្យញ្ជនៈពួក អ៊ ទៅព្យញ្ជនៈពួក អ

ញ. សញ្ញាវណ្ណយុត្តិ៖ ត្រីសព្ទ

□ បំបែរសូរព្យញ្ជនៈពួក អ ទៅព្យញ្ជនៈពួក អ៊

□ កត់សូរ អ់ អ៉ំ អា ប្រកបនឹង ម ឬ កត់សូរ អ៉រ ប្រកបនឹងព្យញ្ជនៈ ម

□ ដាក់ពីលើព្យញ្ជនៈមួយដើម្បីឱ្យមានសូរញ័រ រ

ដ. សញ្ញាវណ្ណយុត្តិ៖ ជើងក្អែក

□ កត់សូរខ្លាំង ខ្ពស់ឡើងជាងប្រក្រតី

□ កត់សូរ អ់ អ៉ំ អា ប្រកបនឹង ម ឬ កត់សូរ អ៉រ ប្រកបនឹងព្យញ្ជនៈ ម

□ បំបែរសូរព្យញ្ជនៈពួក អ ទៅព្យញ្ជនៈពួក អ៊

**៣. ចូរអ្នកជ្រើសរើសពាក្យក្នុងអត្ថបទដើម្បីបំពេញតារាងខាងក្រោមឱ្យបានត្រឹមត្រូវ៖**

| |
|---|
| យើងម្នាក់ៗសុទ្ធតែមានសេចក្ដីប្រាថ្នារៀងៗខ្លួន។ ដើម្បីញ៉ាំងឱ្យសេចក្ដីប្រាថ្នារបស់យើងសម្រេចបានជោគជ័យ យើងគប្បីតាំងចិត្តតស៊ូអំណត់ ព្យាយាមរៀនសូត្រធ្វើការងារនិងប្រព្រឹត្តតែអំពើល្អ។ សេចក្ដីប្រាថ្នាមានន័យថាអ្វីៗដែលយើងប៉ងទុក នឹកគួចនៅក្នុងចិត្តជាមុន។ ការរស់នៅប្រកបដោយសេចក្ដីស្រឡាញ់ សាមគ្គីភាព សេចក្ដីថ្លៃថ្នូរ ព្យាយាម និងការពិចារណាប្រកបដោយបញ្ញា ជាមធ្យោបាយធ្វើឱ្យសម្រេចសេចក្ដីប្រាថ្នារបស់យើង។ |

| សញ្ញាវណ្ណយុត្តិ | ពាក្យ |
|---|---|
| បន្តក់ | |
| រះមុខ | |
| យុគលពិន្ទុ | |
| សំយោគ | |
| ត្រីសព្ទ | |
| ធ្មេញកណ្ដុរ | |
| អស្ដា | |
| ទណ្ឌឃាត | |
| ដំលើ | |
| របាទ | |
| លេខទោ | |

**៤. ចូរអ្នករកពាក្យដែលមានសញ្ញាវណ្ណយុត្តិខាងក្រោមឱ្យបានបីៗពាក្យ៖**

ក. ត្រីសព្ទ៖ ____________ ____________ ____________

ខ. ធ្មេញកណ្ដុរ៖____________ ____________ ____________

គ. ទណ្ឌឃាត៖____________ ____________ ____________

ឃ. របាទ៖ ____________ ____________ ____________

ង. សំយោគ៖ ____________ ____________ ____________

**៥. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ៖**

| កេរ្ដិ៍ ព័ត៌មាន រហ័ស អាស្រ័យ វប្បធម៌ នុះន៎ ក្រុមហ៊ុន ព័ទ្ធ កុំព្យូទ័រ ឧស្សាហ៍ |
|---|

ក. ប្រាសាទអង្គរវត្តជាកេរមតិក______ របស់ខ្មែរដែលបុព្វបុរសបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ។

ខ. បឹងទន្លេសាបមានខេត្ត៦ _____ជុំវិញ គឺខេត្តសៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ។

គ. រាជធានីភ្នំពេញជាប់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមទីក្រុង៩៦ អំពី

ការអភិវឌ្ឍឆាប់______ ។

ឃ. ______________ដឹកជញ្ជូននេះមានសេវាល្អលើសគេ។

ង. ជាទូទៅការប្រើប្រាស់__________ តិចឬច្រើនសុទ្ធតែប៉ះពាល់ដល់ភ្នែករបស់យើង។

ច. កសិករ_______________ ធ្វើស្រែចម្ការ។

ឆ. បើបងនៅតែប្រព្រឹត្តយ៉ាងនេះតទៅទៀត ________ឈ្មោះឪពុកយើងនិងធនធានបងច្បាស់ជារលាយពិតប្រាកដ។

ជ. ការប្រើប្រាស់ភាសា ពាក្យពេចន៍ ក៏____________ តាមឋានៈ តួនាទី ឬស្ថានភាពសង្គមផងដែរ។

ឈ.___! ជាសមិទ្ធផលដែលពលរដ្ឋយើងបានកសាងឡើង។

ញ. ថ្ងៃនោះ ខ្ញុំពិតជាទៅចូលរួមជាមិនខាន។ អរគុណសម្រាប់_______ នេះ។

**៦. ចូរអ្នកជ្រើសរើសចម្លើយដែលត្រឹមត្រូវ៖**

| | | | |
|---|---|---|---|
| ក. សញ្ញាខណ្ឌ៖ | ☐ … | ☐ [ ] | ☐ ។ |
| ខ. សញ្ញាសួរ៖ | ☐ . | ☐ ? | ☐ > |
| គ. សញ្ញាឧទាន៖ | ☐ ! | ☐ < | ☐ “ ” |
| ឃ. សញ្ញាត្រេះ៖ | ☐ ( ) | ☐ - | ☐ ៕ |
| ង. សញ្ញាពងត្រី៖ | ☐ ៖ | ☐ = | ☐ … |
| ច. សញ្ញាចុចមួយ៖ | ☐ ? | ☐ ។ | ☐ . |
| ឆ. សញ្ញាដំណកឃ្លា៖ | ☐ ! | ☐ ។ល។ | ☐ |
| ជ. សញ្ញាដំពីរ៖ | ☐ ( ) | ☐ ៖ | ☐ “ ” |
| ឈ. សញ្ញាខណ្ឌចប់៖ | ☐ [ ] | ☐ = | ☐ ៕ |
| ញ. សញ្ញាអព្ភន្តរៈ | ☐ “ ” | ☐ ? | ☐ > |
| ដ. សញ្ញាបេយ្យាលៈ | ☐ ។ល។ | ☐ - | ☐ … |
| ឋ. សញ្ញាវង់ក្រចក៖ | ☐ [ ] | ☐ ( ) | ☐ ! |
| ឌ. សញ្ញាឃ្នាប៖ | ☐ ។ | ☐ < | ☐ [ ] |
| ឍ. សញ្ញាស្មើ៖ | ☐ ៖ | ☐ = | ☐ “ ” |
| ណ. សញ្ញាតូចជាង៖ | ☐ < | ☐ . | ☐ … |
| ត. សញ្ញាធំជាង៖ | ☐ - | ☐ ? | ☐ > |

## ៧. ចូរអ្នកផ្គូផ្គង A និង B ឱ្យបានត្រឹមត្រូវ៖

| A | B | ចម្លើយ |
|---|---|---|
| ១. សញ្ញាខណ្ឌ | ក. សម្គាល់ន័យថាស្មើឬមានន័យថា។ | ១. |
| ២. សញ្ញាខណ្ឌចប់ | ខ. ប្រើនៅចុងបញ្ចប់នៃល្បះសំណួរ។ | ២. |
| ៣. សញ្ញាដកឃ្លា | គ. ជំនួសវង់ក្រចកឬកត់ត្រាសូរក្នុងភាសាវិទ្យា។ | ៣. |
| ៤. សញ្ញាបេយ្យាលៈ | ឃ. ប្រើក្នុងករណីមានដំណកឃ្លាច្រើនកន្លែង។ | ៤. |
| ៥. សញ្ញាចំណុចពីរគូស | ង. សម្គាល់ន័យថាទៅជា។ | ៥. |
| ៦. សញ្ញាត្រេ | ច. ប្រើនៅចុងបញ្ចប់ល្បះឧទាន។ | ៦. |
| ៧. សញ្ញាវង់ក្រចក | ឆ. សម្រាប់ចុះលេខក្នុងច្បាប់ឬជំនួសសន្ទានសព្វឬ។ | ៧. |
| ៨. សញ្ញាចុចមួយ | ជ. ដកស្រង់ឬលើកយកសម្ដី, បង្ហាញចំណងជើង, បង្ហាញពាក្យដែលគេចង់ពន្យល់។ | ៨. |
| ៩. សញ្ញាពងត្រី | ឈ. ប្រាប់ព័ត៌មានបន្ថែម, ប្រាប់ថាតាមបាន គឺអាចប្រើឬមិនប្រើ។ | ៩. |
| ១០. សញ្ញាក្បៀស | ញ. សម្គាល់ន័យថាមកពី។ | ១០. |
| ១១. សញ្ញាសួរ | ដ. សម្រាប់ដកឃ្លារវាងពាក្យពីរម៉ាត់ឬកន្សោមពាក្យពីរ។ | ១១. |
| ១២. សញ្ញាឧទាន | ឋ. សម្រាប់បញ្ចប់អត្ថបទ។ | ១២. |
| ១៣. សញ្ញាអព្ភន្តរ | ឌ. បង្ហាញថាមិនត្រឹមត្រូវតាមក្បួនវេយ្យាករណ៍របស់ភាសាណាមួយ។ | ១៣. |
| ១៤. សញ្ញាឃ្នាប | ឍ. សម្រាប់រៀបអ្វីៗដែលគេរាប់, បង្ហាញការឆ្លើយឆ្លងគ្នា, ផ្ដាច់ព្យាង្គ។ | ១៤. |
| ១៥. សញ្ញាទ្រេត | ណ. សម្រាប់ប្រាប់ថាពាក្យសេចក្ដីមិនទាន់ចប់។ | ១៥. |
| ១៦. សញ្ញាស្មើ | ត. ប្រើជាមួយអក្សរកាត់។ | ១៦. |

| | | |
|---|---|---|
| ១៧. សញ្ញាផ្កាយ | ថ. សម្គាល់ន័យថាពាក្យនៅខាងឆ្វេងមានន័យផ្ទុយពីពាក្យនៅខាងស្ដាំ។ | ១៧. |
| ១៨. សញ្ញាទៅជា | ទ. ប្រើដូចសញ្ញាចុចពីររបស់អឺរ៉ុប។ | ១៨. |
| ១៩. សញ្ញាមកពី | ធ. បង្ហាញថាសេចក្ដីរៀបរាប់នៅមានច្រើនទៀត។ | ១៩. |
| ២០. សញ្ញាផ្ទុយពី | ន. សម្រាប់បញ្ជាក់ល្បះប្រកាសឬវគ្គនៃកំណាព្យ។ | ២០. |

**៨. ចូរអ្នកបញ្ជាក់ថាល្បះទាំងនេះប្រើសញ្ញាល្បះ ខុស ឬ ត្រូវ។ បើខុស ចូរកែសម្រួលឱ្យបានត្រឹមត្រូវ។**

□ ខុស □ ត្រូវ ក. យុវជនកម្ពុជាមានភារកិច្ចសំខាន់ណាស់ក្នុងការរួមចំណែកអភិវឌ្ឍជាតិឱ្យរីកចម្រើន។

□ ខុស □ ត្រូវ ខ. កិរិយាសុទ្ធះ (ពោល លូក ស៊ី ឱនខាំស៊ី យក...)។

□ ខុស □ ត្រូវ គ. ទុក (កិ.) ដាក់វត្ថុអ្វីនៅទីណាមួយដើម្បីឱ្យគង់នៅ។

ឱ. ទុកទ្រព្យ។

□ ខុស □ ត្រូវ ឃ. ពាក្យផ្ទុយនឹងពាក្យះ

-មនុស្សធម៌ = អមនុស្សធម៌

-សាធារណៈ = អសាធារណៈ

-សប្បុរស = អសប្បុរស។

□ ខុស □ ត្រូវ ង. តើភ្ញៀវទេសចរមកកាន់ខេត្តសៀមរាបមានអារម្មណ៍ដូចម្ដេច?

□ ខុស □ ត្រូវ ច. ការកម្សាន្តដែលធ្វើឱ្យបង្កើនប្រាជ្ញា គឺការលេងអុក លេងរ៉ែកះ

**៩. ចូរអ្នកពិនិត្យមើលអត្ថបទដកស្រង់ខាងក្រោម តើមានប្រើសញ្ញាល្បះអ្វីខ្លះ?៖**

[...] សុមេធឃើញភរិយារំកិលដំណើរមកក្បែរក៏ទម្លាក់ខ្លួនអង្គុយចុះទាំងពេបមាត់ជិនឆ្អន់។ អមរាដាក់ចានផ្លែឈើមកលើតុមុខស្វាមីដោយសម្លក់សម្លឹងះ

-នេះឬការប្រៀនប្រដៅរបស់បងដែលជាឪពុកនោះ...? បងពន្យូសកូនឱ្យវ៉ៃគ្នា ហើយឈរទះដៃសើចសប្បាយ...! អ្នកឈ្នះ ឧបដើរលេង...! អ្នកចាញ់នាំទៅពេទ្យ...! បើស្លាប់យកទៅធ្វើបុណ្យ...! តើបងសមធ្វើជាឪពុកគេទេ បើអប់រំកូនតាមរយៈសម្ដីបែបនេះ...? បងដូចជាជ្រុកពេកហើយ...! [...]

(ដកស្រង់ចេញពីរឿងផ្លូវមាស និពន្ធដោយ អ៊ុន សុខហ៊ាង ឆ្នាំ២០០៦)

**១០. ចូរអ្នកសរសេរសញ្ញាល្បះដើម្បីបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. សុភីនិយាយ______ ______ការគោរពវិន័យនាំមកនូវសេចក្ដីថ្លៃថ្នូរ___ ____

ខ. តើអ្វីខ្លះជាសញ្ញានៃទឹកជំនន់______

គ. មេឃធ្លាប់ស្រឡះប្រែជាមីរដេរដាសងងឹតពាសពេញឰដ៍វេហា ____វេហាស៍ ______។

ឃ. ចូររកពាក្យសូរដូច _សទិសសូរ____ នឹងពាក្យ____ គ្រា លាន់ កុំ__

ង. ថ្វីដ្បិតតែផ្សារនេះតូចមែន ប៉ុន្តែខ្ញុំឃើញលក់គ្រឿងបរិភោគច្រើនមុខដូចជា ខាងបន្លែមានស្ពៃ សាលាដ ខាត់ណា ត្រកួន ផ្ទី ត្រយូងចេក __ខាងផ្លែឈើមាន ចេក ស្វាយ ដូង ខ្នុរ ឪឡឹក ចំណែកម្ហូបមានត្រី សាច់ជ្រូក មាន់ ទា សាច់គោ__ ______

# អនុវត្តន៍
# មេរៀនទី៣ ពាក្យ

I. **សំណួរ**

១. ដូចម្ដេចហៅថាពាក្យ?

២. អ្វីជាសំណូររបស់ពាក្យ?

៣. ដូចម្ដេចដែលហៅថាសូរអាន? តើសូរអានបែងចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៤. ចូរអ្នកពន្យល់ប្រភេទនីមួយៗនៃសូរអាន។

៥. ដូចម្ដេចដែលហៅថាសំណេររបស់ពាក្យ?

៦. តើពាក្យថា សំណេរ និង អក្ខរាវិរុទ្ធ ខុសគ្នាដូចម្ដេច?

៧. តើមានមូលដ្ឋានអ្វីខ្លះសម្រាប់សម្រេចអក្ខរាវិរុទ្ធនៃពាក្យ?

៨. តើអក្ខរាវិទ្ធខ្មែរមានលក្ខណៈសម្គាល់អ្វីខ្លះ?

៩. តើអក្ខរាវិរុទ្ធពាក្យកម្ចីបាលី-សំស្រ្កឹតមានលក្ខណៈសម្គាល់អ្វីខ្លះ?

១០. ដូចម្ដេចដែលហៅថាន័យរបស់ពាក្យ?

១១. តើន័យរបស់ពាក្យចែកចេញជាប៉ុន្មានដំណាក់កាល? អ្វីខ្លះ? ចូរបញ្ជាក់។

១២. តើន័យរបស់ពាក្យចែកចេញជាប្រភេទអ្វីខ្លះ? ចូរឱ្យនិយមន័យ។

១៣. តាមរយៈទំនាក់ទំនងរបស់ពាក្យ តើអ្នកសិក្សាចែកពាក្យសព្ទជាប្រភេទអ្វីខ្លះ?

១៤. តើការបែងចែកប្រភេទពាក្យសព្ទឈរលើមូលដ្ឋានអ្វីខ្លះ? ផ្អែកលើមូលដ្ឋាននីមួយៗ តើមានប្រភេទពាក្យសព្ទអ្វីខ្លះ?

១៥. មូលហេតុអ្វីខ្លះនាំឱ្យបម្រើបម្រាស់ពាក្យក្នុងភាសាខ្មែរមានជម្រើស?

១៦. តើបម្រើបម្រាស់ពាក្យក្នុងភាសាខ្មែរមានជម្រើសអ្វីខ្លះ?

១៧. តើបម្រើបម្រាស់ពាក្យក្នុងភាសាខ្មែរប្រព្រឹត្តទៅតាមអ្វីខ្លះ? ចូរពន្យល់។

II. **លំហាត់អនុវត្តន៍**

**១. ចូរអ្នកជ្រើសរើសឯកតាដែលជាពាក្យដោយគូសសញ្ញា ✓ក្នុងប្រអប់៖**

| | | | |
|---|---|---|---|
| ក. | ☐ សំបែង | ☐ ស្រែ | ☐ ទូល |
| ខ. | ☐ ក្បាង | ☐ ផ្អែង | ☐ តុ |

គ. ☐ [អង់-] ☐ រូប ☐ កសិ-

ឃ. ☐ ឥន្ទ ☐ វិជ្ជា ☐ កែវ

ង. ☐ -ករ ☐ ករ ☐ ក្រហម

**២. តើក្នុងបណ្ដាពាក្យខាងក្រោមគេអាចអានបានប៉ុន្មានយ៉ាង? ចូរបញ្ជាក់។**

ក. បទដ្ឋាន ខ. ទស្សនៈ គ. បរលោក ឃ. សមធម៌ ង. អង្គរមាស

ច. អគ្គនាយកដ្ឋាន ឆ. បរិវេណ ជ. កម្ពុជា ឈ. ផ្ដិល ញ. លិច

**៣. ចូរអ្នកពិនិត្យមើលសំណេរ API ខាងក្រោម រួចសរសេរពាក្យដោយប្រើអក្សរខ្មែរឱ្យបានត្រឹមត្រូវ៖**

ក. [kɑː] ________________________________

ខ. [sah] ________________________________

គ. [sɔŋ] ________________________________

ឃ. [caɔt] ________________________________

ង. [poː] ________________________________

**៤. តើអក្ខរាវិរុទ្ធខាងក្រោមមួយណាខុសមួយណាត្រូវ? ចូរពន្យល់ពីមូលហេតុដែលនាំឱ្យកើតមានអក្ខរាវិរុទ្ធខុស។**

ក. ☐ ទុរេន ☐ ធូរេន ខ. ☐ ឃាតករ ☐ ឃាតក

គ. ☐ ផ្ញើ ☐ ផ្ញើរ ឃ. ☐ កុហាក ☐ កុហាក់

ង. ☐ រពឹង ☐ អាពឹង

**៥. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់យកទៅបំពេញក្នុងតារាងខាងក្រោម៖**

| |
|---|
| អ្នក ម្ខាង ប៉ុស្ដិ៍ បង្កើត ស៊ីម៉ង់ត៍ ដើរ ឆ្នាំ ម្យ៉ាង ម្សៅ សណ្ដោង ខ្វះ ចម្ការ បណ្ណាល័យ ចៃដី នរោត្តម ជាតិ រាជូបត្ថម្ភ បញ្ចេញ ខ្ញុំ ក្លិង្គ សង្គ្រាជ ស្នាធ៌ ប្ដី |

| មូលដ្ឋានកំណត់អក្ខរាវិរុទ្ធ | ពាក្យ |
|---|---|
| ឫសគល់ពាក្យ | |
| បម្រែបម្រួលសូរ | |

| | |
|---|---|
| ទំនាញសូរ | |
| សម្ព័ន្ធរូបសព្ទ | |
| សម្ព័ន្ធសញ្ញាព្យាង្គ | |

**៦. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់យកទៅបំពេញក្នុងតារាងខាងក្រោម៖**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ផ្តែផ្តាំ | កុំព្យូទ័រ | ភក្ត្រា | គ្រប់គ្រង | ហ្វូម | ក្តោបក្តាប់ | និរន្តរ៍ | កាន់ |
| ចម្លើយ | ស្ត្រី | មើល | ដើម | បច្ចុប្បន្ន | ដេប៉ាតឺម៉ង់ | មុខ | កុងដង់ |
| ទក្សិណ | ភីហ្សា | បុរាណ | ហាតដក | កត្តិក | កុម្ម៉ង់ | ពេទ្យ | កាហ្វេ |

| ប្រភពពាក្យ | ពាក្យ |
|---|---|
| ពាក្យខ្មែរ | |
| ពាក្យបាលី-សំស្ក្រឹត | |
| ពាក្យបារាំង-អង់គ្លេស | |

**៧. ចូរអ្នកពិនិត្យមើលពាក្យខាងក្រោម រួចបញ្ជាក់ថាន័យរបស់ពាក្យអក្សរទ្រេតមួយណាជាន័យដំណាក់ទី១ និងមួយណាជាន័យដំណាក់ទី២៖**

ក. *ជើង*ជ្រូក, *ជើង*ភ្នំ, *ជើង*ល្អ

ខ. *ផ្កា*ម្លិះ, *ផ្កា*ភ្លើង, *ផ្កា*មាស

គ. ផាត់*មុខ*, *មុខ*ម្ហូប, បាត់*មុខ*, បាក់*មុខ*

ឃ. ក្មេង*ស្រី*, *ស្រី*ក្មុង, មាន*ស្រី*

**៨. ចូរអ្នករកពាក្យន័យដូចនឹងពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. ផ្ទះ = ____________________

ខ. មើល = ____________________

គ. ល្អ = ____________________

ឃ. ខ្ញុំ = ____________________

ង. ប្រញាប់ = ____________________

**៩. ចូរអ្នករកពាក្យន័យផ្ទុយនឹងពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. តូច ≠ ____________ ខ. លក់ ≠ ____________

គ. ម្ដាយ ≠ ____________. ឃ. កុមារា ≠ ____________

ង. ប្រែ ≠ ____________ ច. លឿន ≠ ____________

**១០. តើពាក្យដែលជាអក្សរទ្រេតខាងក្រោមមានន័យដូចម្ដេច?**

ក. *កប់*កំណប់, តម្លៃថ្លៃ*កប់*

ខ. *ដង*សន្ទូច, *ដង*ទឹក

គ. ស្វាយ*ខ្ចី*, *ខ្ចី*លុយ

ឃ. សាលា*ឃុំ*, *ឃុំ*ខ្លួន

ង. *ប៉ាន់*ប្រមាណ, ត្រូវ*ប៉ាន់*

**១១. ចូរអ្នកពិនិត្យមើលល្បះខាងក្រោម រួចជ្រើសរើសចម្លើយដែលត្រឹមត្រូវ៖**

□ ន័យត្រង់ □ ន័យធៀប ក. ខ្ញុំចង់លក់ដីមួយកន្លែងនៅជិត*ភ្នំ*គូលែន។

□ ន័យត្រង់ □ ន័យធៀប ខ. ធីតាធ្វើសាច់គោឡើង*ភ្នំ*។

□ ន័យត្រង់ □ ន័យធៀប គ. គាត់ជាមនុស្សចិត្ត*ខ្មៅ*។

□ ន័យត្រង់ □ ន័យធៀប ឃ. នាងចូលចិត្តពាក់អាវ*ខ្មៅ*។

□ ន័យត្រង់ □ ន័យធៀប ង. ស្រី*ក្ងោក* មាសហ៊ានក្បត់ប្ដី។

□ ន័យត្រង់ □ ន័យធៀប ច. ព្រានចាប់បាន*ក្ងោក* មួយក្បាល។

□ ន័យត្រង់ □ ន័យធៀប ឆ. Man Utd *សំពង* Chelsea ទក់សាច់ ៤-០។

□ ន័យត្រង់ □ ន័យធៀប ជ. ក្រុមសង្គមងងឹតវាយ*សំពង* ក្រុមបាតុករ។

□ ន័យត្រង់ □ ន័យធៀប ឈ. ចិនមិនឈរ*ឱបដៃ* បើសិនអាមេរិកបង្កើតសង្គ្រាម។

□ ន័យត្រង់ □ ន័យធៀប ញ. *ឱបដៃ* ឈរមើលហើយ ដើរចេញយ៉ាងរំភើយ។

**១២. ចូរអ្នកស្រង់ពាក្យពីក្នុងប្រអប់យកទៅបំពេញក្នុងតារាងឱ្យបានត្រឹមត្រូវ៖**

ស្រេ សំណោរ ម៉ាស្សា សំណូរ របប ត្រី របក មេធាវី អំណាន កម្រតេង ឆាត វ្រះ បាយ សាសង ដេក ផឹក ដើរ កុំព្យូទ័រ ផ្សារ មន្ត្រី មេដ្យាទ័រ អាជ្ញាធរ ទំរិង ទ្រឹស្តី ស៊ី និយាយ សោ គោរពជូន កំប៉េះ ពឹត អនុគ្រោះ មិត លួត ហត្ថលេខា ត្រីចក្រយាន ច្កេ ចតុកោណកែង ទស្សនា បុរេប្រវត្តិ ត្មុរ ភាពយន្ត គឹមឈី សុទិដ្ឋិនិយម កម្មវត្ថុ គេហដ្ឋាន អុកស៊ីតកម្ម រូបារម្មណ៍ យោង កែវចរណៃ ស្នេហា មេត្រី នេត្រា សាប៊ូ មីក្រូហិរញ្ញវត្ថុ ថ្លើមថ្លៃ

| ប្រភេទពាក្យសព្ទ | ពាក្យ |
|---|---|
| ពាក្យថ្មី | |
| ពាក្យបុរាណ | |
| ពាក្យសកម្ម | |
| ពាក្យអកម្ម | |
| ពាក្យប្រជាជន | |
| ពាក្យតំបន់ | |
| ពាក្យវប្បធម៌ | |
| ពាក្យបច្ចេកទេស | |
| ពាក្យក្នុងលិខិតផ្លូវការ | |

| | |
|---|---|
| ពាក្យក្នុងកំណាព្យ-ចម្រៀង | |
| ពាក្យកម្ចី | |

**១៣. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញឈ្មោះខាងក្រោម៖**

| |
|---|
| អញ្ជើញ  បុប្ផា  ទៅ  ញ៉ាំ  ម៉ែ  ហៅ  ពិសា  ហៅ  ផ្កា  ស៊ី  ម៉ាក់ៗ |

ក. ...សុំស្គាល់ផងសម្រស់__________ កំពង់ធំ។

ខ. តើ________ អ័រគីដេនៅកម្ពុជាមានប៉ុន្មានប្រភេទ?

គ. សម្តេចក្រឡាហោម ស ខេង ___________ចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំ។

ឃ. ចិនបញ្ជូនទ័ព___________ ព្រំដែនហុងកុង។

ង. __________ភ្លាមបានភ្លាម! _______ម៉ូតូកង់បីនិងតាក់ស៊ី...

ច. ត្រីឆ្តោរជាត្រីទឹកសាបប្រភេទមំសាសី ពោលគឺ________ សាច់ជាអាហារ។

ឆ. បង្កើនថាមពលតាមរយៈការ____________ អាហារសម្រន់...

ជ. អាហារថ្ងៃត្រង់យ៉ាងឆ្ងាញ់________ ...

ឈ. សេចក្តីស្រឡាញ់របស់_________ ជាសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ។

ញ. ______ត្រូវដឹង បើគភ៌ស្លិតក្នុងករណីទាំងនេះ ពេទ្យមិនឱ្យទុកទៀតទេ។

**១៤. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញចន្លោះខាងក្រោម៖**

ក. (ហត្ថលេខា, ស៊ីញ៉េ) របស់នាយកសាលាត្រូវចុះពីឆ្វេងទៅស្តាំ។

ខ. ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ (មន្ត្រី, នាម៉ឺន) ក្នុងមណ្ឌលប្រឡង។

គ. ផ្តល់ជូនពិសេសក្នុងឱកាសបវេសនកាលឆ្នាំ (រៀន, សិក្សា) ថ្មី។

ឃ. ត្រូវការអ្នកវាយអត្ថបទលើ (គេហទំព័រ, វេបសាយ)។

ង. អ្នកណាខ្លះធ្លាប់ប្រៀបធៀបមនុស្សស្រីទៅនឹង (ផ្កា, បុប្ផា) ?

ច. អាមេរិកលក់យន្តហោះ (ចម្បាំង, សង្គ្រាម) ទៅឱ្យតៃវ៉ាន់។

**១៥. ចូរអ្នកបង្ហាញពីបម្រើបម្រាស់ពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. ផ្លូវ វិថី　　ខ. វត្ថុបុរាណ បុរាណវត្ថុ　　គ. រៀន សិក្សា

ឃ. ដំណឹង ព័ត៌មាន　　ង. ភ្លើង អគ្គិសនី

# អនុវត្តន៍
## មេរៀនទី៤ ការបែងចែកថ្នាក់ពាក្យ

I. **សំណួរ**

១. ដូចម្ដេចហៅថាថ្នាក់ពាក្យ?

២. តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះក្នុងការបែងចែកថ្នាក់ពាក្យ?

៣. ចូរអ្នករៀបរាប់ដោយសង្ខេបអំពីប្រវត្តិនៃការបែងចែកថ្នាក់ពាក្យ។

៤. តើនៅក្នុងភាសាខ្មែរបែងចែកថ្នាក់ពាក្យជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

II. **លំហាត់អនុវត្តន៍**

**១. ចូរអ្នកអានអត្ថបទ រួចសរសេរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវះ**

ក. ពាក្យស្ដែងពីមនុស្ស សត្វ រុក្ខជាតិ ទីកន្លែង ស្ថានភាព សកម្មភាព... គេហៅថា ____________________។

ខ. ពាក្យប្រើសម្រាប់ស្ដែងពីអ្នកនិយាយនិងអ្នកដែលគេនិយាយទៅរកឬសម្រាប់ជំនួសកន្សោមនាមដែលគេនិយាយរួចហើយ គេហៅថា____________________ ______។

គ. ពាក្យសម្រាប់ប្រើជាពាក្យរណបឱ្យនាម គេហៅថា ______________។

ឃ. ពាក្យសម្ដែងអំពើឬប្រាប់សភាពរបស់មនុស្ស សត្វ រុក្ខជាតិ វត្ថុអ្វីមួយ គេហៅថា________________។

ង. ពាក្យដែលប្រើសម្រាប់សម្ដែងលក្ខណៈឱ្យកិរិយាសព្ទ គុណនាម និងគុណកិរិយាដូចគ្នា គេហៅថា_______________។

ច. ពាក្យប្រើជាមួយនាម កន្សោមនាម កិរិយា កន្សោមកិរិយាដើម្បីបង្កើតកន្សោមមានធ្នាក់ គេហៅថា________________។

ឆ. ពាក្យដែលគេប្រើសម្រាប់ភ្ជាប់ពាក្យទៅនឹងពាក្យ កន្សោមពាក្យទៅនឹងកន្សោមពាក្យ ឬល្បះទៅនឹងល្បះ គេហៅថា _______________។

ជ. ពាក្យឬកន្សោមពាក្យដែលគេប្រើភ្ជាប់ជាមួយកន្សោមពាក្យឬល្បះសម្រាប់សម្តែងការភ្ញាក់ផ្អើល ត្រេកអរ តក់ស្លុត ងឿងឆ្ងល់ កោតសរសើរ ខឹង បញ្ចេញកំហឹង... គេហៅថា_______________។

**២. ចូរអ្នកបញ្ជាក់ថា តើបណ្តាក្រុមពាក្យខាងក្រោមមានថ្នាក់ពាក្យជាអ្វី?**

ក. លើ ក្រោម ក្នុង ក្រៅ ចន្លោះ ក្បែរ សម្រាប់ ដើម្បី ____________

ខ. យី! ព្រះ! អើយ! នុះ! វើយ! ពុទ្ធោ! រំបល់យក៍! ចុម! ____________

គ. លេង មើល រត់ ជួញ លាង ស្រោច ដើរ ____________

ឃ. គាត់ វា គេ នាង អ្នក អញ អាត្មា លោក ____________

ង. កាច ធូរ ច្រពើស ថ្លៃ រដិបរដុប ប្លែក ជ្រៅ សាញ ____________

ច. ព្រោះ លុះត្រាតែ ថ្វីបើ កាលណា ល្គឹកណា បើ ____________

ឆ. ផ្កា ថ្ម ទឹក ខ្យល់ ចូ ម៉ូតូ សៀវភៅ សាលា ____________

ជ. ច្រវាត់ ជ្រុល ពពាក់ពពើម រេល ប៉ផ្លោត ____________

**៣. ចូរកំណត់ថ្នាក់ពាក្យដែលជាអក្សរទ្រេតក្នុងល្បះខាងក្រោមដោយភ្ជាប់ហេតុផល៖**

ក. ស៊ីក្លូជាមធ្យោបាយដឹកជញ្ជូនដ៏*ពេញនិយម* មួយក្នុងប្រទេសកម្ពុជា។

ខ. លោកតាមានស្រុកកំណើត*មកពី* ខេត្តតាកែវ។

គ. របរនេះជួបផលលំបាកច្រើនណាស់ត្រូវ*ចំណាយ* កម្លាំងធាក់បែកញើសជោកទាំងកណ្តាលថ្ងៃ។

ឃ. បច្ចុប្បន្ន មានអ្នករត់ស៊ីក្លូមិនច្រើនប៉ុន្មានឡើយប្រកបរបរនេះ *ហើយ* ភាគច្រើនជាមនុស្សចាស់កម្លាំងខ្សោយ។

ង. សម្តេចព្រះបរមនាថ នរោត្តម សីហមុនី *ទ្រង់* ឡើងគ្រងរាជសម្បត្តិនៅថ្ងៃសុក្រទី២៩ ខែតុលា ឆ្នាំ២០០៤។

ច. ខ្មែរក្រហម*ដែល* កំពុងកាន់អំណាចបាន*ប្រឆាំង* នឹងរាជានិយម។

**៤. ចូរអ្នកអានអត្ថបទ រួចជ្រើសរើសពាក្យស្ថិតក្នុងថ្នាក់ពាក្យនីមួយៗឱ្យបានពីរ៖**

**នាងចែមនិងនាងចាន់៖** ព្រះម៉ែម្ចាស់!... ព្រះម៉ែម្ចាស់!...

**ព្រះម៉ែយសូរច័ន្ទវតី៖** នែ៎! មានការអីនាងសាវឡឹកបានដូចជាអន្ទះអន្ទែងខ្លាំងម្ល៉េះ?

**នាងចែម៖** មិនឱ្យអន្ទះអន្ទែងយ៉ាងម៉េចព្រះម៉ែម្ចាស់! បើព្រះអង្គម្ចាស់តូយាងមក

វិញហើយនេះ! ហើយខ្ញុំម្ចាស់បានទៅលបស្ដាប់នៅឯព្រះរាជដំណាក់ធំ ដឹងថា ព្រះអង្គនឹងលាចាកសិក្ខាបទនៅថ្ងៃ១៥កើតខាងមុខនេះ ព្រះអង្គលែងបួសទៀតហើយ។

**ព្រះម៉ែយួរច័ន្ទវតី៖** ចុះក្រែងថាព្រះអង្គបួសលែងសឹកហើយនោះ ម៉េចក៏ពេលនេះព្រះអង្គបែរជាសឹកទៅវិញ ក្រែងមិនពិតទេដឹង?

**នាងចាន់៖** រឿងនេះពិតហើយព្រះម៉ែម្ចាស់ សម្ដេចព្រះឧភយោរាជក៏បានចូលរួមជំនុំពេលនោះដែរ គឺព្រះអង្គម្ចាស់តូពិតជាសុំលាចាកព្រះផ្នួសមែន!... ព្រះម៉ែម្ចាស់អើយ ខ្ញុំបានលបមើលតាមវាំងននឃើញព្រះភិក្ខុតូពិតមែនតែជាអ្នកបួស កោរសក់កោរចិញ្ចើម តែមានព្រះរូបឆោមលោមពណ៌ស្រស់សង្ហារណាស់!... ហើយមានបន្ទូលមួយម៉ាត់ៗ ក៏ពីរោះត្រជាក់ចិត្តទៀតផង!... នេះលោកនៅជាសង្ឃ ស្រស់ប៉ុណ្ណឹងទៅហើយ ចុះទម្រាំដល់លោកសឹកមែនទែន ស្លៀកពាក់មកជាគ្រហស្ថ តើស្រស់សង្ហារប៉ុណ្ណាទៀត?

**ព្រះម៉ែយួរច័ន្ទវតី៖** ចុះពួកឯងមានឮព្រះស្វាមីនិងព្រះអង្គម្ចាស់តូជជែកគ្នាពីរឿងយើងទេ?

**នាងថែម៖** ដូចជាមាននិយាយខ្លះដែរ តែព្រះអង្គម្ចាស់តូគ្រាន់តែថ្លែងឱ្យដឹងថា ព្រះម៉ែម្ចាស់និងព្រះអង្គ ប្រហែលពុំមែនគូព្រេងនឹងគ្នាទេ បានជាព្រះម៉ែម្ចាស់មិនអាចរង់ចាំព្រះអង្គបាន!...

**នាងចាន់៖** ហើយព្រះអង្គតូបានជូនពរឱ្យព្រះម៉ែម្ចាស់និងព្រះឧភយោរាជបានសុខសាន្តជាមួយគ្នាទៀតផង!...

**ព្រះម៉ែយួរច័ន្ទវតី៖** យើងចង់ជួបព្រះអង្គដោយផ្ទាល់ដើម្បីថ្វាយដំណឹងដល់ព្រះអង្គពីរបីម៉ាត់ឱ្យអស់ចិត្ត តែមិនដឹងធ្វើយ៉ាងណានឹងបានជួប?

**នាងថែម៖** ត្រង់ជួបបានយ៉ាងណានោះ ខ្ញុំម្ចាស់មិនដឹងទេ តែបើព្រះម៉ែចង់ឃើញមិនពិបាកឡើយ ព្រោះថ្ងៃ១៥កើត ព្រះអង្គតូនឹងយាងទៅធ្វើពិធីលាងព្រះផ្នួសនៅវត្តសឹង នោះព្រះម៉ែម្ចាស់ពិតជាបានឃើញដោយជាក់ស្បាន់ជាមិនខាន បើព្រះម៉ែម្ចាស់បានយាងទៅក្នុងពេលនោះដែរ។

ក. នាម៖ ________ ______ ខ. គុណនាម៖ ______ ______

គ. កិរិយា៖ ________ ______ ឃ. គុណកិរិយា៖ ____ ______

ង. សព្វនាមៈ ________ ______ ច. ផ្នាក់ៈ ____________ ______

ឆ. ឈ្នាប់ៈ __________ ______ ជ. ឧទានសព្ទៈ ______ ______

# អនុវត្តន៍
## មេរៀនទី៥ នាម

I. **សំណួរ**

១. ដូចម្ដេចដែលហៅថានាម?

២. តើនាមចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. តើនាមករណ៍មានធាតុអ្វីសម្គាល់ខ្លះ? ចុះនាមការក៏វិញ?

៤. តើនាមមានមុខងារជាអ្វីខ្លះ? ចូររកឧទាហរណ៍បញ្ជាក់។?

៥. តើនាមដែលមានមុខងារជាគុណនាមនិងឧបបទខុសគ្នាដូចម្ដេច? ចូរពន្យល់។

II. **លំហាត់អនុវត្តន៍**

**១. ចូរអ្នកគូសបន្ទាត់ពីក្រោមពាក្យដែលសម្គាល់នាមសាធារណ៍ក្នុងល្បះខាងក្រោម៖**

ក. កសិករទៅស្រែនៅក្បែរផ្ទះរបស់គាត់។

ខ. ពូសំកំពុងជីកស្មៅក្នុងសួនច្បារ។

គ. គោស៊ីស្លឹកចេកជិតសាលារៀន។

ឃ. សំយកប៊ិកក្រហម បន្ទាត់ ដែកឈាន ជ័រលុប ដាក់ក្នុងកាតាប។

ង. កម្មករនេះចូលចិត្តហូបបាយជាមួយឪឡឹកនិងត្រីងៀត។

ច. មន្ទីរពេទ្យនេះកសាងឡើងតាំងពីសម័យសង្គមរាស្ត្រនិយម។

ឆ. គ្រឿងសង្ហារិមមានដូចជា តុ ទូ កៅអី គ្រែ ជាដើម។

ជ. ឆ្កែនេះមានត្រចៀកវែង ភ្នែកធំ ចង្កូមស្រួច ជើង៤ និងកន្ទុយខ្លី។

ឈ. ស្វាយនេះមានផ្កានិងផ្លែច្រើនណាស់។

ញ. ទន្លេនេះមានត្រី ក្រពើ ខ្ជៅ ខ្យង លៀស និងកំប្លោកច្រើន។

**២. ចូរអ្នកគូសបន្ទាត់ពីក្រោមពាក្យដែលសម្គាល់នាមអសាធារណ៍ក្នុងល្បះខាងក្រោម៖**

ក. បុប្ផាតែងតែទៅលេងខេត្តកំពតជាមួយធារី។

ខ. ភ្នំពេញជាទីក្រុងដែលមានសាកលវិទ្យាល័យនិងភោជនីយដ្ឋានច្រើន។

គ. ប្រទេសកម្ពុជាមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម ថៃ និងឡាវ។

ឃ. សុជាតានឹងធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិកនិងបារាំង។

ង. សួនសត្វភ្នំតាម៉ៅមានសត្វជាច្រើនដូចជា ខ្លា គោ ពស់ថ្លាន់ ក្រពើ ដំរី...។

ច. តាជាដឹកអាត្មោតនិងមីចម៉្បាទៅលាងទឹកនៅមាត់ទន្លេសាប។

ឆ. អាពពាលអត់ស៊ីស្មៅពីរថ្ងៃហើយ។

ជ. ខេត្តរតនគីរីមានជនជាតិព្នងរស់នៅច្រើនជាងគេ។

ឈ. កូនប្រុសមីងសាននិងពូសនចូលរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ញ. ឆ្នេរសមុទ្រកំពង់សោមមានទេសភាពស្អាត។

**៣. ចូរស្រង់ពាក្យក្នុងប្រអប់ដាក់តាមប្រភេទនាមសាធារណ៍នីមួយៗ៖**

កូន មូស ព្រីង សំបុត្រ គយ សំពៅ ស្ទឹង ជ្រោះ ពាណិជ្ជករ សណ្ឋាគារ ចៅក្រម ទាហាន ក្រវ៉ាត់ក ធុងទឹក បបែល កញ្ជ្រោង ទន្សាយ ប្រពន្ធ ប្រឡាយ គុក ក្រសួង ឈ្លូស ជាងភ្លើង កន្ទុំរុយ ប្រលានយន្តហោះ រនាស់ដៃ ពីងពាង វេជ្ជបណ្ឌិត ក្រមា

| មនុស្ស | សត្វ | ទីកន្លែង | វត្ថុ |
|---|---|---|---|
| | | | |

**៤. ចូរអ្នកតែងល្បះដោយប្រើពាក្យសម្រាប់សម្គាល់នាមសាធារណ៍និងនាមអសាធារណ៍៖**

ក. ____________________

ខ. ____________________

គ. ____________________

ឃ. ____________________

ង. ____________________

ច. ____________________

ឆ. ________________________________________

ជ. ________________________________________

## ៥. ចូរបង្កើតនាមករណ៍ជាមួយពាក្យទាំងនេះ៖

| ពាក្យ | នាមករណ៍ | ពាក្យ | នាមករណ៍ |
|---|---|---|---|
| ចាំ | | ដេក | |
| សិក្សា | | តក់ | |
| តែង | | សរសេរ | |
| និយាយ | | ចូល | |
| ចាយ | | គូរ | |
| ចង់ | | ស្រែក | |
| រាស់ | | រក | |
| ច្រៀង | | ទាក់ទង | |
| សង | | ដាំ | |
| ជាន់ | | ឃើញ | |

## ៦. ចូរបង្កើតនាមការក៍ជាមួយពាក្យទាំងនេះ៖

| ពាក្យ | នាមការក៍ | ពាក្យ | នាមការក៍ |
|---|---|---|---|
| សើច | | ខ្លាំង | |
| ចម្លង | | ប្រាជ្ញ | |
| ឆ្លៀត | | ស្អាត | |
| ជឹក | | ខិលខូច | |
| ល្ងូន | | ទស្សនៈ | |
| មាន | | ខ្ពស់ | |
| បាញ់ | | ក្រ | |
| លេង | | ជំងឺ | |
| ខ្លៅ | | កប៉ាល់ | |
| ល្ងង់ | | បច្ចេកទេស | |

**៧. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញតារាងខាងក្រោមឱ្យបានត្រឹមត្រូវ៖**

| ចំណូលចិត្ត សេះ គំនិត ដើមឈើ មួក ទូរសព្ទ របាំ កៅអី ម្ដាយ វត្ត ចំណេះដឹង ស្លាបព្រា តា ឆ័ត្រ ប្រពៃណី ខ្លាឃ្មុំ ដបទឹក កែវ ពូ បាយ |
|---|

| ប្រភេទនាម | ពាក្យ |
|---|---|
| នាមជីវចល | |
| នាមអជីវចល | |
| នាមរូបី | |
| នាមអរូបី | |

**៨. ចូរអ្នកកំណត់មុខងារនាមដែលមានអក្សរទ្រេតនៅក្នុងល្បះខាងក្រោម៖**

ក. *បុព្វបុរសខ្មែរ* បានបន្សល់ទុកកេរដំណែលដ៏ច្រើនសន្ធឹកសន្ធាប់។

ខ. អ្នកគ្រូបង្រៀន*ភាសាខ្មែរ*។

គ. ព្រះនាងអាក់អ *បុត្រីស្ដេច* មានចិត្តប្រតិព័ទ្ធទៅលើបុរសទុគ៌តម្នាក់។

ឃ. គេប្រសិទ្ធនាមលោក វណ្ណ មូលីវណ្ណ *បិតាស្ថាបត្យករខ្មែរ*។

ង. គង់ហ៊ានបានក្លាយជា *មេទ័ព* ដោយសារប្រពន្ធទាំងពីរ។

ច. យុវជន*កម្ពុជា* មានភារកិច្ចសំខាន់ណាស់ក្នុងការរួមចំណែកអភិវឌ្ឍជាតិ។

**៩. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើប្រាស់នាមឱ្យបានត្រឹមត្រូវ៖**

# អនុវត្តន៍
# មេរៀនទី៦ សព្វនាម

**I. សំណួរ**

១. ដូចម្ដេចដែលហៅថាសព្វនាម?

២. តើសព្វនាមចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររកឧទាហរណ៍បញ្ជាក់។

៣. តើគុណនាមចង្អុលនិងសព្វនាមចង្អុលខុសគ្នាដូចម្ដេចខ្លះ? ចូរបញ្ជាក់។

៤. តើសព្វនាមមានមុខងារជាអ្វីខ្លះក្នុងល្បះ? ចូររកឧទាហរណ៍បញ្ជាក់។

**II. លំហាត់អនុវត្តន៍**

**១. ចូរអ្នកស្រង់ពាក្យនៅក្នុងប្រអប់ដាក់តាមប្រភេទសព្វនាមនីមួយៗ៖**

គាត់ លោក យើង គេ នេះ នោះ ទាំងនេះ ទាំងនោះ នរណា អ្វីខ្លះ នរណាម្នាក់ ខ្លះ ម្នាក់ៗ ទាំងអស់ ទាំងឡាយ វា អ្នក អាត្មា ដែល ពួកគេ ខ្ញុំ ស្អីខ្លះ អានេះ អានោះ អាត្មា លោកស្រី គេ អី អ្វី នរណាមួយ អ្វីខ្លះ អញ ព្រះអង្គ នីមួយៗ មីនោះ មីនេះ

| សព្វ.បុរិសៈ | សព្វ.ចង្អុល | សព្វ.សំណួរ | សព្វ.មិនច្បាស់ |
|---|---|---|---|
| | | | |

**២. ចូរអ្នកជ្រើសរើសសព្វនាមខាងក្រោមដើម្បីបំពេញល្បះឱ្យបានត្រឹមត្រូវ៖**

| | | | | |
|---|---|---|---|---|
| ពួកយើង | ទាំងអស់នេះ | ពួកគេ | ព្រះអង្គ | នរណាខ្លះ |

ក. ដារីនិងពួកម៉ាកនាងទៅផ្សារជាមួយគ្នា។ ________ទិញអីវ៉ាន់ច្រើនណាស់។

ខ. ________________នឹងទៅដើរលេងនៅមាត់ទន្លេ។

គ. តើ________ រៀនជាមួយប្អូណា?

ឃ. _________ជាប្រលោមលោកល្បីឈ្មោះ។

ង. ព្រះបាទជ័យវរ្ម័នទី៧ ជាស្ថាបនិកក្រុងអង្គរធំ។ ____ជាមហាវីរក្សត្រខ្មែរ។

**៣. ចូរបំពេញសព្វនាមបុរិសៈក្នុងល្បះខាងក្រោមនេះ៖**

ក. សត្វខ្លាចូលចិត្តស៊ីសាច់ឆៅ។ ___________មិនស៊ីស្មៅទេ។

ខ. ពូសុកទៅដើរលេងតាមមាត់ទន្លេ។ _______ចូលចិត្តទេសភាពនៅទីនោះណាស់។

គ. កុមារនេះចេះនិយាយច្រើន។ ___________ជាក្មេងឆ្លាត។

ឃ. ដារីនិងពួកម៉ាកនាងទៅផ្សារជាមួយគ្នា។ ________ទិញអីវ៉ាន់ច្រើន។

ង. និស្សិតទាំងអស់ខិតខំរៀនសូត្រណាស់។ ________ប្រឡងជាប់ទាំងអស់គ្នា។

**៤. ចូរអ្នកតែងល្បះដោយប្រើជាមួយសព្វនាមនីមួយៗឱ្យបានយ៉ាងតិច៥ល្បះ៖**

ក. ____________________________________________________________

ខ. ____________________________________________________________

គ. ____________________________________________________________

ឃ. ______________________________________________________

ង. ____________________________________________________________

**៥. ចូរអ្នកដកស្រង់សព្វនាមចេញពីក្នុងអត្ថបទខាងក្រោមឱ្យបានត្រឹមត្រូវ៖**

[...]

**ហ្លួង៖** ក្មួយឯងមែនទេឬអីឈ្មោះថៅចិត្រដែលពេទ្យស្អាតបានបញ្ជូនខ្លួនមកឱ្យខ្ញុំ?

**ចិត្រ៖** ទានប្រោស! ខ្ញុំបាទនេះហើយ។

**ហ្លួង៖** ចុះក្មួយធ្វើការយ៉ាងនេះបានដែរឬទេ? ការរបស់ខ្ញុំនេះវាធ្ងន់ណាស់

តោងទ្រាំជីកដីក្នុង១ថ្ងៃ ៥-៦ម៉ោង ទើបស្មុះរួច រូបរាងស្អាតបាតដូចជាក្លួយនេះ ខ្ញុំយល់ថាទ្រាំទ្រការងារមិនបានយូរប៉ុន្មានទេ មុខជារត់ទៅផ្ទះវិញហើយ។

**ចិត្រ៖** "មនុស្សដទៃទៀត គេទ្រាំធ្វើបានយ៉ាងណា ឯខ្ញុំបាទគង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណ កុំព្រួយឱ្យសោះ!" ចៅចិត្រពោលរ៉ាប់រងយ៉ាងម៉ឺងម៉ាត់។ [...] (ដកស្រង់ចេញពីរឿងកុលាបប៉ៃលិន)

**៦. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើសព្វនាមឱ្យបានត្រឹមត្រូវ៖**

# អនុវត្តន៍
## មេរៀនទី៧ គុណនាម

I. **សំណួរ**

១. ដូចម្ដេចដែលហៅថាគុណនាម?

២. តើគុណនាមចែកជាប៉ុន្មានប្រភេទ? ប្រភេទនីមួយៗចែកជាប៉ុន្មានទៀត?

៣. ដូចម្ដេចដែលហៅថាគុណនាមប្រក្រតី? គុណនាមកំណត់?

៤. តើសព្វនាមនិងគុណនាមកម្មសិទ្ធិខុសគ្នាដូចម្ដេចខ្លះ? ចូរបញ្ជាក់។

៥. បើគិតលើទម្រង់ តើគុណនាមចែកជាអ្វីខ្លះ? ចូររកឧទាហរណ៍បញ្ជាក់។

៦. តើកម្រិតគុណនាមមានប៉ុន្មាន? អ្វីខ្លះ? ចូរបញ្ជាក់។

៧. ចូរពន្យល់ពីលំដាប់គុណនាមក្នុងកន្សោមនាម។

៨. ចូរសិក្សាពីសម្ព័ន្ធគុណនាមនៅក្នុងល្បះ។

II. **លំហាត់អនុវត្តន៍**

**១. ចូរគូសបន្ទាត់នៅពីខាងក្រោមពាក្យដែលជាគុណនាមក្នុងល្បះខាងក្រោម៖**

ក. នេះជាតុធំ ហើយនោះជាកៅអីល្អ។

ខ. សិទ្ធីវន្តជាកុមារឆ្លាត រីឯសុជាតាជាក្មេងឧស្សាហ៍។

គ. គាត់ឃើញគោស ក្របីខ្មៅ សេះពពាល និងលាតូចមួយ។

ឃ. សត្វខ្លានោះកំពុងស៊ីសាច់ឆៅ។

ង. នាងជាមនុស្សធូរធារ។

ច. សួនបន្លែនេះមានដំណាំច្រើន។

ឆ. នាងចង់ទិញផ្ទះដ៏ធំមួយ។

ជ. សៀវភៅនេះក្រាស់ជាងសៀវភៅនោះ។

ឈ. ផ្ទះគាត់ស្ថិតនៅក្បែរសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ញ. ប្អូនស្រីខ្ញុំរៀនថ្នាក់ទីប្រាំបួន។

ដ. មនុស្សម្នាក់ៗតែងតែគិតពីការរស់នៅរបស់ខ្លួន។

ឋ. តើអ្នកចង់ពិសាម្ហូបអ្វី?

## ២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ដាក់តាមប្រភេទគុណនាមនីមួយៗ៖

នេះ ស្រស់ នោះ បៃតង បួន កំសាក ខ្ពស់ ផ្ទះគាត់ ទាំងនេះ ទីដប់ ណាមួយ ចាស់ ប្រាំ ទាំងនោះ ស្រែខ្ញុំ ស្អី ទុំ អ្វី ទាំងអស់នេះ នរណា ម្នាក់ៗ ទាំងអស់ ខ្លះ ទន់ រឹងខ្សោយ ស្តើង ផ្សេងៗ ណាខ្លះ ទាំងអស់នោះ ទាំងមូល ស្គម សាមសិប

| គុ.ប្រក្រតី | គុ.ចំនួន | គុ.ចង្អុល | គុ.មិនច្បាស់ |
|---|---|---|---|
| | | | |

## ៣. ចូរតែងល្បះដោយប្រើតាមទម្រង់ខាងក្រោម៖

ក. ក.ន. ទម្រង់៖ នាម + គុ.ចំ + នាមរនាប់ + គុ.ចង្អុល

________________________________________

ខ. ក.ន.ទម្រង់៖ នាម + គុ.ចំ + រនាប់ + គុ.ចង្អុល

________________________________________

គ. ក.ន.ទម្រង់៖ នាម + គុ.កម្មសិទ្ធិ + គុ.ចំនួន + នាមរនាប់ + គុ.ចង្អុល

________________________________________

ឃ. ក.ន.ទម្រង់៖ នាម + គុ.ប្រក្រតី + គុ.កម្មសិទ្ធិ + គុ.ចំនួន + នាមរនាប់ + គុ.ចង្អុល

________________________________________

ង. ក.ន. ទម្រង់៖ នាម + គុ.ពណ៌ + នាម + គុ.ចំនួន + នាមរនាប់ + គុ.ចង្អុល

________________________________________

ច. ក.ន. ទម្រង់៖ នាម + ដ៏ + គុ.ប្រក្រតី + គុ. ចំនួន +នាមរនាប់ + គុ.ចង្អុល

________________________________________

៤. ចូររកន័យផ្ទុយជាមួយគុណនាមខាងក្រោមនេះ៖

| គុណនាម | ន័យផ្ទុយ | គុណនាម | ន័យផ្ទុយ |
|---|---|---|---|
| ថោក | | ខ្ពស់ | |
| ភ្លឺ | | ខ្លាំង | |
| មាន | | ជ្រៅ | |
| ចាស់ | | ក្រាស់ | |
| យឺត | | ស្រួល | |
| រឹង | | ក្ដៅ | |
| ធម្មតា | | ចង្អៀត | |
| ស្អាត | | ធ្ងន់ | |
| ធាត់ | | ឆៅ | |
| ផ្អែម | | សាប | |
| សាហាវ | | ពូកែ | |

៥. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើប្រាស់គុណនាមឱ្យបានត្រឹមត្រូវ៖

# អនុវត្តន៍
# មេរៀនទី៨ កិរិយាសព្ទ

I. **សំណួរ**

១. ដូចម្តេចដែលហៅថាកិរិយាសព្ទ?

២. តើកិរិយាសព្ទមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. តើគុណនាមអាចមានមុខងារជាកិរិយាសព្ទក្នុងល្បះបានដែរឬទេ? ចូរបញ្ជាក់។

៤. ចូរសិក្សាមុខងារកិរិយាសព្ទក្នុងល្បះ។

II. **លំហាត់អនុវត្តន៍**

**១. ចូរអ្នកគូសបន្ទាត់ពីខាងក្រោមពាក្យដែលជាកិរិយាសព្ទ៖**

ក. ទីយារុធស្តាប់សំឡេងច្រៀងក្នុងរាត្រី។

ខ. រថយន្តឈប់គៀកនឹងជើងភ្នំដ៏មានថ្មធំៗ។

គ. ចៅចិត្រជាកម្មករត្បូង។

ឃ. សិស្សនេះមិនចូលចិត្តវិទ្យាសាស្ត្រទេ។

ង. លោកហ្លួងរតនសម្បត្តិមានសន្តានចិត្តល្អ។

ច. យុននារីស្រឡាញ់ចៅចិត្រ។

ឆ. ធម្មតា អ្នករៀនសូត្រមិនស្ងួរទំនេរដូចយើងទេ។

ជ. កាលពីមុន លោកសន្យាថានឹងនាំខ្ញុំដើរលេង។

ឈ. ធីតាស្លៀកពាក់យ៉ាងសមសួន។

ញ. កុំយំថ្មីអូន បងសូមលាសិនហើយ។

**២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ទៅបំពេញក្នុងល្បះខាងក្រោមឱ្យ៖**

| | | | | | | |
|---|---|---|---|---|---|---|
| លេង | ដេក | ទន្ទេញ | ពន្យល់ | មើល | វាយ | ជួសជុល |
| ដាំ | ចាប់ | កាត់ | នឹក | បើក | អង្គុយ | រង់ចាំ |
| ភ្ជួរ | | | | | | |

ក. វាសនាកំពុង________________ឡានក្រុង។

ខ. ពួកគេចូលចិត្ត_______________បាល់នៅរាល់ពេលល្ងាច។
គ. និស្សិតទាំងអស់ត្រូវតែ_______________មេរៀនឱ្យចាំស្ទាត់។
ឃ. អ្នកគ្រូ_______________លំហាត់ដល់សិស្ស។
ង. លេខាដ៏ស្រស់ស្អាតម្នាក់យកកុំព្យូទ័រទៅ________អត្ថបទឱ្យលោកប្រធាន។
ច. ក្មេងៗចូលចិត្ត_______________តុក្កតានៅក្នុងទូរទស្សន៍។
ឆ. គាត់កំពុង_____________ដំបូលផ្ទះ។
ជ. កូនទន្សាយកំពុង_____________នៅក្នុងទ្រុង។
ឈ. ប៉ូលីស______________ចោរដែលលួចម៉ូតូ។
ញ. យើងទាំងអស់គ្នា_____________ស្រុកកំណើតណាស់។
ដ. ពូសំបាន______________ស្រែនោះរួចហើយ។
ឋ. កសិករម្នាក់កំពុង_____________ដំណាំនៅក្រោយផ្ទះគាត់។
ឌ. មីងសៅ_______________សក់ឱ្យកូនគាត់។
ឍ. គាត់កំពុងតែ________________លើកៅអីដែលនៅក្រោមដើមជ្រៃ។
ណ. លោក សម្បត្តិ ចេះ_________________យន្តហោះយ៉ាងស្ទាត់ជំនាញ។

**៣. ចូររកន័យផ្ទុយជាមួយកិរិយាសព្ទខាងក្រោមនេះ៖**

| **កិរិយាសព្ទ** | **ន័យផ្ទុយ** | **កិរិយាសព្ទ** | **ន័យផ្ទុយ** |
|---|---|---|---|
| ចេញ | | ទាញ | |
| ដើរ | | ឈប់ | |
| ដេក | | យំ | |
| អង្គុយ | | រះ | |
| បិទ | | ខ្ចី | |
| ទិញ | | ឈ្នះ | |
| ស្រលាញ់ | | ផ្ងារ | |
| ស្រាយ | | កសាង | |
| ឡើង | | ទៅ | |
| ឈឺ | | សប្បាយ | |
| បង្អាប់ | | បញ្ចូល | |
| លក់ | | យល់ស្រប | |

៩. ចូរជ្រើសរើសពាក្យក្នុងប្រអប់ដាក់តាមប្រភេទកិរិយាសព្ទនីមួយៗ៖

ស៊ី បន្ស៊ី ចូល បញ្ចូល រៀន ក្លាយជា ជា កំពុង បាន ធ្វើជា ចេញ បញ្ចេញ ពន្យល់ យល់ ហាត់ រលាយជា បង្ហាត់ អាច រួម បង្រួម ប្រែក្លាយជា ចេះ នឹង កើត បង្កើត ដើរតួជា ដេក ផ្ដេក ឡើងជា ឃើញ ប្រៀបដូចជា បង្ខូច ពន្យារ ពង្រឹង ជូន មក

| កិរិយាសុទ្ធ | កិរិយាហេតុ | កិរិយាចំណង | កិរិយាជំនួយ |
|---|---|---|---|
| | | | |

៩. ចូរតែងល្បះដោយប្រើកិរិយាសព្ទហេតុ និងកិរិយាសព្ទជំនួយឱ្យបាន៧ល្បះ

ក. ______________________________

ខ. ______________________________

គ. ______________________________

ឃ. ______________________________

ង. ______________________________

ច. ______________________________

ឆ. ______________________________

ជ. ______________________________

ឈ. ______________________________

ញ. ______________________________

ដ. ______________________________

ប. ______________________________

៩. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើកិរិយាសព្ទឱ្យបានត្រឹមត្រូវ៖

# អនុវត្តន៍
## មេរៀនទី៩ គុណកិរិយា

I. **សំណួរ**

១. ដូចម្ដេចដែលហៅថាគុណកិរិយា?

២. តើគុណកិរិយាចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. បើគិតលើទម្រង់ តើគុណកិរិយាចែកជាប៉ុន្មាន? អ្វីខ្លះ?

៤. តើគុណនាមប្រក្រតីនិងគុណកិរិយាបំណែបខុសគ្នាដូចម្ដេចខ្លះ? ចូរពន្យល់។

៥. ចូរអ្នកសិក្សាអំពីសម្ព័ន្ធគុណកិរិយាក្នុងល្បះ។

II. **លំហាត់អនុវត្តន៍**

**១. ចូរគូសបន្ទាត់ពីក្រោមពាក្យដែលជាគុណកិរិយាក្នុងល្បះខាងក្រោមនេះ៖**

ក. គោរត់ឃីត រីឯសេះរត់លឿនណាស់។

ខ. តារានិយាយលឿនណាស់។

គ. ដារីសរសេរភាសាខ្មែរល្អមែនទែន។

ឃ. សុខាតែងតែទៅលេងស្រុកកំណើតគាត់ យូរៗម្ដង។

ង. និស្សិតទាំងនេះឧស្សាហ៍អង្គុយអានសៀវភៅនៅក្រោមបណ្ណាល័យ។

ច. ពូសំ ជានិច្ចកាល ព្រួយបារម្ភអំពីជោគវាសនាកូនគាត់។

ឆ. ចៅចិត្រសម្លឹង យុន នារី ម្ដងហើយម្ដងទៀត។

ជ. នាងអង្គុយគិតស្ងៀមស្ងាត់។

ឈ. វាសនា ជាសិស្សម្នាក់ដែលរៀនពូកែណាស់។

ញ. តើគាត់និយាយដូចម្ដេច?

ដ. តើនាងបើកម៉ូតូយ៉ាងមេច?

ឋ. ចិន្ដាធ្វើលំហាត់ ត្រឹមត្រូវហើយ។

ឌ. ពួកគេស្រែកខ្លាំងពេក។

ឍ. គាត់និយាយបូរបាច់ច្រើនណាស់។

ណ. ស្អែក គាត់ចេញដំណើរទៅស្រែហើយ។

ត. សព្វថ្ងៃនេះ វិទ្យាសាស្ត្រដើរលឿនអស្ចារ្យ។
ថ. បន្តិចទៀត ខ្ញុំទៅតាមក្រោយ។
ទ. បងខ្ញុំ កាលពីមុន ធ្វើជាងកំបោរ។
ធ. គាត់ ឥឡូវនេះ ធ្វើជាងឈើ ។
ន. វាចេញទៅ អម្បាញ់មិញ។
ប. យើងមានលុយច្រើនល្មមសម្រាប់ដើរលេង។
ផ. គាត់បើកម៉ូតូលឿនហួស។
ព. សិទ្ធិវន្តសរសេរអក្សរលឿនបំផុត។
ភ. ទឹកភ្នែកកុមារីជាវីហូរសស្រាក់។
ម. ចង្រឹតដែកយំច្រែតៗ។

**២. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដាក់តាមប្រភេទគុណកិរិយានីមួយៗ៖**

លឿន ណាស់ យឺត ពេក ខ្លាំង មែនទែន អស់ទាស់ ហួស ខ្សោយ ពូកែ ជ្រុល ច្រើន តិច ពិតជា ស្ងៀមស្ងាត់ ដូចម្ដេច ត្រឹមត្រូវ យ៉ាងមេច ឥតខ្ចោះ ដូចម្ដេចខ្លះ បែបណា ជានិច្ចកាល ម្ដងហើយម្ដងទៀត ឧស្សាហ៍ ល្អ រហ័ស សន្សឹមៗ បូរបាច់

| គុណកិរិយាបំណែប | គុណកិរិយាកម្រិត | គុណកិរិយាសំណួរ |
|---|---|---|
| | | |

**៣. ចូរអ្នកជ្រើសរើសគុណកិរិយាខាងលើដើម្បីបំពេញចន្លោះខាងក្រោម៖**

ក. និយាយ__________ និយាយ____________ និយាយ______
ខ. ល្អ________ ល្អ_________________ ល្អ_________________

គ. ធ្វើ________ ធ្វើ________________ ធ្វើ________________

ឃ. ដើរ________ ដើរ________________ ដើរ________________

ង. ស________ ស________________ ស________________

**៤. ចូរអ្នកជ្រើសរើសគុណកិរិយាចេញពីក្នុងប្រអប់ រួចតែងល្បះឱ្យបានត្រឹមត្រូវ៖**

| |
|---|
| ស របស់ អាក្រក់ ខ្ជិល ស្អាត ឧស្សាហ៍ រលោង ធំ យឺត មាំ ល្អ លូត ខ្ពស់ ខ្ពស់ ខ្សោយ ពូកែ ញាប់ ខ្លាំង រឹង ដូចម្ដេច ចង្អៀត ច្រើន ជិត យ៉ាងម៉េច |

ក. __________៖________________________________________

ខ. __________៖________________________________________

គ. __________៖________________________________________

ឃ. __________៖________________________________________

ង. __________៖________________________________________

ច. __________៖________________________________________

ឆ. __________៖________________________________________

ជ. __________៖________________________________________

ឈ. __________៖________________________________________

ញ. __________៖________________________________________

**៥. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញចន្លោះខាងក្រោម៖**

| | | | | | |
|---|---|---|---|---|---|
| ភិបៗ | ភ្លែត | ជាប់ | ស្រួលបួល | ខ្ញៅៗ | ជាប់ |

[...] ដូច្នេះហើយបានជានៅល្ងាចថ្ងៃមួយ ទីឃាវុធស្នើរអង្គុយមិន______ ______ ក្នុងស៊ីក្លូ ព្រោះនឹករំខាននឹងល្បឿនយឺត___________ នៃយាននេះ។ ចិត្តអរ_______ ព្រោះប្រឡង_______ ថ្មីៗ ថ្មីបើវិញ្ញាសាយ៉ាងលំបាក ថៅមាណពរីកដើមទ្រូង រីកចិត្តប្រុងនឹងយកដំណឹងដ៏ប្រសើរនេះទាំងក្ដៅៗទៅប្រាប់ឆោមស្នេហា។ ដល់ហើយស្ទុះលោតចុះ______ រកតែស៊ីក្លូឈប់___________ មិនទាន់ហុចឱ្យថ្លៃឈ្នួលយ៉ាងដំណាំទៅឱ្យអ្នកធាក់ដើម្បីឱ្យគេជួយគ្រេកអរខ្លួនផង។ អ្នកកម្លោះទើបបានជោគជ័យបោលចូលក្នុងបាហុនដ្ឋានដោយឥតផ្សូរផ្សង ស្រាប់តែទុចង៉ក់ ស្រឡាំងកាំង។ [...] (ដកស្រង់ចេញពីរឿងមាលាដួងចិត្ត)

៦. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើប្រាស់គុណកិរិយាឱ្យបានត្រឹមត្រូវ៖

# អនុវត្តន៍
## មេរៀនទី១០ ផ្នាក់

I. **សំណួរ**

១. ដូចម្ដេចដែលហៅថាផ្នាក់?

២. តើផ្នាក់មានប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. តើផ្នាក់មានលក្ខណៈសម្គាល់ដូចម្ដេចខ្លះ? ចូរពន្យល់។

៤. តើកន្សោមមានផ្នាក់មានមុខងារជាអ្វីខ្លះក្នុងល្បះ? ចូរបញ្ជាក់។

II. **លំហាត់អនុវត្តន៍**

**១. ចូរគូសបន្ទាត់ពីក្រោមពាក្យដែលជាផ្នាក់ក្នុងល្បះខាងក្រោមនេះ៖**

ក. មីងសានដូសបាយនឹងស្លាបព្រាឱ្យកូនប្រុសគាត់។

ខ. ភ្នំពេញជារាជធានីនៃប្រទេសកម្ពុជា។

គ. ដារីកំពុងដើរលេងក្នុងសួនច្បារជាមួយសុធារី។

ឃ. ឆ្កែដេកក្រោមតុដែលនៅជិតដើមឈើធំមួយ។

ង. យើងខិតខំរៀនសូត្រដើម្បីអនាគតយើង។

ច. ព្រះបរមរាជវាំងស្ថិតនៅក្បែរសារមន្ទីរជាតិនិងនៅតាមមាត់ទន្លេចតុមុខ។

ឆ. គោរបស់ពូសុករត់តាមក្រោយសេះរបស់ពូសៅ។

ជ. វាសនាតែងតែគិតដល់ឪពុកម្ដាយគេជានិច្ច។

ឈ. រទេះសេះបរលើផ្លូវលំដែលនៅក្រៅភូមិ។

ញ. សាលារៀនយើងសង់កណ្ដាលទីក្រុង។

ដ. ផ្ទះខ្ញុំនៅចន្លោះសាលារៀននិងវាលស្រែ។

ឋ. សុខា ពូកែខាងគណិតវិទ្យា រីឯសុជាតា ពូកែខាងអក្សរសាស្ត្រ។

ឌ. យើងចូលរៀននៅម៉ោង៧:៣០ នាទីព្រឹក។

ឍ. និស្សិតទាំងអស់ចូលអង្គុយក្នុងថ្នាក់ដោយស្ងៀមស្ងាត់។

ណ. ថ្ងៃបុណ្យចូលឆ្នាំថ្មី កូនៗតែងតែទិញសម្លៀកបំពាក់ជូនឪពុកម្ដាយ។

ត. គាត់មករស់ទីក្រុងភ្នំពេញចាប់តាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ។

ថ. នាងធ្វើការងារនេះប្រហែលមួយសប្ដាហ៍ហើយ។

ទ. យើងរស់នៅដោយសុភមង្គលជាមួយគ្រួសារយើង។

**២. ចូរអ្នកជ្រើសរើសពាក្យចេញពីប្រអប់ដើម្បីបំពេញល្បះខាងក្រោម៖**

| | | | | | | |
|---|---|---|---|---|---|---|
| ចំពោះ | ដើម្បី | នឹង | នៅចន្លោះ | ចាប់ពី | ក្នុង | របស់ |
| នៅ | ជិត | សម្រាប់ | ដល់ | ជាមួយ | ក្នុង | ដោយសារ |

ក. អ្នកដឹកនាំត្រូវតែយកចិត្តទុកដាក់________ បុគ្គលិក។

ខ. យើងខំរៀន______ ប្រទេសជាតិយើង។

គ. គាត់រស់នៅ______ គ្រួសារ។

ឃ. លោកដូណាល់ត្រាំ អះអាងថាកុំភ័យ__________ មេរោគកូរ៉ូណា។

ង. កម្លាំងអាវុធហត្ថមានពេលតិច__________ គ្រួសារ។

ច. សង្គ្រាម_________សម័យចតុមុខនិងល្វែកបានផ្ដើមឡើង______ ឆ្នាំ១៥០៩-១៥២៦។

ឆ. រថភ្លើងអាកាសជាដំណោះស្រាយកាត់បន្ថយកកស្ទះចរាចរណ៍_________ ទីក្រុង។

ជ. ប្រេងសាំងធម្មតាបានធ្លាក់ថ្លៃ_____ថ្ងៃទី១៦ ខែឧសភា ___ដំណាច់ខែនេះ។

ឈ. ចិននិងឥណ្ឌារងផលប៉ះពាល់ជាងគេ____ ល្អងធូលី____ បរិយាកាស។

ញ. កន្លែងធ្វើការ__________ ខ្ញុំនៅ_______ វត្តភ្នំ។

**៣. ចូរតែងល្បះដោយប្រើធ្នាក់តាមប្រភេទនីមួយៗ៖**

ក. ________________________________________________

ខ. ________________________________________________

គ. ________________________________________________

ឃ. ________________________________________________

ង. ________________________________________________

ច. ________________________________________________

ឆ. ________________________________________________

ជ. ________________________________________________

## ៤. ចូរជ្រើសរើសពាក្យក្នុងប្រអប់ដាក់តាមប្រភេទផ្ទាក់នីមួយៗ

| |
|---|
| លើ ប្រហែល ក្រោម តាំងពី ជាមួយ សម្រាប់ ក្នុង នៅ ក្បែរ នឹង ដើម្បីនឹង តាម ដើម្បី ដោយសារ ដើម្បីឱ្យ ជាមួយនឹង ដោយសារតែ ជុំវិញ ដល់ បន្ទាប់ពី នៅក្នុង នា ជិត ខណៈនោះ ចន្លោះ រហូតដល់ ចាប់តាំងពី ខាង កៀន ពីក្រោយ |

| ទីកន្លែង | ពេលវេលា | មធ្យោបាយ | គោលបំណង |
|---|---|---|---|
| | | | |

## ៥. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញចន្លោះខាងក្រោម៖

| | | | | | | |
|---|---|---|---|---|---|---|
| ជាប់ | របស់ | នៅ | ដល់ | ដល់ | នៅ | ក្នុង |

[...] អ្នកស្រី កែវ ដារី អាជីវករលក់វត្ថុអនុស្សាវរីយ៍__________ ផ្សាររាត្រីបានប្រសាសន៍ថាផ្សាររាត្រី________ មាត់ទន្លេមួយនេះ បានផ្តល់ប្រាក់ចំណូលជាមធ្យមប្រមាណ២០០ដុល្លារ_______ មួយយប់ និងបានផ្តល់ការងារ_______ ពលរដ្ឋជាច្រើនគ្រួសារទាំងនៅភ្នំពេញ ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល ដែលសុទ្ធតែជាសិប្បករកែច្នៃវត្ថុអន-ុស្សាវរីយ៍។ អ្នកស្រីបញ្ជាក់ប្រាប់ខេមបូឌាមីសទាំងរីករាយថា៖ «ខ្ញុំមានលក់ផលិតផលខ្មែរដូចជាផ្កាកែច្នៃពីសំបកពោត ស្លឹកត្នោត និងកែច្នៃពីស្នោរ ដែលវាជាស្នាដៃ_____ខ្មែរយើង។ ផ្សាររាត្រីមានភ្ញៀវទេសចរជាច្រើនទាំងក្នុងស្រុកនិងក្រៅស្រុក ដែលពួកគាត់បានមកទស្សនា និងបានទិញផលិតផលយើង។ ផ្សាររាត្រីបានជួយលើកទឹកចិត្តពលរដ្ឋ និងបានជួយច្រើន________ សេដ្ឋកិច្ចពលរដ្ឋ បើគ្មានទីផ្សារទេ ប្រជាពលរដ្ឋក៏មិនដឹងផលិតយកទៅលក់_________ ឯណាទេ» ។ [...]

(https://cambonomist.com/news/night-market-generates-income/)

៦. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើប្រាស់ធ្នាក់ឱ្យបានត្រឹមត្រូវ៖

# អនុវត្តន៍
# មេរៀនទី១១ ឈ្នាប់

I. **សំណួរ**

១. ដូចម្ដេចដែលហៅថាឈ្នាប់?

២. តើឈ្នាប់មានទីតាំងស្ថិតនៅត្រង់ណាខ្លះនៃល្បះ? ចូរបញ្ជាក់។

៣. តើឈ្នាប់ចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៤. តើឈ្នាប់ឃ្លាត្រូវបានប្រើសម្រាប់ធ្វើអ្វីខ្លះ? ចូរពន្យល់។

៥. តើឈ្នាប់និងធ្នាក់ខុសគ្នាដូចម្ដេចខ្លះ? ចូរពន្យល់។

II. **លំហាត់អនុវត្តន៍**

**១. ចូរគូសបន្ទាត់ពីក្រោមពាក្យដែលជាឈ្នាប់ក្នុងល្បះខាងក្រោមនេះ៖**

ក. ចាប់និងក្រូច ហើរលើមេឃ។

ខ. ដរាបណា គាត់មិនទាន់ធ្វើការងារនេះហើយ ដរាបនោះ គាត់មិនទៅផ្ទះទេ។

គ. នាងមិនត្រឹមតែស្អាតទេ ថែមទាំងមានលុយច្រើនទៀត។

ឃ. គាត់ធ្វើខុស ប៉ុន្តែគាត់ពុំហ៊ានសារភាព។

ង. តើបងចង់ផឹកកាហ្វេ ឬតែ?

ច. ធានីនៅតែចាំម្ដាយនាង ទំរាំម្ដាយនាងមកពីផ្សារ។

ឆ. គាត់មិនមកធ្វើការទេ ព្រោះគាត់ឈឺ។

ជ. ទាំង គ្រូ ទាំងសិស្ស សុទ្ធតែយកចិត្តទុកដាក់ធ្វើការងារទាំងនេះឱ្យបានល្អ។

ឈ. នាងមកធ្វើការនៅទីនេះដោយសារតែនាងចង់បានប្រាក់ខែច្រើន។

ញ. គាត់បានចាកចេញពីផ្ទះបន្ទាប់ពីយើងមកដល់។

ដ. ពួកគេនឹងទៅលេងកំពង់សោម ប្រសិនបើពួកគេមានពេលទំនេរ។

ឋ. ទោះបីមេឃភ្លៀងក៏ដោយ ក៏យើងនៅតែទៅរៀនដែរ។

ឌ. យើងនឹងចេញទៅផ្ទះឥឡូវនេះ នៅពេលគាត់ធ្វើការងារនេះហើយ។

ឍ. ចូរឯងនិយាយតិចៗ ក្រែងលោគេស្ដាប់ឮ។

ណ. និស្សិតទាំងអស់ខិតខំរៀន ដូច្នេះពួកគេនឹងប្រឡងជាប់គ្រប់ៗគ្នា។

## ២. ចូរជ្រើសរើសពាក្យក្នុងប្រអប់ដាក់តាមប្រភេទឈ្នាប់នីមួយៗ

ពេល ក្រែងលោ បើ កាល ទោះ ដើម្បី ទោះបី នៅពេល ទោះជា ទោះបីជា បន្ទាប់ពី ប៉ុន្តែ តែ ដើម្បីនឹង ទាល់តែ ព្រោះ ក្នុងពេលដែល ខ្លាច ទាល់តែ ដោយសារ មិនឱ្យ ព្រោះតែ កុំឱ្យ ពីព្រោះ ដើម្បីកុំឱ្យ ដោយមូលហេតុ ដ្បិត

| មូលហេតុ | ពេលវេលា | ទំនាស់ | បំណង |
|---|---|---|---|
| | | | |

## ៣. ចូរតែងល្បះដោយប្រើឈ្នាប់តាមទម្រង់ខាងក្រោមនេះ៖

ក. នាម + ឈ្នាប់ + នាម

ខ. កិរិយា + ឈ្នាប់ + កិរិយា

គ. គុណនាម + ឈ្នាប់ + គុណនាម

ឃ. សព្វនាម + ឈ្នាប់ + សព្វនាម

ង. គុណកិរិយា + ឈ្នាប់ + គុណកិរិយា

ច. ល្បះទោល + ឈ្នាប់ + ល្បះទោល

**៤. ចូរអ្នកជ្រើសរើសពាក្យចេញពីប្រអប់ដើម្បីបំពេញល្បះខាងក្រោម៖**

| | | | | |
|---|---|---|---|---|
| ដរាបណា, | បន្ទាប់ពី, | ដូចនេះ, | ហើយ, | មុខជា, |
| ច្រើនជាង, | ទោះបី, | កាលណា, | លុះត្រាតែ, | ទាំង…ទាំង… |

ក. ________អាជ្ញាកណ្តាល______ ចៅក្រមសុទ្ធតែមានសុភវិនិច្ឆ័យ។

ខ. ពងមាន់មិនអាចធ្វើឱ្យអ្នកឡើងទម្ងន់ទេ ___អ្នកគួរតែបរិភោគឱ្យបានច្រើន។

គ. ប្រទេសអាចរីកចម្រើនបាន______ ធនធានមនុស្សមានគុណភាព។

ឃ. គាត់និយាយដូចនេះ__________ គេខឹងមិនខាន។

ង. ជ័យជម្នះនឹងមានពិតប្រាកដ__________ យើងមិនបោះបង់ការតស៊ូ។

ច. ពលរដ្ឋមិនត្រូវភ្លេចខ្លួន_________ កម្ពុជាមានអ្នកឆ្លងកូវីដតិចតួច។

ឆ. គាត់ទៅការមិត្តភក្តិ______ បង្ហួសទៅស្រុកកំណើត។

ជ. ________ថ្ងៃរះ បងដាស់អូនផង។

ឈ. គាត់ដាក់ខ្លួននៅដាច់ដោយឡែក______ គាត់ឆ្លងជំងឺកូវីដ។

ញ. គាត់និយាយ__________ គាត់ធ្វើ។

**៥. ចូរអ្នកជ្រើសរើសឈ្នាប់ក្នុងប្រអប់ដើម្បីបំពេញអត្ថបទខាងក្រោម៖**

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ហើយ | និង | ហើយ | តែ | ទុកដូច | កាល | ទើប | ចុះ | ហើយ | នៅតែ | តែ |

[…] វេលានោះ រស្មីព្រះចន្ទ្រកំពុងតែចាំងចូលមកតាមចន្លោះបង្អួច____ _____ ចន្លោះទ្វារ ________នាងមើលទៅឃើញរាងកាយចៅចិត្រដេកលក់ស្លូកស្លឹងនៅទីនោះយ៉ាងច្បាស់លាស់។ នាងក៏ស្រែកដាស់ចៅចិត្រពីរបីម៉ាត់ ចៅចិត្រក៏ប្រែខ្លួនស្ទុះក្រោកឡើងទាំងងងុយងោក។ __________ឃើញអ្នកដែលចូលមកដាស់ច្បាស់ហើយ ក៏ម្ទីម្ទានិយាយអញ្ជើញឱ្យអង្គុយដោយកិរិយាឱនលំទោន។

- អញ្ជើញអង្គុយ យុននារី!

ចៅចិត្រនិយាយព្រមទាំងលើកកៅអីមួយជូននាងអង្គុយ _____ _____និយាយថា៖

- ការដែលយុនអញ្ជើញលេងផ្ទះខ្ញុំបាទនេះ ខ្ញុំបាទមានសេចក្តីត្រេកអរណាស់________ បានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់!

នាងនារីធ្វើមុខក្រញូវបន្តិចហើយស្តីទៅថា៖

- អ្នកណានិយាយថា ខ្ញុំមកលេងនឹងអ្នកឯង!

ចៅចិត្រនឹកសង្ស័យក៏សួរទៅវិញថា៖

- ចុះយុនអញ្ជើញមកមានការអ្វី?

នាងតបទៅវិញយ៉ាងកំបុតកំបុយថា៖

- ខ្ញុំមកស្តាប់មនុស្សច្រៀងទេតើ ________អម្បាញ់មិញនេះអ្នកណាច្រៀងទំនុកយុវាភិរម្យក្តែងៗក្នុងទីនេះ?

ចៅចិត្រធ្វើភ្នែកឡឹងឡង់ និយាយសួរទៅនាងថា៖

- ទានប្រោស យុវាភិរម្យជាអ្វី ជាសត្វឬជាមនុស្ស ខ្ញុំបាទមិនដែលឮឈ្មោះសោះឡើយ?

នាងនារីខឹងឡើងមុខក្រហម _______ប្រាប់ទៅថា៖

- នែ! អ្នកភ្លើ យុវាភិរម្យជាទំនុកភ្លេងមួយ ខ្ញុំចង់ដឹងតើអម្បាញ់មិញនេះនរណាច្រៀង?
- ចិត្រ៖ អេទេ! នរណាច្រៀងខ្ញុំបាទឥតដឹងសោះឡើយ _________ខ្ញុំបាទមិនមែនច្រៀងទេ។ ឯខ្ញុំបាទនេះកុំថាដល់ទៅភ្លេងយុវាភិរម្យជាទំនុកទំនើបថ្មីអ្វីនោះឡើយ តែបទសករវាទិចុះផែអុំទូករាល់ឆ្នាំនោះ ខ្ញុំបាទក៏ឥតចេះនឹងគេសោះឡើយ។
- នារី៖ កុំភូត ខ្ញុំបានឮសូរសំឡេងច្រៀងអំពីខាងលើផ្ទះនេះឯង ________នៅលើផ្ទះនេះក៏មានតែអ្នកឯងម្នាក់ឯងមែនទេ?
- ចិត្រ៖ បាទ មានតែខ្ញុំបាទម្នាក់ឯងមែន _________ខ្ញុំបាទមិនមែនជាអ្នកច្រៀងទេ!
- អ្នកឯងច្រៀងក្តែងៗ___________ ប្រកែកនឹងគេទៀត។ [...]

(សម្រង់ចាករឿងកុលាបប៉ៃលិន និពន្ធដោយលោក ញ៉ុក ថែម)

**៦. ចូរអ្នកសរសេរអត្ថបទខ្លីមួយដោយប្រើប្រាស់ឃ្នាប់ឱ្យបានត្រឹមត្រូវ៖**

________________________________________

________________________________________

________________________________________

________________________________________

# អនុវត្តន៍
# មេរៀនទី១២ ឧទានសព្ទ

I. **សំណួរ**

១. ដូចម្តេចដែលហៅថាឧទានសព្ទ?

២. តើឧទានសព្ទចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. តើឧទានសព្ទត្រូវបានប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះ? ចូរពន្យល់។

II. **លំហាត់អនុវត្តន៍**

**១. ចូរអ្នកជ្រើសរើសចម្លើយដែលត្រឹមត្រូវដោយគូសសញ្ញា ✓ក្នុងប្រអប់៖**

□ ក. ឧទានសព្ទ គឺជាពាក្យមួយម៉ាត់ឬជាកន្សោមពាក្យ។

□ ខ. ឧទានសព្ទ គឺជាល្បះខ្លីឬល្បះវែងៗ។

□ គ. ឧទានសព្ទស្ថិតនៅខាងដើមល្បះ។

□ ឃ. ឧទានសព្ទត្រូវបានប្រើសម្រាប់បញ្ជាក់ន័យឱ្យល្បះកាន់តែច្បាស់លាស់។

□ ង. ឧទានសព្ទត្រូវបានប្រើសម្រាប់ប្រតិកម្មនឹងការជាប់ចិត្តយ៉ាងខ្លាំង ការព្រមាន ការភ្ញាក់ផ្អើល ការងឿងឆ្ងល់ ការខ្លាច។ល។

□ ច. ពេលលំបាកចិត្តខ្លាំង គេក៏អាចប្រើឧទានសព្ទបានដែរ។

□ ឆ. ឧទានសព្ទស្ថិតនៅខាងចុងល្បះ។

□ ជ. ឧទានសព្ទមានន័យសម្គាល់សកម្មភាពឬអំពើផ្សេងៗ។

□ ឈ. ឧទានសព្ទអាចជាពាក្យគ្រាប់ស្ទួរធម្មជាតិឬសម្តែងចំណាប់អារម្មណ៍ភ្លាមៗ។

**២. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញតារាងខាងក្រោម៖**

| | | | | | | | |
|---|---|---|---|---|---|---|---|
| អេហ៍ | ចុយយក្ស | យី | យ៉ឺះ | ងាប់តែម្តង | អូយយ៉ូយ | អ៊ី | ងាប់ហើយ |
| ព្រះអើយ | ងាប់ | ពុទ្ធោ | ម៉ែអើយ | ព្រះអង្គអើយ | ចុយ | ពុទ្ធោអើយ | |

| ប្រភេទ | ឧទានសព្ទ |
| --- | --- |
| សម្រែកឬសំឡេងត្រាប់តាម | |
| សាធារណនាមឬអសាធារណនាម | |
| កិរិយាសព្ទ | |

## ៣. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញតារាងខាងក្រោម៖

| |
| --- |
| យី ព្រះអង្គអើយ អូហ៍ ព្រះអើយ ហ្អាក ពុទ្ធោ យីអើ ពុទ្ធោអើយ ព្រះ នែ |

| គោលបំណង | ឧទានសព្ទ |
| --- | --- |
| ឧទ្ទិសដល់ព្រះពុទ្ធ | |
| សម្ដែងអារម្មណ៍ | |

## ៤. ចូរអ្នកពិនិត្យល្បះ រួចគូសបន្ទាត់ពីខាងក្រោមពាក្យដែលជាឧទានសព្ទ៖

ក. ឱ! ប្រហែលជាឡានដែលខ្ញុំបានជិះមកឡើងរថភ្លើងហើយមើលទៅ។

ខ. អូ! អ្នកដែលទៅជួយបារាំងនោះមិនទាន់បានមកទេ។

គ. យីអាំ! សម្ដីរឹងណាស់ហ្ន៎!

ឃ. អើ! យកបាយលីងសាច់ក្ដាមលាយសាច់មាន់ ហើយដាក់ពងទាផង។

ង. នែអ្នកសុវណ្ណ! រឿងពន្ធម៉េចទៅ! ឆ្នាំមុននិងឆ្នាំនេះឡើងខុសគ្នាឆ្ងាយណាស់។

ច. យី! ក្អួយទេតើ។

ឆ. អីក៏អាក្រក់ដល់ម្លឹងហ្ន៎!

ជ. ហ៍អាគ្នោត! យកឆ្អឹងមួយបណ្ដោះអាសន្នសិនទៅ។

ឈ. ឱពុទ្ធោអើយ! ខ្ញុំយ៉ាងណាក៏មិនហ៊ានដែរ ទុកជាគេឱ្យប៉ុន្មាន ក៏មិនហ៊ានសម្លាប់មនុស្សដែរ។

ញ. ប្អូនអើយ! កាលដែលខ្ញុំទៅលេងស្រុកខ្មែរ ខ្ញុំបានជួបបុរសចិត្តជានេះឯង។

**៥. ចូរអ្នកជ្រើសរើសពាក្យចេញពីប្រអប់ដើម្បីបំពេញល្បះខាងក្រោម៖**

| | | | | | |
|---|---|---|---|---|---|
| យី!, | អាចឹហ៎!, | ហាស! | ហាស! | ហាស!, | យើសលោកបារាំង!, |
| អើ!, | យីអានេះ!, | នាងអើយ!, | ចុម!, | នែលោកធំ!, | ងឺ! |

ក. _______________កាន់តែព្រហើនឡើងៗ ចេញពីផ្ទះអញឱ្យឆាប់។

ខ. ___អញឱ្យឯងបុកកុំឱ្យស្លាប់ ឥឡូវមានស្លាប់ រឿងវាធំ អញមិនដឹងទេ។

គ. _________រឿងថៅកែកម្សត់មែន គួរសរសេរជាសៀវភៅទុក។

ឃ. ___យ៉ាងណាទៅ មិនស្រួលទេដឹង?

ង. _____________________លោកឯងអាងសាសន៍លោកត្រួតលើក្បាលខ្មែរ លោកចង់ជាន់លើក្បាលខ្មែរ លោកចង់ជាន់លើខ្មែរស្មើម៉ានបានស្មើណោះឬ?

ច. ____________ ក្នុងពេលនេះ ខ្ញុំរវល់ដកខ្លួនពុំរួចសោះតែម្ដង អស់ពីរឿងមួយធ្លាក់ទៅរឿងមួយទៀត។

ឆ. _______________ស៊ីអុយហ៎?

ជ. _______________ លោកប្រើអំណាចមកលើខ្ញុំនិងជាតិខ្ញុំជ្រុលហួសហើយ។

ឈ. ________ល្បងជូននិងល្បងនៅទេតើ!

ញ. _______________ខ្ញុំជាជើងឯកត្រឹមតែខាងការពារខ្លួនទល់នឹងសត្រូវដែលចង់ព្យាបាទមកលើរូបខ្ញុំប៉ុណ្ណោះទេ។

**៦. ចូរអ្នកបង្កើតល្បះដោយប្រើឧទានសព្ទដូចខាងក្រោម៖**

ក. ហ្អាក! ៖ ________________________________________________

ខ. ឱះឱ! ៖ ________________________________________________

គ. អូយយ៉ូយ! ៖ ____________________________________________

ឃ. អែយ៉ា! ៖ _______________________________________________

ង. ចុយយក្ស! ៖ _____________________________________________

**៧. ចូរអ្នកជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញអត្ថបទសន្ទនាខាងក្រោម៖**

| | | | | | | |
|---|---|---|---|---|---|---|
| បាទ!, | កុំអី! | កុំអី!, | លោកអើយ!, | ពូតយ!, | ទេ! | ទេ!, |
| អីយ៉ា! | អីយ៉ា!, | អើ!, | យី!, | មិនឈប់ទេវ៉ើយ!, | លោកអើយ! | |

[...] **នាយតយ៖** ____________អាម្នាក់នេះហេតុអីមិនព្រមរត់នឹងគេ បែរជាសសុលចូលក្រោមគ្រែដូចនេះវិញ យកកម្រាលព្រំមកគ្របពីលើក្បាលបញ្ចេញគូទទៅវិញ! អ្នកក្លាហានចេញភ្លាមមក!

**នាយទិន៖** ____________កុំសម្លាប់ខ្ញុំ។ (ទាហានរបស់ស្ដេចសម្រែ)

**នាយតយ៖** ចេញមក! ចេញមក! (អ្នកបម្រើតែជោមាស)

**នាយទិន៖** ____________ខ្ញុំចេញហើយ! ខ្ញុំចេញហើយ!

**នាយតយ៖** យើងនឹងសម្លាប់ឯងដោយពូថៅនេះ។

**នាយទិន៖** ____________ឈប់សិនលោក!

**នាយតយ៖** ____________ (ច្រៀង) អញនឹងកាប់ឯងជាបីបួនកំណាត់ អញកាត់សាច់ឯងប្រឡាក់ ធ្វើផ្អកទុកដល់ឆ្នាំក្រោយ (២ដង) ទុកហូបបាយកកធ្វើទាំងសាច់ក្រក ធ្វើទាំងសាច់ក្រកច្រកក្នុងពោះវៀន...។

**នាយទិន៖** (ច្រៀងបន្ត) បើហូបសាច់យើង ក៏ហូបទៅចុះ តែបិទច្រមុះ ព្រោះពោះយើងមានវត្ថុសំណល់ដង្កូវព្រូនអៀន តើអ្នកណាហ៊ានទទួលទានឬទេ?

**យ៉ត៖** បានហើយៗ ពូតយ! ដោះលែងគាត់ឱ្យត្រឡប់ទៅវិញចុះ។

**នាយទិន៖** ____________ខ្ញុំមិនទៅវិញទេ! ខ្ញុំនៅទីនេះហើយ។

**នាយតយ៖** ម៉េចអ៊ីចឹង!

**នាយទិន៖** ខ្ញុំទៅឯណា? បើខ្ញុំចង់ធ្វើការបម្រើប្រទេសជាតិជាមួយលោកម្ចាស់ហ្នឹងទាន!

**នាយតយ៖** ______ម៉េចនិយាយត្រឡប់ត្រឡិនបាយបិណ្ឌបាយបាត្រម្ដងថាទៅ ម្ដងថានៅ!

**នាយទិន៖** ____________កាលដែលខ្ញុំចូលបម្រើស្ដេចសម្រែដោយសារតែស្ដេចនេះមកកៀរមកកេណ្ឌ តើបើតាមការពិតស្ដេចសម្រែជាអ្នកលោភលន់ណាស់ វាមានប្រាថ្នាចង់សោយរាជ្យ វាមិនមែនគិតគូរដល់ផលប្រយោជន៍ប្រជារាស្ត្រនិងអ្នកស្រែចម្ការឯណាទេទាន!

**យ៉ត៖** ពូឯងឈ្មោះអី?

**នាយទិន៖** បាទ! ខ្ញុំឈ្មោះទិន។

**យ៉ត៖** ____________ឱ្យគាត់នៅជាមួយយើងចុះណា!

**នាយតយ៖** បាទ! តែប៉ុណ្ណេះ ខ្ញុំបានក្លើម្នាក់ហើយ។

**នាយទិន៖** ______យើងរាប់គ្នាជាក្លើ។ [...]

(សម្រង់ចាករឿងតេដោយ៉ត និពន្ធដោយលោក ទី ជីហ្វូត ឆ្នាំ១៩៨៣)

**៨. ចូរអ្នកសរសេរអត្ថបទសន្ទនាមួយដោយប្រើប្រាស់ឧទានសព្ទឱ្យបានត្រឹមត្រូវ៖**

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

____________៖ ______________________________________________

# អនុវត្តន៍
## មេរៀនទី១៣ កន្សោមពាក្យ

**I. សំណួរ**

១. ចូរអ្នកឱ្យនិយមន័យកន្សោមពាក្យ។

២. តើកន្សោមពាក្យមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

៣. តើការបែងចែកកន្សោមពាក្យនៅក្នុងភាសាខ្មែរ គេឈរលើមូលដ្ឋានអ្វីខ្លះ?

៤. ចូរអ្នកបង្ហាញពីទម្រង់កន្សោមកិរិយា រួចវិភាគទម្រង់កន្សោមកិរិយាណាមួយ។

៥. តើមុខងារកន្សោមពាក្យមានអ្វីខ្លះ?

**II. លំហាត់អនុវត្តន៍**

**១. ចូរអ្នកពិនិត្យមើលកន្សោមពាក្យខាងក្រោម តើកន្សោមពាក្យទាំងនោះជាកន្សោមអ្វី ហើយស្ថិតក្នុងទម្រង់ណាមួយ?៖**

ក. ឧបសគ្គនានាក្នុងជីវិតរបស់យើង

ខ. ទទួលយករថយន្តក្នុងក្ដីស្រមៃ

គ. ពីបំណងប្រាថ្នារបស់ប្រជាជនចិន

**២. ចូរអ្នកតាងកន្សោមពាក្យខាងក្រោមជាមែកធាង៖**

ក. បញ្ជូនកូនតូចទៅសិក្សានៅក្រៅប្រទេស

ខ. ថ្នាក់ដឹកនាំកំពូលៗនៃរាជរដ្ឋាភិបាលកម្ពុជា

គ. នៃអាទិទេពក្នុងរឿងកូរសមុទ្រទឹកដោះ

**៣. ចូរអ្នកកែកន្សោមពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. កូនសោររបស់បន្ទប់អ្នក

ខ. អាចសួរតាមទូរសព្ទទៅបុគ្គលិកសណ្ឋាគារ

គ. ចុះថ្លៃយ៉ាងច្រើនណាស់

ឃ. បង្ហាញអត្តសញ្ញាណបណ្ណរបស់អ្នកឱ្យខ្ញុំ

# អនុវត្តន៍
# មេរៀនទី១៨ ល្បះ

I. **សំណួរ**

១. ចូរអ្នកឱ្យនិយមន័យល្បះ។

២. តើទម្រង់នៃការបង្កើតល្បះមានអ្វីខ្លះ?

៣. ក្នុងល្បះចែកជាកន្សោមពាក្យអ្វីខ្លះ?

៤. តើកន្សោមនាមប្រធានអាចជាអ្វីខ្លះ? ចុះកន្សោមកិរិយាវិញ?

៥. តើល្បះមានប៉ុន្មានប្រភេទ? អ្វីខ្លះ?

៦. ចូរអ្នកឱ្យនិយមន័យល្បះទោល ល្បះផ្សំ ល្បះក្រង។

៧. តើនៅក្នុងល្បះផ្សំមានឃ្នាអ្វីខ្លះ?

៨. តើល្បះក្រងមានប៉ុន្មានទម្រង់? ចូរបង្ហាញ។

៩. តើល្បះមានប៉ុន្មានបែប? អ្វីខ្លះ?

១០. តើល្បះមានរូបរាងប៉ុន្មានយ៉ាង? អ្វីខ្លះ?

១១. តើល្បះកត្តុនិងល្បះកម្មខុសគ្នាដូចម្ដេចខ្លះ?

១២. តើល្បះសង្កត់មានលក្ខណៈសម្គាល់អ្វីខ្លះ?

១៣. ដូចម្ដេចហៅថាកថាផ្ទាល់ កថាមិនផ្ទាល់?

II. **លំហាត់អនុវត្តន៍**

**១. ចូរអ្នកបង្កើតល្បះតាមទម្រង់ខាងក្រោម៖**

ក. ល → កនប្រ + កកិ [ (កិ + កមធ (ធ + កន) ) ]

ខ. ល → កនប្រ + កកិ [ (កិ + កន + កមធ (ធ + កន) ) ]

គ. ល → កនប្រ + កកិ [ (កិ (ជា) + កន) ]

**២. ចូរអ្នកកំណត់ទម្រង់ល្បះខាងក្រោម៖**

ក. ខ្ញុំឧទ្ទិសរឿងនេះចំពោះដែនកំណើតរបស់ខ្ញុំ។

គ. លោកគ្រូពេទ្យមានទឹកមុខរីករាយ។

ក. ការនេះជាការប្រឡងថ្មីក្នុងជីវិតរបស់ខ្ញុំបាទ។

**៣. ចូរអ្នកវិភាគល្បះខាងក្រោម រួចតាងល្បះជាមែកធាង៖**

ក. នៅទីធ្លាមុខផ្ទះមានស្មៅរាបស្អាតដូចកម្រាលព្រំ។

ខ. កម្មករនេះមានកម្លាំងខ្លាំងណាស់។

គ. ថៅចិត្រមានកិរិយាអង់អាចខុសពីកម្មករឯទៀតៗ។

**៤. ចូរអ្នកពិនិត្យល្បះខាងក្រោម រួចបញ្ជាក់ថាជាល្បះអ្វីដោយប្រាប់ពីហេតុផល៖**

ក. នាងមានប្តីជាជនជាតិខ្មែរ ហើយមានកូនប្រុសតូចម្នាក់។

ខ. នៅខាងស្តាំមាត់ទ្វារមានក្តារឿធំក្រាស់មួយដែលជូតខាត់ឡើងរលោងស្រិល។

គ. ផ្ទះរបស់នាងជាផ្ទះឈើប្រក់ស័ង្កសី សង់នៅលើដីភូមិមួយនៅជាយក្រុងតាមផ្លូវដែលចេញពីទីក្រុងទៅចន្ទបូរី។

ឃ. នៅពេលនោះស្ត្រីម្នាក់អាយុកណ្តាលមនុស្សនិងក្មេងកំលោះម្នាក់មុខស្ងួតស្ងប់ សម្បុរស្បែកឡើងទង់ដែងដោយត្រូវកម្តៅថ្ងៃ ដើរមកខាងត្បូងចូលមកក្នុងភូមិ។

ង. សួនអ៊ីហ៊ីយានមានធម្មជាតិស្រស់បំព្រង ផ្កាគ្រប់ពណ៌រីកស្គុះស្គាយ មនុស្សដើរលេងពពាក់ពពូន។

**៥. ចូរអ្នកបង្កើតល្បះតាមទម្រង់ខាងក្រោម៖**

ក. ល → កនប្រ + កិ (សកម្ម) + កន (កបផ) + កមធ

ខ. ល → កនប្រ + កិ + ឃ្លា (ឈ្នាប់ឃ្លា + ល្បះរណប)

គ. ល → កនប្រ + កិ + កន + ព (ឃ្លារណប)

ឃ. ល → លរង + ឈចង + លរង

ង. ល → លរង + លរង + លរង

**៦. ចូរអ្នកវិភាគនិងតាងល្បះខាងក្រោមជាមែកធាង៖**

ក. នៅទីធ្លាមុខផ្ទះមានស្មៅរាបស្អាតដូចកម្រាលព្រំ។

ខ. ក្នុងពេលដែលនាងសយកំពុងតែរៀបចំបោសសម្អាតបន្ទប់តូចនៅខាងក្រោយថៅកែហុកក៏បានចូលទៅជួបនាងតែពីរនាក់តទល់។

គ. ពេលទៅដល់មណ្ឌលសុខភាព លោកគ្រូពេទ្យវ័យក្មេងម្នាក់ដែលប្រចាំការបានចេញមកសាកសួរដោយរាក់ទាក់បំផុត។

**៧. ចូរអ្នកកែល្បះខាងក្រោមឱ្យបានត្រឹមត្រូវ៖**

ក. មហាកំពែងដែលកន្លែងទាក់ចិត្តខ្ញុំជាងគេ ហើយមានទេសភាពល្អ ខ្ញុំចង់ទៅលេងច្រើនណាស់។

ខ. ផានអានមិនជាល្បីឈ្មោះនៅប្រទេសចិន។

គ. ដល់សៀមរាបហើយ យើងចុះឡាន។

ឃ. ខ្ញុំបានដើរលេងប៉េកាំងម្ដងហើយ។

ង. តើមានមនុស្សជាមួយមិត្តទៅប្រទេសបារាំងឬទេ?

**៨. ចូរអ្នកបង្កើតល្បះតាមបែបដូចខាងក្រោម៖**

ក. ល្បះបញ្ជាក់៖ ________________________________

ខ. ល្បះបញ្ជា៖ ________________________________

គ. ល្បះសំណួរ៖ ________________________________

ឃ. ល្បះឧទាន៖ ________________________________

**៩. ចូរអ្នកប្រែក្លាយល្បះកម្មខាងក្រោមទៅជាល្បះកត្តុ៖**

ក. គណនីរបស់ខ្ញុំត្រូវបានបិទ។

ខ. អ៊ីនធើណិតត្រូវបានគេយកធ្វើជាជំនួញក្នុងឆ្នាំ១៩៩៥។

គ. សមាជិកសហជីព៩នាក់ត្រូវបានចាប់ខ្លួន។

ឃ. រដ្ឋធម្មនុញ្ញអាស៊ានត្រូវបានអនុម័តនិងចូលជាធរមាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨។

ង. សត្វនិងរុក្ខជាតិថ្មីជាង២០០ប្រភេទត្រូវបានរកឃើញនៅតំបន់ទន្លេមេគង្គ។

**១០. ចូរអ្នកប្រែក្លាយកថាផ្ទាល់ខាងក្រោមទៅជាកថាមិនផ្ទាល់៖**

ក. ថៅកែបន្ទោសហាំ៖ "ឃើញទេអាហាំ អញនិយាយអាឯងមិនជឿ"។

ខ. ហាំសួរ៖ "តើពួកគិញ គេមកធ្វើដូចម្ដេចខ្លះ"?

គ. នាងនិយាយត្អូញថា៖ "ពុទ្ធោអើយ! នេះហើយជាកម្មក្រាស់របស់សារុន"។

ឃ. លោកឧកញ៉ាម្ចាស់ផ្ទះអង្គុយនឹកមួយស្របក់ក៏ចេញវាចា៖ "ឱ! ខ្ញុំនឹកឃើញហើយគ្រានោះខ្ញុំបានទៅនឹងគេដែរ បានទាំងនាំកូនក្រមុំខ្ញុំទាំងគូទៅជាមួយផង"។

ង. នាងក្រមុំសារុនភ្ញាក់ព្រើតទាំងខ្លួនប្រាណ ហើយនិយាយឆ្លើយឆ្លងដោយសេចក្ដីធ្លាប់រាប់អានថា៖ "ចុះលោកឱ្យខ្ញុំអាណិតមេត្តាប្រាប់សេចក្ដីពិតអ្វី? លោកបាឡាត់ ខ្លួនខ្ញុំឥតមានរឿងស្ងាត់កំបាំងអ្វីលាក់ទុកក្នុងចិត្តទេ"។

# គន្ថនិទ្ទេស


១. កេង វ៉ាន់សាក់, ១៩៦៤, *មូលភាពនៃការបង្កើតពាក្យថ្មី។*

២. ក្រសួងអប់រំ,១៩៨៣, *វេយ្យាករណ៍ខ្មែរថ្នាក់ទី៥,* ភ្នំពេញះមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

៣. ក្រសួងអប់រំ,១៩៨២, *វេយ្យាករណ៍ខ្មែរថ្នាក់ទី៦,* ភ្នំពេញះមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

៤. ក្រសួងអប់រំ,១៩៨៣, *វេយ្យាករណ៍ខ្មែរថ្នាក់ទី៧,* ភ្នំពេញះមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

៥. ក្រសួងអប់រំ,១៩៨៦, *វេយ្យាករណ៍ខ្មែរថ្នាក់ទី៨,* ភ្នំពេញះមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា។

៦. ក្រសួងអប់រំ,២០០០, *ភាសាខ្មែរថ្នាក់ទី១០,* ភ្នំពេញះគ្រឹស្ថានបោះពុម្ពនិងចែកផ្សាយ។

៧. ក្រសួងអប់រំ,២០០០, *ភាសាខ្មែរថ្នាក់ទី១១,* ភ្នំពេញះគ្រឹស្ថានបោះពុម្ពនិងចែកផ្សាយ។

៨.ក្រសួងអប់រំ,២០០០, *ភាសាខ្មែរថ្នាក់ទី១២,* ភ្នំពេញះគ្រឹស្ថានបោះពុម្ពនិងចែកផ្សាយ។

៩. គីម សែត, *វេយ្យាករណ៍ខ្មែរទំនើប និងសម្ព័ន្ធ,* កំពង់ចាមះ បណ្ណាគាររស្មី។

១០. គេន រង្សី, , ២០០៩, *តួនាទីនៃពាក្យសព្ទដែលស្តែងពីសរីរាង្គកាយមនុស្សនៅក្នុងយន្តការស្ថាបនាន័យនៃសំនួនវោហារសព្ទខ្មែរ*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

១១. គេន រង្សី, ២០១៤, *សទ្ទានុក្រមសំនួនវោហារសព្ទខ្មែរ*, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ភ្នំពេញ។

១២. គេន រង្សី, ២០១៤, *វចនសព្ទវិទ្យា*, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ភ្នំពេញ។

១៣. ឃឹន សុខ,២០០៥, *វេយ្យាករណ៍ភាសាខ្មែរ,* ភ្នំពេញះ រាជបណ្ឌិត្យសភាកម្ពុជា។

១៤. ច័ន្ទ សំណព្វ, ២០១០, *បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ*, រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ។

១៥. ច័ន្ទ សំណព្វ, ២០១២, *សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*, រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ។

១៦. ញ៉ុក ថែម,១៩៦២, *បែបរៀនថ្មី ភាសាបាលីជាន់ដំបូង*, ម. អក្សរសាស្រ្តនិងមនុស្សសាស្រ្ត។

១៧. ឆាយ សុខ,២០០២, *វេយ្យាករណ៍ខ្មែរនិងបំណិនសំខាន់ៗ។*

១៨. ឆ្មារ សាឡេះ,១៩៦៩, *សំយោគខេមរវេយ្យាករណ៍*។
១៩. ឧ. គាមុនី,១៩៥៤, *វេយ្យាករណ៍ខ្មែរសម្រាប់គ្រប់ថ្នាក់*។
២០. ប៊ី សុខគង់,២០០២, *ប្រភេទពាក្យក្នុងភាសាខ្មែរបច្ចុប្បន្ន,* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកភាសាវិទ្យា, ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា។
២១. ពុទ្ធសាសនបណ្ឌិត្យ,១៩៦៧-១៩៦៨, *វចនានុក្រមខ្មែរ,* បោះពុម្ពគ្រាទី៥, ភ្នំពេញ។
២២. ពូវ អ៊ុម,១៩៦៨, *វេយ្យាករណ៍ខ្មែរពិស្តារ,* ភ្នំពេញ។
២៣. ព្រុំ ម៉ល់,២០០៦, *វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប,* ភាគ សូរវិទ្យា និង សទ្ទតាវិទ្យា, ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា។
២៤. វ៉ា សោភា, ចាន់ វឌ្ឍនា, ឆាន់ គឹមសឿន, គេន រង្សី, ២០២១, *សទ្ទានុក្រមគុណនាម និងគុណកិរិយា,* មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ក្រុមហ៊ុនបោះពុម្ពអាយភីអឹមអឹល, ភ្នំពេញ
២៤. វ៉ាន់ មួន,២០០៤, *កន្សោមកិរិយាសព្ទក្នុងភាសាខ្មែរទំនើប,* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកភាសាវិទ្យា, ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា។
២៥. សៀន ខ័នឌី និង ព្រហ្ម ស៊ុនណារ៉េត,ព.ស.២៤៩៨, *នរវេយ្យាករណ៍និងខេមរភាសា* , ភ្នំពេញ។
២៦. ស៊ីសុវត្ថិ ប៉ូរក្ខស៊ី, ១៩៧២, *បរិវារសព្ទក្នុងភាសាខ្មែរ*, សមាគមសម្ដេច ជួន ណាត, ភ្នំពេញ។
២៧. ឡុង សៀម, ១៩៩៩, *បញ្ហាវចនសព្ទវិទ្យាខ្មែរ*, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
២៨. អុក ជួន, ១៩៨៧, *វចនវិទ្យានិងវេយ្យាករណ៍វិទ្យា*, ឯកសារប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់។
២៩. អៀវ កើស, ១៩៦៧, *ភាសាខ្មែរ សាកល្បងពិនិត្យដោយរកហេតុផល*, ពុទ្ធសាសនបណ្ឌិត្យ។
៣០. អ៊ុក វិបុល,២០០១, *វេយ្យាករណ៍ភាសាខ្មែរទំនើបសម្រាប់ថ្នាក់ទី១២,* ភ្នំពេញ។
៣១. អ៊ុយ ជួន,១៩៥៨, *វេយ្យាករណ៍ខ្មែរពិសេស,* ភ្នំពេញ។
៣២. Crystal, D. 2008. *A Dictionary of Linguistics and Phonetics.* Oxford: Blackwell Publishing.
៣៣. Freidin, R. 2012. *Syntax: Basic Concepts and Applications.* New York: Cambridge University Press.
៣៤. Hudson, G. 2000. *Essential Introductory to Linguistics*. publishing Blackwell.